# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ

## ១២

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារមឿន

ព. ស. ២៥៥៧ គ. ស. ២០១៣

# បរមត្ថទីបនី

## តតិយភាគ

## ១២

ព. ស.

២៥៥៧

គ. ស.

២០១៣

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះថា  បញ្ចបករណ៍

### មហាបដ្ឋានប្បករណ៍  (ត)

### តតិយភាគ

### ១២

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារមៀន

ព. ស.  ២៥៥៨    គ. ស.  ២០១៣

# **សេចក្តីបញ្ជាក់**

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍*** *តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក តតិយភាគ ១២*** *កើតឡើងដោយស្នាព្រះហស្តនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ* ***សូមបញ្ជាក់*** និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា *ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង*

នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរផនូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះយើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាគរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់

ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣

**ខ្ញុំព្រះករុណា ខ្ញុំបាទ *សុន្ទរ៍ សាមៀន***

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ឮ”

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

### អដ្ឋកថាតតិយភាគ ១២ នេះ មាន ៖

-ភិក្ខុសាមណេរជាពហូសូតក្នុង ***វត្តធុតង្គ*** (ចម្ការដូង) មាន ៩រូប

-ភិក្ខុសាមណេរជាពហូសូតក្នុង ***វត្តនិគ្រោធវ័ន*** មាន ៦ រូប

-ភិក្ខុខន្តិជាតិកោ ***វ៉ៃ ភិរក្ស*** -ធម្មាចារ្យ ធម្មានន្ទោ ***សួង សឿ***

-ភិក្ខុធម្មរក្ខិតោ ***គង់ ខន*** -ភិក្ខុជោតញ្ញាណោ ***វ៉ែត សុផាន់***

-ឧបាសក ***ពុជ ស៊ីម*** -ឧបាសក ***ជាំ កុយ***

-ឧបាសក ***សំរ៉ែង ខ័ណ្ឌ*** -ឧបាសក ***វឿង សិរីសុគន្ធ***

-អ្នកគ្រូ ***ធី សុធី*** -ឧបាសក ***ង៉ូវសុខុម*** ។

### អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

-ភិក្ខុបញ្ញាបទីបោ ***ព្រឿង ប៊ុនធឿន*** -ភិក្ខុខន្តិជាតិកោ ***វ៉ៃ ភិរក្ស***

-ឧបាសិកា ***លី ស៊ីវង្ង*** ជាដើម -ឧបាសិកា ***ឃុន ស៊ូគី*** ជាដើម

-ឧបាសិកា ***ប៉ូ ផាវ៉ាន*** ជាដើម -លោក ***ឃាន សុផាន*** ជាដើម

-ភិក្ខុសាមណេរ ***វត្តគិរីរម្យចាស់*** ជាដើម

-លោក ***ហេង សុវណ្ណារ៉ា*** និងក្រុមគ្រួសារ

-ឧបាសក **ស្រុខ ចាន់ណា** និងក្រុមគ្រួសារ

-ឧបាសក **ម៉ៅ ផុន** ហៅ **ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យគម្ពីរនេះចេញជារូបរាងឡើង ។

បន្ទាប់ពីតតិយភាគ ១២ នេះទៅ ខ្ញុំព្រះករុណា ខ្ញុំបាទ នឹងដំណើរការបោះពុម្ពនូវសៀវភៅផ្សេងៗ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា ឬថា ចង់ចូលរួមជួយជាមតិយោបល់ ក្នុងន័យស្ថាបនា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៤៦ ៥២ ៣៤

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះគ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

**ដោយអំណាចនៃមហាកុសលជាធម្មទាននេះ សូមឲ្យ ៖**

**-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ**

**-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា**

**-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ**

**-សត្វទាំងឡាយ រក្សានូវខ្លួន ឲ្យបានជាសុខតរៀងទៅ ៕**

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**តតិយភាគ ១២** ឈ្មោះ ..........................

សម្រាប់បោះពុម្ពលើកទី ៣ អាសយដ្ឋាន .................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

## បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក

### ឈ្មោះ បញ្ចបករណ៍

### តតិយភាគ

### មហាបដ្ឋានប្បករណ៍ (ត)

**ពណ៌នាអំពីបច្ចយនិទ្ទេសវារៈ ... ... ... ... ... ... ... .... ១**

### ១.បណ្ណត្តិវារៈ

### បុច្ឆាវារៈ

១.ពណ៌នាអំពីបច្ចយានុលោមន័យ ... ... ... ... ... ... ២៣

២. ,, បច្ចយបច្ចនីយន័យ ... ... ... ... ... ... .. ៥១

៣. ,, អនុលោមបច្ចនីយន័យ... ... ... ... ... .... ៥៤

៤. ,, បច្ចយបច្ចនីយានុលោមន័យ ... ... ... ... ... ៥៧

### ១.កុសលត្តិកៈ

១.ពណ៌នាអំពីសេចក្តីនៃបដិច្ចវារៈ

១. ,, បច្ចយានុលោមន័យ ... ... ... ... ... ... ... ៦១

១.វិភង្គវារៈ

មាតិកាធម៌ ទំព័រ

## បដិច្ចវារៈ

២.ពណ៌នាអំពីបច្ចយានុលោមន័យ
២.សង្ខ្យាវារៈ ... ... ... ... ... ... .. ៧៦

៣.ពណ៌នាអំពីបច្ចយបច្ចនីយន័យ ... ... ... ... ... .... ៨៤

៤. ,, បច្ចយានុលោមបច្ចនីយន័យ ... ... ... .... ៩១

៥. ,, បច្ចយបច្ចនីយានុលោមន័យ ... ... ... ... ... ៩២

## ២.សហជាតវារៈ

## ៣.បច្ចយវារៈ

១.ពណ៌នាអំពីបច្ចយានុលោមន័យ ... ... ... ... ... ..... ១០០

២. ,, បច្ចយបច្ចនីយន័យ ... ... ... ... ... .... ១០៧

៣. ,, អនុលោមបច្ចនីយន័យ បច្ចនីយានុលោមន័យ ... ១១១

## ៤.និស្សយវារៈ

## ៥.សំសដ្ឋវារៈ

១.ពណ៌នាអំពីអនុលោមន័យ ... ... ... ... ... ... .... ១១៤

២. ,, បច្ចនីយន័យ ... ... ... ... ... ... ... .. ១១៥

មាតិកាធម៌ ទំព័រ

៣.ពណ៌នាអំពីអនុលោមបច្ចនីយន័យ ... ... ... ... ... .. ១១៧

៤. ,, បច្ចនីយានុលោមន័យ ... ... ... ... ... .. ១១៨

## ៦.សម្បយុត្តវារៈ

## ៧.បញ្ហាវារៈវិភង្គ

ពណ៌នាអំពីហេតុប្បច្ច័យ ... ... ... ... ... ... ... .. ១២១

,, អារម្មណប្បច្ច័យ ... ... ... ... ... ... ... ១២៣

,, អធិបតិប្បច្ច័យ ... ... ... ... ... ... ... .. ១៣០

,, អនន្តរប្បច្ច័យ ... ... ... ... ... ... ... .. ១៣០

,, ឧបនិស្សយប្បច្ច័យ ... ... ... ... ... ... .. ១៤៤

,, បុរេជាតប្បច្ច័យ ... ... ... ... ... ... ... .. ១៦២

,, បច្ឆាជាតប្បច្ច័យ ... ... ... ... ... ... ... .. ១៦៣

,, អាសេវនប្បច្ច័យ ... ... ... ... ... ... ... .. ១៦៣

,, កម្មប្បច្ច័យ ... ... ... ... ... ... ... ... .. ១៦៤

,, អាហារប្បច្ច័យ ... ... ... ... ... ... ... ... ១៦៥

អធិប្បាយការរាប់វារៈក្នុងអនុលោម ក្នុងឃដនានៃបញ្ហាវារៈ ហេតុមូលកន័យ ១៦៧

មាតិកាធម៌ ទំព័រ


អារម្មណមូលកន័យ ... ... ... ... ... ... ... ... ... ១៨២

អធិបតិមូលកន័យ ... ... ... ... ... ... ... ... ... .. ១៨៥

អនន្តរ_សមនន្តរមូលកន័យ ... ... ... ... ... ... ... .. ១៨៩

សហជាតមូលកន័យ ... ... ... ... ... ... ... ... ... ១៩០

អញ្ញមញ្ញមូលកន័យ ... ... ... ... ... ... ... ... ... ១៩២

និស្សយមូលកន័យ ... ... ... ... ... ... ... ... ... .. ១៩២

ឧបនិស្សយមូលកន័យ ... ... ... ... ... ... ... ... .. ១៩៥

បុរេជាតមូលកន័យ ... ... ... ... ... ... ... ... .... ១៩៧

បច្ឆាជាតមូលកន័យ ... ... ... ... ... ... ... ... ... . ១៩៨

កម្មមូលកន័យ ... ... ... ... ... ... ... ... ... ... ១៩៩

វិបាកមូលកន័យ ... ... ... ... ... ... ... ... ... .. ២០០

អាហារមូលកន័យ ... ... ... ... ... ... ... ... ... ២០០

ឥន្ទ្រិយមូលកន័យ ... ... ... ... ... ... ... ... ... .. ២០២

ឈានមូលកន័យ ... ... ... ... ... ... ... ... ... .. ២០៤

មគ្គមូលកន័យ ... ... ... ... ... ... ... ... ... ... ២០៥

បរមត្ថទីបនី

**មាតិកាធម៌** ទំព័រ


សម្បយុត្តមូលកន័យ ... ... ... ... ... ... ... ... ... ២០៦

វិប្បយុត្តមូលកន័យ ... ... ... ... ... ... ... ... .... ២០៦

អត្ថិមូលកន័យ ... ... ... ... ... ... ... ... ... .... ២០៨

នត្ថិ-វិគតមូលកន័យ ... ... ... ... ... ... ... ... ... ២១០

អវិគតមូលកន័យ ... ... ... ... ... ... ... ... ... .. ២១១


## បច្ចនីយន័យ


ពណ៌នាអំពីសេចក្តីនៃបច្ចនីយុទ្ធារៈ ... ... ... ... ... ... ២១៧

១.ពណ៌នាអំពីកុសលត្តិកប្បដ្ឋាន ... ... ... ... ... .... ២៣៦

នអារម្មណមូលកន័យជាដើម ... ... ... ... ... ... .... ២៤៩

ពណ៌នាអំពីអនុលោមបច្ចនីយន័យ ... ... ... ... ... ... ២៥៤

ពណ៌នាអំពីបច្ចនីយានុលោមន័យ ... ... ... ... ... .... ២៥៩

២.ពណ៌នាអំពីវេទនាត្តិកប្បដ្ឋាន ... ... ... ... ... .... ២៧០

៣. ,, វិបាកត្តិកប្បដ្ឋាន ... ... ... ... ... ..... ២៨២

៤. ,, ឧបាទិន្នត្តិកប្បដ្ឋាន ... ... ... ... ... .... ២៨៦

៥-២២.ពណ៌នាអំពីសង្កិលិដ្ឋត្តិកប្បដ្ឋាន ... ... ... .... ២៨៧

,, វិតក្កត្តិកប្បដ្ឋាន... ... ... ... ... ... ២៨៨

មាតិកាធម៌ ទំព័រ

ពណ៌នាអំពីបីតិត្តិកប្បដ្ឋាន … … … … … … …. ២៨៨
,, ទស្សនត្តិកប្បដ្ឋាន … … … … … …. ២៨៩
,, ទស្សនេនបហាតព្វហេតុកត្តិកប្បដ្ឋាន … …. ២៨៩
,, អាចយគាមិត្តិកប្បដ្ឋាន … … … … …. ២៩០
,, សេក្ខត្តិកប្បដ្ឋាន … … … … … …. ២៩០
,, បរិត្តារម្មណត្តិកប្បដ្ឋាន … … … … …. ២៩១
,, មិច្ឆត្តត្តិកប្បដ្ឋាន … … … … … ….. ២៩២
,, មគ្គារម្មណត្តិកប្បដ្ឋាន … … … … …. ២៩៣
,, ឧប្បន្នត្តិកប្បដ្ឋាន និងអតីតត្តិកប្បដ្ឋាន … …. ២៩៣
,, អជ្ឈត្តត្តិកប្បដ្ឋាន … … … … … …. .. ២៩៥
,, អជ្ឈត្តារម្មណត្តិកប្បដ្ឋាន … … … … … ២៩៥
,, សនិទស្សនត្តិកប្បដ្ឋាន … … … … … … ២៩៦
២.ពណ៌នាអំពីទុកប្បដ្ឋាន ហេតុទុកៈជាដើម … … … … … … … ២៩៦
ពណ៌នាអំពីលោកិយទុកៈជាដើម … … … … … … ២៩៧

បរមត្ថទីបនី

មាតិកាធម៌ ទំព័រ


៣.ពណ៌នាអំពីទុកត្តិកប្បដ្ឋាន … … … … … … … ២៩៩

៤. ,, តិកទុ្កកប្បដ្ឋាន … … … … … … …. ៣០១

៥. ,, តិកត្តិកប្បដ្ឋាន … … … … … … … ៣០២

៦. ,, ទុកទុ្កកប្បដ្ឋាន … … … … … … … ៣០៤

៧. ,, អនុលោមប្បដ្ឋាន … … … … … … ៣០៥

៨_១២.ពណ៌នាអំពីបច្ចនីយប្បដ្ឋាន … … … … … … ៣០៥

៩_១៨. ,, អនុលោមបច្ចនីយប្បដ្ឋាន … … … … ៣០៧

១០_២៤. ,, បច្ចនីយានុលោមប្បដ្ឋាន … … … … ៣០៩

**បរិយោសានវណ្ណនា** (ពណ៌នាចុងក្រោយបករណ៍) … … … ៣១១

បរិយោសានកថា … … … … … … … … … .. ៣១៣

# អក្សរសង្ខេប
## ដែលប្រើក្នុងអដ្ឋកថាគតិយភាគ ១២ នេះ គឺ

| | | |
|---|---|---|
| អំ. តិក. | = | អង្គុត្តរនិកាយ តិកនិបាត |
| ខ. ឧ. | = | ខន្ធកសំយុត្ត ឧបរិបណ្ណាសកៈ |
| ម. មូ. | = | មជ្ឈិមនិកាយ មូលបណ្ណាសកៈ |
| សំ. សឡា. | = | សំយុត្តនិកាយ សឡាយតនវគ្គ ។ |

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចប្បករណ៍

## តតិយភាគ ១២

## ព. ស. ២៥៥៧

# បរមត្ថទីបនី
# អដ្ឋកថាព្រះអភិធម្មបិដក
## ឈ្មោះ បញ្ចបករណ៍
## តតិយភាគ
## មហាបដ្ឋានប្បករណ៍ (ត)

***នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។***

## ពណ៌នាអំពីបច្ចយនិទ្ទេសវារៈ

*ដើម្បីសេចក្តីជាក់ច្បាស់នូវការប្រព្រឹត្តទៅរបស់ញាណ ក្នុងបច្ច័យទាំង ២៤ នេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយឧទ្ទេស និងនិទ្ទេសដូចពណ៌នាមកហើយ; ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាប* ***បកិណ្ណកវិនិច្ឆ័យ*** *ដោយអំណាចនៃបទទាំង ១០ នេះ គឺ*

*១.ដោយភាវៈនៃធម៌ច្រើនៗយ៉ាង មានបច្ច័យតែម្យ៉ាងដូចគ្នា*

*២.ដោយភាវៈនៃធម៌តែម្យ៉ាង មានបច្ច័យបានច្រើនៗ យ៉ាង*

*៣.ដោយភាវៈនៃបច្ច័យតែម្យ៉ាង មានបច្ច័យបានច្រើនៗ យ៉ាង*

*៤.ដោយបច្ច័យដែលជាសភាគនឹងគ្នា*

*៥.ដោយបច្ច័យដែលជាវិសភាគនឹងគ្នា*

*៦.ដោយបច្ច័យដែលជាគូនឹងគ្នា*

៧.ដោយជនកប្បច្ច័យ និងអជនកប្បច្ច័យ

៨.ដោយបច្ច័យដែលប្រកបចូលជាមួយធម៌បាន និងមិនបានប្រកបជាមួយធម៌ទាំងអស់ទេ ។

៩.ដោយការកំណត់ថា "រូបជាបច្ច័យដល់រូប" ជាដើម

១០.ដោយការចែកក្នុងភព ៣ ។

ក្នុង ១០ យ៉ាងនោះ គឺ ៖

១-បទថា **"ដោយភាវៈនៃធម៌ច្រើនៗ យ៉ាង មានបច្ច័យតែម្យ៉ាងដូចគ្នា"** សេចក្តីថា ធម៌ច្រើនយ៉ាង ជាបច្ច័យដោយសេចក្តីជាមួយគ្នា ក្នុងបច្ច័យ ២៣ ដ៏សេស វៀរកម្មប្បច្ច័យទាំងនេះចេញ ។ ចំណែកកម្មប្បច្ច័យបានដល់ ចេតនាធម៌តែម្យ៉ាងប៉ុណ្ណោះ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យដោយភាវៈនៃធម៌ច្រើនៗ យ៉ាង ជាបច្ច័យតែម្យ៉ាងដូចគ្នា ក្នុងអធិការនេះយ៉ាងនេះ ។

២-បទថា **"ដោយភាវៈនៃធម៌តែម្យ៉ាង មានបច្ច័យច្រើនៗ យ៉ាង"** សេចក្តីថា **ក្នុងហេតុប្បច្ច័យ** ធម៌ម្យ៉ាង **គឺអមោហៈ** មិនត្រឹមតែជាបុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឈានប្បច្ច័យប៉ុណ្ណោះទេ, ថែមទាំងជាបច្ច័យដោយអំណាចនៃបច្ច័យ ២០ ដែលនៅសល់ទៀតផង ។ អលោភៈ និងអទោសៈ សូម្បីមិនជាឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យ, តែក៏ជាបច្ច័យ

ដោយអំណាចនៃបច្ច័យ ១៨ ដែលនៅសល់ ។ ***លោភៈ និងមោហៈ*** សូម្បីមិនមែនជាវិបាកប្បច្ច័យ, តែក៏ជាបច្ច័យដោយអំណាចនៃបច្ច័យ ១៧ ដែលនៅសល់ដែរ ។ ទោសៈ សូម្បីមិនជាអធិបតិប្បច្ច័យ, ប៉ុន្តែ ក៏ជាបច្ច័យដោយអំណាចនៃបច្ច័យ ១៦ ដែលនៅសល់ដែរ ។

ក្នុង ***អារម្មណប្បច្ច័យ*** រូបាយតនៈ ជាបច្ច័យ ៤ យ៉ាង គឺអារម្មណ-ប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យនិងអវិគតប្បច្ច័យ ដល់ចក្ខុវិញ្ញាណធាតុ មនោធាតុ និងអហេតុកមនោវិញ្ញាណធាតុ; ប៉ុន្តែ នៅជាបច្ច័យដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យទៀត ដល់សហេតុកមនោវិញ្ញាណធាតុ ។ អ្នកសិក្សាគប្បីជ្រាបសេចក្តីនៃអារម្មណប្ប-ច្ចយធម៌ទាំងអស់ ជាបច្ច័យច្រើនយ៉ាង ដោយន័យនេះចុះ ។

ក្នុង ***អធិបតិប្បច្ច័យ*** អ្នកសិក្សាគប្បីជ្រាបសេចក្តីនៃអារម្មណាធិបតី ជាបច្ច័យច្រើនយ៉ាង តាមន័យដែលពោលហើយ ក្នុងអារម្មណប្បច្ច័យ ។ ក្នុងធម៌ដែលជាសហជាតាធិបតី ***វីមំសាធិបតី*** ជាបច្ច័យ ២០ យ៉ាង ដូចអមោហហេតុដែរ ។ ឆន្ទៈ មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្ម-ប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ, ប៉ុន្តែ ជាបច្ច័យដោយអំណាចនៃបច្ច័យ ១៧ ដែលនៅសល់ ។ ចិត្តមិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ,

តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដែលនៅសល់ ។ ***វីរិយៈ*** មិនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឈានប្បច្ច័យទេ, ប៉ុន្តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដែលនៅសល់ ។

ក្នុង ***អនន្តរប្បច្ច័យ*** បណ្ដាខន្ធ ៤ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា **“ចក្ខុវិញ្ញាណធាតុ”** ។

***វេទនាខន្ធ*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដែលនៅសល់ ។

***សញ្ញាខន្ធ*** មិនមែនជាឥន្ទ្រិយប្បច្ច័យ និងឈានប្បច្ច័យទេ, តែជាបច្ច័យ ដោយអំណាចនៃបច្ច័យ ១៧ ដែលនៅសល់ ។

ក្នុង ***សង្ខារក្ខន្ធ*** ហេតុ ជាបច្ច័យតាមន័យដែលបានពោលហើយក្នុងហេតុប្បច្ច័យ, ***ឆន្ទៈ និងវីរិយៈ*** ជាបច្ច័យតាមន័យដែលពោលមកហើយក្នុងអធិបតិប្បច្ច័យ ។

***ផស្សៈ*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៨ ដែលនៅសល់ ។

***ចេតនា*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ

ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដែលនៅសល់ ។

***វិតក្កៈ*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដែលនៅសល់ ។

***វិចារៈ*** មិនមែនជាមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៨ ដែលនៅសល់ ។

***បីតិ*** ជាបច្ច័យដោយអំណាចនៃបច្ច័យទាំង ១៨ នោះ ដូចគ្នា ។

***ឯកគ្គតា*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ និងអាហារប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ២០ ដែលសល់ ។

***សទ្ធា*** មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៨ ដែលនៅសល់ ។

***សតិ*** ជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ គឺបច្ច័យទាំង ១៨ នោះ និងមគ្គប្បច្ច័យ ។

***ជីវិតិន្ទ្រិយ*** ជាបច្ច័យដោយអំណាចនៃបច្ច័យទាំង ១៨ ដែលពោលហើយក្នុងសទ្ធា ។

***ហិរិ និងឱត្តប្បៈ*** ជាបច្ច័យដោយអំណាចនៃបច្ច័យ ១៧ ដែលនៅសល់ ដោយដកយកឥន្ទ្រិយប្បច្ច័យចេញ ។

*ចេតសិកដែលជាគូៗ គ្នា មាន* ***កាយបស្សទ្ធិ*** *ជាដើម និងបណ្ដា* ***យេវាបនកចេតសិក គឺអធិមោក្ខ មនសិការ តត្រមជ្ឈត្តតា ករុណា និងមុទិតា*** *ក៏ដូចគ្នា គឺជាបច្ច័យដោយអំណាចនៃបច្ច័យទាំង ១៧ នោះ ។*

*ចំណែក* ***វិរតិចេតសិក*** *ជាបច្ច័យ ១៨ យ៉ាង គឺបច្ច័យទាំង ១៧ នោះ និងមគ្គប្បច្ច័យ ។*

***មិច្ឆាទិដ្ឋិ*** *ជាបច្ច័យ ១៧ យ៉ាង ដោយនាំវិបាកប្បច្ច័យចេញ ។* ***មិច្ឆាវាចា មិច្ឆាកម្មន្តៈ និងមិច្ឆាអាជីវៈ*** *ជាបច្ច័យ ១៩ យ៉ាង គឺបច្ច័យទាំង ១៧ នោះ រួមកម្មប្បច្ច័យ និងអាហារប្បច្ច័យ ។*

*ចេតសិកធម៌ទាំងនេះ* ***គឺអហិរិកៈ អនោត្តប្បៈ មានះ ថីនៈ មិទ្ធៈ ឧទ្ធច្ចៈ*** *មិនមែនជាហេតុប្បច្ច័យ បុរេជាតប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ, តែជាបច្ច័យដោយអំណាចនៃបច្ច័យ ១៦ ដែលនៅសល់ ។*

***វិចិកិច្ឆា ឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ*** *ជាបច្ច័យ ១៥ យ៉ាង ដោយយកអធិបតិប្បច្ច័យចេញអំពីនោះ ។*

*គប្បីជ្រាបសេចក្ដីនៃវិញ្ញាណក្ខន្ធ ជាបច្ច័យច្រើនយ៉ាង តាមន័យ*

ដែលពោលហើយ ក្នុងអធិបតិប្បច្ច័យ ។ សូម្បីក្នុងសមនន្តរប្បច្ច័យ ក៏មាន ន័យដូចគ្នានេះដែរ ។

ក្នុង ***សហជាតប្បច្ច័យ*** ខន្ធ ៤ គប្បីជ្រាបសេចក្ដីនៃធម៌មួយៗ ជាបច្ច័យច្រើនយ៉ាង តាមន័យដែលបានពោលហើយនោះឯង ។

***មហាភូតរូប ៤*** ជាបច្ច័យ ៩ យ៉ាង គឺអារម្មណប្បច្ច័យ អារម្មណា-ធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

***ហទយវត្ថុ*** ជាបច្ច័យ ១០ យ៉ាង គឺបច្ច័យទាំង ៩ នេះ និង វិប្បយុត្តប្បច្ច័យ ។

ក្នុង ***អញ្ញមញ្ញប្បច្ច័យ*** មិនមានធម៌ដែលមិនធ្លាប់មានមកអំពីមុនទេ (គឺដូចគ្នានឹងសហជាតប្បច្ច័យដែរ) ។

ក្នុង ***និស្សយប្បច្ច័យ*** ចក្ខាយតនៈជាដើម ជាបច្ច័យ ៩ យ៉ាង គឺ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយ-ប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុង ***ឧបនិស្សយប្បច្ច័យ*** មិនមានធម៌ដែលមិនធ្លាប់បានពោលមកអំពី មុនឡើយ ។

ក្នុង ***បុរេជាតប្បច្ច័យ*** រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ និង រសាយតនៈ ជាបច្ច័យ ៦ យ៉ាង គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; ក្នុងបុរេជាតប្បច្ច័យនេះ មានពាក្យដែលនៅមិនទាន់បានអធិប្បាយ ត្រឹមតែប៉ុណ្ណេះ ។

ក្នុង ***បច្ឆាជាតប្បច្ច័យ*** ជាដើម មិនមានធម៌ដែលមិនធ្លាប់មានមក អំពីមុនឡើយ ។

ក្នុង ***អាហារប្បច្ច័យ*** កវឡិង្ការាហារ មានបច្ច័យ ៦ យ៉ាង គឺ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាហារប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ក្នុង ***ឥន្ទ្រិយប្បច្ច័យ*** ជាដើម មិនមានធម៌ដែលនៅមិនធ្លាប់មានមក ទេ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយភាវៈនៃធម៌តែម្យ៉ាង ជាបច្ច័យបានច្រើនយ៉ាង ក្នុងអធិការនេះ ដូចពណ៌នាមកហើយនេះឯង ។

៣-បទថា ***“ដោយភាវៈនៃបច្ច័យមួយ ក៏ជាបច្ច័យបានច្រើនយ៉ាង”*** សេចក្តីថា ធម៌ណា ជាបច្ច័យនៃបច្ចយុប្បន្នប្រភេទណាមួយ ក្នុងបណ្តា ***ហេតុប្បច្ច័យ*** ជាដើម ដោយអាការណា ដោយអត្ថណា, ធម៌នោះ មិន

លះបង់អាការនោះ អត្ថនោះ ដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដល់ធម៌ទាំងនោះ ក្នុងខណៈនោះឯង ដោយអាការណា ដោយអត្ថណា យ៉ាងដទៃទៀត, អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យធម៌នោះ ដោយភាវៈនៃបច្ច័យបានច្រើនយ៉ាង ដោយអាការនោះ ដោយអត្ថនោះ គឺ

**អមោហៈ** ជាហេតុប្បច្ច័យ, អមោហៈនេះ មិនលះបង់អត្ថនៃហេតុប្បច្ច័យនេះឡើយ រមែងដល់ភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១១ ទៀត គឺអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

**អលោភៈ និងអទោសៈ** រមែងដល់ភាពជាបច្ច័យបានច្រើនយ៉ាង ដោយអំណាចនៃបច្ច័យដែលនៅសល់អំពីបច្ច័យ ១១ នោះ ដោយនាំនូវបច្ច័យ ៣ គឺអធិបតិប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យចេញ ។ **អលោភៈ និងអទោសៈ** ទាំងពីរនេះ រមែងកើតក្នុងហេតុប្បច្ច័យ និងវិបាកប្បច្ច័យដងដែរ ។ ចំណែកក្នុងកុសល និងកិរិយា មិនជាវិបាកប្បច្ច័យទេ ។ **លោភៈ ទោសៈ និងមោហៈ** រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអំណាចនៃបច្ច័យដែលសល់ វៀរបច្ច័យ ៤ គឺបច្ច័យទាំង ៣ នោះ និងវិបាកប្បច្ច័យ ។

***អារម្មណប្បច្ច័យ*** *មិនលះបង់អត្ថនៃអារម្មណប្បច្ច័យនោះឡើយ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអាការ ៧ ទៀត គឺ អារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាត-ប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាការ កំណត់យ៉ាងខ្ពស់បំផុត ក្នុងអារម្មណប្បច្ច័យនេះ ។ ក៏កាលបើអរូបធម៌ ឬរូបធម៌ ដែលជាអតីត និងអនាគត ជាអារម្មណប្បច្ច័យ រមែងបានបច្ច័យ បន្ថែមឡើង ត្រឹមតែអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ប៉ុណ្ណោះ ។* ***វីមំសា*** *ក្នុង* ***អធិបតិប្បច្ច័យ*** *ដូចគ្នានឹងអមោហៈដែរ ។* ***ឆន្ទៈ*** *មិនលះបង់អត្ថ នៃអធិបតិប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យច្រើន យ៉ាង ដោយអាការ ៨ ទៀត គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិ-ប្បច្ច័យ និងអវិគតប្បច្ច័យ ។* ***វីរិយៈ*** *ដល់នូវភាពជាបច្ច័យច្រើនយ៉ាង ដោយអាការ ១០ ដោយអំណាចនៃបច្ច័យទាំងនេះ គឺបច្ច័យទាំង ៨ នោះ រួមទាំងឥន្ទ្រិយប្បច្ច័យជាមួយ នឹងមគ្គប្បច្ច័យ ។* ***ចិត្ត*** *ដល់នូវភាពជាបច្ច័យ បានច្រើនយ៉ាង ដោយអាការ ១០ ក្រៅអំពីអធិបតិប្បច្ច័យ ដោយ អំណាចនៃការនាំមគ្គប្បច្ច័យចេញអំពីនោះ ហើយបន្ថែមអាហារប្បច្ច័យ ចូលទៅ ។ ចំណែក* ***អារម្មណាធិបតិប្បច្ច័យ*** *អ្នកសិក្សាគប្បីជ្រាបថា*

ជាបច្ច័យបានច្រើនយ៉ាង តាមន័យដែលពោលហើយ ក្នុងអារម្មណប្បច្ច័យ អំពីខាងដើម ។ ***អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ*** មិនលះបង់អត្ថនៃអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអាការ ៥ ទៀត គឺឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ; ***ចេតនាក្នុងអរិយមគ្គប៉ុណ្ណោះ រមែងបានសភាពជាកម្មប្បច្ច័យ ក្នុងអនន្តរប្បច្ច័យនេះ, ធម៌ដែលនៅសល់មិនមានឡើយ*** ។ ***សហជាតប្បច្ច័យ*** មិនលះបង់នូវអត្ថនៃសហជាតប្បច្ច័យទេ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអាការ ១៤ ទៀត គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាការកំណត់យ៉ាងខ្ពស់ (ឧក្រិដ្ឋ) បំផុត ។ ប៉ុន្តែ ពោលដោយអំណាចនៃវត្ថុសហជាត (វត្ថុដែលកើតព្រម គឺហទយៈ) ជាដើម គប្បីជ្រាបថា មិនមានហេតុប្បច្ច័យជាដើម ក្នុងវត្ថុសហជាតនេះទេ ។ សូម្បីក្នុងអញ្ញមញ្ញប្បច្ច័យ ក៏មានន័យដូចគ្នានេះដែរ ។ ***និស្សយប្បច្ច័យ*** មិនលះបង់អត្ថនៃនិស្សយប្បច្ច័យឡើយ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង សូម្បីដោយអាការ ១៧ ដទៃទៀត ដោយអំណាចនៃបច្ច័យ

ដែលនៅសល់ ដោយនាំនូវបច្ច័យ ៦ ក្នុងបណ្ដាបច្ច័យ ២៤ ចេញ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអត្ថនៃនិស្សយប្បច្ច័យរបស់ខ្លួន ។ នេះជាការកំណត់យ៉ាងខ្ពស់បំផុត ។ ក៏កាលបើពោលដោយអំណាចនៃវត្ថុនិស្សយៈជាដើម គប្បីជ្រាបថា មិនមានហេតុប្បច្ច័យជាដើម ក្នុងនិស្សយប្បច្ច័យនេះទេ ។ ក្នុង ***ឧបនិស្សយប្បច្ច័យ*** អារម្មណូបនិស្សយប្បច្ច័យ ដូចគ្នានឹងអារម្មណាធិបតិប្បច្ច័យដែរ ។ អនន្តរូបនិស្សយប្បច្ច័យ មិនលះបង់អត្ថនៃអនន្តរូបនិស្សយប្បច្ច័យទេ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងដោយអាការ ៦ ទៀត គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ កម្មប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ***អរិយមគ្គចេតនាប៉ុណ្ណោះ រមែងបានសភាពជាកម្មប្បច្ច័យ ក្នុងអនន្តរូបនិស្សយប្បច្ច័យនេះ ធម៌ដែលនៅសល់ មិនបានជាបច្ច័យទេ*** ។ ***បកតូបនិស្សយៈ*** ក៏គឺបកតូបនិស្សយ-ប្បច្ច័យនោះឯង ។ ***បុរេជាតប្បច្ច័យ*** មិនលះបង់អត្ថនៃបុរេជាតប្បច្ច័យរបស់ខ្លួនទេ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអាការ ៨ ទៀត គឺអារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ នេះជាការសម្ដែងបច្ច័យដែលច្រើនបំផុត, ប៉ុន្តែ ក្នុង

អារម្មណបុរេជាតប្បច្ច័យ រមែងមិនបាននិស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ និងវិប្បយុត្តប្បច្ច័យទេ ។ គប្បីជ្រាបនូវបច្ច័យដែលបាន ឬមិនបានក្រៃលែងទៅជាងនេះ ។ ***បច្ឆាជាតប្បច្ច័យ*** មិនលះបង់អត្ថនៃបច្ឆាជាតប្បច្ច័យរបស់ខ្លួនទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាង ដោយអាការ ៣ ទៀត គឺវិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ***អាសេវនៈប្បច្ច័យ*** មិនលះបង់អត្ថនៃអាសេវនប្បច្ច័យឡើយ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ៥ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ***កម្មប្បច្ច័យ*** មិនលះបង់អត្ថនៃកម្មប្បច្ច័យ ដែលជាបច្ច័យក្នុងខណៈជាមួយគ្នា (ឯកខណិកកម្មប្បច្ច័យ គឺសហជាតកម្ម) ទេ នៅដល់ភាវៈជាបច្ច័យច្រើនយ៉ាងទៀត ដោយអាការ ៩ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ដែលជា ***នានាក្ខណិកកម្មប្បច្ច័យ*** រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ៥ គឺឧបនិស្សយប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ ***វិបាកប្បច្ច័យ*** មិនលះអត្ថនៃវិបាកប្បច្ច័យទេ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១៨ គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ

សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ក្នុង ***អាហារប្បច្ច័យ*** កវឡិង្ការាហារ មិនលះអត្ថនៃអាហារប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ២ យ៉ាង គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ អាហារ ៣ ដែលនៅសល់ មិនលះអត្ថនៃអាហារប្បច្ច័យទេ, រមែងដល់នូវភាពជាបច្ច័យ បានច្រើនយ៉ាងទៀត ដោយអាការ ១១ គឺ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តាមសមគួរ ។ ក្នុង ***ឥន្ទ្រិយប្បច្ច័យ*** រូបឥន្ទ្រិយ ៥ មិនលះអត្ថនៃឥន្ទ្រិយប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ៥ គឺនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ សូម្បី ***រូបជីវិតិន្ទ្រិយ*** ក៏មិនលះអត្ថនៃឥន្ទ្រិយប្បច្ច័យដែរ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ២ គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ***អរូបឥន្ទ្រិយ*** មិនលះអត្ថនៃឥន្ទ្រិយប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១៣ គឺហេតុប្បច្ច័យ

អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្ត-ប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តាមសមគួរ ។

***ឈានប្បច្ច័យ*** មិនលះអត្ថនៃឈានប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១០ គឺសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

***មគ្គប្បច្ច័យ*** មិនលះអត្ថនៃមគ្គប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១២ គឺបច្ច័យ ១០ ដែលពោលហើយ ក្នុងឈានប្បច្ច័យ និងហេតុប្បច្ច័យព្រមជាមួយអធិបតិប្បច្ច័យតាមសមគួរ ។

***សម្បយុត្តប្បច្ច័យ*** មិនលះអត្ថនៃសម្បយុត្តប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១៣ គឺហេតុប្បច្ច័យ អធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

***វិប្បយុត្តប្បច្ច័យ*** មិនលះអត្ថនៃវិប្បយុត្តប្បច្ច័យឡើយ, រមែងដល់នូវភាពជាបច្ច័យបានច្រើនយ៉ាងទៀត ដោយអាការ ១៧ តាមសមគួរ

គឺបច្ច័យដែលនៅសល់ ដោយនាំយកបច្ច័យ ៦ ចេញ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និង វិគតប្បច្ច័យ ។ គប្បីជ្រាបនូវការវិភាគនៃបច្ច័យរបស់រូប និងអរូប ក្នុង វិប្បយុត្តប្បច្ច័យនោះចុះ ។

***អត្ថិប្បច្ច័យ*** មិនលះអត្ថនៃអត្ថិប្បច្ច័យទេ រមែងដល់នូវភាពជាបច្ច័យ បានច្រើនយ៉ាងទៀត ដោយអាការ ១៨ យ៉ាង តាមសមគួរ ដោយអំណាច នៃបច្ច័យដែលនៅសល់ ដោយនាំបច្ច័យ ៥ ចេញ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

***នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ*** ដូចគ្នានឹងអនន្តរប្បច្ច័យដែរ ។

***អវិគតប្បច្ច័យ*** ដូចគ្នានឹងអត្ថិប្បច្ច័យដែរ ។ អ្នកសិក្សា គប្បីជ្រាប វិនិច្ឆ័យ សូម្បីដោយភាពជាបច្ច័យតែម្យ៉ាង ក៏ជាបច្ច័យបានច្រើនយ៉ាង ក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។

៤-បទថា ***“ដោយបច្ច័យដែលជាសភាគគ្នា”*** សេចក្ដីថា ពិតមែន ហើយ ក្នុងបច្ច័យ ២៤ នេះ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូប-និស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ជាសភាគ គ្នា ។ ម្យ៉ាងទៀត អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ និងអារម្មណូ-បនិស្សយប្បច្ច័យ ក៏ជាសភាគគ្នាដែរ ។ គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយ

អំណាចនៃបច្ច័យដែលសភាគគ្នាក្នុងអធិការនេះ ដោយឧបាយនេះចុះ ។

៥-បទថា **"ដោយបច្ច័យដែលជាវិសភាគគ្នា"** សេចក្ដីថា បណ្ដាបច្ច័យទាំងនេះ បុរេជាតប្បច្ច័យ ជាវិសភាគគ្នានឹងបច្ឆាជាតប្បច្ច័យ, សម្បយុត្តប្បច្ច័យ ជាវិសភាគគ្នានឹងវិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ ជាវិសភាគគ្នានឹងនត្ថិប្បច្ច័យ, វិគតប្បច្ច័យ ជាវិសភាគគ្នានឹងអវិគតប្បច្ច័យ ។ គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយអំណាចនៃបច្ច័យដែលជាវិសភាគគ្នា ក្នុងអធិការនេះ ដោយឧបាយនេះចុះ ។

៦-បទថា **"ដោយបច្ច័យដែលជាគូគ្នា"** មានអធិប្បាយថា អ្នកសិក្សាគប្បីជ្រាបនូវវិនិច្ឆ័យ ដោយអំណាចនៃបច្ច័យដែលជាគូគ្នា ក្នុងបច្ច័យទាំងនេះ ដោយហេតុទាំងនេះ គឺដោយមានអត្ថដូចគ្នា, មានសព្ទដូចគ្នា, មានការខុសគ្នា, ជាហេតុ និងជាផលជាមួយគ្នា ថែមទាំងជាបដិបក្ខចំពោះគ្នានឹងគ្នា ។

ពិតមែនហើយ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ចាត់ជាគូមួយ ព្រោះមានសេចក្ដីដូចគ្នា ។

និស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យចាត់ជាគូមួយ ព្រោះមានសព្ទដូចគ្នា ។

បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ចាត់ជាគូមួយ ព្រោះមានកាលជាបដិបក្ខនឹងគ្នា ។

កម្មប្បច្ច័យ និងវិបាកប្បច្ច័យ ចាត់ជាគូមួយ ព្រោះជាហេតុ និងជាផលនឹងគ្នា ។

សម្បយុត្តប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ ចាត់ជាគូមួយ ព្រោះជាបដិបក្ខនូវគ្នានឹងគ្នា ។

អត្ថិប្បច្ច័យ និងនត្ថិប្បច្ច័យ, វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ក៏មានន័យដូចគ្នានេះដែរ ។ អ្នកសិក្សា គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយ

អំណាចនៃបច្ច័យដែលជាគូគ្នាក្នុងអធិការនេះ ដូចពោលមកហើយ ។

៧-បទថា ***“ដោយជនកប្បច្ច័យ និងអជនកប្បច្ច័យ”*** សេចក្ដីថា បណ្ដាបច្ច័យទាំងនេះ បច្ច័យ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ បកតូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នានាក្ខណិកកម្មប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យនេះ ចាត់ជាជនកប្បច្ច័យតែម្យ៉ាង, មិនមែនជាអជនកប្បច្ច័យទេ; បច្ឆាជាតប្បច្ច័យ ជាចំណែកឧបត្ថម្ភប៉ុណ្ណោះ, មិនមែនជាជនកប្បច្ច័យទេ; បច្ច័យដែលនៅសល់ ជាជនកប្បច្ច័យ អជនកប្បច្ច័យ និងឧបត្ថម្ភកប្បច្ច័យ ។ គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយអំណាចនៃបច្ច័យដែលជាជនកប្បច្ច័យ និងអជនកប្បច្ច័យ ក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។

៨-បទថា **“ដោយបច្ច័យដែលចូលជាមួយធម៌ទាំងអស់ និងមិនចូលទាំងអស់”** សេចក្ដីថា ក្នុងបច្ច័យទាំងនេះ សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ឈ្មោះថា ចូលបានជាមួយនឹងធម៌ទាំងអស់ (សព្វដ្ឋានិក), អធិប្បាយថា ជាទីតាំង ជាហេតុនៃរូបធម៌ និងអរូបធម៌ ដែលជាសង្ខតៈទាំងអស់ អធិប្បាយថា សូម្បីធម៌តែម្យ៉ាង កាលបើកើតឡើង វៀរចាកបច្ច័យទាំងនេះចេញ ក៏រមែងមិនមាន ។ អារម្មណប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ បកតូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ឈ្មោះថា បច្ច័យដែលចូលមិនបាន ជាមួយធម៌ទាំងអស់ (អសព្វដ្ឋានិក), ព្រោះមិនជាទីតាំងនៃរូបធម៌ និងអរូបធម៌ទាំងអស់; អធិប្បាយថា ជាទីតាំង ជាហេតុនៃអរូបក្ខន្ធទាំងឡាយប៉ុណ្ណោះ ។ ពិតមែនហើយ មានតែអរូបធម៌ប៉ុណ្ណោះ រមែងកើត ព្រោះបច្ច័យទាំងនេះ, ឯរូបធម៌ មិនកើតឡើងទេ ។ សូម្បីបុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ឈ្មោះថា បច្ច័យដែលចូលមិនបាន ជាមួយនឹងធម៌ទាំងអស់ (អសព្វដ្ឋានិក) ព្រោះជាបច្ច័យដល់អរូបក្ខន្ធ និងរូបក្ខន្ធប៉ុណ្ណោះតាមលំដាប់ ។ សូម្បីបច្ច័យដែលនៅសល់អំពីការពោលហើយ ក៏ឈ្មោះថា ប្រកបមិនបានគ្រប់កន្លែង ព្រោះជាហេតុនៃការកើតឡើងរបស់រូបធម៌ និង

អរូបធម៌ពួកខ្លះ ។ គប្បីជ្រាបនូវវិនិច្ឆ័យសូម្បីដោយអំណាចនៃបច្ច័យដែលចូលបានគ្រប់កន្លែង និងចូលមិនបានគ្រប់កន្លែង ក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។

៩-បទថា **“ដោយការកំណត់ថា ‘រូបជាបច្ច័យដល់រូប’ ជាដើម”** សេចក្ដីថា ក្នុងបច្ច័យទាំង ២៤ នេះ សូម្បីបច្ច័យតែមួយ ដែលជារូបតែម្យ៉ាង និងឈ្មោះថា ជាបច្ច័យដល់រូបប៉ុណ្ណោះ ក៏មិនមាន ។ ប៉ុន្តែរូបដោយចំណែកមួយ ឈ្មោះថា ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។

***សួរថា*** បច្ច័យទាំងនោះ គឺបច្ច័យណា ? ឆ្លើយថា គឺបុរេជាតប្បច្ច័យ ។ ពិតមែនហើយ បុរេជាតប្បច្ច័យ ជារូបដោយពិត, (ប៉ុន្តែ) ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។ បច្ច័យដែលជារូបតែម្យ៉ាង ឈ្មោះថា ជាបច្ច័យដល់រូប និងអរូបមិនមាន, តែមានជាអរូបតែម្យ៉ាង ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។ ***សួរថា*** បានដល់បច្ច័យណា ? ឆ្លើយថា បានដល់បច្ច័យ ៦ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ សម្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

ពិតមែនហើយ បច្ច័យទាំង ៦ នោះ អរូបតែម្យ៉ាង ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។

បច្ច័យដែលជាអរូបតែម្យ៉ាងប៉ុណ្ណោះ ជាបច្ច័យដល់រូប ។ ***សួរថា***

បានដល់បច្ច័យណា ? ឆ្លើយថា បានដល់ បច្ឆាជាតប្បច្ច័យ ។ ពិតមែនហើយ បច្ឆាជាតប្បច្ច័យនោះ អរូបតែម្យ៉ាង ជាបច្ច័យដល់រូបប៉ុណ្ណោះ ។

ចំណែកបច្ច័យដែលជាអរូបធម៌តែម្យ៉ាង ជាបច្ច័យដល់រូប និងអរូប ។ **សួរថា** បានដល់ បច្ច័យណាខ្លះទៅ ? ឆ្លើយថា បានដល់ បច្ច័យ ៥ គឺ ហេតុប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ។ ពិតមែនហើយ បច្ច័យទាំង ៥ នោះ អរូបតែម្យ៉ាង ជាបច្ច័យដល់រូបធម៌ក៏បាន, ដល់អរូបធម៌ ក៏បាន ។ ប៉ុន្តែ បច្ច័យទាំងរូប និងអរូបនោះឯង ឈ្មោះថា ជាបច្ច័យដល់រូបប៉ុណ្ណោះ រមែងមិនមាន, ប៉ុន្តែ ជាបច្ច័យដល់អរូប ។

**សួរថា** បានដល់បច្ច័យណា ? ឆ្លើយថា បានដល់ អារម្មណ-ប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ពិតមែនហើយ បច្ច័យទាំង ២ នេះ ទាំងជារូប និងអរូបមែនពិត, (ប៉ុន្តែ) ជាបច្ច័យដល់អរូបប៉ុណ្ណោះ ។

ម្យ៉ាងទៀត ដែលជាបច្ច័យទាំងរូប និងអរូបនោះឯង ជាបច្ច័យដល់រូប និងអរូប ។ **សួរថា** បានដល់បច្ច័យណា ? ឆ្លើយថា បានដល់ បច្ច័យទាំង ៩ គឺអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិ-ប្បច្ច័យ និងអវិគតប្បច្ច័យ ។ ពិតមែនហើយ បច្ច័យទាំងអស់នោះ ជារូប និងជាអរូប ថែមទាំងជាបច្ច័យដល់រូប និងអរូបផង ។ គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយការកំណត់ថា រូបជាបច្ច័យដល់រូបជាដើម ក្នុងអធិការនេះ

ដូចបានពោលមកហើយ ។

១០-បទថា ***“ដោយការចែកក្នុងភព”*** សេចក្ដីថា បណ្ដាបច្ច័យទាំង ២៤ នេះ ក្នុង ***បញ្ចវោការភព*** បច្ច័យណាមួយ ដែលឈ្មោះថា មិនបាន រមែងមិនមាន ។ ចំណែកក្នុង ***ចតុវោការភព*** បច្ច័យ ២១ ដែលនៅសល់ រមែងរាប់បាន ដោយនាំនូវបច្ច័យ ៣ គឺបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ និងវិប្បយុត្តប្បច្ច័យចេញ ។ ក្នុង ***ឯកវោការភព*** រមែងបានបច្ច័យទាំង ៧ នោះ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយ-ប្បច្ច័យ កម្មប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ចំណែកក្នុងរូបដែលមិនជាប់ដោយឥន្ទ្រិយខាងក្រៅ រមែងបានបច្ច័យតែ ៥ ប៉ុណ្ណោះ គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិ-ប្បច្ច័យ និងអវិគតប្បច្ច័យ ។

គប្បីជ្រាបនូវវិនិច្ឆ័យ សូម្បីដោយការចែកក្នុងភព ក្នុងអធិការនេះ ដូចបានពោលមកហើយនេះឯង ៕

## ចប់បច្ចយនិទ្ទេសវារៈ

## ១.បណ្ណត្តិវារៈ វារៈនៃការតាំងឈ្មោះ

### បុច្ឆាវារៈ

### ១.ពណ៌នាអំពីបច្ចយានុលោមន័យ

*ពាក្យថា* **“តិកប្បដ្ឋាន ទុកប្បដ្ឋាន ។ ល ។ ទុកទុកប្បដ្ឋាន”** *នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងមហាបដ្ឋានប្បករណ៍ ដែលជាទីរួមនៃសមន្តប្បដ្ឋាន ២៤ ដោយអំណាចនៃតិកប្បដ្ឋានជាដើម ក្នុងបណ្តាបដ្ឋានទាំងឡាយ មានអនុលោមប្បដ្ឋានជាដើម ដូចបានពោលមកហើយ ដោយទ្រង់អាស្រ័យ តិកប្បដ្ឋានជាដើម ពួកណា, ដើម្បីពង្រីកសេចក្តីនៃតិកប្បដ្ឋានជាដើមនោះ ទ្រង់ចែកបដ្ឋានទាំងនោះ មានតិកប្បដ្ឋានជាដើម ដោយអំណាចនៃបច្ច័យពួកណា, កាលទ្រង់សម្តែងចំពោះបច្ច័យនោះ ដែលមិនជាប់ទាក់ទិនដល់តិកប្បដ្ឋានជាដើមនោះ ដោយខទ្ទេស និងនិទ្ទេស ដោយវារៈ ពោលគឺការចែកបច្ច័យដោយការតាំងមាតិកានេះជាមុនហើយ ព្រោះព្រះអង្គទ្រង់អាស្រ័យ តិកប្បដ្ឋានជាដើមពួកណា ទើបទ្រង់ត្រាស់ពាក្យថា* **“តិកប្បដ្ឋាន ទុកប្បដ្ឋាន ។ ល ។ ទុកទុកប្បដ្ឋាន”** *។ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែង* ***តិកប្បដ្ឋាន*** *ជាដើមនោះ ឲ្យពិស្តារដោយអំណាចនៃបច្ច័យទាំងនេះ ទើបទ្រង់អាស្រ័យតិកៈ និងទុកៈមួយៗ ហើយទេសនាដោយវារៈធំ ៧ ។ ឈ្មោះនៃវារៈទាំង ៧ នោះ គឺបដិច្ចវារៈ សហជាតវារៈ បច្ចយវារៈ និស្សយវារៈ សំសដ្ឋវារៈ សម្បយុត្តវារៈ និងបញ្ហាវារៈ ។*

*បណ្ដាវារៈទាំង ៧ នេះ វារៈដែលព្រះមានព្រះភាគត្រាស់ទុក ដោយព្រះតម្រាស់ថា* **“បដិច្ច = ***អាស្រ័យ យ៉ាងនេះថា* **‘កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ”** *ឈ្មោះថា* ***បដិច្ចវារៈ*** *។*

*ដែលត្រាស់ទុកដោយអំណាចនៃព្រះតម្រាស់ថា* **“សហជាតោ** *យ៉ាងនេះថា* **‘កុសលំ ធម្មំ សហជាតោ កុសលោ ធម្មោ”** *ឈ្មោះថា* ***សហជាតវារៈ*** *។ សហជាតវារៈនោះ ពោលដោយសេចក្ដីហើយ មិនផ្សេងអំពីបដិច្ចវារៈ ដែលបានពោលមកអំពីមុនទេ ។ ប៉ុន្តែវារៈទី ១ ទ្រង់ត្រាស់ទុកដោយអំណាចនៃវេនេយ្យសត្វ ដែលនឹងត្រាស់ដឹងដោយអំណាចនៃព្រះតម្រាស់ថា* ***បដិច្ចៈ*** *។ វារៈទី ២ ទ្រង់ត្រាស់ទុកដោយអំណាចនៃវេនេយ្យសត្វដែលនឹងត្រាស់ដឹងដោយអំណាចនៃព្រះតម្រាស់ថា* ***សហជាត*** *។ ក្នុងវារៈទាំង ២ នេះ អ្នកសិក្សា គប្បីជ្រាបបច្ច័យទាំងឡាយ ដោយចំពោះនិងបច្ចយុប្បន្នធម៌ ដោយអំណាចនៃរូបធម៌ និងអរូបធម៌ ។ ឯបច្ច័យនិងបច្ចយុប្បន្នធម៌ទាំងនោះ បានចំពោះតែ (ធម៌) ដែលកើតព្រមគ្នាប៉ុណ្ណោះ, ដែលកើតមុន ឬកើតក្រោយ រមែងមិនបាន ។*

*វារៈដែលទ្រង់ត្រាស់ទុកដោយអំណាចនៃព្រះតម្រាស់ថា* **“ បច្ចយា** *យ៉ាងនេះថា* **‘កុសលំ ធម្មំ បច្ចយា កុសលោ ធម្មោ”** *ឈ្មោះថា* ***បច្ចយវារៈ*** *។ សូម្បីបច្ចយវារៈនុ៎ះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃរូបធម៌*

*និងអរូបធម៌ ដូច ២ វារៈមុន ។ ម្យ៉ាងទៀត សូម្បីបុរេជាតប្បច្ច័យ ក៏រមែងបានក្នុងអធិការនេះដែរ ។ នេះជាសេចក្ដីប្លែកគ្នានៃបច្ចយវារៈ ជាមួយនឹង ២ វារៈមុន ។*

*វារៈតអំពីនោះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយអំណាចនៃព្រះតម្រាស់ថា* **"*និស្សាយៈ*** *យ៉ាងនេះថា* **'កុសលំ ធម្មំ និស្សាយ កុសលោ ធម្មោ"** *ឈ្មោះថា* ***និស្សយវារៈ*** *។ និស្សយវារៈនោះ ដោយសេចក្ដីមិនផ្សេងអំពីបច្ចយវារៈ ដែលពោលមកអំពីមុនទេ, ប៉ុន្តែ វារៈទី ១ ទ្រង់ត្រាស់ទុក ដោយអំណាចនៃសត្វដែលនឹងត្រាស់ដឹង ដោយអំណាចនៃព្រះតម្រាស់ថា* ***បច្ចយវារៈ****; ទី ២ ត្រាស់ដោយអំណាចនៃសត្វដែលនឹងត្រាស់ដឹង ដោយអំណាចនៃព្រះតម្រាស់ថា* ***និស្សយៈ*** *។*

*តអំពីនោះ ទ្រង់ត្រាស់ទុកដោយអំណាចនៃព្រះតម្រាស់ថា* **"សំសដ្ឋា** *យ៉ាងនេះថា* **'កុសលំ ធម្មំ សំសដ្ឋោ កុសលោ ធម្មោ"** *ឈ្មោះថា* ***សំសដ្ឋវារៈ*** *។*

*វារៈដែលទ្រង់ត្រាស់ទុកដោយអំណាចនៃព្រះតម្រាស់ថា* **"សម្បយុត្តា** *យ៉ាងនេះថា* **'កុសលំ ធម្មំ សម្បយុត្តោ កុសលោ ធម្មោ"** *ឈ្មោះថា* ***សម្បយុត្តវារៈ*** *។ សម្បយុត្តវារៈនេះ ដោយសេចក្ដីមិនផ្សេងអំពីសំសដ្ឋ-វារៈទេ ។ វារៈទី ១ ទ្រង់ត្រាស់ទុកដោយអំណាចនៃវេនេយ្យសត្វដែលនឹង*

ត្រាស់ដឹង ដោយអំណាចនៃព្រះតម្រាស់ថា ***សំសដ្ឋៈ*** វារៈទី ២ ទ្រង់ត្រាស់ទុកដោយព្រះតម្រាស់ថា ***សម្បយុត្ត*** ។ ក្នុងវារៈពីរនេះ អ្នកសិក្សាគប្បីជ្រាបបច្ច័យ និងបច្ចយុប្បន្នធម៌ ដោយអំណាចនៃអរូបធម៌ប៉ុណ្ណោះ ។

ចំណែកក្នុងវារៈទី ៧ ព្រះមានព្រះភាគទ្រង់លើកបញ្ហានោះឡើងដោយន័យជាដើមថា ***"កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយហេតុ-បច្ច័យ"*** ហើយទ្រង់ចែកបញ្ហាទាំងអស់នោះ មិនឲ្យច្របូកច្របល់ មិនឲ្យស្រពេចស្រពិលទៀត ដោយន័យជាដើមថា ***"កុសលហេតុ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តដោយហេតុបច្ច័យ"*** , ព្រោះហេតុដូច្នោះ វារៈនោះទើបឈ្មោះថា ***បញ្ហាវារៈ*** ព្រោះទ្រង់ចែកបញ្ហាទាំងឡាយទុកល្អហើយ ។ ក្នុងអធិការនេះ គប្បីជ្រាបបច្ច័យ និងបច្ចយុប្បន្ន ដោយអំណាចនៃរូបធម៌និងអរូបធម៌ ។

បណ្ដាវារៈទាំងនោះ វារៈទី ១ ដែលឈ្មោះថា បដិច្ចវារៈនោះ វារៈនេះ មាន ២ យ៉ាង គឺដោយឧទ្ទេស និងនិទ្ទេស ។ ក្នុង ២ យ៉ាងនោះ ឧទ្ទេសវារៈទី ១ ហៅថា ***បុច្ឆាវារៈខ្លះ*** ។

***សូម្បីពាក្យថា បណ្ណត្តិវារៈ ក៏ជាឈ្មោះនៃឧទ្ទេសវារៈនុ៎ះដែរ*** ។ ពិតមែនហើយ វារៈនុ៎ះ ឈ្មោះថា ***ឧទ្ទេសវារៈ*** ព្រោះព្រះមានព្រះភាគទ្រង់អាស្រ័យកុសលជាដើម ហើយលើកកុសលជាដើមនោះ សម្ដែងដោយ

អំណាចនៃហេតុប្បច្ច័យជាដើម ។ ឈ្មោះថា **បុច្ឆាវារៈ** ព្រោះទ្រង់អាស្រ័យកុសលជាដើម ត្រាស់សួរដល់ការកើតឡើងនៃកុសលជាដើម ដោយអំណាចនៃហេតុប្បច្ច័យជាដើម ។ សូម្បីវារៈនោះ ក៏ត្រាស់ថា បណ្ណត្តិវារៈ ព្រោះព្រះមានព្រះភាគទ្រង់អាស្រ័យកុសលជាដើម ហើយឲ្យជ្រាបនូវការកើតឡើងនៃកុសលជាដើម ដោយអំណាចនៃហេតុប្បច្ច័យជាដើម ។ ក្នុងសេចក្ដីនេះ មានបរិកប្បបុច្ឆាថា ***"កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យឬ ?"*** ដូច្នេះ ។

ក្នុងបរិកប្បបុច្ឆានេះ មានសេចក្ដីដូច្នេះ ៖

កុសលធម៌ណា គប្បីកើតឡើង ព្រោះហេតុប្បច្ច័យ, កុសលធម៌នោះ ត្រូវអាស្រ័យកុសលធម៌ឬ ? ។ ម្យ៉ាងទៀត ក្នុងអធិការនេះ មានសេចក្ដីថា ៖

កុសលធម៌ណា គប្បីអាស្រ័យកុសលធម៌កើតឡើង, កុសលធម៌នោះ គប្បីមាន ព្រោះហេតុប្បច្ច័យឬ ?

សព្ទថា **បដិ** ក្នុងពាក្យថា **បដិច្ច** ប្រព្រឹត្តទៅក្នុងអត្ថថា ដូចគ្នា; បុគ្គលដូចគ្នា ហៅថា ***បដិបុគ្គល***, ចំណែកប៉ុនគ្នា ហៅថា ***បដិភាគ*** ។ ពាក្យថា **ឥច្ច** នេះ ពោលដល់សេចក្ដីខ្វល់ខ្វាយក្នុងការទៅ ។ កាលនិយាយរួមគ្នាទាំងពីរសព្ទ ទើបមានអធិប្បាយថា ៖

បទថា **“បដិច្ច”** សេចក្តីថា ប្រព្រឹត្តទៅស្មើគ្នា គឺដំណើរទៅដោយសេចក្តីជាធម៌ស្មើគ្នា ពោលគឺកើតឡើងព្រមគ្នា អធិប្បាយថា ចូលដល់ភាវៈគឺការកើតឡើងព្រមជាមួយនឹងបច្ច័យនោះ ។ ពីរបទថា **“កុសលោ ធម្មោ”** ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា “កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យ ដោយភាវៈ គឺការកើតឡើងព្រមគ្នាយ៉ាងនោះឬ ?” ។

ន័យម្យ៉ាងទៀត បទថា **“បដិច្ច”** សេចក្តីថា ធ្វើឲ្យជាបច្ច័យ ។ ការធ្វើឲ្យជាបច្ច័យនោះ រមែងបានក្នុងបុរេជាតប្បច្ច័យ និងសហជាត-ប្បច្ច័យ ។ ក្នុងទីនេះ បំណងយកសហជាតប្បច្ច័យ ។ សូម្បីក្នុងពាក្យថា **“សិយា កុសលំ ធម្មំ បដិច្ច អកុសលោ ធម្មោ”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងពាក្យថា **“សិយា កុសលំ ធម្មំ បដិច្ច អកុសលោ ធម្មោ”** ជាដើមនោះ អកុសលធម៌អាស្រ័យកុសលធម៌កើតឡើង ដោយអំណាចនៃសហជាតប្បច្ច័យ មិនមានក៏ពិតមែន, ប៉ុន្តែ បច្ច័យណាដែលព្រះអង្គទ្រង់បានវិសជ្ជនាដោយសេចក្តី (អត្ថ) និងមិនបានដោយសេចក្តី (អត្ថ) ក្នុងបុច្ឆាវារៈនេះ, បច្ច័យទាំងអស់នោះ ព្រះអង្គទ្រង់លើកឡើងដោយអំណាចនៃបុច្ឆា ។ ចំណែកក្នុងវិសជ្ជនាខាងមុខ បច្ច័យណាដែលមិនបានវិសជ្ជនា, ទ្រង់លះបច្ច័យនោះចេញ, បច្ច័យណាបានវិសជ្ជនា, ទ្រង់វិសជ្ជនាចំពោះ

តែបច្ច័យនោះប៉ុណ្ណោះ ។ អ្នកសិក្សាកាលជ្រាបអត្ថនៃបុច្ឆា និងគន្លងផ្លូវនៃបុច្ឆាក្នុងអធិការនេះ ដូចបានពោលមកហើយ; ឥឡូវនេះ គប្បីជ្រាបការកំណត់បុច្ឆា ដោយអំណាចនៃការរាប់ដូចតទៅ ៖

ក្នុងពាក្យថា **“កុសលំ ធម្មំ បដិច្ច”** នេះ បុច្ឆាមាន ៣ គឺមានកុសលបទ ជាបទដើម មានកុសល អកុសល និងអព្យាកតៈ ជាបទអវសាន, បុច្ឆា ៣ ទៀត គឺមានកុសលបទនោះឯង ជាបទដើម មានការចែកដោយទុកៈ ដោយអំណាចនៃកុសល និងអព្យាកតៈជាដើម ជាអវសានបទ, បុច្ឆាមួយទៀត គឺមានកុសលបទនោះ ជាបទដើម មានតិកៈជាអវសានបទ ។ បុច្ឆា ៧ ដែលមានកុសលបទជាបទដើម ក្នុងពាក្យថា **“កុសលំ ធម្មំ បដិច្ច”** ដូច្នេះ រមែងមានដោយប្រការយ៉ាងនេះ ។ បុច្ឆាដែលមានអកុសលបទជាបទដើម មានអព្យាកតបទ ជាបទដើម, មានកុសលាព្យាកតបទ ជាបទដើម, មានអកុសលាព្យាកតបទ ជាបទដើម, មានកុសលាកុសលបទ ជាបទដើម, មានកុសលាកុសលាព្យាកតបទ ជាបទដើម ក៏មានន័យដូចគ្នានេះដែរ ។ បុច្ឆាទាំងអស់ ក្នុងហេតុប្បច្ច័យ មាន ៤៩ វារៈ អាស្រ័យកុសលត្តិកៈដោយអំណាចនៃបទដើម (គឺកុសលបទជាដើម) ៧ បទ បទនីមួយ ៗ មាន ៧ បុច្ឆា; ក្នុងអធិការនេះ គប្បីជ្រាបបុច្ឆាទាំងនោះ សូម្បីដោយអំណាចនៃមូល និងអវសានយ៉ាងនេះ គឺបុច្ឆា ៩ មានមូលបទ ១ មានអវសានបទ ១,

បុច្ឆា ៩ មានមូលបទ ១ មានអវសានបទ ២, បុច្ឆា ៣ មានមូលបទ ១ មានអវសានបទ ៣, បុច្ឆា ៩ មានមូលបទ ២ មានអវសានបទ ១, បុច្ឆា ៩ មានមូលបទ ២ មានអវសានបទ ២, បុច្ឆា ៣ មានមូលបទ ២ មានអវសានបទ ៣, បុច្ឆា ៣ មានមូលបទ ៣ មានអវសានបទ ១, បុច្ឆា ៣ មានមូលបទ ៣ មានអវសានបទ ២, បុច្ឆា ១ មានមូលបទ ៣ និងមានអវសានបទ ៣ ។ សូម្បីក្នុងអារម្មណប្បច្ច័យជាដើម ក៏មានបុច្ឆា ៤៩ ដូចក្នុងហេតុប្បច្ច័យនុ៎ះដែរ ។ សូម្បីក្នុងបច្ច័យទាំងអស់ ២៤ ៖

***ក្នុងន័យដែលមានមូលបទ ១ ព្រះមានព្រះភាគទ្រង់ប្រមូលបុច្ឆាទុក រួមមាន ១.១៧៦ វារៈ*** ។

តអំពីនោះ ព្រះមានព្រះភាគទ្រង់ផ្ដើមន័យដែលមានមូល ២ ថា **“ហេតុប្បច្ចយា អារម្មណប្បច្ចយា”** ជាដើម ។ ក្នុងន័យដែលមានមូល ២ នុ៎ះ មានទុកៈ ២៣ ព្រមជាមួយហេតុប្បច្ច័យ គឺ ***ហេតារម្មណទុកៈ ។ ល ។ ហេតាវិគតទុកៈ*** ។ សូម្បីក្នុងហេតារម្មណទុកៈ ក៏មានបុច្ឆា ៤៩ វារៈ ដូចហេតុប្បច្ច័យដែរ ។ បណ្ដាបុច្ឆាទាំងនោះ ទ្រង់សម្ដែងទុកក្នុង បាលី ២ វារៈប៉ុណ្ណោះ ។ សូម្បីក្នុងហេតាធិបតិទុកៈជាដើម ក៏មានបុច្ឆា ៤៩ វារៈ ដូចក្នុងហេតារម្មណទុកៈដែរ ។ បណ្ដាទុកៈទាំងនោះ ព្រះមានព្រះភាគ

*កាលទ្រង់សម្ដែងទុកៈ ៣ ទុកតាមលំដាប់ គឺហេតាធិបតិទុកៈ ហេតានន្តរ-ទុកៈ ហេតុសមនន្តរទុកៈ ដោយអំណាចនៃបុច្ឆាទី ១ ហើយទ្រង់សម្ដែងហេតាវិគតទុកៈជាទីបំផុត ពាក្យដែលនៅសល់ ទ្រង់សង្ខេបទុក ។ អ្នកសិក្សាគប្បីជ្រាបការកំណត់បុច្ឆាក្នុងអធិការនេះ យ៉ាងនេះ គឺៈ*

***ក្នុងទុកមូលន័យ ព្រោះក្នុងទុកៈ ២៣ ទើបមានបុច្ឆា ១.១២៧ វារៈ*** ។

*តអំពីនោះ ព្រះមានព្រះភាគទ្រង់ផ្ដើមតិមូលកន័យថា* **“ហេតុ-ប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា”** *ជាដើម ។ ក្នុងតិមូលកន័យនុ៎ះ មានតិកៈ ២២ ដោយអំណាចនៃការភ្ជាប់បច្ច័យនីមួយៗ ក្នុងបច្ច័យ ២២ មានអធិបតិប្បច្ច័យជាដើម ជាមួយនឹងហេតារម្មណទុកៈ ។ បណ្ដាតិកៈទាំងនោះ ព្រះមានព្រះភាគគ្រាទ្រង់សម្ដែងតិកៈទី ១ និងតិកៈទី ២ ដោយអំណាចនៃបុច្ឆាទីមួយហើយ ទើបទ្រង់សម្ដែងតិកៈក្នុងទីបំផុត ។ ពាក្យដែលនៅសល់ ទ្រង់សង្ខេបទុកក្នុងទុកៈ យ៉ាងណា, សូម្បីក្នុងតិកៈ ក៏ដូច្នោះដែរ; ទ្រង់ចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងតិកៈមួយៗ ។*

*ក្នុងតិមូលកន័យ ក្នុងតិកៈ ២២ ទាំងអស់ ទើបមានបុច្ឆា ១,០៧៨ វារៈ ដោយការរាប់ចំនួន ។*

*បន្ទាប់ពីនោះមក ទ្រង់ផ្ដើម* ***ន័យដែលមានមូល ៤ ថា*** **“ហេតុ-ប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា អនន្តរប្បច្ចយា”** *ជាដើម;*

*ក្នុងន័យដែលមានមូល ៤ នោះ មានចតុក្កៈ ២១ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យ ១ និងបច្ច័យ ១ ក្នុងបណ្តាបច្ច័យ ២១ មានអនន្តរប្បច្ច័យជាដើម ជាមួយនឹងតិកៈទី ១ ។ បណ្តាចតុក្កៈទាំងនោះ ព្រះមានព្រះភាគទ្រង់សម្តែង ២ ចតុក្កៈ ហើយសង្ខេបចតុក្កៈដែលនៅសល់ទុក ។ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងចតុក្កៈមួយៗ សូម្បីក្នុងអធិការនេះ ។*

*ក្នុងចតុមូលកន័យ គ្រប់ចតុក្កៈទាំងអស់ ២១ ទើបមានបុច្ឆា ១,០២៩ វារៈ ដោយការរាប់ចំនួន ។*

*តអំពីនោះមក ព្រះមានព្រះភាគទ្រង់ផ្តើមទេសនាតាំងតែអំពី* ***បញ្ចមូលកន័យ*** *រហូតដល់* ***សព្វមូលកន័យ*** *។ ន័យដែលទ្រង់ត្រាស់សង្ខេបទុកហើយអំពីខាងដើម នឹងគប្បីត្រាស់តទៅខាងមុខ ទាំងអស់នោះ ទ្រង់ធ្វើឲ្យជាបែបរបៀបដូចគ្នាហើយ សម្តែងបាលីទុកថា* ***" ឯកមូលកន័យ ទុមូលកន័យ តិមូលកន័យ ចតុមូលកន័យ បញ្ចមូលកន័យ សព្វមូលកន័យ*** *ដែលអ្នកមិនភ័ន្តច្រឡំ គប្បីឲ្យពិស្តារ" ។ ក្នុងឯកមូលកន័យជាដើមនោះ ពាក្យដែលគួរពោល ខ្ញុំបានពោលទុករៀបរយហើយ ។ ចំណែកក្នុងបញ្ចមូលកន័យមានបច្ច័យមួយពួកៗ ៥ រួមត្រូវជាបញ្ចកៈ ២០ ពួកគត់ ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបច្ច័យ ២០ គត់ មានសមនន្តរប្បច្ច័យជាដើមជាមួយនឹងចតុក្កៈមុន (គឺពោលមកអំពីមុន ៤ បច្ច័យ ក្នុងចតុមូលកន័យ)*

ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងបញ្ចកៈមួយៗ ក្នុងបញ្ចកៈទាំងនោះ ៖

ក្នុង ***បញ្ចមូលកន័យ មានបុច្ឆា ៩៨០ វារៈ ដោយការរាប់ចំនួន*** ។

ក្នុង ***ឆមូលកន័យ*** មានបច្ច័យមួយពួកៗ ៦ រួមត្រូវជា ១៩ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ១៩ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ១៩ មានសហជាតប្បច្ច័យជាដើម ជាមួយនឹងបញ្ចកៈមុន ។ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងបច្ច័យមួយៗ ក្នុងឆក្កៈទាំងនោះ ៖

ក្នុង ***ឆមូលកន័យ មានបុច្ឆា ៩៣១ វារៈ ដោយការរាប់ចំនួន*** ។

ក្នុង ***សត្តមូលកន័យ*** មានបច្ច័យមួយពួកៗ ៧ រួមត្រូវជា ១៨ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ១៨ មានអញ្ញមញ្ញប្បច្ច័យជាដើម ជាមួយនឹងឆក្កៈមុន ព្រោះចាត់ជាបុច្ឆា ៤៩ វារៈ ចូលក្នុងសត្តកៈមួយៗ បណ្ដាសត្តកៈទាំងនោះ ៖

ក្នុង ***សត្តមូលកន័យ មានបុច្ឆា ៨៨២ វារៈ ដោយការរាប់ចំនួន*** ។

ក្នុង ***អដ្ឋមូលកន័យ*** មានបច្ច័យមួយពួកៗ ៨ រួមត្រូវជា ១៧ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ១៧ មាននិស្សយប្បច្ច័យជាដើម ជាមួយនឹងសត្តកៈមុន ព្រោះចាត់ជាបុច្ឆា ៤៩ វារៈ ចូលក្នុងអដ្ឋកៈមួយៗ បណ្ដាអដ្ឋកៈទាំងនោះ ៖

ក្នុង ***អដ្ឋមូលកន័យ*** មានបុច្ឆា ៨៣៣ វារៈ ដោយការរាប់ចំនួន ។

ក្នុង ***នវមូលកន័យ*** មានបច្ច័យមួយពួកៗ ៩ រួមត្រូវជា ១៦ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបច្ច័យទាំង ១៦ មានឧបនិស្សយប្បច្ច័យជាដើម ជាមួយនឹងអដ្ឋកៈមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងនវកៈមួយៗ បណ្ដានវកៈទាំងនោះ ៖

ក្នុង ***នវមូលកន័យ មានបុច្ឆា ៧៨៤ វារៈ ដោយការគណនា*** ។

ក្នុង ***ទសមូលកន័យ*** មានបច្ច័យមួយពួកៗ ១០ រួមជា ១៥ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ បណ្ដាបច្ច័យ ១៥ មានបុរេជាតប្បច្ច័យជាដើម ជាមួយនឹងនវកៈមុន ព្រោះចាត់ជាបុច្ឆា ៤៩ វារៈ ចូលក្នុងទសកៈមួយៗ បណ្ដាទសកៈនោះៗ ៖

ក្នុង ***ទសមូលកន័យ មានបុច្ឆា ៧៣៥ វារៈ ដោយការរាប់ចំនួន*** ។

ក្នុង ***ឯកាទសមូលកន័យ*** មានបច្ច័យមួយពួកៗ ១១ រួមត្រូវជា ១៤ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ បណ្ដាបច្ច័យ ១៤ មានបច្ឆាជាតប្បច្ច័យជាដើម ជាមួយនឹងទសកៈមុន ព្រោះចាត់ជាបុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាឯកាទសកៈទាំងនោះ ៖

ក្នុង ***ន័យដែលមានមូល ១១ ទើបមានបុច្ឆា ៦៨៦ វារៈ*** ។

ក្នុង ***ន័យដែលមានមូល ១២*** មានបច្ច័យមួយពួកៗ ១២ រួមត្រូវជា

១៣ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្តាបច្ច័យទាំង ១៣ មានអាសេវនប្បច្ច័យជាដើម ជាមួយនឹងឯកាទសកៈមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្តាទ្វាទសកៈទាំងនោះ ៖

ក្នុង **ន័យដែលមានមូល ១២ ទើបមានបុច្ឆា ៦៣៧ វារៈ ដោយការគណនា** ។

ក្នុង **ន័យដែលមានមូល ១៣** មានបច្ច័យមួយពួកៗ ១៣ រួមត្រូវជា ១២ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបច្ច័យទាំង ១២ មានកម្មប្បច្ច័យជាដើម ជាមួយនឹងទ្វាទសកៈមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្តាតេរសកៈ ៖

ក្នុង **ន័យដែលមានមូល ១៣ ទើបមានបុច្ឆា ៥៨៨ វារៈ ដោយការគណនា** ។

ក្នុង **ន័យដែលមានមូល ១៤** បច្ច័យមួយពួកៗ មាន ១៤ រួមត្រូវជា ១១ ពួក ដោយអំណាចនៃការភ្ជាប់មួយៗ ក្នុងបច្ច័យទាំង ១១ មានវិបាកប្បច្ច័យជាដើម ជាមួយនឹងតេរសកៈមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្តាចុទ្ទសកៈទាំងនោះ ៖

**ក្នុងន័យដែលមានមូល ១៤ ទើបមានបុច្ឆា ៥៣៩ វារៈ ដោយការគណនា** ។

***ក្នុងន័យដែលមានមូល ១៥ មានបច្ច័យមួយពួកៗ ១៥ រួមត្រូវជា ១០ ពួក*** *ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ១០ មានអាហារប្បច្ច័យជាដើម ជាមួយនឹងចុទ្ទសកៈមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ១៥ ពួកនោះ ៖*

*ក្នុង* ***ន័យដែលមានមូល ១៥ ទើបមានបុច្ឆា ៤៩០ វារៈ ដោយការគណនា*** *។*

*ក្នុង* ***ន័យដែលមានមូល ១៦*** *មានបច្ច័យមួយពួកៗ ១៦ រួមជា ៩ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៩ មានឥន្ទ្រិយប្បច្ច័យជាដើម ជាមួយនឹង ១៥ ពួកមុន ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ១៦ ពួកនោះ ៖*

*ក្នុង* ***ន័យដែលមានមូល ១៦ ទើបមានបុច្ឆា ៤៤១ វារៈ ដោយការគណនា*** *។*

*ក្នុង* ***ន័យដែលមានមូល ១៧*** *មានបច្ច័យមួយពួកៗ ១៧ រួមត្រូវជា ៨ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ៨ មានឈានប្បច្ច័យជាដើម ជាមួយនឹង ១៦ ពួកមុនៗ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ១៧ នោះ ៖*

*ក្នុង* ***ន័យដែលមានមូល ១៧ ទើបមានបុច្ឆា ៣៩២ វារៈ ដោយការ***

***គណនា*** ។

ក្នុង ***ន័យដែលមានមូល ១៨*** មានបច្ច័យមួយពួកៗ ១៨ រួមត្រូវជា ៧ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៧ មានមគ្គប្បច្ច័យជាដើម ជាមួយនឹងបច្ច័យទាំង ១៧ មុន ៗ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ១៨ ពួកនេះ ៖

ក្នុង ***ន័យដែលមានមូល ១៨ ទើបមានបុច្ឆា ៣៤៣ វារៈ ដោយការគណនា*** ។

ក្នុង ***ន័យដែលមានមូល ១៩*** មានបច្ច័យមួយពួកៗ ១៩ រួមត្រូវជា ៦ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៦ មានសម្បយុត្តប្បច្ច័យជាដើម ជាមួយនឹងបច្ច័យទាំង ១៨ មុន ៗ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ១៩ ពួកនោះ ៖

ក្នុង ***ន័យដែលមានមូល ១៩ ទើបមានបុច្ឆា ២៩៤ វារៈ ដោយការគណនា*** ។

ក្នុង ***ន័យដែលមានមូល ២០*** មានបច្ច័យមួយពួកៗ ២០ រួមត្រូវជា ៥ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៥ មានវិប្បយុត្តប្បច្ច័យជាដើម ជាមួយនឹងបច្ច័យទាំង ១៩ មុន ៗ ព្រោះ

ចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ២០ ពួកនោះ ៖

ក្នុង ***ន័យដែលមានមូល ២០ ទើបមានបុច្ឆា ២៤៥ វារៈ ដោយការគណនា*** ។

ក្នុង ***ន័យដែលមានមូល ២១*** មានបច្ច័យមួយពួកៗ ២១ រួមត្រូវជា ៤ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៤ មានអត្ថិប្បច្ច័យជាដើម ជាមួយនឹងពួក ២០ មុន ។ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ២១ ពួកនោះ ៖

ក្នុង ***ន័យដែលមានមូល ២១ អ្នកដឹងលក្ខណៈ ទើបរាប់ប្រមូលបុច្ឆាបាន ១៩៦ វារៈ*** ។

ក្នុង ***ន័យដែលមានមូល ២២*** មានបច្ច័យមួយពួកៗ ២២ រួមត្រូវជា ៣ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យទាំង ៣ មាននត្ថិប្បច្ច័យជាដើម ជាមួយនឹង ២១ ពួកមុន ។ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុងពួកមួយៗ បណ្ដាបច្ច័យទាំង ២២ ពួកនោះ ៖

ក្នុង ***ន័យដែលមានមូល ២២ ទើបមានបុច្ឆា ១៤៧ វារៈ ដោយការគណនា*** ។

ក្នុង ***ន័យដែលមានមូល ២៣*** មានបច្ច័យពួកទី ២៣ រួមត្រូវជា ២ ពួក ដោយអំណាចនៃការភ្ជាប់បច្ច័យមួយៗ ក្នុងវិគតាវិគតប្បច្ច័យទាំង

ពីរ ជាមួយនឹង ២២ ពួកមុន ។ ព្រោះចាត់បុច្ឆា ៤៩ វារៈ ចូលក្នុង ពួកមួយៗ បណ្តាបច្ច័យទាំង ២៣ ពួកនោះ ៖

ក្នុង **ន័យដែលមានមូល ២៣ ជាគម្រប់ទី ២៣ នេះ ទើបមាន បុច្ឆា ៩៨ វារៈ ដោយការគណនា** ។

ចំណែក **ន័យដែលមានមូល ២៤** អ្នកសិក្សា គប្បីជ្រាបដោយអំណាចនៃការប្រជុំបច្ច័យទាំងអស់, ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា មានបច្ច័យទាំងអស់ជាមូល ។ ក្នុងន័យដែលមានមូល ២៤ នោះ មានបុច្ឆាតែ ៤៩ វារៈប៉ុណ្ណោះ ។

បុច្ឆាទាំងអស់នោះ ព្រះសាស្តាទ្រង់កាន់យកចំពោះបទថា ហេតុប្បច្ច័យប៉ុណ្ណោះ ចែកដោយពិស្តារក្រៃលែងក្នុងទេពបរិស័ទ ដោយអំណាចនៃន័យដែលមានមូលមួយជាដើម ចប់ដោយន័យដែលមានបច្ច័យទាំងអស់ជាមូល ។ ក្នុងអធិការនេះ ទ្រង់សម្តែងបុច្ឆាទុកដោយសង្ខេប ។ ក៏ប្រមូលការរាប់បុច្ឆាទាំងអស់នោះ ដូច្នេះ ៖

ពិតមែនហើយ ក្នុងន័យដែលមានមូលមួយ បុច្ឆាមានមកហើយ ១.១៧៦ វារៈ ។ បណ្តាបុច្ឆាទាំងនោះ ក្នុងន័យហេតុប្បច្ច័យ អ្នកសិក្សាគប្បីតែងបុច្ឆា ៤៩ វារៈ និងដោយបច្ច័យដែលជាមូលនោះឯង ហើយគប្បីកាន់យកក្នុងន័យដែលមានហេតុប្បច្ច័យជាមូលនេះ ។ បុច្ឆាដែលនៅសល់

អ្នកសិក្សា គប្បីដាក់ក្នុងន័យដែលមានបច្ច័យដ៏សេសជាមូល ។ ក្នុងន័យដែលមានមូលពីរ មានបុច្ឆា ១.១២៧ វារៈ, ដែលមានមូល ៣ មានបុច្ឆា ១.០៧៨ វារៈ, ដែលមានមូល ៤ មានបុច្ឆា ១.០២៩ វារៈ, ដែលមានមូល ៥ មានបុច្ឆា ៩៨០ វារៈ, ដែលមានមូល ៦ មានបុច្ឆា ៩៣១ វារៈ, ដែលមានមូល ៧ មានបុច្ឆា ៨៨២ វារៈ, ដែលមានមូល ៨ មានបុច្ឆា ៨៣៣ វារៈ, ដែលមានមូល ៩ មានបុច្ឆា ៧៨៤ វារៈ, ដែលមានមូល ១០ មានបុច្ឆា ៧៣៥ វារៈ, ដែលមានមូល ១១ មានបុច្ឆា ៦៨៦ វារៈ, ដែលមានមូល ១២ មានបុច្ឆា ៦៣៧ វារៈ, ដែលមានមូល ១៣ មានបុច្ឆា ៥៨៨ វារៈ, ដែលមានមូល ១៤ មានបុច្ឆា ៥៣៩ វារៈ, ដែលមានមូល ១៥ មានបុច្ឆា ៤៩០ វារៈ, ដែលមានមូល ១៦ មានបុច្ឆា ៤៤១ វារៈ, ដែលមានមូល ១៧ មានបុច្ឆា ៣៩២ វារៈ, ដែលមានមូល ១៨ មានបុច្ឆា ៣៤៣ វារៈ, ដែលមានមូល ១៩ មានបុច្ឆា ២៩៤ វារៈ, ដែលមានមូល ២០ មានបុច្ឆា ២៤៥ វារៈ, ដែលមានមូល ២១ មានបុច្ឆា ១៩៦ វារៈ, ដែលមានមូល ២២ មានបុច្ឆា ១៤៧ វារៈ, ដែលមានមូល ២៣ មានបុច្ឆា ៩៨ វារៈ, ដែលមានបច្ច័យទាំងអស់ជាមូល មានបុច្ឆា ៤៩ វារៈ, ក្នុងន័យដែលមានមូលមួយជាដើម ដែលចែកចេញទៅដោយលើកហេតុបទឡើងជាខាងដើម ដូចពោលមកហើយ ៖

*ចំពោះហេតុបទប៉ុណ្ណោះ ពោលដោយប្រភេទនៃមូលមួយជាដើម ទើបមានបុច្ឆា ១៤.៧០០ វារៈ* ។

*ព្រះមានព្រះភាគ ត្រាស់សម្តែងប្រភេទនៃបុច្ឆា តាំងអំពីន័យដែលមានមូលមួយ រហូតដល់ន័យដែលមានបច្ច័យទាំងអស់ជាមូល ដោយលើកហេតុប្បច្ច័យឡើងជាខាងដើម ដូចពោលមកហើយ; ឥឡូវនេះ ដើម្បីនឹងលើកអារម្មណប្បច្ច័យជាដើមឡើងសម្តែង ទើបត្រាស់ពាក្យថា “កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យឬ ?” ជាដើម* ។

*បណ្តាបទទាំងនោះ ព្រះមានព្រះភាគទ្រង់សម្តែងន័យដែលមានមូលមួយ មានអារម្មណប្បច្ច័យជាដើម មានហេតុប្បច្ច័យជាទីបំផុត ដោយពាក្យមានប្រមាណប៉ុណ្ណេះថា* **“អារម្មណប្បច្ចយា ហេតុប្បច្ចយា”** ។ *តអំពីនោះ ទ្រង់ផ្តើមន័យដែលមានមូលពីរថា* **“អារម្មណប្បច្ចយា អធិបតិប្បច្ចយា”** ។ *ក្នុងន័យដែលមានមូលពីរនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងទុកៈទីមួយនេះ និងអារម្មណាវិគតទុកៈ ហើយទ្រង់សង្ខេបពាក្យដែលនៅសល់ទុក ។ ទុកៈទីបំផុតថា* **“អារម្មណប្បច្ចយា ហេតុប្បច្ចយា”** *ដូច្នេះ ទ្រង់មិនសម្តែងទេ ។ ក៏បើទុកៈទីបំផុតនោះ ប្រាកដក្នុងផ្នែកណា, អ្នកសិក្សាគប្បីកាន់យកផ្នែកនោះចុះ ។ តអំពីនោះ ដើម្បីនឹងមិនសម្តែងតិមូល*

*កន័យជាដើម ដោយអំណាចនៃអារម្មណប្បច្ច័យ ហើយសម្ដែងបច្ច័យមួយៗ ជាដើម ដោយលើកអធិបតិប្បច្ច័យជាដើម ទើបត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះថា* **"អធិបតិប្បច្ចយា អនន្តរប្បច្ចយា សមនន្តរប្បច្ចយា សហជាតប្បច្ចយា អញ្ញមញ្ញប្បច្ចយា"** *។ ពាក្យនោះ អ្នកសិក្សាគប្បីជ្រាបដោយអំណាចរបស់ន័យដែលមានមូលមួយ ឬដែលមានបច្ច័យទាំងអស់ជាមូល ។*

*តអំពីនោះ ដើម្បីទ្រង់នឹងសម្ដែងចំពោះទុមូលកន័យប៉ុណ្ណោះ ដោយលើកអវិគតប្បច្ច័យឡើងជាខាងដើម ទើបផ្ដើមពាក្យថា* **"អវិគតប្បច្ចយា ហេតុប្បច្ចយា"** *ជាដើម ។ ក្នុងទុមូលកន័យនោះ គ្រាត្រាស់ទុកៈ ៣ តាមលំដាប់ គឺអវិគតហេតុទុកៈ អវិគតារម្មណទុកៈ និងអវិគតាធិបតិទុកៈ ហើយទើបទ្រង់សម្ដែងទុកៈមួយ គឺអវិគតវិគតទុកៈ ក្នុងទីបំផុត ។*

*លំដាប់នោះ ដើម្បីទ្រង់នឹងសម្ដែងន័យដែលមានមូល ៣ ដោយអំណាចនៃអវិគតប្បច្ច័យ កាលបើទ្រង់ត្រាស់តិកៈ ៣ តាមលំដាប់យ៉ាងនេះ គឺ* **"អវិគតប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា, អវិគតប្បច្ចយា ហេតុប្បច្ចយា អធិបតិប្បច្ចយា, អវិគតប្បច្ចយា ហេតុប្បច្ចយា អនន្តរ-ប្បច្ចយា"** *ហើយទើបទ្រង់ត្រាស់តិកៈចុងបំផុតថា* **"អវិគតប្បច្ចយា ហេតុ-ប្បច្ចយា វិគតប្បច្ចយា"** *។*

*លំដាប់នោះ ដើម្បីទ្រង់សម្ដែងន័យដែលមានមូល ៤ ដោយអំណាច*

នៃអវិគតប្បច្ច័យនុ៎ះឯង កាលបើទ្រង់ត្រាស់ពួក ៤ ពីរពួក គឺ **“អវិគត-ប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិប្បច្ចយា, អវិគតប្បច្ចយា ហេតុប្បច្ចយា អារម្មណប្បច្ចយា អនន្តរប្បច្ចយា”** ហើយទ្រង់លើកបទថា **“វិគតប្បច្ចយា”** មកតាំងទុក, ពាក្យដែលនៅសល់ទាំងអស់ ទ្រង់សង្ខេបទុក ។ ដើម្បីទ្រង់សម្ដែងថា ពាក្យទាំងអស់នោះ ទ្រង់សង្ខេបទុក ទើបត្រាស់ថា “ឯកមូលកន័យ ទុមូលកន័យ តិមូលកន័យ ចតុមូលកន័យ សព្វមូលកន័យ របស់បទមួយៗ ដែលអ្នកសិក្សាមិនគប្បីអល់អែក គប្បីពង្រីកសេចក្ដីឲ្យពិស្ដារចុះ” ។

ព្រោះហេតុដូច្នោះ ក្នុងឯកមូលកន័យ មានបុច្ឆា ១.១៧៦ វារៈ ។ ល ។ ក្នុងសព្វមូលកន័យ មានបុច្ឆា ៤៩ វារៈ ដោយអំណាចនៃបទថា ***ហេតុ*** ជាដើម ដោយលើកហេតុប្បច្ច័យឡើងជាខាងដើម យ៉ាងណា, ក្នុងឯកមូលកន័យរបស់បទមួយៗ ក៏មានបុច្ឆា ១.១៧៦ វារៈ ក្នុងសព្វ-មូលកន័យ មានបុច្ឆា ៤៩ វារៈ ដោយអំណាចនៃបទថា ***អារម្មណ៍*** ជាដើម ដោយលើកបច្ច័យមួយៗ មានអារម្មណប្បច្ច័យជាដើម ឡើងជាខាងដើម ព្រោះហេតុដូច្នោះ ក្នុងការចែកបទមួយៗ ដោយឯកមូលកន័យជាដើម ទើបមានបុច្ឆា ១៤.៧០០ វារៈ ដូចពោលមកហើយ ។ ការកំណត់គណនាបុច្ឆាទាំងនោះ ក្នុងបច្ច័យទាំង ២៤ មានដូច្នេះ គឺ ៖

ក្នុង ***អនុលោមន័យ ទ្រង់ចែកបុច្ឆានៃកុសលត្តិកៈទុក ៣៥២.៨០០ បុច្ឆាវារៈ ទុកយ៉ាងល្អហើយ*** ។

*កុសលត្តិកៈ យ៉ាងណា, វេទនាតិកៈជាដើម ក៏ដូច្នោះដែរ ។ ក្នុងតិកៈទាំងអស់ ២២ តិកៈ ពោលដោយការចែកប្រភេទនៃតិកៈហើយ មានបុច្ឆា ៧.៧៦១.៦០០ វារៈ ដ៏វៀង (ពលសេចក្តី) ព្រះមានព្រះភាគទ្រង់សង្ខេបទុក ។*

*ក្នុងទុកៈទាំងឡាយ ព្រះបាលីថា* **“សិយា ហេតុំ ធម្មំ បដិច្ច ហេតុ ធម្មោ ឧប្បជ្ជេយ្យ ហេតុប្បច្ចយា** *= ធម៌ដែលជាហេតុ គប្បីអាស្រ័យធម៌ដែលជាហេតុ កើតឡើងឬ ?” ដូច្នេះ រមែងបានបុច្ឆា ៩ វារៈ ក្នុងបច្ច័យមួយៗ មានហេតុប្បច្ច័យជាដើម ក្នុងទុកៈមួយៗ យ៉ាងនេះ គឺហេតុអាស្រ័យហេតុ, នហេតុ អាស្រ័យហេតុ, ហេតុ និងនហេតុ អាស្រ័យហេតុ, នហេតុ អាស្រ័យនហេតុ, ហេតុ អាស្រ័យនហេតុ, ហេតុ និងនហេតុ អាស្រ័យនហេតុ, ហេតុ អាស្រ័យហេតុ និងនហេតុ, នហេតុ អាស្រ័យហេតុ និងនហេតុ, ហេតុ និងនហេតុ អាស្រ័យហេតុ និងនហេតុ ។*

*បណ្តាបុច្ឆាទាំងនោះ ក្នុងឯកមូលកន័យ លើកហេតុប្បច្ច័យឡើងជាខាងដើម មានបុច្ឆា ២១៦ វារៈ ។ បណ្តាបុច្ឆាទាំង ២១៦ វារៈនោះ សម្រាប់ហេតុប្បច្ច័យតែម្យ៉ាង អ្នកសិក្សាគប្បីកាន់យកបុច្ឆា ៩ វារៈ ដែល*

មិនប្រឡូកប្រឡំជាមួយបច្ច័យដទៃ ៗ ដែលនៅសល់ លោកកាន់យកដោយវារៈនៃការអធិប្បាយបុច្ឆាទាំងនោះ ៗ

មានកំណត់ការគណនា ក្នុងវារៈ ២៣ មានទុមូលជាដើម រហូតដល់មូលទាំងអស់ជាដើម ដោយនាំនវកៈមួយៗ ចេញ ដូច្នេះ ៖

ក្នុង ***ទុមូលកន័យ*** បណ្ដាបុច្ឆា ២១៦ វារៈ ដែលសម្ដែងទុកក្នុង ***ឯកមូលកន័យ*** នាំបុច្ឆាចេញ ៩ វារៈ ទើបមានបុច្ឆា ២០៧ វារៈ ៗ តអំពីនោះ ក្នុងតិមូលកន័យ យកចេញ ៩ វារៈទៀត គង់នៅសល់ ១៩៨ វារៈ យកបុច្ឆាចេញអំពីមូលខាងដើមរៀងៗ គ្នា ៩ វារៈ ដូចពោលមកហើយ ៗ ក្នុង ***ចតុមូលកន័យ*** ទើបមានបុច្ឆា ១៨៩ វារៈ ៗ ក្នុង ***បញ្ចមូលកន័យ*** មានបុច្ឆា ១៨០ វារៈ ៗ ក្នុង ***ឆមូលកន័យ*** មានបុច្ឆា ១៧១ វារៈ ៗ ក្នុង ***សត្តមូលកន័យ*** មានបុច្ឆា ១៦២ វារៈ ៗ ក្នុង ***អដ្ឋមូលកន័យ*** មានបុច្ឆា ១៥៣ វារៈ ៗ ក្នុង ***នវមូលកន័យ*** មានបុច្ឆា ១៤៤ វារៈ ៗ ក្នុង ***ទសមូលកន័យ*** មានបុច្ឆា ១៣៥ វារៈ ៗ ក្នុង ***ឯកាទសមូលកន័យ*** មានបុច្ឆា ១២៦ វារៈ ៗ ក្នុង ***ទ្វាទសមូលកន័យ*** មានបុច្ឆា ១១៧ វារៈ ៗ ក្នុង ***តេរសមូលកន័យ*** មានបុច្ឆា ១០៨ វារៈ ៗ ក្នុង ***ចុទ្ទសមូលកន័យ*** មានបុច្ឆា ៩៩ វារៈ ៗ ក្នុង ***បណ្ណរសមូលកន័យ*** មានបុច្ឆា ៩០ វារៈ ៗ ក្នុង ***សោឡសមូលកន័យ*** មានបុច្ឆា ៨១ វារៈ ៗ

ក្នុង ***សត្តរសមូលកន័យ*** មានបុច្ឆា ៧២ វារៈ ។ ក្នុង ***អដ្ឋារសមូលកន័យ*** មានបុច្ឆា ៦៣ វារៈ ។ ក្នុង ***ឯកូនវីសតិមូលកន័យ*** មានបុច្ឆា ៥៤ វារៈ ។ ក្នុង ***វីសមូលកន័យ*** មានបុច្ឆា ៤៥ វារៈ ។ ក្នុង ***ឯកវីសតិមូលកន័យ*** មានបុច្ឆា ៣៦ វារៈ ។ ក្នុង ***ពាវីសតិមូលកន័យ*** មានបុច្ឆា ២៧ វារៈ ។ ក្នុង ***តេវីសតិមូលកន័យ*** មានបុច្ឆា ១៨ វារៈ និងក្នុង ***សព្វមូលកន័យ*** មានបុច្ឆា ៩ វារៈ ។

ដូចជាក្នុង ***ឯកមូលកន័យ*** មានបុច្ឆា ២១៦ វារៈ ។ល។ ក្នុង ***សព្វមូលកន័យ*** មានបុច្ឆាទាំង ៩ វារៈនេះ ដោយអំណាចនៃហេតុ-ប្បច្ច័យ យ៉ាងណា, ពោលដោយអំណាចនៃបទ មានអារម្មណបទជាដើម ធ្វើនូវបច្ច័យមួយៗ មានអារម្មណប្បច្ច័យជាដើម ឡើងជាខាងដើម ក្នុងឯកមូលកន័យនៃបទមួយៗ ក៏មានបុច្ឆា ២១៦ វារៈ ។ល។ ក្នុងសព្វមូលកន័យ មានបុច្ឆា ៩ វារៈ ដូចគ្នាដែរ, ព្រោះហេតុដូច្នោះ ក្នុងការចែកបទមួយៗ ដោយឯកមូលកន័យជាដើម ទើបមានបុច្ឆា ២.៧០០ វារៈ ។ មានការកំណត់ចំនួនបុច្ឆាទាំងនោះ ក្នុងបច្ច័យ ២៤ ទាំងអស់ដូច្នេះ ក្នុងអនុលោមន័យ នៃហេតុទុកៈ មានបុច្ឆា ៦៤.៨០០ វារៈ ។ សូម្បីក្នុងសហេតុទុកៈជាដើម ក៏ដូចនឹងហេតុទុកៈដែរ ។

***សូម្បីក្នុងទុកៈទាំងអស់ ១០០ លោកអ្នកត្រាស់ដឹងពោលបុច្ឆាទុក***

***ក្នុងទុកៈ ១០០, បុច្ឆា ៦.៤៨០.០០០ វារៈ*** ។

*នេះជាការកំណត់ចំនួនបុច្ឆា ក្នុងតិកបដ្ឋាន និងទុកបដ្ឋានសុទ្ធៗ ជាមុន ។*

*ចំណែកដែលឈ្មោះថា ទុកត្តិកបដ្ឋានណា ដែលព្រះមានព្រះភាគទ្រង់កាន់យកតិកៈ ២២ បន្ថែមចូលក្នុងទុកៈ ១០០ ទុកៈ សម្តែងទុកតអំពីនោះ, ក្នុងទុកត្តិកបដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការកំណត់ចំនួនបុច្ឆាដែលគួរសម្តែងប្រកបតិកៈនីមួយៗ ក្នុងបណ្តាតិកៈ ២២ ចូលជាមួយទុកៈ ១០០ ដោយអំណាចន័យដែលមានមូលមួយជាដើមទាំងអស់ តាមន័យដែលព្រះមានព្រះភាគត្រាស់ហើយអំពីខាងដើម យ៉ាងនេះថា* ***“កុសលធម៌ដែលជាហេតុ គប្បីអាស្រ័យកុសលធម៌ដែលជាហេតុកើតឡើង ព្រោះហេតុ-ប្បច្ច័យឬ ?”*** *ដូច្នេះ ។*

*តអំពីនោះ ព្រះមានព្រះភាគទ្រង់កាន់យកទុកៈ ១០០ រួមបញ្ចូលក្នុងតិកៈ ២២ ហើយសម្តែងបដ្ឋានឈ្មោះថា តិកទុកបដ្ឋានណាទុក សូម្បីក្នុងតិកទុកបដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការកំណត់ចំនួនបុច្ឆា ដែលគប្បីសម្តែងប្រកបទុកៈនីមួយៗ ក្នុង ១០០ ទុកៈ បញ្ចូលជាមួយតិកៈ ២២ ដោយអំណាចន័យដែលមានមូលមួយជាដើមទាំងអស់ តាមន័យដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយអំពីខាងដើម យ៉ាងនេះថា* ***“ធម៌ដែលជាហេតុ***

***ដែលជាកុសល គប្បីអាស្រ័យធម៌ ដែលជាហេតុ ដែលជាកុសល កើតឡើង ព្រោះហេតុប្បច្ច័យឬ ?”*** ។

*តអំពីនោះ ទ្រង់បន្ថែមតិកៈទាំងឡាយ បញ្ចូលក្នុងតិកៈនោះឯង ហើយសម្ដែងបដ្ឋាន ឈ្មោះថា តិកត្តិកប្បដ្ឋាន យ៉ាងណាទុក, ក្នុងតិកត្តិកប្បដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការកំណត់ បុច្ឆាដែលគប្បីសម្ដែងប្រកបតិកៈមួយៗ ក្នុងបណ្ដាតិកៈ ២២ បញ្ចូលជាមួយតិកៈ ២១ ដែលនៅសល់ ដោយអំណាចន័យដែលមានមូលមួយជាដើមទាំងអស់នោះ តាមន័យដែលព្រះមានព្រះភាគត្រាស់ហើយអំពីខាងដើម យ៉ាងនេះថា* ***“ធម៌ដែលសម្បយុត្តដោយសុខវេទនាដែលជាកុសល គប្បីអាស្រ័យធម៌ដែលសម្បយុត្តដោយសុខវេទនាដែលជាកុសលកើតឡើង ព្រោះហេតុប្បច្ច័យឬ ?”*** ។

*តអំពីនោះ ទ្រង់បន្ថែមទុកៈ បញ្ចូលក្នុងទុកៈនោះឯង ហើយសម្ដែងបដ្ឋាន ដែលឈ្មោះថា ទុកទុកប្បដ្ឋាន យ៉ាងណាទុក, ក្នុងទុកទុកប្បដ្ឋាននោះ អ្នកសិក្សាគប្បីជ្រាបការកំណត់វិធីរាប់បុច្ឆា ដែលគប្បីសម្ដែងប្រកបទុកៈមួយៗ ក្នុង ១០០ ទុកៈ ជាមួយនឹងទុកៈ ៩៩ ដែលនៅសល់ ដោយអំណាចន័យដែលមានមូលមួយជាដើម តាមន័យដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយអំពីខាងដើម យ៉ាងនេះថា* ***“ធម៌ដែលមានហេតុ (និង) ជាហេតុ គប្បីអាស្រ័យធម៌ដែលជាហេតុ (និង) មានហេតុកើតឡើង ព្រោះ***

*ហេតុប្បច្ច័យឬ ?”* ។

*ពិតមែនហើយ ព្រះតថាគត គ្រាទ្រង់សម្ដែងប្រភេទទាំងអស់នោះហើយ ទើបទ្រង់សម្ដែងធម៌ក្នុងទេពបរិស័ទ ។ ប៉ុន្តែ ព្រះធម្មសេនាបតីរួបរួមសង្ខេបទុកថា “ធម៌នេះៗ ព្រះអង្គទ្រង់សម្ដែងក្នុងថ្ងៃនេះ” ហើយពោលក្នុងទេសនាដោយសម្ដែងត្រឹមតែន័យនោះប៉ុណ្ណោះ ។ ន័យមិនសំខាន់ដែលពោលសង្ខេបទុក ព្រះថេរៈបំប្រួញឲ្យប្រព្រឹត្តទៅហើយ ។ ន័យមិនសំខាន់នោះ ព្រះធម្មសង្គាហកាចារ្យលើកឡើងកាន់សង្គហៈក្នុងសង្គីតិកាល តាមន័យដែលព្រះថេរៈឲ្យប្រព្រឹត្តទៅហើយនោះឯង ។ ក៏ដើម្បីសម្ដែងសង្ខេបន័យដែលមិនសំខាន់នោះ ទើបខ្ញុំតាំងគាថានេះទុកថា* **“ តិកញ្ច បដ្ឋានវរំ ”** *ជាដើម ។*

*គាថានោះ មានសេចក្ដីថា ពាក្យថា* **“តិកញ្ច បដ្ឋានវរំ** *= តិកប្បដ្ឋានដ៏ប្រសើរ” គឺដ៏បវរ ។ បទថា* **“ទុកុត្តមំ** *= ទុកប្បដ្ឋានដ៏ឧត្ដម” គឺដ៏ប្រសើរបំផុត ។ បទថា* **“ទុកត្តិកញ្ចេវ”** *គឺទុកត្តិកប្បដ្ឋាន ។ បទថា* **“ តិកទុកញ្ច ”** *គឺតិកទុកប្បដ្ឋាន ។ បទថា* **“ តិកត្តិកញ្ចេវ ”** *គឺតិកត្តិកប្បដ្ឋាន ។ បទថា* **“ ទុកទុកញ្ច ”** *គឺទុកទុកប្បដ្ឋាន ។ ពាក្យថា* **“ ឆ អនុលោមម្ហិ នយា សុគម្ភីរា”** *សេចក្ដីថា អ្នកសិក្សាគប្បីជ្រាបន័យ ៦ ដ៏ជ្រាលជ្រៅ ដោយល្អ មានតិកប្បដ្ឋានជាដើមនេះ ក្នុងអនុលោម ។*

*បណ្ដាន័យទាំងនោះ អនុលោមមាន ២ គឺធម្មានុលោម និងបច្ចយា-នុលោម ក្នុងអនុលោមពីរនេះ បដ្ឋានដែលព្រះអង្គឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃទេសនា ដែលជាអនុលោមដល់ធម៌ដែលលោករួបរួមដោយបទអភិធម្មមាតិកា យ៉ាងនេះថា "កុសលធម៌អាស្រ័យកុសលធម៌" ឈ្មោះថា* ***ធម្មានុលោម*** *។ បដ្ឋានដែលព្រះអង្គឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃទេសនាដែលជាអនុលោមដល់បច្ច័យ ២៤ យ៉ាងនេះថា* **"ហេតុប្បច្ចយា អារម្មណ-ប្បច្ចយា"** *ឈ្មោះថា* ***បច្ចយានុលោម*** *។*

*បណ្ដាពាក្យដែលជាគាថាទាំងនោះ គាថានេះថា* **"តិកញ្ច បដ្ឋានវរំ ។ល។ ឆ អនុលោមម្ហិ នយា សុគម្ភីរា"** *លោកពោលទុកក្នុងអដ្ឋកថាខាងដើម សំដៅដល់ធម្មានុលោម ។ ប៉ុន្តែក្នុងអធិការនេះ គាថានេះលោកពោលសំដៅដល់បច្ចយានុលោមក្នុងធម្មានុលោមនោះ ។ ព្រោះហេតុដូច្នោះ ពាក្យថា* **"ឆ អនុលោមម្ហិ នយា សុគម្ភីរា"** *អ្នកសិក្សាគប្បីជ្រាបសេចក្ដីក្នុងអដ្ឋកថាយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើមក្នុងធម្មានុលោមដ៏ជ្រាលជ្រៅក្រៃលែង ។ ប៉ុន្តែក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មា-នុលោម ត្រង់បច្ចយានុលោមដែលប្រព្រឹត្តទៅយ៉ាងនេះថា* **"ហេតុប្បច្ចយា អារម្មណប្បច្ចយា"** *ដ៏ជ្រាលជ្រៅក្រៃលែង ។ បណ្ដាន័យទាំង ៦ នោះ*

ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគទ្រង់សម្ដែង ដោយសង្ខេប ក្នុង ***បណ្ណត្តិវារៈ*** នៃបដិច្ចវារៈ ដោយអំណាចនៃកុសលត្តិកៈប៉ុណ្ណោះ ក្នុង ***តិកប្បដ្ឋាន*** ដែលជាអនុលោម ។ ចំណែកក្នុងតិកៈ និងទុកៈដែលសល់ និងក្នុងបដ្ឋានដែលនៅសល់ មិនមានបុច្ឆា សូម្បីតែមួយឡើយ ។

ក៏ក្នុងសហជាតវារៈជាដើម តអំពីនោះ ព្រះមានព្រះភាគទ្រង់មិនលើកបុច្ឆាឡើង ដោយអំណាចនៃកុសលត្តិកៈទេ ទ្រង់សម្ដែងចំពោះតែវិសជ្ជនា ដោយអំណាចនៃវារៈដែលមានប៉ុណ្ណោះ ។ ព្រោះព្រះបាលីថា **“ ឆ អនុលោមម្ហិ នយា សុគម្ភីរា ”** ។ អ្នកសិក្សាគប្បីលើកបដ្ឋានន័យទាំង ៦ នេះ ឡើងសម្ដែងក្នុងបច្ចយានុលោមនេះ ដោយអំណាចនៃបុច្ឆាទាំងឡាយ; ព្រោះថា នោះជាភារៈនៃអាចារ្យអ្នកអធិប្បាយបដ្ឋាន ៕

---

## ២.ពណ៌នាអំពីបច្ចយបច្ចនីយន័យ

ឥឡូវនេះ ដើម្បីនឹងសម្ដែងបច្ចនីយប្បដ្ឋាន ព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា ***“ កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះនហេតុប្បច្ច័យឬ ? ”*** ក្នុងបច្ចនីយប្បដ្ឋាននោះ មានការកំណត់បុច្ឆាស្មើនឹងអនុលោមបុច្ឆា; ព្រោះហេតុនោះ ក្នុងបច្ចនីយប្បដ្ឋាននេះ ទើបព្រះមានព្រះភាគត្រាស់ថា

*"អ្នកសិក្សា គប្បីអធិប្បាយហេតុប្បច្ច័យ សូម្បីនៅក្នុងបច្ចនីយប្បដ្ឋាន ដូចការអធិប្បាយហេតុប្បច្ច័យ ក្នុងអនុលោមប្បដ្ឋានដែរ" ហើយត្រាស់ទុកក្នុងទីបំផុតទៀតថា "គប្បីអធិប្បាយឯកមូលកៈ រហូតដល់តេវីសតិមូលកៈនៃបទនីមួយៗ ក្នុងបច្ចនីយប្បដ្ឋាន ដូចក្នុងអនុលោមប្បដ្ឋានដែរ" ។*

*ពាក្យថា* **"តេវីសតិមូលកំ"** *នេះ ទ្រង់ត្រាស់សំដៅដល់ទុមូលកប្បដ្ឋានប៉ុណ្ណោះ ក្នុងអធិការនេះ; ចំណែកសព្វមូលកន័យក្នុងទីបំផុត បានដល់ចតុវីសតិមូលកន័យនោះឯង ។ ន័យទាំងអស់នោះ ទ្រង់សង្ខេបទុកដូច្នេះឯង ។*

*ព្រះបាលីថា* **"តិកញ្ច បដ្ឋានវរំ ។ ល ។ ឆ បច្ចនីយម្ហិ នយា សុគម្ភីរា"** *នេះ បានដល់ បច្ចនីយៈ ២ យ៉ាង គឺធម្មប្បច្ចនីយៈ និងបច្ចយប្បច្ចនីយៈ ។ ក្នុង ២ យ៉ាងនោះ ន័យដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅហើយ ដោយអំណាចនៃការសម្ដែងធម៌ ដែលសង្គ្រោះដោយបទអភិធម្មមាតិកា យ៉ាងនេះថា* **"កុសលា ធម្មា"** *ដោយសម្ដែងជាបច្ចនីយៈថា* **"ន កុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មោ"** *ឈ្មោះថា ធម្មប្បច្ចនីយៈ ។ ន័យដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការសម្ដែងបច្ច័យ ២៤ ដោយអំណាចជាបច្ច័យយ៉ាងនេះថា* **"ន ហេតុប្បច្ចយា នារម្មណប្បច្ចយា"** *ឈ្មោះថា បច្ចយប្បច្ចនីយៈ ។ ក្នុង ២ យ៉ាងនោះ គាថានេះថា* **"តិកញ្ច បដ្ឋានវរំ ។ ល ។ ឆ បច្ចនីយម្ហិ នយា សុគម្ភីរា"** *ក្នុងអដ្ឋកថា*

អំពីខាងដើម លោកពោលសំដៅដល់ធម្មប្បច្ចនីយៈ, ប៉ុន្តែក្នុងអធិការនេះ គាថានេះ លោកពោលសំដៅដល់បច្ចយប្បច្ចនីយៈ ក្នុងធម្មានុលោមប៉ុណ្ណោះ ។ ព្រោះហេតុដូច្នោះ ក្នុងគាថានៃអដ្ឋកថាដែលថា **“ឆ បច្ចនីយម្ហិ នយា សុគម្ភីរា”** អ្នកសិក្សាគប្បីជ្រាប សេចក្ដីយ៉ាងនេះថា ន័យ ៦ មាន ***តិកប្បដ្ឋាន*** ជាដើម ក្នុងធម្មប្បច្ចនីយៈ ដ៏ជ្រាលជ្រៅក្រៃលែង ។ ប៉ុន្តែ ក្នុងបច្ចនីយៈដែលប្រព្រឹត្តទៅយ៉ាងនេះថា **“នហេតុ-ប្បច្ចយា នអារម្មណប្បច្ចយា”** ក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មានុលោមប៉ុណ្ណោះដ៏ជ្រាលជ្រៅ ។ បណ្ដាន័យទាំង ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគទ្រង់សម្ដែងដោយសង្ខេប ក្នុងបណ្ណត្តិវារៈនៃបដិច្ចវារៈនេះ ដោយអំណាចនៃធម៌ត្រឹមតែកុសលត្តិកៈ ក្នុងអនុលោមតិកប្បដ្ឋានប៉ុណ្ណោះ, សូម្បីក្នុងតិកៈ និងទុកៈដែលនៅសល់ និងក្នុងបដ្ឋានដែលសល់ ក៏មិនមានបុច្ឆាតែមួយឡើយ ។ ក្នុងសហជាតវារៈជាដើម តអំពីនោះ ព្រះមានព្រះភាគទ្រង់មិនលើកបុច្ឆាឡើង ដោយអំណាចនៃកុសលត្តិកៈទេ, ទ្រង់សម្ដែងចំពោះតែវិសជ្ជនា ដោយអំណាចនៃវារៈដែលវិសជ្ជនាបានប៉ុណ្ណោះ ។ ក៏ព្រោះព្រះបាលីថា **“ឆ បច្ចនីយម្ហិ នយា សុគម្ភីរា”** គប្បីលើកបដ្ឋានន័យទាំង ៦ នេះ ឡើងសម្ដែងក្នុងបច្ចយប្បច្ចនីយៈនោះ ដោយអំណាចនៃបុច្ឆា; ព្រោះថា

នោះជាភារៈនៃអាចារ្យអ្នកអធិប្បាយបដ្ឋាន ។

---

## ៣.ពណ៌នាអំពីអនុលោមបច្ចនីយន័យ

ឥឡូវនេះ ដើម្បីនឹងសម្ដែងអនុលោមបច្ចនីយប្បដ្ឋាន ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **"កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើងព្រោះហេតុប្បច្ច័យ នអារម្មណប្បច្ច័យឬ ?"** ក្នុងអនុលោមបច្ចនីយ-ប្បដ្ឋាននោះ ក្នុងមូលដែលមានមូលមួយ មានហេតុបទជាដើម មានអនុ-លោមបច្ចនីយប្បដ្ឋាន ២៣ ដោយអំណាចនៃការភ្ជាប់ហេតុបទ ជាមួយបច្ច័យមួយៗ ក្នុងបណ្ដាបច្ច័យ ២៣ ដែលនៅសល់ថា **"ហេតុប្បច្ចយា នអារម្មណប្បច្ចយា ។ ល ។ ហេតុប្បច្ចយា នោអវិគតប្បច្ចយា"** ក្នុងអនុលោមបច្ចនីយប្បដ្ឋាននោះ មានបុច្ឆា ១.១២៧ វារៈ ព្រោះមួយបទៗចែកចេញបានបុច្ឆា ៤៩ វារៈ ។ ចំណែកក្នុងទុមូលកន័យ អ្នកសិក្សាគប្បីជ្រាបការគណនាបុច្ឆា ដោយអំណាចនៃបទដែលនៅសល់ ដោយបន្ថយបទមួយៗ ក្នុងឯកមូលកន័យទាំងអស់ជាដើម ដែលពោលទុកក្នុងអនុលោមយ៉ាងនេះថា "អនុលោមបច្ចនីយប្បដ្ឋាន មាន ២២ ដោយអំណាចនៃការភ្ជាប់ហេតារម្មណបទ ជាមួយបច្ច័យមួយៗ ក្នុងបច្ច័យទាំង ២២

*ដែលនៅសល់"* ។

*ម្យ៉ាងទៀត ក្នុងឯកមូលកន័យជាដើម ក្នុងអធិការនេះ បុច្ឆាណា មានមកហើយ និងមិនបានមកហើយក្នុងព្រះបាលី យ៉ាងណា, បុច្ឆាទាំងអស់នោះ អ្នកសិក្សាគប្បីជ្រាបតាមគន្លងផ្លូវរបស់ន័យ ដែលខ្ញុំពោលហើយអំពីខាងដើម ។*

*ក្នុងពាក្យថា* **"តិកញ្ច បដ្ឋានវរំ ។ល។ ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា"** *នេះ មានអនុលោមបច្ចនីយប្បដ្ឋាន ២ យ៉ាង គឺធម្មានុលោមបច្ចនីយៈ និងបច្ចយានុលោមបច្ចនីយៈ តាមន័យដែលពោលហើយអំពីខាងដើមនោះឯង ។ ក្នុង ២ យ៉ាងនោះ បដ្ឋានដែលព្រះអង្គទ្រង់ឲ្យប្រព្រឹត្តទៅដោយអំណាចនៃការសម្តែងធម៌ ដែលសង្គ្រោះទុកដោយបទអភិធម្មមាតិកាយ៉ាងនេះថា* **" កុសលា ធម្មា"** *ដោយអនុលោមបច្ចនីយន័យថា* **"កុសលំ ធម្មំ បដិច្ច ន កុសលា ធម្មា"** *ឈ្មោះថា* ***ធម្មានុលោមបច្ចនីយប្បដ្ឋាន*** *។ បដ្ឋានដែលព្រះពុទ្ធអង្គទ្រង់ឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការសម្តែងបទដែលបានក្នុងបច្ច័យ ២៤ យ៉ាងថា* **" ហេតុប្បច្ចយា នអារម្មណប្បច្ចយា"** *នេះ* ***ដោយអនុលោមបច្ចនីយន័យ*** *ឈ្មោះថា បច្ចយានុលោមបច្ចនីយប្បដ្ឋាន ។ ក្នុង ២ យ៉ាងនោះ គាថាដែលថា* **"តិកញ្ច បដ្ឋានវរំ ។ល។ ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា"**

នេះ ក្នុងអដ្ឋកថាខាងដើម លោកពោលសំដៅដល់ធម្មានុលោមបច្ចនីយ-ប្បដ្ឋាន, ក្នុងធម្មានុលោមប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ក្នុងគាថានៃអដ្ឋកថាដែលថា “ **ឆអនុលោមបច្ចនីយម្ហិ នយា សុគម្ភីរា** ” គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្មានុលោមបច្ចនីយ-ន័យ ដ៏ជ្រាលជ្រៅក្រៃលែង ។

ចំណែកក្នុងបច្ចយានុលោមបច្ចនីយប្បដ្ឋាន ដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅហើយយ៉ាងនេះថា “ **ហេតុប្បច្ចយា នអារម្មណប្បច្ចយា** ” ក្នុងឱកាសនេះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានទាំងនេះជាដើម ចំពោះក្នុងធម្មានុលោមប៉ុណ្ណោះ ដ៏ជ្រាលជ្រៅក្រៃលែង ។ បណ្ដាន័យទាំង ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះអង្គទ្រង់សម្ដែងដោយសង្ខេបទុកក្នុងបណ្ណត្តិវារៈនៃបដិច្ចវារៈនេះ ដោយអំណាចនៃធម៌ត្រឹមតែកុសលត្តិកៈ ចំពោះក្នុងអនុលោមតិកប្បដ្ឋានប៉ុណ្ណោះ, ចំណែកក្នុងតិកៈ និងទុកៈដែលសល់ និងបដ្ឋានដែលសល់ មិនបានសម្ដែងបុច្ឆាទុកសូម្បីត្រឹមតែមួយបុច្ឆាវារៈឡើយ ។

ក្នុងសហជាតវារៈជាដើម តអំពីនោះ ទ្រង់មិនលើកបុច្ឆាឡើងដោយអំណាចនៃកុសលត្តិកៈទេ, ទ្រង់សម្ដែងចំពោះតែវិសជ្ជនា ដោយអំណាចនៃវារៈដែលវិសជ្ជនាបាន ។ ព្រោះព្រះបាលីថា “**ឆ អនុលោមបច្ចនីយម្ហិ**

**នយា សុគន្ធិកា”** *គប្បីលើកបដ្ឋានន័យទាំង ៦ នេះឡើងសម្ដែងដោយអំណាចនៃបុច្ឆា ក្នុងបច្ចយានុលោមបច្ចនីយបដ្ឋាននេះ; ព្រោះថា នោះជាភារៈនៃអាចារ្យអ្នកអធិប្បាយបដ្ឋាន ។*

---

## ៤.៣ពណ៌នាអំពីបច្ចនីយានុលោមន័យ

*ឥឡូវនេះ ដើម្បីនឹងសម្ដែងបច្ចនីយានុលោមបដ្ឋាន ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យមានជាអាទិ៍ថា* ***“កុសលធម៌ គប្បីអាស្រ័យកុសលធម៌កើតឡើង ព្រោះនហេតុប្បច្ច័យ អារម្មណប្បច្ច័យឬ ?”*** *; ក្នុងបច្ចនីយានុលោមបដ្ឋាននោះ មានកំណត់បុច្ឆាស្មើនឹងអនុលោមបច្ចនីយបដ្ឋាន ។ ក៏ក្នុងន័យដែលមានមូលមួយជាដើម ក្នុងអធិការនេះ បុច្ឆាណាដែលមានមកហើយ និងដែលមិនទាន់មានមកក្នុងព្រះបាលី យ៉ាងណា, បុច្ឆាទាំងអស់នោះ អ្នកសិក្សាគប្បីជ្រាបតាមគន្លងផ្លូវរបស់ន័យទាំងឡាយ ដែលខ្ញុំពោលហើយអំពីខាងដើម ។ សូម្បីក្នុងពាក្យថា* **“តិកញ្ច បដ្ឋានវរំ ។ល។ ឆបច្ចនីយានុលោមម្ហិ នយា សុគន្ធិកា”** *នេះ អ្នកសិក្សាគប្បីជ្រាបបច្ចនីយានុលោម ២ យ៉ាង* ***គឺធម្មបច្ចនីយានុលោម និងបច្ចយបច្ចនីយានុលោម*** *តាមន័យដែលខ្ញុំពោលហើយអំពីខាងដើម; ក្នុង ២ យ៉ាងនេះ បដ្ឋានដែលព្រះអង្គឲ្យប្រព្រឹត្តទៅដោយអំណាចនៃការសម្ដែងធម៌ ដែលសង្គ្រោះ*

*ដោយបទអភិធម្មមាតិកាយ៉ាងនេះថា* **“កុសលា ធម្មា”** *ដោយបច្ចយានុលោមថា* **“ន កុសលំ ធម្មំ បដិច្ច កុសលោ ធម្មោ”** *ឈ្មោះថា ធម្មបច្ចនីយានុលោមប្បដ្ឋាន; បដ្ឋានដែលឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការសម្ដែងបទដែលបាននៅក្នុងបច្ច័យ ២៤ យ៉ាងនេះថា* **“ នហេតុប្បច្ចយា អារម្មណប្បច្ចយា”** *ដោយបច្ចយបច្ចនីយានុលោម ឈ្មោះថា បច្ចយ-បច្ចនីយានុលោមប្បដ្ឋាន ។ ក្នុង ២ យ៉ាងនោះ គាថាដែលថា* **“តិកញ្ច បដ្ឋានវរំ ។ល ។ ឆបច្ចនីយានុលោមម្ហិ នយា សុគម្ភីរា”** *នេះ ក្នុងអដ្ឋកថាអំពីខាងដើម លោកពោលសំដៅដល់ធម្មបច្ចនីយានុលោមប្បដ្ឋាន ។ ប៉ុន្តែក្នុងអធិការនេះ គាថានេះ លោកពោលសំដៅដល់បច្ចយបច្ចនីយានុលោម-ប្បដ្ឋាន ចំពោះតែក្នុងធម្មានុលោមប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ ក្នុងគាថានៃអដ្ឋកថាដែលថា* **“ឆបច្ចនីយានុលោមម្ហិ នយា សុគម្ភីរា”** *អ្នកសិក្សាគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើម ក្នុងធម្ម-បច្ចនីយានុលោមដ៏ជ្រាលជ្រៅក្រៃលែង ។ ចំណែកក្នុងបច្ចយបច្ចនីយា-នុលោម ដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅហើយ យ៉ាងនេះថា* **“នហេតុ-ប្បច្ចយា អារម្មណប្បច្ចយា”** *ក្នុងឱកាសនេះ អ្នកសិក្សា គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ន័យ ៦ មានតិកប្បដ្ឋានជាដើមនេះ ចំពោះក្នុងធម្មានុលោម*

*នោះ ដ៏ជ្រាលជ្រៅក្រៃលែង ។ បណ្ដាន័យទាំង ៦ នោះ ប្រភេទនៃបុច្ឆានេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដោយសង្ខេបទុកក្នុងបណ្ណត្តិវារៈនៃបដិច្ចវារៈនេះ ដោយអំណាចនៃធម៌ត្រឹមតែកុសលត្តិកៈ ក្នុងអនុលោមប្បដ្ឋានប៉ុណ្ណោះ ។*

*ប៉ុន្តែ ក្នុងតិកៈ និងទុកៈដែលនៅសល់ និងក្នុងបដ្ឋានដែលនៅសល់ ទ្រង់មិនបានសម្ដែងបុច្ឆាទុក សូម្បីត្រឹមតែបុច្ឆាវារៈមួយឡើយ ។ ក្នុង* ***សហជាតវារៈ*** *ជាដើម តអំពីនោះ ទ្រង់មិនលើកបុច្ឆាឡើង ដោយអំណាចនៃកុសលត្តិកៈទៀតទេ ទ្រង់សម្ដែងចំពោះវិសជ្ជនា ដោយអំណាចនៃវារៈដែលវិសជ្ជនាបាន ព្រោះព្រះបាលីថា* **“ ឆ បច្ចយានុលោមម្ហិ នយា សុគម្ភីរា ”** *គប្បីលើកបដ្ឋានន័យទាំង ៦ នេះ ឡើងសម្ដែងដោយអំណាចនៃបុច្ឆាក្នុងបច្ចយបច្ចនីយានុលោមប្បដ្ឋាននេះ; ព្រោះថា នុ៎ះជាភារៈរបស់អាចារ្យអ្នកអធិប្បាយបដ្ឋាន ៕*

## ចប់បណ្ណត្តិវារៈ

# ១.កុសលត្តិកៈ

## ១.ពណ៌នាអំពីសេចក្តីនៃបដិច្ចវារៈ

## ១.ពណ៌នាអំពីបច្ចយានុលោមន័យ

### ១.វិភង្គវារៈ

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីនឹងលះបោលបញ្ហាដែលវិសជ្ជនាមិនបានយ៉ាងនេះថា ***“អកុសលធម៌ អាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យ (មិនបាន)”*** ព្រោះកុសលធម៌ និងអកុសលធម៌ជាដើម កើតព្រមគ្នាមិនបាន ហើយដោះស្រាយចំពោះបញ្ហាដែលវិសជ្ជនាបាន ក្នុងបញ្ហាទាំងឡាយដែលព្រះមានព្រះភាគទ្រង់អាស្រ័យកុសលត្តិកៈ ក្នុងបណ្ណត្តិវារៈកាលទ្រង់សម្ដែងត្រឹមតែន័យ ទ្រង់បានសម្ដែងទុករកប្រមាណមិនបាន ផ្ដើមតាំងពីបញ្ហានៃបុច្ឆា ៤៩ វារៈ ដោយអំណាចនៃ ***ហេតុប្បច្ច័យ*** ជាដើម ទើបទ្រង់ផ្ដើមនិទ្ទេសវារៈនៃបដិច្ចវារៈ ដោយន័យមានជាអាទិ៍ថា ***“កុសលធម៌ អាស្រ័យកុសលធម៌កើតឡើង ព្រោះហេតុប្បច្ច័យ”*** ។

ក្នុងបុច្ឆាវារៈនោះ គប្បីមានពាក្យសួរថា បញ្ហា ៤៩ បុច្ឆា ប្រសិនបើហេតុប្បច្ច័យជាដើមនេះ រមែងវិសជ្ជនាមិនបានទាំងអស់ហើយ តើព្រះមានព្រះភាគទ្រង់សម្ដែងទុកធ្វើអ្វី ? ព្រះអង្គគួរសម្ដែងចំពោះបញ្ហាដែលវិសជ្ជនាបានប៉ុណ្ណោះ មិនមែនឬ ? ឆ្លើយថា មិនគួរសម្ដែងយ៉ាងនោះទេ, ប៉ុន្តែ កាលបើសម្ដែងយ៉ាងនោះ ក៏មិនចាំបាច់សម្ដែងឲ្យប្រញាប់ប្រញាល

ក្នុងតិកៈ ទុកៈ តិកទុកៈ តិកត្តិកៈ និងទុកទុកៈនីមួយៗ ក្នុងបដ្ឋានទាំងអស់ មានតិកទុកបដ្ឋានជាដើមឡើយ ។ ព្រោះហេតុអ្វី ? ព្រោះបញ្ហាដែលមាននៅក្នុងកុសលត្តិកៈ មិនមានក្នុងវេទនាតិកៈជាដើមទេ; ម្យ៉ាងទៀត ពេលវិសជ្ជនា វិតក្កត្តិកៈ និងបីតិត្តិកៈ ក្នុងតិកបដ្ឋានដែលពោលដោយធម្មានុលោមបច្ចនីយៈ បញ្ហាទាំងនេះ រមែងបានទទួលវិសជ្ជនាទាំងអស់ផង ព្រោះហេតុដូច្នោះ ដោយការកំណត់យ៉ាងល្អិតល្អន់ បញ្ហាដែលមាននៅក្នុងតិកៈនីមួយៗ ទាំងអស់ ព្រះអង្គទ្រង់សម្ដែងទុកហើយ ក្នុងកុសលត្តិកៈ ។ ពិតមែនហើយ កាលព្រះអង្គទ្រង់សម្ដែងបញ្ហាទុកយ៉ាងនេះ បញ្ហាដែលវិសជ្ជនាបាន ព្រះអង្គទ្រង់លះចោលបញ្ហាដែលដោះស្រាយមិនបាន ក្នុងកុសលត្តិកៈនោះ ហើយទ្រង់សម្ដែងទុក, កុលបុត្រ ក៏នឹងយល់បានងាយឡើង ។ ព្រោះហេតុដូច្នោះ ដើម្បីនឹងញុំាងកុលបុត្រឲ្យយល់បានងាយឡើង ទើបព្រះអង្គទ្រង់សម្ដែងបញ្ហាទាំងអស់ (រួមត្រូវជា ៤៩ បុច្ឆាវារៈ) ទុកក្នុងកុសលត្តិកៈ ។ បណ្ឌិតគប្បីជ្រាបថា បញ្ហាណាដែលមិនបានវិសជ្ជនាទុកក្នុងកុសលត្តិកៈនេះទេ, ព្រះមានព្រះភាគទ្រង់លះចោលបញ្ហានោះ, ហើយទ្រង់វិសជ្ជនា ចំពោះតែបញ្ហាដែលដោះស្រាយបានប៉ុណ្ណោះ ។

គប្បីជ្រាបសេចក្ដីក្នុងពាក្យទាំងនេះ ដូចតទៅ ៖

ពាក្យថា **“កុសលំ ធម្មំ បដិច្ច”** សេចក្ដីថា អាស្រ័យ គឺពឹងពាក់

នូវធម៌តែមួយដែលផ្សេងគ្នាដោយខន្ធ មានវេទនាខន្ធជាដើម ក្នុងកុសល-ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ គឺដល់ដោយសេចក្ដីប្រព្រឹត្តទៅដូចគ្នា អធិប្បាយថា ចូលដល់ការកើតឡើងរួមជាមួយនឹងធម៌នោះ ។

ពីរបទថា **“កុសលោ ធម្មោ”** គឺធម៌តែមួយដែលផ្សេងគ្នាដោយខន្ធ មានសញ្ញាខន្ធជាដើម ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដូចៗ គ្នា ។

បទថា **“ឧប្បជ្ជតិ”** សេចក្ដីថា ដល់ខាងដើមតាំងអំពីឧប្បាទក្ខណៈ រហូតដល់និរោធក្ខណៈ, គឺរមែងកើត ។ អធិប្បាយថា រមែងបាននូវការតជាប់គ្នា គឺចូលដល់ខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើម ។ បទថា **“ហេតុប្បច្ចយា”** គឺព្រោះកុសលហេតុដែលឲ្យសម្រេចសេចក្ដីជាហេតុ-ប្បច្ច័យ ។ ព្រះមានព្រះភាគទ្រង់វិសជ្ជនាថា **“ឧប្បជ្ជតិ** = រមែងកើតឡើង” ក្នុងបុច្ឆាថា “គប្បីកើតឡើង” ដូចពណ៌នាមកហើយ; ឥឡូវនេះ ដើម្បីសម្ដែងនូវធម៌ជាទីអាស្រ័យ (បច្ច័យ) ***និងធម៌ដែលចូលទៅអាស្រ័យកើតឡើង*** (បច្ចយុប្បន្ន) ដោយអំណាចនៃខន្ធ ទើបត្រាស់ពាក្យថា **“កុសលំ ឯកំ ខន្ធំ”** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **“ឯកំ”** គឺខន្ធណាមួយ ក្នុងបណ្ដាខន្ធ ៤ មានវេទនាខន្ធជាដើម ។ ពីរបទថា **“តយោ ខន្ធា”** គឺខន្ធ ៣ ដែលនៅសល់

វៀរខន្ធដែលលោកចាត់ជាបច្ច័យចេញ ។ ពាក្យថា **"តយោ ខន្ធេ"** គឺនូវខន្ធ ៣ ដែលនៅសល់ក្នុងបណ្ដាខន្ធទាំងឡាយ មានវេទនាខន្ធជាដើម វៀរខន្ធ ១ ដែលលោកចាត់ថា កំពុងកើត (ព្រោះហេតុប្បច្ច័យ) ចេញ ។ ពាក្យថា **"ទ្វេ ខន្ធេ"** សេចក្ដីថា អាស្រ័យខន្ធ ២ ខន្ធណាមួយ ក្នុងទុកៈ ៦ មានវេទនាទុកៈ និងសញ្ញាទុកៈជាដើម ។ ពីរបទថា **"ទ្វេ ខន្ធា"** សេចក្ដីថា ខន្ធ ២ ដែលនៅសល់ វៀរខន្ធដែលលោកចាត់ថា ជាបច្ច័យចេញ រមែងកើតឡើង ព្រោះកុសលហេតុ ដែលឲ្យសម្រេចសេចក្ដីជាហេតុ-ប្បច្ច័យ ។ ព្រោះខន្ធ ១ នឹងជាបច្ច័យដល់ខន្ធ ១ ឬខន្ធ ២ មិនបាន ឬថាខន្ធ ២ នឹងជាបច្ច័យដល់ខន្ធ ១ ក៏មិនបានដូចគ្នា, ព្រោះហេតុដូច្នោះ ទើបព្រះអង្គមិនទ្រង់ត្រាស់ថា **"ឯកំ ខន្ធំ បដិច្ច ឯកោ ខន្ធោ, ឯកំ ខន្ធំ បដិច្ច ទ្វេ ខន្ធា, ទ្វេ ខន្ធេ បដិច្ច ឯកោ ខន្ធោ"** ជាដើម ។ ក្នុងពាក្យមានជាអាទិ៍ថា ***"អព្យាកតធម៌ អាស្រ័យកុសលធម៌កើតឡើង"*** បណ្ឌិតគប្បីជ្រាបសេចក្ដីតាមន័យដែលពោលហើយនោះឯង ។

ពាក្យថា **"ចិត្តសមុដ្ឋានំ រូបំ"** នេះ លោកពោលទុកដើម្បីសម្ដែងនូវរូបដែលបានសហជាតប្បច្ច័យ និងហេតុប្បច្ច័យជាមួយកុសល ព្រោះអត្ថនៃពាក្យថា **បដិច្ច** មានសេចក្ដីសម្គាល់ថា សហជាត (ព្រោះពាក្យថា អាស្រ័យ មានអត្ថថា កើតរួម), សូម្បីក្នុងកន្លែងតអំពីនេះ ក្នុងឋានដូច្នេះ

គប្បីជ្រាបន័យនេះចុះ ។ ក្នុងពាក្យថា **“ វិបាកាព្យាកតំ កិរិយាព្យាកតំ ”** នេះ នឹងយកអហេតុកចិត្តចូលមករួមផងមិនបាន ព្រោះមិនមានហេតុ-ប្បច្ច័យ និងមិនសំដៅដល់អរូបវិបាកផងទេ ព្រោះមិនកើតរួមជាមួយរូប ។

បទថា **“បដិសន្ធិក្ខណេ”** លោកពោលទុកដើម្បីសម្ដែងថា អព្យាកត-ធម៌ គឺកម្មជរូប អាស្រ័យអព្យាកតធម៌កើតឡើង ។ បទថា **“ វិបាកា-ព្យាកតំ”** លោកពោលដោយអំណាចនៃ ***អព្យាកតធម៌*** ដែលមាននៅក្នុងខណៈនោះ ។ ពាក្យថា **“ ខន្ធេ បដិច្ច វត្ថុំ”** នេះ លោកពោលទុកដើម្បីសម្ដែងថា សូម្បីកាលវត្ថុរូប (ហទយវត្ថុ) ដែលលោកកាន់យកដោយសព្ទថា ***កដត្តារូប*** ក៏នៅតែអាស្រ័យខន្ធទាំងឡាយហើយកើតឡើង ។ ពាក្យថា **“ វត្ថុំ បដិច្ច ខន្ធា”** លោកពោលទុកដើម្បីសម្ដែងថា ខន្ធទាំងឡាយ អាស្រ័យវត្ថុហើយកើតឡើង ។ ពាក្យថា **“ ឯកំ មហាភូតំ”** ជាដើម លោកពោលទុកដើម្បីសម្ដែងថា អព្យាកតធម៌ គឺរូបអាស្រ័យអព្យាកតធម៌ ។ ចំណែករូបកើត ក្នុងពាក្យទាំងនេះ បណ្ឌិតគប្បីជ្រាបអត្ថយោជនា (ការអធិប្បាយសេចក្ដី) តាមន័យដែលពោលទុកហើយក្នុងពាក្យថា **“ឯកំ ខន្ធំ”** ជាដើម ។

ក្នុងអព្យាកតធម៌ចំណែកខាងរូប ព្រះមានព្រះភាគទ្រង់ត្រាស់ដល់

មហាភូតរូបអាស្រ័យមហាភូតរូបកើតយ៉ាងនេះហើយ; ឥឡូវនេះ ដើម្បីសម្តែងដល់ឧបាទាយរូប អាស្រ័យមហាភូតរូប ហើយកើត ទើបត្រាស់ពាក្យថា "**មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ**" ជាដើម; មានពាក្យសួរថា កាលបើដូច្នេះ ក៏គួរនឹងហៅយ៉ាងនេះថា ឧបាទាយរូប, ប៉ុន្តែ ហៅ ២ យ៉ាងឲ្យផ្សេងគ្នាធ្វើអ្វី ? ដោះស្រាយថា ដើម្បីសម្តែងដល់រូបអាស្រ័យមហាភូតរូប ហើយកើត; ពាក្យថា "**មហាភូតំ ឧបាទាយរូបំ**" នេះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់ទុកដើម្បីសម្តែងថា រូបណាដែលសម្តែងទុកអំពីខាងដើមថា កើតអំពីចិត្ត និងកើតអំពីកម្ម, រូបនោះ មិនបានអាស្រ័យខន្ធទាំងឡាយ ហើយកើតតែម្យ៉ាងទេ, លុះត្រាតែអាស្រ័យមហាភូតរូបហើយទើបកើតបាន ។ បណ្តារូបទាំង ២ នោះ រូបដែលមានចិត្តជាសមុដ្ឋាន រមែងកើតក្នុងបវត្តិកាលប៉ុណ្ណោះ រូបកើតអំពីកម្មរមែងកើតសូម្បីក្នុងបដិសន្ធិកាលដែរ ។ បទថា "**ឧបាទាយរូបំ**" ជាវិសេសនៈរបស់ ២ បទនុ៎ះឯង ។ ក្នុងពាក្យថា "**កុសលេ ខន្ធេ ច មហាភូតេ ច បដិច្ច** = អាស្រ័យកុសលក្ខន្ធ និងមហាភូតរូប" នេះ សំដៅយកមហាភូតរូបដែលមានចិត្តជាសមុដ្ឋានប៉ុណ្ណោះ ។ ចំណែកក្នុងពាក្យថា "**ចិត្តសមុដ្ឋានំ រូបំ**" នេះ ***សំដៅយកមហាភូតរូប និងឧបាទាយរូប***; ពិតមែនហើយ សូម្បីមហាភូតរូប ក៏អាស្រ័យខន្ធទាំងឡាយ និងមហាភូតរូបខ្លួនឯងហើយកើត

ដោយន័យជាដើមថា **“ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា”** ; សូម្បីឧបាទាយរូប ក៏អាស្រ័យខន្ធ និងមហាភូតរូបហើយកើត ដោយន័យដែលលោកពោលទុកថា **“មហាភូតេ បដិច្ច ឧបាទារូបំ”** ។ សូម្បីក្នុងការវិសជ្ជនាបញ្ហាថា **“អកុសលញ្ច អព្យាកតញ្ច”** ក៏មានន័យដូចគ្នានេះដែរ ។ បុច្ឆា ៩ វារៈ ក្នុងហេតុប្បច្ច័យ ត្រូវបានទទួលវិសជ្ជនាហើយ ដោយប្រការដូច្នេះ ។ ពិតមែនហើយ បញ្ហាទាំងនេះប៉ុណ្ណោះ ដែលអាចបានក្នុងហេតុប្បច្ច័យនេះ បញ្ហាដែលនៅសល់ ៤០ បុច្ឆាវារៈទៀត ជាមោឃបញ្ហា, ព្រោះហេតុនោះ ទើបមិនបានទទួលវិសជ្ជនា ។ បណ្ឌិតគប្បីជ្រាបអត្ថនៃបុច្ឆា និងវិសជ្ជនា សូម្បីក្នុងអារម្មណប្បច្ច័យជាដើម តាមន័យនេះចុះ ។ ចំណែកពាក្យដែលគួរនឹងវិនិច្ឆ័យទុក ក្នុងបច្ច័យនោះៗ ខ្ញុំនឹងវិនិច្ឆ័យតទៅ ៖

គប្បីជ្រាបនូវវិនិច្ឆ័យក្នុងអារម្មណប្បច្ច័យជាមុន, បណ្ដាបុច្ឆា ៩ វារៈ លោកវិសជ្ជនាទុក ៣ បុច្ឆាវារៈប៉ុណ្ណោះ ដោយលះបុច្ឆាដែលជាប់ទាក់ទិនជាមួយនឹងរូបចេញ ព្រោះរូបមិនកើតដោយអំណាចនៃអារម្មណប្បច្ច័យទេ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ***“ខន្ធទាំងឡាយអាស្រ័យវត្ថុ”*** មិនត្រាស់ថា ***“វត្ថុអាស្រ័យខន្ធទាំងឡាយ”*** ទេ; ***ព្រោះថា វត្ថុរូបនោះ មិនកើតឡើង ព្រោះអារម្មណប្បច្ច័យឡើយ*** ។

ក្នុងអធិបតិប្បច្ច័យ ពាក្យថា **“វិបាកាព្យាកតំ”** នេះ ព្រះអង្គទ្រង់

ត្រាស់សំដៅយកចំពោះ ***លោកុត្តរវិបាក*** ប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ ក្នុងបច្ច័យនេះ ទើបលោកមិនបំណាងយកថា **"*ក្នុងបដិសន្ធិខណៈ*"** ដូច្នេះទេ ។ ពាក្យដែលនៅសល់ ដូចនឹងហេតុប្បច្ច័យដែរ ។

សូម្បីក្នុង ***អនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ*** រូបក៏មិនបានមានដូច្នេះ ទើបមានបុច្ឆា ៣ វារៈ ដូចក្នុងអារម្មណប្បច្ច័យដែរ ។

ក្នុង ***សហជាតប្បច្ច័យ*** ពាក្យថា **"បដិសន្ធិក្ខណេ"** ព្រះអង្គត្រាស់ដោយអំណាចនៃបដិសន្ធិក្នុងបញ្ចវោការភព, ចំណែកក្នុងបច្ចយវិភង្គអំពីខាងដើម មានមកហើយថា **"ឱក្កន្តិក្ខណេ"** ។ សូម្បីពាក្យនោះ និងពាក្យនេះ ពោលដោយសេចក្តីហើយ ត្រូវដូចគ្នា, ពិតមែនហើយ ពាក្យពីរនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពាក្យថា **"ឱក្កន្តិ"** នេះជាឈ្មោះនៃបញ្ចវោការបដិសន្ធិ ដោយព្រះបាលីថា "ព្រោះការប្រជុំព្រមនៃអង្គ ៣ សត្វរមែងចុះកាន់គភ៌" [១] ។ ពាក្យថា **"បដិសន្ធិ"** ប្រើទូទៅដល់ភពទាំងពួង ។ ប៉ុន្តែក្នុងទីនេះ ប្រាថ្នាយកចំពោះបញ្ចវោការបដិសន្ធិប៉ុណ្ណោះ ព្រោះព្រះបាលីថា **"កដត្តា ច រូបំ"** ជាដើម ។ ពិតមែនហើយ ពាក្យថា **"បដិសន្ធិ"** នោះ រមែងប្រមូលមកនូវសេចក្តីជាបច្ច័យរបស់

---

[១] ម. មូ. ។

*បច្ចុប្បន្ននៃរូប និងអរូបចូលជាមួយគ្នា ។ ព្រោះហេតុដូច្នោះ ការវិសជ្ជនាដែលបរិបូណ៌ ទើបលោកកាន់យកថា មាន, ពាក្យថា* **“ ពាហិរំ ឯកំ មហាភូតំ”** *លោកពោលសំដៅយកមហាភូតរូបក្នុងទីទាំងឡាយ មានដី និងថ្មជាដើម ដែលមិនជាប់ដោយឥន្ទ្រិយ ។ ពិតមែនហើយ ក្នុងបច្ចយ-វិភង្គវារៈ លោកកាន់យករួមគ្នា ទាំងខាងក្នុង ទាំងខាងក្រៅថា* **“ ចត្តារោ មហាភូតា”** *។ ព្រោះពាក្យនោះ ជាការសម្តែងដោយសង្ខេប ។ ប៉ុន្តែនេះជាការសម្តែងដោយពិស្តារ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលនឹងសម្តែងបែកឲ្យអស់ ទើបទ្រង់ត្រាស់ថា* **“ពាហិរំ ឯកំ មហាភូតំ”** *ជាដើម ។ ពាក្យថា* **“ អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច”** *ព្រះអង្គត្រាស់ដោយអំណាចនៃមហាភូតរូបដែលមានសន្តតិ និងសមុដ្ឋាន ២ ។ ចំណែកពាក្យថា* **“មហាភូតេ បដិច្ច កដត្តារូបំ”** *នេះ លោកពោលដោយអំណាចនៃរូប មានកម្មជាសមុដ្ឋាន ។ ពាក្យថា* **“ ឧបាទារូបំ”** *នេះ លោកពោលដោយអំណាចនៃរូបមានឧតុជាសមុដ្ឋាន ។*

*ក្នុង* ***អញ្ញមញ្ញប្បច្ច័យ*** *លោកពោលថា* **“ខន្ធេ បដិច្ច វត្ថុ, វត្ថុំ បដិច្ច ខន្ធា** *= វត្ថុអាស្រ័យខន្ធ ខន្ធអាស្រ័យវត្ថុ” ដូច្នេះ ក៏ដើម្បីសម្តែងថា សូម្បី (នាម) ខន្ធទាំង ៤ ជាអញ្ញមញ្ញប្បច្ច័យ ដោយវត្ថុ មានចំណែក*

តែមួយ ។

ក្នុង ***និស្សយប្បច្ច័យ*** ដែលជាអត្ថនៃពាក្យថា **“ បដិច្ច ”** សេចក្ដីដូចគ្នានឹងសហជាតដែរ, ព្រោះហេតុដូច្នោះ ភាវៈនៃចក្ខាយតនៈជាដើមជានិស្សយប្បច្ច័យ ដែលលោកសម្ដែងទុកហើយក្នុងបច្ចយវិភង្គវារៈអំពីខាងដើម ទើបព្រះមានព្រះភាគទ្រង់មិនកាន់យកទេ ។ ពិតមែនហើយចក្ខាយតនៈជាដើម ជាបុរេជាតប្បច្ច័យ, ប៉ុន្តែក្នុងទីនេះ បានចំពោះតែសហជាតប្បច្ច័យប៉ុណ្ណោះ ព្រោះហេតុនោះឯង ទើបលោកពោលទុកថា និស្សយប្បច្ច័យ ដូចគ្នានឹងសហជាតប្បច្ច័យដែរ ។

ក្នុងឧបនិស្សយប្បច្ច័យ រមែងបានវិសជ្ជនា ៣ វារៈប៉ុណ្ណោះ ព្រោះភាវៈនៃរូបជាឧបនិស្សយប្បច្ច័យមិនបាន ។ ព្រោះហេតុនោះ ទើបលោកពោលថា “ដូចគ្នានឹងអារម្មណប្បច្ច័យ” ។ ក្នុងឧបនិស្សយប្បច្ច័យនោះ កុសល អកុសល និងអព្យាកតធម៌ទាំងអស់ រមែងមិនបានអារម្មណូប-និស្សយប្បច្ច័យ ក៏ពិតមែន, ប៉ុន្តែពាក្យនោះ បណ្ឌិតគប្បីជ្រាបថា លោកពោលដោយអំណាចនៃធម៌ដែលបាន (អារម្មណូបនិស្ស័យ) ប៉ុណ្ណោះ ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង ***បុរេជាតប្បច្ច័យ*** ដូចតទៅ ៖

ពីរបទថា **“ វត្ថុំ បុរេជាតប្បច្ចយា ”** សេចក្ដីថា ធម៌ទាំងឡាយកើតឡើងព្រោះអាស្រ័យវត្ថុ គឺដោយវត្ថុដែលឲ្យសម្រេចជាបុរេជាតប្បច្ច័យ ។

*ក្នុងពាក្យថា* **" ទិបាកាព្យាកតំ ឯកំ ខន្ធំ "** *នេះ មានអធិប្បាយថា ក្នុងអធិការនេះ វត្ថុរូបណា ជាសហជាតប្បច្ច័យដល់អព្យាកតវិបាក បណ្ឌិតមិនគប្បីកាន់យកវត្ថុរូបនោះ ក្នុងបុរេជាតប្បច្ច័យនេះឡើយ ព្រោះនឹងត្រូវចែកដោយបុរេជាតប្បច្ច័យ ។ សូម្បីធម៌ទាំងឡាយ មានកុសលធម៌ជាដើម ដែលមិនបានបុរេជាតប្បច្ច័យក្នុងអរូបភព, ក៏មិនគួរកាន់យកក្នុងអធិការនេះទេ ព្រោះនឹងត្រូវចែកជាបុរេជាតប្បច្ច័យដូចគ្នា ។ ចំណែកអារម្មណ៍ រមែងមិនបានភាវៈជាបុរេជាតប្បច្ច័យដោយពិត ។ ព្រោះថា រូបាយតនៈជាដើម ឲ្យសម្រេចជាបុរេជាតប្បច្ច័យ ដល់ចក្ខុវិញ្ញាណជាដើមប៉ុណ្ណោះ ។ អារម្មណ៍ទាំងឡាយដែលជាអតីត និងអនាគត រមែងមានដល់មនោ-វិញ្ញាណធាតុប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ ទើបលោកមិនកាន់យកក្នុងទីនេះទេ ។ ព្រោះថា នេះជាការសម្ដែងដោយអំណាចនៃខន្ធ, មិនមែនដោយអំណាចនៃវិញ្ញាណធាតុឡើយ ។ម្យ៉ាងទៀត ព្រោះទេសនាថា* **" ទិបាកាព្យាកតំ ឯកំ ខន្ធំ "** *លោកសំដៅយកវិញ្ញាណធាតុទាំងអស់ មិនសំដៅយកចំពោះតែចក្ខុវិញ្ញាណធាតុជាដើមប៉ុណ្ណោះឡើយ ។*

***ធម៌ដែលកើតឡើងខាងក្រោយ រមែងមិនជាបច្ច័យដល់កុសល និងអកុសល, ត្រឹមតែឧបត្ថម្ភអព្យាកតធម៌ប៉ុណ្ណោះ, មិនមែនជាតួតាក់តែងឱ្យកើតទេ; ព្រោះហេតុនោះ សូម្បីធម៌តែម្យ៉ាង ដែលគួរនឹងពោលយ៉ាងនេះថា***

*កើតឡើង ព្រោះបច្ឆាជាតប្បច្ច័យ ទើបមិនមាន. ព្រោះហេតុដូច្នោះ ទើបលោកមិនបានវិសជ្ជនាទុក ដោយអំណាចនៃបច្ឆាជាតប្បច្ច័យឡើយ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុង ***អាសេវនប្បច្ច័យ*** ៖

កិរិយាចិត្ត រមែងមិនបានអាសេវនប្បច្ច័យទាំងអស់ ក៏ពិតមែន, ប៉ុន្តែ ក៏លោកពោលថា **“កិរិយាព្យាកតំ”** ដោយអំណាចនៃកិរិយាចិត្តដែលបាន (អាសេវនប្បច្ច័យ) ។ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ជវនកិរិយា គឺលោកកាន់យកហើយ ក្នុងអធិការនេះ ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង ***កម្មប្បច្ច័យ*** ៖

គប្បីជ្រាបថា ក្នុងកុសលចិត្ត អកុសលចិត្តមានកម្មប្បច្ច័យដែលកើតឡើងក្នុងខណៈជាមួយគ្នា, សូម្បីអព្យាកតកិរិយា ក៏មានន័យដូចគ្នានេះដែរ ។ ដោយឡែកក្នុងអព្យាកតៈ ចំណែកខាងវិបាក គប្បីជ្រាបថា ***កម្មប្បច្ច័យ*** ប្រព្រឹត្តទៅផ្សេងខណៈគ្នា ។ ម្យ៉ាងទៀត ក្នុងខណៈបដិសន្ធិនានក្ខណិកកម្មប្បច្ច័យ គប្បីជ្រាបថា មានដល់មហាភូតរូបដែរ ។ ចំណែករូបដែលមានចិត្តជាសមុដ្ឋាន មានឯកក្ខណិកកម្មប្បច្ច័យប៉ុណ្ណោះ ។ កម្មជរូបនិងរូប របស់អសញ្ញសត្តព្រហ្ម រមែងមាននានក្ខណិកកម្មប្បច្ច័យដូចគ្នា ។ ក៏កម្មជរូបក្នុងទីនេះ បានដល់ជីវិតិន្ទ្រិយ ។ រូបដែលនៅសល់ លោកហៅថា ឧបាទាយរូប (រូបជាទីអាស្រ័យ) ព្រោះមិនបានកើតអំពីកម្មតែម្យ៉ាងទេ ។

*កាលបើដូច្នោះ ក្នុងអធិការនេះ លោកប្រាថ្នាយកចំពោះតែកម្មជរូបប៉ុណ្ណោះ ។*

*កុសល អកុសល និងកិរិយា រមែងមិនបានក្នុង* ***វិបាកប្បច្ច័យ*** *ទេ, ព្រោះហេតុដូច្នោះ ទើបលោកតែងវិសជ្ជនា ដោយអំណាចនៃអព្យាកតៈប៉ុណ្ណោះ ។ បទថា* **“ ចិត្តសមុដ្ឋានំ ”** *សំដៅយករូបដែលមានវិបាកចិត្តជាសមុដ្ឋានប៉ុណ្ណោះ ។ បទថា* **“កដត្តារូបំ ”** *គឺឥន្ទ្រិយរូប និងវត្ថុរូបតាមសមគួរដល់ភូមិដែលនឹងមានបាន ។ បទថា* **“ឧបាទារូបំ ”** *គឺឧបាទាយរូបនៅសល់អំពីនោះ ដែលមានក្នុងសម័យនោះ ។*

*ក្នុង* ***អាហារប្បច្ច័យ*** *គប្បីជ្រាបការកើតឡើងនៃខន្ធទាំងឡាយ មានកុសលក្ខន្ធជាដើមទាំងអស់ នៃរូបដែលមានចិត្តជាសមុដ្ឋាននៃអរូប និងមហាភូតរូប ក្នុងខណៈបដិសន្ធិ (ក៏កើតឡើង) ដោយអំណាចនៃអាហារដែលជានាម ។ បទថា* **“ ចិត្តសមុដ្ឋានំ ”** *គឺមានភវង្គចិត្តជាដើម ជាសមុដ្ឋាន ។ បទថា* **“ អាហារសមុដ្ឋានំ ”** *គឺមានកវឡិង្ការាហារជាសមុដ្ឋាន ។ បទថា* **“ ចិត្តសមុដ្ឋានំ ”** *គឺមានកុសលចិត្ត និងអកុសលចិត្ត ជាសមុដ្ឋានប៉ុណ្ណោះ; ពោលដោយលំដាប់នៃអាហារ ក្នុងបច្ចយវិភង្គវារៈ លោកសម្ដែងកវឡិង្ការាហារ ទុកជាទី ១, ប៉ុន្តែក្នុងទីនេះ គប្បីជ្រាបថា លោកសម្ដែងអាហារដែលជានាមមុន ដោយអំណាចនៃបុច្ឆាថា* **“កុសលំ ធម្មំ”** *ជាដើម ។*

សូម្បីក្នុង ***ឥន្ទ្រិយប្បច្ច័យ*** ដោយការចាត់តាមលំដាប់នៃឥន្ទ្រិយ ក្នុងបច្ចយវិភង្គ លោកសម្តែងចក្ខុន្ទ្រិយ ជាលំដាប់ដំបូង, ចំណែកក្នុងអធិការនេះ លោកសម្តែងភាវៈនៃអរូបឥន្ទ្រិយជាបច្ច័យមុន ដោយការទាក់ទងនឹងពាក្យសួរដល់ធម៌ដែលជាកុសលជាដើម; បណ្តាអរូបឥន្ទ្រិយទាំងនោះ គួរកាន់យកអរូបឥន្ទ្រិយតាមដែលនឹងរកបាន ក្នុងធម៌ទាំងឡាយ មានកុសល-ធម៌ជាដើម ។ សូម្បីក្នុងភូតរូបទាំងឡាយ ដែលកើតហើយ ដល់អសញ្ញ-សត្តព្រហ្មទាំងឡាយ ក៏គួរកាន់យកចំពោះជីវិតិន្ទ្រិយដូច្នេះឯង ។

ក្នុងឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវិសជ្ជនាដូចគ្នានឹងហេតុ-ប្បច្ច័យដែរ, ព្រោះហេតុដូច្នោះ ទើបលោកពោលទុកក្នុងអធិការនេះថា "ដូចគ្នានឹងហេតុប្បច្ច័យដែរ" ។ វិសជ្ជនាក្នុងសម្បយុត្តប្បច្ច័យ មានគតិដូចអារម្មណប្បច្ច័យដែរ, ព្រោះហេតុដូច្នោះ ក្នុងទីនេះ ទើបលោកពោលថា "ដូចអារម្មណប្បច្ច័យដែរ" ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង ***វិប្បយុត្តប្បច្ច័យ*** ដូចតទៅ ៖

ពីរបទថា **"វត្ថុំ វិប្បយុត្តប្បច្ចយា"** សេចក្តីថា ធម៌ទាំងឡាយអាស្រ័យវត្ថុកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ, គឺព្រោះវត្ថុដែលឲ្យសម្រេចសេចក្តីជាវិប្បយុត្តប្បច្ច័យ ។ ពីរបទថា **"ខន្ធេ វិប្បយុត្តប្បច្ចយា"** សេចក្តីថា ធម៌ទាំងឡាយអាស្រ័យខន្ធទាំងឡាយកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ,

*គឺព្រោះខន្ធទាំងឡាយ ដែលឲ្យសម្រេចភាពជាវិប្បយុត្តប្បច្ច័យ ។ ពាក្យថា* **“ខន្ធា វត្ថុំ វិប្បយុត្តប្បច្ចយា”** *អធិប្បាយថា ខន្ធទាំងឡាយ អាស្រ័យវត្ថុកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ, គឺព្រោះវត្ថុដែលឲ្យសម្រេចភាពជាវិប្បយុត្តប្បច្ច័យ ។ ពាក្យថា* **“ចិត្តសមុដ្ឋានំ រូបំ ខន្ធេ វិប្បយុត្តប្បច្ចយា”** *សេចក្ដីថា រូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យខន្ធទាំងឡាយ កើតឡើងព្រោះ* ***វិប្បយុត្តប្បច្ច័យ****, ព្រោះខន្ធទាំងឡាយឲ្យសម្រេចភាព ជាវិប្បយុត្តប្បច្ច័យ; សូម្បីក្នុងវិសជ្ជនាដែលនៅសល់ បណ្ឌិតគប្បីជ្រាបសេចក្ដីតាមន័យដែលលោកពោលទុកក្នុងពាក្យថា* **“វត្ថុំ វិប្បយុត្តប្បច្ចយា”** *ជាដើម ។ ក៏ដោយសព្ទថា* ***វត្ថុ*** *ក្នុងវិបាកាព្យាកតៈនេះ បណ្ឌិតគួររួមយកចក្ខុជាដើមចូលផង ។ ពាក្យថា* **“ឯកំ មហាភូតំ”** *ជាដើម លោកពោលទុកដើម្បីសម្ដែងថា មហាភូតរូប ជាបច្ច័យដល់អព្យាកតធម៌ខាងរូប ។ បទថា* **“ចិត្តសមុដ្ឋានំ”** *សេចក្ដីថា រមែងបានរូប ដែលមានអព្យាកតចិត្តជាសមុដ្ឋាន និងរូបដែលមានកុសលចិត្ត និងអកុសលចិត្ត ជាសមុដ្ឋាន ។*

*ក្នុង* ***អត្ថិប្បច្ច័យ*** *ពាក្យអធិប្បាយទាំងអស់ ប្រព្រឹត្តទៅតាមដំណើរនៃសហជាតប្បច្ច័យនោះឯង; ព្រោះហេតុដូច្នោះ ក្នុងបច្ច័យនេះ លោកពោលថា “ដូចគ្នានឹងសហជាតប្បច្ច័យដែរ” ។*

***នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ*** មានគន្លងផ្លូវដូចគ្នានឹងអារម្មណប្បច្ច័យដែរ, ***អវិគតប្បច្ច័យ*** ក៏មានគតិដូចគ្នានឹងសហជាតប្បច្ច័យដែរ ។ ព្រោះហេតុនោះ ក្នុងបច្ច័យនោះ ទើបលោកពោលថា "ដូចសហជាតប្បច្ច័យដែរ" ។

ពាក្យថា **"ឥមេ តេវីសតិ បច្ចយា"** លោកពោលទុកដោយអំណាចនៃបច្ច័យដែលលោកសម្ដែងទុកដោយសង្ខេប ។ បទថា **"ទិត្ថារេតព្វា"** សេចក្ដីថា អ្នកសិក្សាគប្បីអធិប្បាយឲ្យពិស្ដារដោយអំណាចនៃបុច្ឆា ដែលវិសជ្ជនាបាន; នេះជាការពណ៌នាសេចក្ដីក្នុងការវិសជ្ជនាកុសលត្តិកៈ នៃបដិច្ចវារៈ ក្នុង ***បច្ចយានុលោម*** ដែលមានមូលមួយ ផ្ដើមតាំងអំពីហេតុប្បច្ច័យជាដើមមក ៕

---

# បដិច្ចវារៈ

## ២.ពណ៌នាអំពីបច្ចយានុលោមន័យ

### ២.សង្ខ្យាវារៈ

ឥឡូវនេះ ដើម្បីនឹងសម្ដែងវិសជ្ជនាវារៈ ដែលអាចវិសជ្ជនាបានក្នុងបច្ច័យនីមួយៗ ក្នុងហេតុប្បច្ច័យជាដើមនេះ ដោយអំណាចនៃចំនួនដែល

ព្រះមានព្រះភាគទ្រង់ត្រាស់ថា **“ហេតុយា នវ”** ជាដើម ។ គប្បីជ្រាប នូវវិនិច្ឆ័យក្នុងពាក្យនោះ ដូចតទៅ ៖

ពីរបទថា **“ហេតុយា នវ”** សេចក្ដីថា ក្នុងហេតុប្បច្ច័យ មានវារៈនៃបុច្ឆា និងវិសជ្ជនា ៩ វារៈ ។ គឺដូចម្ដេច ? គឺកុសលជាមួយកុសល, អព្យាកតៈ ជាមួយកុសល, កុសល និងអព្យាកតៈជាមួយកុសល, អកុសល ជាមួយអកុសល, អព្យាកតៈ ជាមួយអកុសល, អកុសល និងអព្យាកតៈ ជាមួយអកុសល, អព្យាកតៈជាមួយអព្យាកតៈ, អព្យាកតៈជាមួយកុសល និងអព្យាកតៈ, អព្យាកតៈជាមួយអកុសល និងអព្យាកតៈ ។ ពីរបទថា **“អារម្មណេ តីណិ”** គឺកុសល ជាមួយកុសល, អកុសលជាមួយអកុសល និងអព្យាកតៈជាមួយអព្យាកតៈ ។

បទថា **“អធិបតិយា នវ”** ដូចគ្នានឹងបទដែលបានពោលហើយ ក្នុងហេតុនោះឯង ។ លោកពោលទុកថា ពិតមែនហើយ ក្នុងបច្ច័យ ១២ លោកចែកចេញទៅជាបច្ច័យនីមួយៗ ៩ វារៈ ។ បុច្ឆា និងវិសជ្ជនា ក្នុងបច្ច័យទាំងពួង ដូចគ្នានឹងហេតុប្បច្ច័យនោះឯង ។ ប៉ុន្តែនៅក្នុងវិភង្គ មាន (អត្ថ) ប្លែកគ្នា ។ ព្រោះថា រូប ក៏នៅមានក្នុងការវិសជ្ជនាអព្យាកតបទ ក្នុងអញ្ញមញ្ញប្បច្ច័យ ។ ក្នុងបុរេជាតប្បច្ច័យ ក៏ដូចគ្នាដែរ ។ ក្នុងអាសេវនប្បច្ច័យ រមែងមិនបានវិបាកចិត្ត និងវីថិចិត្តទេ ។ ពីរបទថា

**“ វិបាកេ ឯកំ ”** *គឺអព្យាកតៈជាមួយនឹងអព្យាកតៈនោះឯង ។ កាលបើពោលដោយសង្ខេប ក្នុងអធិការនេះ មានការកំណត់វារៈ ៣ យ៉ាងប៉ុណ្ណោះ គឺ ៩ វារៈ, ៣ វារៈ និង ១ វារៈ; បើពោលដោយពិស្តារដូច្នេះ គឺពួកនវកៈ មាន ១២ បច្ច័យ, ពួកតិកៈ មាន ១០ បច្ច័យ, ពួកឯកៈ មាន ១ បច្ច័យ ។ ក្នុងបច្ច័យទាំង ២៣ មាន ១៣៩ វារៈ និងបុច្ឆា ១៣៩ វារៈទៀត ។ សូម្បីពាក្យថា* **“ ឯកូនចត្តាឡីសាធិកំ បុច្ឆា វិសជ្ជនសតំ ”** *ក៏បញ្ជាក់ដល់ពាក្យថា* **ឯកូនចត្តាឡីសាធិកំ វារសតំ** *នោះដែរ; លោកអាចារ្យ កាលសម្តែងរាប់ក្នុងបច្ច័យដែលមានមូលមួយ មានហេតុប្បច្ច័យជាដើម យ៉ាងនេះហើយ ដើម្បីនឹងកាន់យកចំពោះចំនួនដែលបាននៅក្នុងទេសនា ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកយ៉ាងពិស្តារ ក្នុងបច្ច័យដែលមានមូល ២ ជាដើម ដទៃក្រៅអំពីនេះ បានសម្តែងទុកក្នុងបច្ច័យដែលមានមូលមួយ សម្តែងការកំណត់វារៈ ទើបពោលពាក្យថា* **“ ហេតុប្បច្ចយា អារម្មណេ តីណិ** = *ព្រោះហេតុប្បច្ច័យក្នុងអារម្មណប្បច្ច័យ មាន ៣ វារៈ ” ជាដើម ក្នុងបច្ច័យដែលមានមូល ២ ជាមុន ។ ក្នុងបញ្ហានោះ មានវិធីកំណត់ដូច្នេះ ៖*

*បច្ច័យដែលមានការរាប់ច្រើន (គឺមានវារៈច្រើន) ប្រកបជាមួយបច្ច័យដែលមានការរាប់តិច មានចំនួន (វារៈ) ស្មើនឹងចំនួនតិចនោះ; ព្រោះ*

*ហេតុនោះ ទើបលោកពោលថា* **“ហេតុប្បច្ចយា អារម្មណេ តីណិ** *= ព្រោះហេតុប្បច្ច័យ ក្នុងអារម្មណប្បច្ច័យ មាន ៣ វារៈ” អធិប្បាយថា ក្នុងហេតុអារម្មណទុកៈ បានវិសជ្ជនា ៣ វារៈ ដែលពោលទុកក្នុងអារម្មណ៍ប៉ុណ្ណោះ ។ ចំណែកបច្ច័យដែលមានវិធីរាប់ស្មើគ្នា ប្រកបជាមួយបច្ច័យដែលមានវិធីរាប់ស្មើគ្នា រមែងមានចំនួនបន្ថែមឡើង និងបន្ថយចុះ, ព្រោះហេតុនោះ ទើបលោកពោលថា* **“ហេតុប្បច្ចយា អធិបតិយា នវ** *= ព្រោះហេតុប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មាន ៩ វារៈ” អធិប្បាយថា ក្នុងហេតុអធិបតិទុកៈ បានវិសជ្ជនា ៩ វារៈ ។*

*ពីរបទថា* **“វិបាកេ ឯកំ”** *សេចក្តីថា ក្នុងហេតុវិបាកទុកៈ រមែងបានវិសជ្ជនាមួយវារៈ ដែលពោលទុកក្នុងវិបាកប៉ុណ្ណោះ, បណ្ឌិតគប្បីជ្រាបការកំណត់វារៈក្នុងបច្ច័យដែលមានមូលពីរប៉ុណ្ណោះជាមុន ដោយប្រការដូច្នេះសិនចុះ ។ ក្នុងវិសជ្ជនាដែលមានមូល ៣ ជាដើម ក៏មានវិធីកំណត់យ៉ាងនេះដូចគ្នាដែរ; ព្រោះហេតុនោះ ទើបពោលថា* **“ហេតុប្បច្ចយា អារម្មណប្បច្ចយា អធិបតិយា តីណិ** *= ព្រោះហេតុប្បច្ច័យ អារម្មណប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មាន ៣ វារៈ” អធិប្បាយថា ក្នុង* ***ហេតុអារម្មណាធិបតីតិកៈ*** *បានវិសជ្ជនា ៣ វារៈ ដែលពោលទុកក្នុងអារម្មណ៍ប៉ុណ្ណោះ; ក្នុងវិសជ្ជនាទាំងពួង បណ្ឌិតគប្បីពង្រីកន័យចេញទៅយ៉ាងនេះ ។ ចំណែក*

ក្នុងវិសជ្ជនាដែលមានមូល ១២ រមែងមិនបានវិបាកប្បច្ច័យទេ, ព្រោះហេតុដូច្នោះ ទើបលោកពោលថា **“អាសេវនប្បច្ចយា កម្មេ តីណិ** = ព្រោះអាសេវនប្បច្ច័យក្នុងកម្មប្បច្ច័យ មាន ៣ វារៈ” ហើយពោលថា **“អាហារេ តីណិ** = ក្នុងអាហារប្បច្ច័យ មាន ៣ វារៈ” ជាដើម មិនសំដៅសេចក្ដីទៅដល់វិបាកឡើយ; សូម្បីក្នុងវិសជ្ជនាដែលមានមូល ១៣ ជាដើម ក៏មានន័យដូចគ្នានេះដែរ; ប៉ុន្តែថា ក្នុងទីនេះ លោកសង្ខេបបច្ច័យទាំងនេះ ហើយពោលដល់បច្ច័យដែលមានមូល ២៣ ។

បច្ច័យដែលមានមូល ២៣ នោះ ចែកជាពីរប្រភេទ គឺដែលមានអាសេវនៈខ្លះ, មានវិបាកខ្លះ; ក្នុងពីរយ៉ាងដែលមានអាសេវនៈ លោកសម្ដែងទុកមុន; បច្ច័យដែលមានអាសេវនៈនោះ បានវិសជ្ជនា ៣ ប៉ុណ្ណោះ; ព្រោះហេតុនោះ ទើបលោកពោលថា **“អាសេវនប្បច្ចយា អវិគតេ តីណិ** = ព្រោះអាសេវនប្បច្ច័យ ក្នុងអវិគតប្បច្ច័យ មាន ៣ វារៈ” , ចំណែកបច្ច័យដែលមានវិបាក (កើតរួមជាមួយវិបាក) រមែងមិនបានអាសេវនៈទេ, ព្រោះហេតុដូច្នោះ ដើម្បីនឹងលះអាសេវនៈ ហើយសម្ដែងចំនួន ដោយអំណាចនៃវិបាក ទើបលោកសម្ដែងន័យមួយយ៉ាងទុកថា **“ហេតុប្បច្ចយា ។ល។ វិបាកប្បច្ចយា អាហារេ ឯកំ”** ហើយ សម្ដែងមូល ២៣ ខាង

ក្រោយ; បណ្តាបច្ច័យដែលមានមូល ២៣ ពីរពួកនេះ វិបាកប្បច្ច័យមិនមានក្នុងពួកមួយទេ, អាសេវនប្បច្ច័យ មិនមាននៅក្នុងពួកមួយ ក៏ពិតមែន, ប៉ុន្តែ បច្ឆាជាតប្បច្ច័យមានទាំងពីរពួក ។ តែក៏បណ្ឌិតគប្បីជ្រាបមូល ២៣ នេះប៉ុណ្ណោះ ដោយសព្ទដែលលើស មក; ក្នុងបច្ច័យទាំង ២ នោះ ចំណែកខាងអាសេវនៈ បានវិសជ្ជនា ៣ ដោយអំណាចនៃអាសេវនៈ, ចំណែកខាងវិបាក បានវិសជ្ជនា ១ ដោយអំណាចនៃវិបាកប្បច្ច័យ នេះជាការរាប់ក្នុងបច្ច័យដែលមានមូលមួយជាដើម ផ្តើមតាំងតែអំពីហេតុប្បច្ច័យមកដោយប្រការដូច្នេះ ។

ពាក្យនេះ យ៉ាងណា លោកពោលទុកថា **“អារម្មណេ ឋិតេន សព្វត្ថ តីណេវ បញ្ហា”** ក្នុងលំដាប់បច្ច័យដែលមានហេតុប្បច្ច័យជាមូល, ពាក្យនោះលោកពោលទុកដើម្បីសម្តែងថា “ក្នុងអារម្មណបទ គ្រប់បទ ទាំងក្នុងចំណែកបច្ច័យដែលមានមូលមួយ និងមានមូល ២ ជាដើម ផ្តើមតាំងអំពីអារម្មណ-ប្បច្ច័យទៅ ទាំងក្នុងការប្រកបអធិប្បាយបច្ច័យដែលនៅសល់ ព្រមជាមួយនឹងអារម្មណប្បច្ច័យ ដែលមានបញ្ហា ៩ វារៈ មាន បុច្ឆា ៣ វារៈប៉ុណ្ណោះ” ; ចំណែកក្នុងវិបាកបទ និងក្នុងការប្រកបបច្ច័យដែលនៅសល់ ព្រមជាមួយនឹងវិបាកបទ មានបញ្ហាមួយវារៈប៉ុណ្ណោះ; ពាក្យណា ដែលខ្ញុំពោលទុកហើយអំពីខាងដើមថា “បច្ច័យដែលមានវិធីរាប់ច្រើន រួមជាមួយនឹងបច្ច័យ

ដែលមានវិធីរាប់តិច រមែងមានចំនួនស្មើគ្នានឹងបច្ច័យ ដែលតិចនោះ" ដូច្នេះ, ពាក្យនោះ ខ្ញុំបានពោលទុកត្រឹមត្រូវហើយ ។

ឥឡូវនេះ គប្បីសម្ដែងបច្ច័យដែលមានមូលមួយជាដើម ដោយអំណាចនៃអារម្មណប្បច្ច័យជាដើម, ក្នុងបច្ច័យទាំងនោះ បច្ច័យដែលមានមូល ១ លោកមិនបានសម្ដែងទុកក្នុងបច្ច័យត្រឹមតែម្យ៉ាងទេ ព្រោះថាដូចគ្នានឹងបច្ច័យដែលមានមូល ១ នៃហេតុប្បច្ច័យនោះឯង ។ ដើម្បីនឹងសម្ដែងចំនួន ក្នុងបច្ច័យដែលមានមូល ២ ដោយអំណាចនៃអារម្មណប្បច្ច័យ ទើបលោកពោលថា **"អារម្មណប្បច្ចយា ហេតុយា តីណិ, អធិបតិយា តីណិ ។ ល ។ អវិគតេ តីណិ"** ក្នុងអធិការនេះ លោកគួរនឹងពោលថា **"អារម្មណប្បច្ចយា អធិបតិយា តីណិ ។ ល ។ អវិគតេ តីណិ"** លោកក៏ដាក់ហេតុប្បច្ច័យនៅខាងមុខ អារម្មណប្បច្ច័យទុកខាងក្រោយ ហើយពោលថា **"អារម្មណប្បច្ចយា ហេតុយា តីណិ** = ព្រោះអារម្មណប្បច្ច័យក្នុងហេតុប្បច្ច័យ មាន ៣ វារៈ" ដើម្បីសម្ដែងបច្ច័យ ដែលមានវិធីរាប់ច្រើន មានហេតុប្បច្ច័យជាដើម និងវិធីរាប់ដែលរកបាន ក្នុងការប្រៀបធៀបបច្ច័យទាំងនោះ ជាមួយនឹងបច្ច័យដែលមានវិធីរាប់តិចជាង និងស្មើគ្នា ។ ពាក្យនេះ រមែងភ្លឺច្បាស់ដោយសេចក្ដីអធិប្បាយនេះ ៖

អារម្មណប្បច្ច័យ រមែងដល់សេចក្ដីផ្សេងគ្នា ដោយជាទុកៈ និងតិកៈ

ព្រោះវិធីរាប់ដែលច្រើនជាង ឬស្មើគ្នានឹងបច្ច័យណាៗ, ក្នុងបច្ច័យទាំងអស់នោះ គប្បីជ្រាបថា មានបញ្ហា (បុច្ឆា) និងវិសជ្ជនា ៣ វារៈប៉ុណ្ណោះ ។ ចំណែកក្នុងការប្រៀបធៀបជាមួយនឹងវិបាកប្បច្ច័យ រមែងបានបុច្ឆា និងវិសជ្ជនា ១ វារៈប៉ុណ្ណោះ, វារៈនោះ លោកមិនបានសម្ដែងទុកក្នុងអធិការនេះទេ ព្រោះថា នឹងមានច្បាស់ក្នុងការរាប់ទាក់ទិនជាមួយនឹងវិបាកប្បច្ច័យជាដើម និងការរាប់ដែលលោកសម្ដែងទុកក្នុងបច្ច័យដែលមានមូល ២ នេះឯង ជាវិធីរាប់ក្នុងបច្ច័យដែលមានមូល ៣ ជាដើមទេ, ព្រោះហេតុដូច្នោះ បច្ច័យដែលមានមូល ៣ ជាដើម ទើបលោកមិនអធិប្បាយទុកយ៉ាងពិស្ដារ ដោយអំណាចនៃអារម្មណប្បច្ច័យឡើយ ។

ឥឡូវនេះ លោកពោលពាក្យមានជាអាទិ៍ថា “ **អធិបតិប្បច្ចយា ហេតុយា នវ** ” ព្រោះអធិបតិប្បច្ច័យ ក្នុងហេតុប្បច្ច័យ មាន ៩ វារៈ ដើម្បីសម្ដែងវិធីរាប់ក្នុងបច្ច័យដែលមានមូល ២ ជាដើម ដោយអំណាចនៃអធិបតិប្បច្ច័យជាដើម; គប្បីជ្រាបនិទ្ទេសនៃបច្ច័យ តាមន័យដែលខ្ញុំពោលទុកហើយ ក្នុងហេតុប្បច្ច័យនោះឯង; ក៏ព្រោះអធិបតិប្បច្ច័យ (ជាមូល) ហេតុប្បច្ច័យ មានបុច្ឆា និងវិសជ្ជនា ៩ វារៈ យ៉ាងណា, ក្នុងបច្ច័យដែលមានវិធីរាប់ស្មើនឹងហេតុប្បច្ច័យដែលនៅសល់ ក៏មាន ៩ វារៈ ដូច្នោះដែរ; ដូចដែលបានអធិប្បាយមកហើយនេះ ក្នុងការប្រៀបធៀបបច្ច័យ

*ដែលមានវិធីរាប់ស្មើនឹងបច្ច័យដែលមាននៅក្នុងលំដាប់ដំបូង ការរាប់រមែងមាន ដោយអំណាចនៃបច្ច័យដែលមាននៅក្នុងលំដាប់ដំបូង, អ្នកសិក្សាគប្បីជ្រាបថា ក្នុងការប្រៀបធៀបបច្ច័យដែលមានការរាប់តិចជាងគ្នា ជាមួយនឹងបច្ច័យ ដែលជាទីតាំងនោះ ចំនួនរាប់រមែងមានដោយអំណាចនៃបច្ច័យដែលមានការរាប់តិចជាង បណ្ឌិតអធិប្បាយនូវបច្ច័យដែលមានមូល ៣ ឲ្យពិស្តារ ដោយអំណាចនៃអារម្មណប្បច្ច័យ យ៉ាងណា, នឹងអធិប្បាយដោយអំណាចនៃអធិបតិប្បច្ច័យក្តី អនន្តរប្បច្ច័យដទៃក្រៅអំពីនោះក្តី ដូចគ្នាយ៉ាងនោះ មិនបានឡើយ ។ ព្រោះហេតុដូច្នោះ ក្នុងបច្ច័យទាំងអស់ គួរឲ្យសម្រេច ដោយអំណាចនៃវិធីរាប់ដែលលោកសម្តែងទុកហើយ ក្នុងបច្ច័យដែលមានមូល ២, ព្រោះហេតុនោះឯង ទើបលោកពោលថា ការធ្វើបច្ច័យនីមួយៗ ឲ្យជាមូល ហើយរាប់តាមគន្លងដែលបានស្វាធ្យាយមក ដោយលំដាប់ទុកចុះ ។*

ចប់បច្ចយានុលោមន័យ

................................

## ៣.ពណ៌នាអំពីបច្ចយបច្ចនីយន័យ

***ក៏ព្រោះវិសជ្ជនា ក្នុងបច្ចយបច្ចនីយៈ (ផ្ទុយគ្នានឹងបច្ច័យ) រមែងមិនបានក្នុងកុសលបទ ដែលវៀរហេតុប្បច្ច័យចេញហើយ កុសលធម៌ ក៏កើតឡើង***

***មិនបានទេ,*** *ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“អកុសលំ ធម្មំ បដិច្ច”** *ជាដើម ។ បណ្ដាបទទាំងនោះ បទថា* **“នហេតុ-ប្បច្ចយា”** *ជាការបដិសេធហេតុប្បច្ច័យ អធិប្បាយថា ទោះវៀរហេតុ-ប្បច្ច័យចេញហើយ ក៏នៅកើត ព្រោះបច្ច័យដទៃទៀតបាន ។ ពិតមែនហើយ ហេតុនេះ គឺមោហៈដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ជាហេតុប្បច្ច័យដោយខ្លួនឯង ដល់ធម៌ដែលសម្បយុត្តនឹងរូបដែលមានចិត្តជាសមុដ្ឋាន ។* ***ប៉ុន្តែ ព្រោះមិនមានហេតុដទៃសម្បយុត្តផង ទើបឈ្មោះថាមិនកើត ព្រោះហេតុប្បច្ច័យ, ព្រោះហេតុដូច្នោះ វៀរហេតុប្បច្ច័យចេញមោហមូលចិត្ត ក៏កើតបាន*** *ព្រោះបច្ច័យដ៏សមគួរដល់ខ្លួន ដែលនៅសល់ក្នុងធម៌ដែលជួយគ្នាទាំងអស់ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីទៅតាមន័យនេះក្នុងការបដិសេធនូវបច្ច័យទាំងពួងចុះ ។ ពាក្យថា* **“ នហេតុកំ ទិបាកា-ព្យាកតំ”** *នេះ គប្បីជ្រាបដោយអំណាចនៃចិត្តដែលញុំាងរូបឲ្យកើតឡើង ។ សូម្បីក្នុងបទដទៃដែលមានសភាពយ៉ាងនេះ ក៏មានន័យដូចគ្នានេះដែរ ។*

*ក្នុង* ***នអធិបតិប្បច្ច័យ*** *តាមពិត សូម្បីអធិបតីក៏មិនបានជាអធិបតិ-ប្បច្ច័យ ព្រោះមិនមានអធិបតីទី ២ កើតរួមជាមួយខ្លួន , ចំណែកមោហៈ (មោហមូលចិត្ត) ដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈនៅជាអហេតុកៈ (ជាធម៌មិនមានហេតុទាំងពីរ) យ៉ាងណា, អធិបតីធម៌ទាំងឡាយ មិនជា*

អធិបតិប្បច្ច័យទេ គឺនៅជានិរាធិបតី (ដដែល) (ព្រោះតែអធិបតីធម៌ទីពីរមិនបានកើតរួមជាមួយខ្លួន) ក៏យ៉ាងនោះដែរ ។ ឯឧទ្ធច្ចៈ ជាអហេតុកៈមិនបានឡើយ ។ ក្នុងវេលាដែលកុសលធម៌ជាដើម មិនបានធ្វើឆន្ទៈជាដើមឲ្យជាអធិបតី ហើយកើតឡើង កុសលធម៌ជាដើមទាំងអស់ ក៏មិនជាអធិបតីដែរ; ព្រោះហេតុដូច្នោះ ទេសនាមានជាអាទិ៍ថា **“ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា”** នេះ គប្បីជ្រាបថា ព្រះអង្គទេសនាទុកដោយអំណាចនៃទេសនា មានការរួបរួមទុកនូវអធិបតីទាំងអស់ មិនមែនលើកឡើងត្រឹមតែអធិបតីប្លែកគ្នាទៅ ដូចមោហៈទេ ។ ក្នុង **នអនន្តរប្បច្ច័យ** និង **នសមនន្តរប្បច្ច័យ** មាន **រូប** ប៉ុណ្ណោះ ជាបច្ចយុប្បន្ន ដូចនៅក្នុង **នអារម្មណប្បច្ច័យ** ដែរ ។ ព្រោះហេតុនោះ ទើបលោកពោលថា **“ នអារម្មណប្បច្ចយសទិសំ”** ។ សហជាតប្បច្ច័យដាច់បាត់ទៅ, និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគត-ប្បច្ច័យ ក៏ដាច់បាត់ទៅដែរ ។ ព្រោះហេតុអ្វី ? ព្រោះបើវៀរចាកបច្ច័យទាំង (៤) នេះហើយ ធម៌អ្វីៗ ក៏កើតឡើងមិនបានឡើយ ។ ពិតមែនហើយ ព្រោះការឆ្លើយបដិសេធ ចេញនូវសហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ, រូបធម៌ និងអរូបធម៌ សូម្បីត្រឹមតែម្យ៉ាងក៏កើតឡើងមិនបាន, ព្រោះហេតុដូច្នោះ បច្ច័យទាំងនោះ ទើបផុតទៅ ។ ក្នុងវិភង្គនៃ **នអញ្ញមញ្ញប្បច្ច័យ** គប្បីជ្រាបការវៀរហទយវត្ថុ ដោយពាក្យថា

***កដត្តារូប*** *អាស្រ័យវិបាកាព្យាកតក្ខន្ធកើតឡើង ក្នុងបដិសន្ធិកាល ។ រូបប៉ុណ្ណោះ ជាបច្ចយុប្បន្ន ក្នុងវិភង្គនៃ* ***នឧបនិស្សយប្បច្ច័យ*** *។ ព្រោះរូបនោះ មិនបានឧបនិស្សយប្បច្ច័យទេ ។ ចំណែកអរូប (នាម) មិនបានអារម្មណូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ក៏ពិតមែន, ប៉ុន្តែក៏មិនផុតអំពីអនន្តរូបនិស្សយប្បច្ច័យទៅបានឡើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា* **“នអារម្មណាប្បច្ចយសទិសំ”** *។*

*ក្នុង* ***នបុរេជាតប្បច្ច័យ*** *ពាក្យថា* **“ចិត្តសមុដ្ឋានំ រូបំ”** *លោកពោលទុកដោយអំណាចនៃបញ្ចវោការភព ។ សហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យ រមែងដល់ការរួមចុះក្នុងពាក្យថា* **“នបច្ឆាជាតប្បច្ចយា”** *នេះ ។ ព្រោះហេតុដូច្នោះ បាលីក្នុងពាក្យនេះ ទើបដូចគ្នានឹងសហជាត-ប្បច្ច័យដែរ ។ បាលីនោះ ពន្យល់ទុកយ៉ាងពិស្តារក្នុង* ***នអធិបតិប្បច្ច័យ,*** *ព្រោះហេតុដូច្នោះ ក្នុងទីនេះ ទើបពោលទុកដោយសង្ខេប ។ ក្នុង* ***នអាសេវន-ប្បច្ច័យ*** *គប្បីជ្រាបដោយអំណាចនៃបឋមជវន ចំណែកខាងកុសល និងអកុសល ។ កិរិយាព្យាកតៈ ក៏មានន័យដូចគ្នានេះដែរ ។ សូម្បីក្នុងអធិការនេះ ក៏គប្បីជ្រាបបាលី ដោយអំណាចនៃពាក្យដែលលោកឲ្យពិស្តារក្នុង* ***នអធិបតិប្បច្ច័យ;*** *ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា*

**“ នបច្ឆាជាតប្បច្ចយម្បិ នអាសេវនប្បច្ចយម្បិ នាធិបតិប្បច្ចយសទិសំ ”** ដូច្នេះ (បាលីបញ្ហា ៩៥) ។ ក្នុង ***នកម្មប្បច្ច័យ*** មិនកាន់យកវិបាកចេតនា ដែលជានានក្ខណិកកម្មប្បច្ច័យទេ ។ ក្នុង ***នអាហារប្បច្ច័យ*** មានចំពោះតែរូប, រូបខ្លះប៉ុណ្ណោះ ជាបច្ចយុប្បន្ន, ក្នុង ***នឥន្ទ្រិយប្បច្ច័យ*** ក៏ដូចគ្នាដែរ ។ ក្នុង ***នឈានប្បច្ច័យ*** មានបញ្ចវិញ្ញាណធម៌ (ទ្វិបញ្ចវិញ្ញាណ) និងរូប, រូបខ្លះ ជាបច្ចយុប្បន្ន ។ ពិតមែនហើយ ក្នុងបញ្ចវិញ្ញាណ, វេទនា និងចិត្តេកគ្គតា រមែងមិនដល់លក្ខណៈនៃការចូលទៅសម្លឹង ព្រោះមានកម្លាំងខ្សោយ, ព្រោះហេតុដូច្នោះ ធម៌ទាំងនោះ ទើបលោកមិនកាន់យកក្នុងឈានប្បច្ច័យទេ ។ ក្នុង ***នមគ្គប្បច្ច័យ*** មានអហេតុកវិបាក កិរិយា និងរូប, រូបខ្លះប៉ុណ្ណោះ ជាបច្ចយុប្បន្ន ។

រូបប៉ុណ្ណោះ ជាបច្ចយុប្បន្ន ក្នុងនសម្បយុត្តប្បច្ច័យ ក្នុងនោនត្ថិ-ប្បច្ច័យ និងក្នុងនោវិគតប្បច្ច័យ ។ ព្រោះហេតុនោះ ទើបលោកពោលថា **“ នារម្មណប្បច្ចយសទិសំ ”** ។ ដំណើររាប់បច្ច័យដែលមានមូលមួយតាមបាលី ដោយពាក្យថា **“នហេតុយា ទ្វេ”** ដូច្នេះឯង ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង ***ទុមូលកប្បច្ច័យ*** ដូចតទៅ ៖

ក្នុងពាក្យថា **“នហេតុបច្ចយា នារម្មណេ ឯកំ”** នេះ អធិប្បាយថា ដោយអំណាចនៃបច្ច័យដែលរាប់បានតិចជាង ក្នុងការប្រៀបធៀបបច្ច័យ

ដែលរាប់បានតិចជាង និងបច្ច័យដែលរាប់បានច្រើន គប្បីមានបច្ច័យ ២ ដូចក្នុងនហេតុប្បច្ច័យ ក៏ពិតមែន, ប៉ុន្តែ ពាក្យថា **“ឯកំ”** លោកពោលសំដៅដល់រូបាព្យាកតៈកើតឡើង ដោយអាស្រ័យអព្យាកតៈ ព្រោះអរូបធម៌ដាច់ទៅ ដោយអំណាចនៃនអារម្មណប្បច្ច័យ ។ សូម្បីក្នុងបច្ច័យតែគ្រប់ៗបច្ច័យ ក្នុងទុកប្បច្ច័យ ក៏មានន័យដូចគ្នានេះដែរ ។ បណ្ឌិតគប្បីជ្រាបវារៈពីរ ដោយការទាក់ទិនដែលមានក្នុងនហេតុប្បច្ច័យ ត្រង់កន្លែងដែលលោកពោលទុកថា **“ទ្វេ”** ។ ចំណែកក្នុងបច្ច័យទាំងពួង ដែលមានមូល ៣ ជាដើម មានវិសជ្ជនា ១ វារៈប៉ុណ្ណោះ ព្រោះនអារម្មណប្បច្ច័យដាច់ទៅ ។ នេះជាការរាប់ចំនួនក្នុងបច្ច័យដែលមានមូល ១ ជាដើម ផ្តើមតាំងពីនហេតុប្បច្ច័យទៅ ក្នុងបច្ចនីយន័យ ។ ***ចំណែកនអារម្មណប្បច្ច័យ*** មិនសម្តែងទុកក្នុងទីនេះទេ ព្រោះដូចគ្នាជាមួយនឹងន័យមុន ក្នុងឯកមូលកៈនោះឯងជាដើម ។

ពាក្យថា **“នារម្មណប្បច្ចយា នហេតុយា ឯកំ”** ក្នុងទុមូលកន័យ ព្រះមានព្រះភាគត្រាស់ទុកក្នុងនហេតុទុកមូលកន័យនោះឯង ដោយអំណាចនៃអារម្មណប្បច្ច័យ ។ ពាក្យថា **“នាធិបតិយា បញ្ច”** គប្បីជ្រាបដោយអំណាចនៃការបានក្នុងនារម្មណប្បច្ច័យ ។

ក្នុងការប្រៀបធៀបបច្ច័យទាំងអស់ គប្បីជ្រាបចំនួនដោយអំណាចនៃបច្ច័យដែលរាប់បានតិចជាង ក្នុងបច្ច័យដែលនារម្មណប្បច្ច័យចូលបាន,

*រូបប៉ុណ្ណោះ ជាបច្ចយុប្បន្ន ។ សូម្បីក្នុងឋានដែលនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នសម្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ចូលបាន ក៏មានន័យដូចគ្នានេះដែរ ។ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ មានវិសជ្ជនាដូចគ្នាទាំងអស់ ។ សូម្បីក្នុងអធិការនេះ បច្ច័យ ៤ ពួក នៃបច្ច័យមាន* ***នសហជាតប្បច្ច័យ*** *ជាដើម ក៏កាត់ផ្តាច់ទៅដូចគ្នា, នេះជាវិធីកំណត់ក្នុងបញ្ហានេះ ។ ដោយលក្ខណៈនេះ បណ្ឌិតគប្បីកំណត់បច្ច័យនោះថា “បច្ច័យដែលមានមូល ២ ជាដើមទាំងអស់ បច្ច័យនេះ ជាមូល ១, ក្នុងបច្ច័យទាំងនេះ បច្ច័យនេះ មានមូល ២, នេះមានមូល ៣, នេះមានមូលទាំងអស់” ដូច្នេះ ហើយគប្បីជ្រាបការគណនា ដោយអំណាចនៃបច្ច័យដែលរាប់បានតិចជាងដូច្នេះឯង ៕*

## ចប់បច្ចយបច្ចនីយន័យ

## ចប់ឧបនិស្សយប្បច្ច័យ

# ៤.ពណ៌នាអំពីបច្ចយានុលោមបច្ចនីយន័យ

*ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“ហេតុប្បច្ចយា ន អារម្មណេ បញ្ច”** *ជាដើម ដើម្បីសម្ដែងការរាប់ក្នុង* ***អនុលោមបច្ចនីយ-ប្បច្ច័យ*** *។ គប្បីជ្រាបនូវវិនិច្ឆ័យក្នុងពាក្យនោះ បច្ច័យទាំង ៨ នេះ គឺ បច្ច័យ ៤ មានសហជាតប្បច្ច័យជាដើម ដែលបញ្ចូលបានគ្រប់កន្លែង និង អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ ៤ ទៀត រមែងមិនបានដោយសេចក្ដីជាបច្ចនីយៈ ក្នុងហេតុប្បច្ច័យ អធិបតិប្បច្ច័យ មគ្គប្បច្ច័យ ដែលតាំងនៅដោយការអនុលោម (តាមលំដាប់) ។ ពិតមែន ហើយ ធម៌កាលនឹងកើតឡើង ដោយអំណាចនៃហេតុប្បច្ច័យជាដើម ឈ្មោះ ថា នឹងមិនបានបច្ច័យទាំង ៨ នេះ រមែងមិនមាន ។ ប៉ុន្តែ អារម្ម-ណប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ សម្ប-យុត្តប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ដែលតាំងនៅដោយអនុ-លោម រមែងមិនបានបច្ច័យដែលឧបការៈក្នុងតំណែងនៃនាម ដោយអំណាច ជាបច្ចនិកៈ ។ ព្រោះថា អនន្តរប្បច្ច័យជាដើម កាលមិនកើតអំពីអា-រម្មណប្បច្ច័យជាដើម ក៏រមែងមិនបាន ។ ចំណែកបច្ច័យ ៤ ដែលឧបការៈ ក្នុងឋានទាំងអស់ រមែងមិនបានដោយសេចក្ដីជាបច្ចនិកៈ ក្នុងសហជាត-ប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ*

ឥន្ទ្រិយប្បច្ច័យ នត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដែលតាំងនៅ ដោយសេចក្តីជាអនុលោមនឹងគ្នា ។ ព្រោះថា ធម៌កាលកើតដោយអំណាចនៃបច្ច័យទាំងនេះ នឹងមិនបានបច្ច័យឧបការៈក្នុងឋានទាំងពួង រមែងមិនមាន ។ បច្ឆាជាតប្បច្ច័យ មិនមានទីតាំងដោយសេចក្តីជាអនុលោមទេ ។ បណ្ឌិតកំណត់បច្ច័យដែលមាន និងមិនមាន ក្នុងបច្ច័យដែលនៅសល់ ដែលតាំងនៅដោយសេចក្តីជាអនុលោមគ្នាហើយ គប្បីជ្រាបការរាប់ដោយអំណាចនៃបច្ច័យដែលរាប់បានតិចជាង ក្នុងការប្រៀបធៀបបច្ច័យនោះៗ ក្នុងបច្ច័យដែលមានមូល ២ ជាដើម សូម្បីទាំងអស់ដូច្នេះឯង៕

ចប់បច្ចយានុលោមបច្ចនីយន័យ

.............................................

# ៥.ពណ៌នាអំពីបច្ចយបច្ចនីយានុលោមន័យ

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្តើមពាក្យថា **“ន ហេតុប្បច្ចយា អារម្មណេ ទ្វេ** = ព្រោះនហេតុប្បច្ច័យ ក្នុងអារម្មណប្បច្ច័យ មាន ២ វារៈ” ជាដើម ដើម្បីសម្តែងការរាប់ក្នុង ***បច្ចនីយានុលោម*** ។ ក្នុងបច្ចនីយា-នុលោមនោះ បច្ច័យដែលនៅសល់ វៀរអធិបតិប្បច្ច័យ រមែងបានដោយអនុលោម ក្នុងហេតុប្បច្ច័យដែលតាំងនៅដោយសេចក្តីជាបច្ចនិកៈ ។ ចំណែកបច្ឆាជាតប្បច្ច័យ រមែងមិនបានដោយអនុលោម ក្នុងបច្ច័យទាំង

អស់នោះមែនពិត ។ បច្ច័យទាំងឡាយឯណា ៩ ដែលលោកពោលទុកថា **“អរូបានំញ្ចេវ”** ដូច្នេះ, បច្ច័យដែលតាំងនៅក្នុងឋាននៃនាមដ៏សេស រមែងមិនបានដោយអនុលោមក្នុងបច្ច័យ ៧ ដែលនៅសល់ វៀរបុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យដែលតាំងនៅជាបច្ចនិកៈ ។ ពិតមែន ធម៌ដែលមិនកើតអំពីអារម្មណប្បច្ច័យជាដើម, រមែងមិនបានអនន្តរប្បច្ច័យជាដើមទេ ។

ក៏បដិសន្ធិវិបាក និងវិបាកទាំងអស់ដែលកើតអំពីបុរេជាតប្បច្ច័យ សូម្បីមិនកើតអំពីអាសេវនៈ និងកិរិយាមនោធាតុ ក៏រមែងបានអនន្តរប្បច្ច័យជាដើមដែរ ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **“បុរេជាតញ្ច អាសេវនញ្ច ឋបេត្វា”** ដូច្នេះ; បច្ច័យដែលនៅសល់ វៀរអវិគតប្បច្ច័យ រមែងបានដោយអនុលោមក្នុងបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ ដែលតាំងនៅជាបច្ចនិកៈ ។ វៀរវិបាកប្បច្ច័យចេញហើយ ដែលនៅសល់រមែងបានដោយអនុលោមក្នុងកម្មប្បច្ច័យដែលតាំងនៅដោយបច្ចនិកៈ ។ វៀរបច្ច័យដែលឧបការក្នុងទីទាំងពួង និងអញ្ញមញ្ញប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ដែលនៅសល់រមែងមិនបានដោយអនុលោមក្នុងអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ដែលតាំងនៅដោយបច្ចនិកៈ ។ បច្ច័យក្រៅ

អំពីនេះ រមែងបានដោយអំណាចន័យដ៏សមគួរដល់ហេតុប្បច្ច័យ អធិបតិ-ប្បច្ច័យ អាសេវនប្បច្ច័យ និងមគ្គប្បច្ច័យ រមែងមិនបានដោយអនុលោម ក្នុងឈានប្បច្ច័យដែលតាំងនៅជាបច្ចនិកៈទេ ។ ក្នុងមគ្គប្បច្ច័យដែលតាំងនៅជាបច្ចនិកៈ រមែងមិនបានហេតុប្បច្ច័យ និងអធិបតិប្បច្ច័យ ដោយអនុលោមឡើយ ។ ក្នុងវិប្បយុត្តប្បច្ច័យដែលតាំងនៅដោយបច្ចនិកៈ វៀរបុរេជាត-ប្បច្ច័យចេញ រមែងបានបច្ច័យដែលនៅសល់ ដោយអនុលោម; បណ្ឌិតកាលជ្រាបបច្ច័យដែលមិនបានជាអនុលោម ក្នុងបច្ច័យដែលតាំងនៅជាបច្ចនិកៈយ៉ាងនេះហើយ គប្បីជ្រាបនូវការរាប់ដោយអំណាចនៃបច្ច័យដែលរាប់បានតិចជាង ក្នុងការប្រៀបធៀបជាមួយនឹងបច្ច័យនោះ ។

ក្នុងមាតិកាទាំងឡាយ មានទុកមាតិកាជាដើមណា ៗ ដែលលោកផ្ដើមសម្ដែងតាំងពីបច្ច័យណា ៗ ក្នុងន័យទាំងឡាយ មានទុមូលកន័យជាដើម, ទុកមាតិកានោះ ៗ លោកសម្ដែងទុកហើយដោយវិធីណា ៗ ដោយអំណាចនៃបច្ច័យដែលរកបាន និងមិនបាន, បណ្ឌិតគប្បីកំណត់ទុកមាតិកាជាដើមនោះឲ្យល្អ ដោយវិធីនោះ ៗ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដែលព្រះមានព្រះភាគកាលបើនឹងទ្រង់សម្ដែងន័យ មានទុមូលកន័យជាដើម ដោយអំណាចនៃហេតុប្បច្ច័យ ក៏ត្រាស់ថា **“ នហេតុប្បច្ចយា នារម្មណ-ប្បច្ចយា ។ ល ។ នាសេវនប្បច្ចយា ”** ដូច្នេះ ហើយត្រាស់ពាក្យណាទុក

*ពាក្យអធិប្បាយទាំងអស់ដូចគ្នា រហូតដល់អាសេវនប្បច្ច័យ គប្បីជ្រាបសេចក្ដីដូចគ្នានៃពាក្យនោះ ជាមួយនឹងពាក្យថា* **“ នអញ្ញមញ្ញបច្ចយា សហជាតេ ឯកំ** = *ព្រោះនអញ្ញមញ្ញប្បច្ច័យក្នុងសហជាតប្បច្ច័យ មាន ១ វារៈ ” ដែលលោកសរសេរទុកក្នុងភាសាសីហឡៈថា “លោកអាចារ្យរមែងរួមយកនូវបច្ច័យ ៥ ក្នុង* ***នកម្មប្បច្ច័យ*** *ដែលគណនាហើយ” គប្បីជ្រាបសេចក្ដីនៃពាក្យនោះដូច្នេះ បច្ច័យ ៥ ផ្ដើមតាំងអំពីនហេតុប្បច្ច័យដែលលោកសម្ដែងទុកយ៉ាងនេះថា បណ្ឌិតរមែងបានវិសជ្ជនាវារៈ ១ ក្នុងសហជាត-ប្បច្ច័យដែលបន្តជាមួយនកម្មប្បច្ច័យ យ៉ាងនេះថា* **“ នកម្មបច្ចយា ”** *ដូច្នេះ រមែងបានដោយអនុលោមប្បច្ច័យដទៃមិនបាន, ក្នុងឋានដទៃដែលមានសភាពបែបនេះ បណ្ឌិតមិនគួរកាន់យកព្យញ្ជនៈទេ, គួរកាន់យកចំពោះតែសេចក្ដីដែលបំណងដល់ប៉ុណ្ណោះ ។ ពិតមែនហើយ ព្យញ្ជនៈដូច្នោះ បុរាណាចារ្យបានចារឹកទុកជាភាសាសំស្រ្កឹតដើម្បីចងក្រងតាមការទ្រទ្រង់របស់ខ្លួន ។*

*ម្យ៉ាងទៀត សូម្បីក្នុងបច្ចយុប្បន្នធម៌ ក្នុងបច្ចនីយានុលោមនេះ អត្ថិធម៌ (អត្ថិប្បច្ច័យ) រមែងបានកម្មប្បច្ច័យ, ប៉ុន្តែ មិនបានឥន្ទ្រិយ-ប្បច្ច័យទេ, អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចនៃ* ***រូបជីវិតិន្ទ្រិយ ក្នុងអសញ្ញសត្វ*** *និងក្នុងបវត្តិកាល ក្នុងបញ្ចវោការភព ។ អត្ថិធម៌ដែលបាន*

មគ្គប្បច្ច័យ, ប៉ុន្តែ មិនបានហេតុប្បច្ច័យទេ, អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចនៃមោហៈដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចសម្បយុត្តចិត្ត ។ អត្ថិធម៌ដែលបានឈានប្បច្ច័យ, ប៉ុន្តែ មិនបានមគ្គប្បច្ច័យទេ, អត្ថិធម៌នោះ គប្បីជ្រាបដោយអំណាចនៃមនោធាតុ និងអហេតុកមនោវិញ្ញាណធាតុចុះ ។ ***បណ្តាសេចក្តីក្នុងអត្ថិប្បច្ច័យនោះ*** កម្មជរូបរមែងបានកម្មប្បច្ច័យ ដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យប៉ុណ្ណោះ ។ ក្នុងបច្ច័យទាំងនោះ រូបធម៌រមែងមិនបានហេតុប្បច្ច័យ អធិបតិប្បច្ច័យ វិបាកប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យទេ ។ បច្ច័យដែលរាប់បញ្ចូលបានគ្រប់កន្លែងមិនមានបច្ចនីយៈក្នុងអហេតុកចិត្ត និងមិនមានអធិបតិប្បច្ច័យដូច្នេះឡើយ ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបវារៈនៃការរាប់ចំនួន ដោយអំណាចនៃបកិណ្ណកៈទាំងនេះ ដោយមិនសាំញ៉ាំចុះ ។

ក្នុងបញ្ហានោះ មានន័យដូចតទៅនេះ ៖

អហេតុកមោហៈ អហេតុកវិបាក និងកិរិយាប៉ុណ្ណោះ ជាបច្ចុប្បន្នធម៌ ក្នុងព្រះបាលីថា **“នហេតុប្បច្ចយា អារម្មណេ ទ្វេ** = ព្រោះនហេតុប្បច្ច័យក្នុងអារម្មណប្បច្ច័យ មាន ២ វារៈ” នេះ, ពាក្យថា ***“មាន ២ វារៈ”*** ក្នុងអធិការនេះ ទើបលោកសំដៅយកអកុសលជាមួយនឹងអកុសល, អព្យាកតៈ ជាមួយនឹងអព្យាកតៈ ។ សូម្បីក្នុងពាក្យដែលនៅសល់ ក៏មាន

*ន័យដូចគ្នានេះដែរ ។ ចំណែកក្នុងអាសេវនប្បច្ច័យ រមែងមិនបានវិបាក និងកិរិយាមនោធាតុទេ; ព្រោះហេតុដូច្នោះ ក្នុងទីនេះ ពាក្យថា* **“អព្យាកតេ នាព្យាកតំ”** *បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអហេតុកមនោវិញ្ញាណធាតុ ចំណែកខាងកិរិយា ។ ពីរបទថា* **“វិបាកេ ឯកំ** *= ក្នុងវិបាកប្បច្ច័យ មាន ១ វារៈ”* *គឺអព្យាកតៈជាមួយនឹងអព្យាកតៈនោះឯង ។ ពាក្យថា* **“មគ្គេ ឯកំ”** *គឺអកុសលជាមួយនឹងអកុសល ។ ពាក្យថា* **“ហេតុយា បញ្ច** *= ក្នុងហេតុប្បច្ច័យ មាន ៥ វារៈ” , ក្នុងអារម្មណមូលកន័យ លោកពោលសំដៅយករូបប៉ុណ្ណោះ ។ ពិតមែនហើយ រូបនោះ រមែងកើត ព្រោះអាស្រ័យចំណែក ៥ គឺកុសល, អកុសល, អព្យាកតៈ, កុសល ជាមួយអព្យាកតៈ និងអកុសលជាមួយអព្យាកតៈ ។ សូម្បីក្នុងបញ្ចកៈទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា* **“អញ្ញមញ្ញេ ឯកំ** *= ក្នុងអញ្ញមញ្ញប្បច្ច័យ មាន ១ វារៈ” លោកពោលសំដៅយក* ***មហាភូតរូប និងវត្ថុរូប*** *។ ពិតមែនហើយ រូបទាំងនោះ រមែងកើត ព្រោះនអារម្មណប្បច្ច័យ និងព្រោះអញ្ញមញ្ញប្បច្ច័យ ។ សូម្បីក្នុង* ***តិមូលកន័យ*** *ក៏មានន័យយ៉ាងនេះដែរ ។*

*ពាក្យថា* **“ហេតុយា នវ** *= ក្នុងហេតុប្បច្ច័យ មាន ៩ វារៈ” , ក្នុង*

*នាធិបតិមូលកន័យ លោកពោលទុកហើយក្នុងហេតុប្បច្ច័យផ្នែកអនុលោម-ន័យ ។ សូម្បីពាក្យថា “**តីណិ** = ៣” ជាដើម ក៏ដូចគ្នានឹងពាក្យដែលពោលហើយ ក្នុងអនុលោមន័យអំពីខាងដើម ។ ក្នុង **តិមូលកន័យ** ពាក្យថា “**ទ្វេ** = ២ វារៈ” ដូចគ្នានឹងការដែលពោលទុកហើយ ក្នុង **នហេតុ-ប្បច្ចយមូល និងអារម្មណប្បច្ចយមូលី** អំពីខាងដើម ។ ក្នុង **នបុរេជាត-មូលកន័យ** ពាក្យថា “**ហេតុយា សត្ត** = ក្នុងហេតុប្បច្ច័យ មាន ៧ វារៈ” ព្រះមានព្រះភាគទ្រង់សម្ដែងទុកក្នុងបុរេជាតប្បច្ច័យអំពីខាងដើម ដោយន័យថា “**អរូបេ្ប កុសលំ ឯកំ ខន្ធំ បដិច្ច** = ខន្ធ ៣ អាស្រ័យកុសលក្ខន្ធ ១ ក្នុងអរូបភូមិ” ។ សូម្បីក្នុងសត្តកៈទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។ ក្នុង**នកម្មមូលកន័យ** ពាក្យថា “**ហេតុយា តីណិ** = ក្នុងហេតុប្បច្ច័យមាន ៣ វារៈ” ជាដើម ចេតនាប៉ុណ្ណោះ ជាបច្ចយុប្បន្ន, ព្រោះហេតុដូច្នោះ ពាក្យថា “**៣ វារៈ**” ទើបលោកពោលសំដៅយកការកើតឡើង ព្រោះអាស្រ័យកុសល អកុសល និងអព្យាកតៈ ។ ដោយន័យនេះ បណ្ឌិតគប្បីជ្រាបការរាប់ចំនួនវារៈ ក្នុងអនាគតស្ថាន (ដែលមក) ថា “១, ២, ៣, ៥, ៧, ៩” ; ចំណែកការរាប់ចំនួន ៣ ទៀតថា “៤, ៦, ៨” ទាំងនេះ មិនមានឡើយ ៕*

## ចប់បច្ចយបច្ចនីយានុលោមន័យ

## ចប់បដិច្ចវារៈ

## ២.សហជាតវារៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សហជាតវារៈ** តទៅ ៖*

*ពាក្យថា* **"កុសលំ ធម្មំ សហជាតោ** *= កើតរួមជាមួយនឹងកុសល-ធម៌" គឺព្រោះអាស្រ័យកុសលធម៌ ទើបកើតរួមនឹងកុសលធម៌នោះ ។ ពាក្យដែលនៅសល់ក្នុងសហជាតវារៈនេះ គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងបដិច្ចវារៈចុះ ។ ក្នុងអវសាននៃបដិច្ចវារៈ លោកពោលពាក្យនេះទុកថា "អត្ថនៃ **សហជាត** សព្ទ ឈ្មោះថា ជាអត្ថនៃបដិច្ចសព្ទ, អត្ថនៃបដិច្ចសព្ទ ឈ្មោះថា ជាអត្ថនៃសហជាតសព្ទ" ដូច្នេះ ដើម្បីសម្តែងថា វារៈទាំងពីរនេះ ពោលដោយសេចក្តីហើយ មិនមានវារៈណាប្លែកផ្សេងគ្នាឡើយ ។ ពិតមែន បើពោលដោយសេចក្តីហើយ វារៈទាំងពីរនេះ មិនមានវារៈណាដែលប្លែកផ្សេងគ្នាទេ; សូម្បីយ៉ាងនោះ ក៏លោកពោលទុកដើម្បីកំណត់ន័យរបស់គ្នានឹងគ្នា; ពិតណាស់ ក្នុងពាក្យថា* **"ចក្ខុញ្ច បដិច្ច រូបេ ច** *= អាស្រ័យចក្ខុ និងរូប" ជាដើម លោកពោលទុកថា បច្ចុប្បន្នធម៌រមែងកើត ព្រោះអាស្រ័យចក្ខុនឹងរូប (ចក្ខុបសាទជាមួយនឹងរូបារម្មណ៍) សូម្បីមិនបានកើតព្រមគ្នាក៏ដោយ ។ ឧបាទាយរូប សូម្បីកើតព្រមគ្នាក៏មិនជាបច្ច័យដល់មហាភូតរូបបានទេ; វារៈទាំងពីរនេះ លោកពោលទុក*

*ដើម្បីកំណត់សេចក្តីជាសហជាតដោយបដិច្ចវារៈ និងភាវៈនៃបច្ច័យដែល លោកពោលថា* **“បដិច្ច** = *ជាសហជាតដោយសហជាតវារៈ”* ។

*មួ៉ាងទៀត វារៈទាំងពីរនេះ លោកពោលទុកដោយអំណាចនៃទេសនា ដែលមានលំអ តាមអធ្យាស្រ័យរបស់ពួកសត្វអ្នកនឹងត្រាស់ដឹង ដោយប្រការនោះ និងដោយអំណាចនៃការដឹងបែកខ្ញរខ្លាយទៅក្នុងនិរុត្តិបដិសម្ភិទា ៕*

ចប់សហជាតវារៈ

..............................

### ៣.បច្ចយវារៈ

### ១.ពណ៌នាអំពីបច្ចយានុលោមន័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***បច្ចយវារៈ*** *ដូចតទៅ ៖*

*ពាក្យថា* **“កុសលំ ធម្មំ បច្ចយា** = *គឺជាសភាពតាំងនៅក្នុងកុសល-ធម៌”* *អធិប្បាយថា ធ្វើកុសលធម៌ឲ្យជាបច្ច័យ ព្រោះអត្ថថា ជាទីពំនាក់អាស្រ័យ ។ ពាក្យថា* **“កុសលំ ឯកំ ខន្ធំ បច្ចយា”** *មានពាក្យអធិប្បាយថា ខន្ធ ៣ ធ្វើកុសលក្ខន្ធ ១ ឲ្យជាទីពំនាក់អាស្រ័យកើតឡើង ព្រោះហេតុ-ប្បច្ច័យ ។ ក្នុងគ្រប់ៗបទ បណ្ឌិតគប្បីជ្រាបសេចក្តី ដោយឧបាយដូចគ្នានេះដែរ ។ ពាក្យថា* ***“ខន្ធដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ”*** *នេះ*

កើតឡើង ព្រោះអាស្រ័យវត្ថុ; ព្រះមានព្រះភាគទ្រង់ត្រាស់ដោយអំណាចនៃបវត្តិកាល ក្នុងបញ្ចវោការភព ។ ពិតមែនហើយ ក្នុងបវត្តិកាលក្នុងបញ្ចវោការភព វត្ថុដែលជាបុរេជាត ជានិស្សយប្បច្ច័យដល់ខន្ធទាំងឡាយ ។ ប៉ុន្តែ ព្រោះ **បដិច្ច** សព្ទ ដែលមានន័យសេចក្តីស្មើគ្នានឹងសហជាត ក្នុង **បដិច្ចវារៈ** ទើបមិនបានន័យដូច្នេះ, ព្រោះហេតុដូច្នោះ ទើបព្រះអង្គត្រាស់ថា **"វត្ថុំ បដិច្ច ខន្ធា** = ខន្ធទាំងឡាយកើតឡើង ព្រោះអាស្រ័យវត្ថុ" ដូច្នេះ សំដៅយកវត្ថុដែលជាសហជាតប៉ុណ្ណោះ ក្នុងបដិសន្ធិកាល ។ សូម្បីក្នុងពាក្យថា "ខន្ធ ៣ កើតឡើង ព្រោះអាស្រ័យកុសលក្ខន្ធ ១ និងវត្ថុរូប" ជាដើម បណ្ឌិតគប្បីជ្រាបសេចក្តីដោយន័យនេះដូចគ្នាចុះ ។ ពាក្យថា "កុសល និងអព្យាកតៈកើតឡើង ព្រោះអាស្រ័យអព្យាកតធម៌" លោកពោលសំដៅយកការកើតព្រមគ្នារវាងកុសល និងអព្យាកតៈ ដោយអំណាចនៃហេតុប្បច្ច័យ ។ ពិតមែនហើយ ក្នុងខណៈកុសលចិត្តកើតឡើង កុសលក្ខន្ធទាំងឡាយ អាស្រ័យវត្ថុរូបហើយកើត និងឧបាទាយរូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យមហាភូតរូបដែលមានចិត្តជាសមុដ្ឋាន កើតឡើងព្រមគ្នាដោយអំណាចនៃហេតុប្បច្ច័យ ។ សូម្បីកាលអព្យាកតធម៌ជាបច្ច័យដែលមានអត្ថប្លែកផ្សេងគ្នា បណ្ឌិតគប្បីជ្រាបពាក្យនេះថា លោកពោលសំដៅយកការកើតព្រមគ្នានៃបច្ចយុប្បន្ន ដោយអំណាចនៃហេតុប្បច្ច័យ,

ក្នុងឋានដទៃដែលមានយ៉ាងនេះ ក៏មានន័យដូចគ្នានេះដែរ ។

ក្នុង ***ហេតុប្បច្ច័យ*** នេះ លោកវិសជ្ជនាបញ្ហា ១៧ វារៈ ព្រោះធ្វើសហជាត និងបុរេជាត ឲ្យជាបច្ច័យ ដោយអត្ថថា ជាទីពំនាក់អាស្រ័យដោយប្រការដូច្នេះ ។ ក្នុងបញ្ហានោះ លោកកាន់យកខន្ធទាំងឡាយ និងមហាភូតរូប ដោយអំណាចនៃសហជាតប្បច្ច័យ, កាន់យកវត្ថុរូបដោយអំណាចនៃសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យ ។ ចំណែកនៅក្នុងបដិច្ចវារៈ រមែងបានបច្ច័យដោយអំណាចនៃសហជាត, ព្រោះហេតុដូច្នោះក្នុងទីនោះ ទើបលោកវិសជ្ជនាបញ្ហាទុក ៩ វារៈប៉ុណ្ណោះ ។

ក្នុងបច្ចយវារៈនោះ ធម៌ណា មានបញ្ហា ១៧ វារៈ ដែលព្រះមានព្រះភាគទ្រង់វិសជ្ជនាហើយ, ក្នុងធម៌ទាំងនោះ មានកុសលធម៌ជាដើមក្នុងការវិសជ្ជនាដែលមានបទដើមមួយបទ, បទអវសាន ក៏មានមួយបទបានបច្ចយុប្បន្នតែម្យ៉ាង អំពីបច្ច័យដូចគ្នា ។ ក្នុងការវិសជ្ជនាដែលមានបទដើមមួយបទ បទអវសាន ២ បទ បានបច្ចយុប្បន្នផ្សេងគ្នា ឯបច្ច័យដូចគ្នា ។ ក្នុងការវិសជ្ជនាដែលមានបទដើម ២ បទ បទអវសាន ១ បទបានបច្ចយុប្បន្នតែម្យ៉ាងដូចគ្នា អំពីបច្ច័យដែលផ្សេងគ្នា ។ ក្នុងការវិសជ្ជនាដែលមានបទដើម ២ បទ, បទអវសាន ២ បទ បានបច្ចយុប្បន្នផ្សេងគ្នាអំពីបច្ច័យដែលផ្សេងគ្នា ។ សូម្បីក្នុងអារម្មណប្បច្ច័យជាដើម គប្បីជ្រាបការចែកបញ្ហា និងវិសជ្ជនា ដោយឧបាយនេះចុះ ។

*ពាក្យណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុង **អារម្មណប្បច្ច័យ** ថា **"ខន្ធទាំងឡាយ រមែងកើតឡើង ព្រោះអាស្រ័យវត្ថុ"** , ពាក្យនោះ លោកសំដៅយកចំពោះវិបាកក្ខន្ធក្នុងបដិសន្ធិកាលប៉ុណ្ណោះ; ចក្ខុវិញ្ញាណជាដើម លោកពោលទុកដើម្បីសម្ដែងប្រភេទនៃធម៌ទាំងឡាយ ដែលអាស្រ័យអព្យាកតៈហើយកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ ពាក្យថា* **"វត្ថុំ បច្ចយា** *= អាស្រ័យវត្ថុ" ព្រះអង្គត្រាស់ទុកទៀត ដើម្បីសម្ដែងការកើតឡើងនៃវិបាកាព្យាកតៈ និងកិរិយាក្នុងបវត្តិកាល ។ (ពោលដោយអាស្រ័យវត្ថុ) ពាក្យដែលនៅសល់ គប្បីជ្រាបដោយន័យមុននោះចុះ ។*

*ក្នុង **អារម្មណប្បច្ច័យ** នេះ លោកវិសជ្ជនាទុក ៧ បញ្ហា ព្រោះលើកសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យឡើងជាបច្ច័យ ដោយប្រការដូច្នេះ ។ ក្នុងបញ្ហាទាំងនោះ ខន្ធទាំងឡាយ លោកកាន់យកដោយអំណាចនៃសហជាត, វត្ថុកាន់យកដោយអំណាចនៃសហជាត និងបុរេជាត, ចក្ខាយតនៈជាដើម កាន់យកដោយអំណាចនៃបុរេជាត; ចំណែកក្នុងបដិច្ចវារៈ រមែងបានបច្ច័យ ដោយអំណាចនៃសហជាតប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ក្នុងវារៈនោះ ទើបវិសជ្ជនាទុក ៣ បញ្ហាប៉ុណ្ណោះ ។*

*ក្នុង **អធិបតិប្បច្ច័យ** គប្បីជ្រាបថា បានដល់ វិបាកាព្យាកតៈដែលជាលោកុត្តរប៉ុណ្ណោះ ។ **អនន្តរប្បច្ច័យ** និង **សមនន្តរប្បច្ច័យ** ដូចគ្នានឹង*

អារម្មណប្បច្ច័យដែរ ព្រោះមិនមានរូប ។ សូម្បីក្នុង ***អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ*** និង ***វិគតប្បច្ច័យ*** ខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។

ក្នុង ***សហជាតប្បច្ច័យ*** ពីរបទថា **“ កដត្តារូបំ ឧបាទារូបំ ”** បានដល់ កដត្តារូប ពោលគឺឧបាទាយរូប ។ ពាក្យនេះ លោកសំដៅយករូបនៃ អសញ្ញសត្វមួយពួកប៉ុណ្ណោះ ។ ចក្ខាយតនៈជាដើម ពោលដោយអំណាច នៃបញ្ចវោការភព ។

ក្នុង ***អញ្ញមញ្ញប្បច្ច័យ*** លោកពោលសំដៅយកបញ្ហាដែលមានវិសជ្ជនា ស្មើគ្នាថា ដូចធម៌ដែលកើត, តែក្នុងបច្ចុប្បន្នធម៌ មានសេចក្តីផ្សេងគ្នា ព្រោះអារម្មណប្បច្ច័យ ។

បទថា **“ អារម្មណបច្ចយសទិសំ ”** ក្នុងឧបនិស្សយប្បច្ច័យ លោក ពោលទុក ព្រោះមានវិសជ្ជនាស្មើគ្នា ដោយសេចក្តីមិនមានរូបខ្លះ ។

ពាក្យថា **“ ឥត្ថិំ បុរេជាតបច្ចយា ”** ជាដើម គប្បីកាន់យកសេចក្តី តាមន័យដែលពោលហើយក្នុងបដិច្ចវារៈ ។

ក្នុង ***កម្មប្បច្ច័យ*** បទថា **“ តីណិ ”** បណ្ឌិតគប្បីជ្រាបនូវវិសជ្ជនា ៣ វារៈយ៉ាងនេះ គឺកុសលកើត ព្រោះអាស្រ័យកុសល ១, អព្យាកតៈកើត ព្រោះអាស្រ័យកុសល ១, កុសល និងអព្យាកតៈកើត ព្រោះអាស្រ័យ កុសល ១ ។ សូម្បីក្នុងអកុសលជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក្នុង ***វិប្បយុត្តប្បច្ច័យ*** ពីរបទថា **"ខន្ធេ វិប្បយុត្តប្បច្ចយា"** សេចក្ដីថា ធម៌ទាំងឡាយ អាស្រ័យខន្ធទាំងឡាយ កើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យថា **"ខន្ធា វត្ថុំ វិប្បយុត្តប្បច្ចយា"** សេចក្ដីថា ខន្ធទាំងឡាយ អាស្រ័យវត្ថុ កើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ។ ពាក្យដែលនៅសល់ គប្បីជ្រាបសេចក្ដីតាមន័យដែលពោលហើយអំពីខាងដើម ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ថា **"ហេតុយា សត្តរស** = ក្នុងហេតុប្បច្ច័យ មាន ១៧ វារៈ" ជាដើម ដើម្បីសម្ដែងវិសជ្ជនា តាមដែលរកបានដោយអំណាចនៃការរាប់ចំនួន ។ បណ្ដាបទទាំងនោះ ពីរបទថា **"ហេតុយា សត្តរស"** សេចក្ដីថា ព្រះមានព្រះភាគត្រាស់វិសជ្ជនាទុក ៣ វារៈ គឺបទដើម ១ បទ និងបទអវសាន ១ បទ មាន ៧ វារៈ, បទដើម ២ បទ និងបទអវសាន ១ បទ មាន ១ វារៈ ដោយអំណាចនៃកុសលយ៉ាងនេះ គឺកុសលជាមួយកុសល, អព្យាកតៈជាមួយកុសល, កុសល និងអព្យាកតៈជាមួយកុសល ។ វិសជ្ជនាដោយអំណាចនៃអកុសល ក៏ដូចគ្នាជាមួយនឹងកុសលដែរ ។ អព្យាកតៈជាមួយអព្យាកតៈ, កុសលជាមួយអព្យាកតៈ, អកុសលជាមួយអព្យាកតៈ, កុសល និងអព្យាកតៈជាមួយអព្យាកតៈ, អកុសល និងអព្យាកតៈជាមួយអព្យាកតៈ, កុសលជាមួយកុសល និងអព្យាកតៈ, អព្យាកតៈជាមួយកុសល និងអព្យាកតៈ, កុសល និងអព្យាកតៈជាមួយកុសល និងអព្យាកតៈ, អកុសល ជាមួយអកុសល

និងអព្យាកតៈ, អព្យាកតៈជាមួយអកុសល និងអព្យាកតៈ, អកុសល និង អព្យាកតៈជាមួយអកុសល និងអព្យាកតៈ; បណ្ឌិតគប្បីជ្រាបបទ ក្នុងហេតុ-ប្បច្ច័យ មាន ១៧ វារៈ យ៉ាងនេះឯង ។

ក្នុងពាក្យថា **“អារម្មណេ សត្ត** = ក្នុងអារម្មណប្បច្ច័យ មាន ៧ វារៈ” សេចក្តីថា មានវិសជ្ជនា ៧ វារៈ យ៉ាងនេះ គឺកុសលជាមួយកុសល, អកុសលជាមួយអកុសល, អព្យាកតៈជាមួយអព្យាកតៈ, កុសលជាមួយអព្យាកតៈ, អកុសលជាមួយអព្យាកតៈ, កុសល ជាមួយកុសល និងអព្យាកតៈ, អកុសលជាមួយអកុសល និងអព្យាកតៈ ។ បទថា **“ឯកំ”** ក្នុង ***វិបាកប្បច្ច័យ*** គឺអព្យាកតៈជាមួយអព្យាកតៈនោះឯង ។ ការកំណត់វារៈ ៣ ប្រការ គឺ ១៧ វារៈ, ៧ វារៈ, ១ វារៈ ក្នុងអនុលោមន័យ, បច្ចយវារៈ រមែងមានដោយប្រការដូច្នេះ ។ ក្នុងបណ្តាវារៈទាំងនោះ បណ្ឌិតកំណត់វារៈទាំងអស់នោះ គឺពួក ១៧ វារៈ មាន ១២ បច្ច័យ, ពួក ៧ វារៈ មាន ១០ បច្ច័យ, ពួក ១ វារៈ មាន ១ បច្ច័យ ឲ្យល្អហើយ គប្បីជ្រាបចំនួនដោយអំណាចនៃចំនួនដែលតិចជាង ក្នុងការប្រៀបធៀបបច្ច័យ ដោយអំណាចនៃទុកត្តិកប្បដ្ឋានជាដើមខាងមុខចុះ ។ ពិតមែនហើយ ដោយវិធីគណនាចំនួននេះ បណ្ឌិតអាចជ្រាបការកំណត់វារៈ ក្នុងន័យទាំងឡាយ មានទុកមូលកន័យជាដើមបាន ព្រោះហេតុដូច្នោះ ដើម្បីនឹងសម្តែង

ការកំណត់វារៈ ដោយអំណាចនៃការរាប់ចំនួនប៉ុណ្ណោះ មិនប៉ះពាល់ទៅដល់ (បទវិសជ្ជនា) ថា **“កុសលធម៌កើតឡើង ព្រោះអាស្រ័យ កុសលធម៌”** ទៀតទេ ទើបព្រះអង្គទ្រង់ផ្ដើមពាក្យថា **“ហេតុប្បច្ចយា អារម្មណេ សត្ត** = ព្រោះហេតុប្បច្ច័យក្នុងអារម្មណប្បច្ច័យ មាន ៧ វារៈ” ជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា កុសលធម៌រមែងកើត ព្រោះអាស្រ័យកុសលធម៌ ដោយហេតុប្បច្ច័យ និងអារម្មណប្បច្ច័យ ។ បណ្ឌិតគប្បីអធិប្បាយវិសជ្ជនា ដែលបានក្នុងអារម្មណប្បច្ច័យ ឲ្យពិស្ដារចេញទៅ ដោយន័យនេះថា “ខន្ធ ៣ អាស្រ័យកុសលខន្ធ ១ ហើយកើតឡើង” ; ន័យនៅនេះជាក្នុងអនុលោមន័យ មានប្រមាណប៉ុណ្ណោះ ៕

ចប់បច្ចយានុលោមន័យ

....................................

## ២.ពណ៌នាអំពីបច្ចយបច្ចនីយន័យ

កុសលធម៌ រមែងមិនបានក្នុងបច្ចនីយន័យ ព្រោះហេតុដូច្នោះ ទើបលោកផ្ដើមវិសជ្ជនាតាំងអំពីអកុសលជាដើមតទៅថា **“អកុសលំ ធម្មំ បច្ចយា”** ដូច្នេះ ។ ពាក្យវិសជ្ជនានោះ រមែងមានដំណើរទៅតាមបាលីប៉ុណ្ណោះ ។ ក៏ពាក្យដែលនឹងគប្បីពោលក្នុងវារៈនេះ បានពោលទុករៀបរយហើយ ក្នុងបច្ចនីយន័យនៃបដិច្ចវារៈ ។ លោកពោលពាក្យថា **“នហេតុយា ចត្តារិ** =

*ក្នុងនហេតុប្បច្ច័យ មាន ៤ វារៈ” ជាដើម ដើម្បីសម្ដែងចំនួនវិសជ្ជនា ដែលបានក្នុងបច្ចនីយន័យយ៉ាងណា ទុកក្នុងវិសជ្ជនានោះ មានការកំណត់ ៦ យ៉ាង គឺវិសជ្ជនា ៤ វារៈ, ១៧ វារៈ, ៧ វារៈ, ៥ វារៈ, ៣ វារៈ និង ១ វារៈ ក្នុងការប្រៀបធៀបបច្ច័យដែលមានមូល ២ និងមូល ៣ ជាដើម គប្បីជ្រាបការរាប់ដោយអំណាចនៃការកំណត់ទាំងនោះ ព្រោះថា បច្ច័យណា* * *ដែលបានវិសជ្ជនាដល់ ១៧ វារៈ, ព្រោះប្រៀបធៀបជាមួយបច្ច័យ ដែលដូចគ្នាជាមួយនឹងបច្ច័យនោះដែរ ។ ការកំណត់ចំនួនបានសូម្បីទាំង ៦ យ៉ាងដែលនៅសល់ ក៏ព្រោះប្រៀបធៀបជាមួយបច្ច័យ ដែលមិនមានចំនួនទាបជាង ។ សូម្បីការកំណត់ចំនួនដែលនៅសល់ ក៏យ៉ាងនេះដែរ ។ កាលវៀរចាកនូវការកំណត់ចំនួនដែលខ្ពស់ជាង ក៏រមែងបានចំនួនដែលស្មើគ្នា និងទាបជាងគ្នា; ក្នុងសេចក្ដីនេះ នឹងមិនបានការកំណត់ចំនួនដែលខ្ពស់ជាងដូច្នោះទេ, នេះទើបជាបញ្ហានិយមក្នុងរឿងកំណត់នេះ ។ ក៏ចំនួនដែលស្មើគ្នា និងចំនួនដែលទាបជាងគ្នា កាលបើមានសេចក្ដីខុសប្លែកគ្នា ក៏គ្មានន័យឡើយ ។ ព្រោះហេតុដូច្នោះ ក្នុងរឿងនេះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* **“នហេតុប្បច្ចយា នារម្មណេ ឯកំ** *= ព្រោះ*

---

* អដ្ឋកថាបាលីខ្លះថា **នោ** ច្បាប់ដទៃទៀតថា **យោ** ប្រែតាមច្បាប់ដទៃ ព្រោះត្រូវតាមសភាវៈ ។

នហេតុប្បច្ច័យ ក្នុងអារម្មណប្បច្ច័យ មាន ១ វារៈ” ជាដើម ។ សេចក្ដីពិត ក្នុងរឿងនេះ គួរនឹងមានពាក្យពោលថា វិសជ្ជនា ៤ វារៈ គួរបានដោយអំណាចនៃនហេតុប្បច្ច័យ ព្រោះព្រះបាលីមានមកហើយថា ក្នុងនហេតុ-ប្បច្ច័យ មាន ៤ វារៈ ក្នុងនអារម្មណប្បច្ច័យ មាន ៥ វារៈ ។ ប៉ុន្តែព្រោះវិសជ្ជនាទាំងនោះ បញ្ចូលគ្នាជាមួយនឹងនារម្មណធម៌, សារម្មណធម៌ ទើបខុស ព្រោះហេតុដូច្នោះ វិសជ្ជនា ៣ វារៈ ទើបបន្ថយចុះទៅ គឺ អកុសលធម៌ អាស្រ័យអកុសលធម៌ហើយកើតឡើង, អកុសលធម៌ អាស្រ័យអព្យាកតធម៌ហើយកើតឡើង, អកុសលធម៌ អាស្រ័យអកុសលធម៌ និងអព្យាកតធម៌ហើយកើតឡើង ។ វិសជ្ជនា ១ វារៈប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃរូបថា “អព្យាកតធម៌អាស្រ័យ អព្យាកតធម៌ហើយកើតឡើង” ។ បណ្ឌិតកាលជ្រាបវិសជ្ជនាដែលខុសប្លែកពីគ្នា ក្នុងបច្ច័យទាំងអស់ហើយ គប្បីជ្រាបការកំណត់ដែលនឹងមានដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ មានការសម្តែងត្រឹមតែន័យដូចតទៅ ៖

ពីរបទថា “**នាធិបតិយា ចត្តារិ** = ក្នុងនអធិបតិប្បច្ច័យ មាន ៤ វារៈ” គឺវិសជ្ជនាបានហើយ ក្នុងវិសជ្ជនា នហេតុប្បច្ច័យ ។ សូម្បីនៅក្នុងចតុក្កៈដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា “**នានន្តរេ ឯកំ** = ក្នុង ***អនន្តរប្បច្ច័យ*** មាន ១ វារៈ” គឺអព្យាកតៈជាមួយ

*អព្យាកតៈ ដោយអំណាចនៃរូបដែលមានអហេតុកចិត្តជាសមុដ្ឋាន និងរូបដ៏សេស ។ បណ្ឌិតគប្បីជ្រាបរូបដែលប្រកបបាន ក្នុងបច្ច័យនីមួយៗទាំងអស់ យ៉ាងនេះចុះ ។ សូម្បីក្នុងពាក្យថា* **"នបុរេជាតេ ទ្វេ** *= ក្នុងនបុរេជាតប្បច្ច័យ មាន ២ វារៈ" នេះ ក៏គួរនឹងពោលថា បានវិសជ្ជនា ៨ វារៈ ដោយអំណាចនៃនហេតុប្បច្ច័យ ។ ប៉ុន្តែ ព្រោះនហេតុប្បច្ច័យបញ្ចូលគ្នាបានជាមួយនឹង នបុរេជាតប្បច្ច័យ និងវិសជ្ជនា ២ វារៈ ដោយអំណាចនៃវត្ថុបុរេជាតថា "អកុសលកើតឡើង ព្រោះអាស្រ័យអព្យាកតធម៌, អកុសលកើតឡើង ព្រោះអាស្រ័យអកុសល និងអព្យាកតៈ" ដូច្នេះ ត្រូវបន្ថយទៅ ។ ចំណែកក្នុងអរូបភព លោកវិសជ្ជនាទុក ២ វារៈ ដោយអំណាចនៃអហេតុកមោហៈ និងអហេតុកកិរិយា ។ ពីរបទថា* **"នវិប្បយុត្តេ ទ្វេ** *= ក្នុងនវិប្បយុត្តប្បច្ច័យ មាន ២ វារៈ" គឺវិសជ្ជនា ២ វារៈ ដោយអំណាចនៃអហេតុកអកុសល និងអហេតុកកិរិយា ក្នុងអរូបភព ។ ក្នុង* **នោនត្ថិ នោវិគតេ** *ពាក្យថា* **"ឯកំ** *= ១" គប្បីជ្រាបថា បានដល់អព្យាកតៈជាមួយនឹងអព្យាកតៈ ដោយអំណាចនៃរូបទាំងអស់ ។ ក្នុងបច្ច័យដែលមានមូល ៣ ជាដើម សម្តែងទុកអស់ហើយ ។ ចំណែកក្នុង* ***នារម្មណ-ទុមូលកន័យ*** *ពាក្យថា* **"នាធិបតិយា បញ្ច** *= ក្នុងនអធិបតិប្បច្ច័យ មាន ៥ វារៈ" គឺវិសជ្ជនាដែលបានក្នុងនអារម្មណប្បច្ច័យនោះឯង ។ ក្នុងពាក្យថា* **"នកម្មេ ឯកំ** *= ក្នុងនកម្មប្បច្ច័យ មាន ១ វារៈ" នេះ បណ្ឌិតមិនគប្បី*

*កាន់យកចិត្តជរូប និងកម្មជរូបឡើយ, គប្បីជ្រាបចំពោះអព្យាកតៈជាមួយអព្យាកតៈដោយអំណាចនៃរូបដែលនៅសល់ ។ ក្នុង* ***នាធិបតិមូលកន័យ*** *ពាក្យថា* **“នបុរេជាតេ សត្ត** *= ក្នុងនបុរេជាតប្បច្ច័យ មាន ៧ វារៈ”* *គឺវិសជ្ជនាដែលបានក្នុងនបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ ពាក្យថា* **“នបច្ឆាជាតេ សត្តរស** *= ក្នុងនបច្ឆាជាតប្បច្ច័យ មាន ១៧ វារៈ” បានដល់វិសជ្ជនា ១៧ វារៈ ក្នុងបច្ឆាជាតប្បច្ច័យប៉ុណ្ណោះ ។ វិសជ្ជនាដែលមាននអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ នសម្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ នោវិគតប្បច្ច័យ ជាមូលដូចគ្នានឹងបច្ច័យដែលមាន* ***នអារម្មណប្បច្ច័យជាមូល*** *ដែរ ។ វិសជ្ជនាដែលកន្លងមកហើយ និងនៅមិនទាន់មកដល់ វិសជ្ជនាដែលមាន និងមិនមានក្នុងបច្ច័យទាំងអស់ គប្បីជ្រាបដោយការសម្តែងត្រឹមតែន័យនេះប៉ុណ្ណោះចុះ ៕*

ចប់បច្ចយបច្ចនីយន័យ

---

## ៣.ពណ៌នាអំពី

## អនុលោមបច្ចនីយន័យ បច្ចនីយានុលោមន័យ

*ដោយលក្ខណៈនេះពិតៗ អ្នកសិក្សាគប្បីចាត់អនុលោមទុកខាងមុខ ហើយកំណត់ចំនួនក្នុង* ***អនុលោមបច្ចនីយ,*** *និងគប្បីចាត់បច្ចនីយទុកខាងមុខ*

*ហើយកំណត់ **បច្ចនីយានុលោម** និងគប្បីជ្រាបវិសជ្ជនាក្នុងបញ្ហា ដែលកន្លងមកហើយ និងនៅមិនទាន់មានមក, ដែលវិសជ្ជនាបាន និងវិសជ្ជនាមិនបានដូច្នេះ ៗ*

ចប់អនុលោមបច្ចនីយន័យ

បច្ចនីយានុលោមន័យ

ចប់បច្ចយវារៈ

............................

## ៤.និស្សយវារៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង **និស្សយវារៈ** តទៅ ៖*

*ពាក្យថា “**កុសលំ ធម្មំ និស្សាយ** = អាស្រ័យកុសលធម៌” អធិប្បាយថា ព្រោះការធ្វើកុសលធម៌ឲ្យជាទីពំនាក់អាស្រ័យ ដោយអត្ថថាជាបច្ច័យ ។ ពាក្យដែលនៅសល់ក្នុងនិស្សយវារៈនេះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងបច្ចយវារៈនោះឯង ។ ក្នុងអវសាននៃបច្ច័យនេះ ពាក្យថា “ក៏អត្ថថា **បច្ច័យ** មានន័យស្មើគ្នាជាមួយនឹងនិស្សយៈ, ក៏អត្ថថា **និស្ស័យ** មានន័យសេចក្តីស្មើគ្នាជាមួយនឹងបច្ច័យ” ដូច្នេះនេះ, លោកពោលទុកដើម្បីសម្តែងសេចក្តីមិនផ្សេងគ្នា ដោយសេចក្តីនៃវារៈទាំងពីរនេះ ។ ពិតមែនហើយ ដោយសេចក្តីនៃវារៈទាំងពីរនេះ មិនមានអ្វីប្លែក*

ផ្សេងគ្នា ដូចបដិច្ចវារៈ និងសហជាតវារៈឡើយ ។ សូម្បីកាលបើយ៉ាងនេះ លោកក៏ពោលទុកដើម្បីបញ្ជាក់សេចក្តីរបស់គ្នានឹងគ្នា ។ ពិតមែនហើយ ក្នុងពាក្យមានជាអាទិ៍ថា “**អវិជ្ជាបច្ចយា សង្ខារា** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ” ព្រះមានព្រះភាគត្រាស់ទុកថា “បច្ច័យទាំងឡាយ សូម្បីមិនត្រូវអាស្រ័យនានាក្ខណិកកម្មប្បច្ច័យ ដែលកំពុងប្រព្រឹត្តទៅ ក៏កើតឡើងបាន” ។ បណ្តាឈើដែលតាំងនៅអាស្រ័យគ្នាជាដើម ឈើមួយមិនបានជានិស្សយប្បច្ច័យដល់ឈើមួយទៀតទេ, ដូចជាឧបាទាយរូប ក៏មិនជានិស្សយប្បច្ច័យដល់មហាភូតរូបដូច្នោះដែរ ។ សូម្បីវារៈទាំងពីរនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដើម្បីកំណត់សេចក្តីជានិស្សយប្បច្ច័យ ដោយបច្ចយវារៈ និងដើម្បីកំណត់សេចក្តីជាសហជាត និងបុរេជាតនៃធម៌ដែលព្រះអង្គត្រាស់ថា “**បច្ចយា**” ដោយនិស្សយវារៈ ។ ប្រការមួយទៀត វារៈទាំងពីរនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដើម្បីជាការលំអនៃទេសនា ដោយអំណាចនៃអធ្យាស្រ័យរបស់ពពួកសត្វដែលត្រូវត្រាស់ដឹងដោយប្រការនោះ និងដោយអំណាចនៃព្រះប្រាជ្ញាបែកខ្ញរខ្ញាយក្នុងនិរុត្តិបដិសម្ភិទា ៕

## ចប់និស្សយវារៈ

## ៥.សំសដ្ឋវារៈ

## ១.ពណ៌នាអំពីអនុលោមន័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***សំសដ្ឋវារៈ*** *ដូចតទៅ ៖*

*ពាក្យថា* **“កុសលំ ធម្មំ សំសដ្ឋោ** *= ប្រឡូកប្រឡំជាមួយកុសលធម៌”* *អធិប្បាយថា ព្រោះធ្វើកុសលធម៌ឲ្យជាបច្ច័យ ដោយអត្ថថា ប្រកបព្រមដោយលក្ខណៈ ដែលមានការកើតឡើងព្រមគ្នាជាដើម ។ ពាក្យថា* **“កុសលំ ឯកំ ខន្ធំ សំសដ្ឋា”** *មានពាក្យអធិប្បាយថា ខន្ធ ៣ ញ៉ាំងកុសលក្ខន្ធមួយ ឲ្យជាសម្បយុត្តប្បច្ច័យកើតឡើង ព្រោះហេតុប្បច្ច័យ ។ គ្រប់ៗបទ គប្បីជ្រាបសេចក្ដីដោយឧបាយនេះចុះ ។ រីឯក្នុងហេតុប្បច្ច័យនេះ លោកចាត់បច្ច័យហើយវិសជ្ជនាបញ្ហាទុក ៣ វារៈ ព្រោះអរូបធម៌ប៉ុណ្ណោះ ដែលនឹងមានអត្ថថា សម្បយោគបាន ។ ក៏ក្នុងហេតុប្បច្ច័យយ៉ាងណា, សូម្បីក្នុងអារម្មណប្បច្ច័យជាដើម ក៏ដូច្នោះដែរ ។ ក្នុងវិបាកប្បច្ច័យ មានវិសជ្ជនា ១ វារៈប៉ុណ្ណោះ ។*

*ឥឡូវនេះ ដើម្បីនឹងសម្ដែងវិសជ្ជនាតាមដែលបាន ដោយអំណាចនៃចំនួន ទើបព្រះមានព្រះភាគត្រាស់ថា* **“ហេតុយា តីណិ** *= ក្នុងហេតុប្បច្ច័យ មាន ៣ វារៈ”* *ជាដើម; ក្នុងវិសជ្ជនាទាំងនោះ លោកកំណត់ទុកក្នុងតិកៈទាំងពួងដូច្នេះ គឺកុសលជាមួយកុសល, អកុសល ជាមួយអកុសល និងអព្យាកតៈ ជាមួយអព្យាកតៈ ។ ក្នុងតិកៈនីមួយៗ រមែងបានអព្យាកតៈ*

*ជាមួយអព្យាកតៈប៉ុណ្ណោះ ។ ក្នុងវារៈនេះ មានការកំណត់ ២ យ៉ាង គឺ ក្នុងបច្ច័យ ២២ មានវិសជ្ជនា ៣ វារៈ, ក្នុងវិបាកប្បច្ច័យ មានវិសជ្ជនា ១ វារៈ ដោយប្រការដូច្នេះឯង ។ វិសជ្ជនាដែលជាអនុលោម រមែងមិនមាន ក្នុងបច្ចាជាតប្បច្ច័យទេ; ព្រោះហេតុដូច្នោះ ក្នុងការប្រៀបធៀបបច្ច័យក្នុង ទុកត្តិកៈជាដើម ដោយអំណាចនៃវិសជ្ជនាទាំងនេះថា " វិសជ្ជនា ៣ និង វិសជ្ជនា ១" ដូច្នេះ វិបាកប្បច្ច័យបញ្ចូលក្នុងទុកត្តិកៈបាន ទុកត្តិកៈនោះ មានវិសជ្ជនា ១ ។ គប្បីជ្រាបការរាប់ចំនួនយ៉ាងនេះថា* **"តីណិ = ៣"** *ក្នុងបច្ច័យដែលនៅសល់ (គប្បីជ្រាបការគណនាចំនួនយ៉ាងនេះថា ក្នុងបច្ច័យ ដែលនៅសល់ មានវិសជ្ជនា ៣ វារៈ) ។ ពាក្យដែលនៅសល់ ក្នុង អនុលោមន័យ ក្នុងសំសដ្ឋវារៈនេះ មានសេចក្ដីងាយស្រួលហើយមែនពិត ៕*

ចប់អនុលោមន័យ

.............................

## ២.ពណ៌នាអំពីបច្ចនីយន័យ

*កុសលរមែងមិនបានក្នុង* ***បច្ចនីយន័យ*** *ព្រោះហេតុដូច្នោះ ទើប លោកចាប់ផ្ដើមវិសជ្ជនាតាំងអំពីអកុសលជាដើមទៅ ។ វិសជ្ជនានោះ មាន សេចក្ដីភ្លឺច្បាស់ហើយ ។ ពាក្យថា* **" នហេតុយា ទ្វេ** *= ក្នុងនហេតុ- ប្បច្ច័យ មាន ២ វារៈ" ជាអាទិ៍នោះ យ៉ាងណា, ដែលលោកពោលទុក*

ដើម្បីការកំណត់វិសជ្ជនាក្នុងបច្ចនីយន័យ ដោយការគណនាចំនួន, ក្នុងពាក្យនោះ មានការកំណត់ (បរិច្ឆេទ) ៣ យ៉ាង គឺ **ទ្វេ** = ២, **តីណិ** = ៣, **ឯកំ** = ១ ។ បណ្ឌិតគប្បីជ្រាបការគណនាចំនួន ព្រោះការប្រៀបធៀបបច្ច័យក្នុងទុកត្តិកៈជាដើម ដោយអំណាចនៃបរិច្ឆេទទាំងនោះ ។ សូម្បីក្នុងអធិការនេះ ក៏រមែងបានចំពោះវិសជ្ជនាដែលមានការគណនាបានតិចជាង ព្រោះប្រៀបធៀបបច្ច័យដែលគណនាបានច្រើនជាង ជាមួយនឹងបច្ច័យដែលគណនាបានតិចជាង ។ រមែងបានវិសជ្ជនាដែលមានចំនួនស្មើគ្នា ព្រោះប្រៀបធៀបជាមួយបច្ច័យដែលគណនាចំនួនបានស្មើគ្នា ។ ក៏ព្រោះតែក្នុងវារៈនេះ មានអរូបធម៌ប៉ុណ្ណោះ ជាបច្ចយុប្បន្ន, ព្រោះហេតុដូច្នោះ ទើបលោកសម្តែងបច្ច័យ ១០ គឺនហេតុប្បច្ច័យ, នអធិបតិប្បច្ច័យ, នបុរេជាតប្បច្ច័យ, នបច្ឆាជាតប្បច្ច័យ, នអាសេវនប្បច្ច័យ, នកម្មប្បច្ច័យ, នវិបាកប្បច្ច័យ, នឈានប្បច្ច័យ, នមគ្គប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ ដោយសេចក្តីជាបច្ចនីកៈ ។ បច្ច័យដែលនៅសល់ ១៤ ទៀត រមែងមិនបាន ។ សូម្បីក្នុងបណ្តាបច្ច័យដែលមានទាំងនោះ នកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ រមែងមិនបានបច្ចយុប្បន្នដែលជាវិបាកទេ ។ ពាក្យថា **“នហេតុប្បច្ចយា នអធិបតិយា ទ្វេ** = ព្រោះនហេតុប្បច្ច័យ ក្នុងនអធិបតិប្បច្ច័យ មាន ២ វារៈ” គឺវិសជ្ជនា ២ ដែលបានក្នុងនហេតុប្បច្ច័យ ។ សូម្បីក្នុងពួក ២ នៃវិសជ្ជនាដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា **“នកម្មេ ឯកំ** = ក្នុងនកម្មប្បច្ច័យ មាន ១ វារៈ” គឺអព្យាកតៈ

*ជាមួយអព្យាកតៈ ព្រោះចាត់អហេតុកកិរិយាចេតនា ឲ្យជាបច្ចុប្បន្ន ។ ពីរបទថា* **“ នទិបាភេ ទ្វេ”** *សេចក្តីថា វិសជ្ជនា ២ ដោយអំណាចនៃអហេតុកមោហៈ និងអហេតុកកិរិយា ។ ពីរបទថា* **“ នឈានេ ឯកំ”** *គប្បីជ្រាបថា ជាអព្យាកតវិសជ្ជនា ដោយអំណាចនៃអហេតុកបញ្ចវិញ្ញាណ ។ ពីរបទថា* **“ នមគ្គេ ឯកំ”** *គប្បីជ្រាបអព្យាកតវិសជ្ជនា ដោយអំណាចនៃអហេតុកវិបាក និងកិរិយា ។ អ្នកសិក្សា គប្បីជ្រាបសេចក្តីក្នុងការប្រៀបធៀបបច្ច័យទាំងពួង ដោយឧបាយនេះឯង ៕*

ចប់បច្ចនីយន័យ

## ៣.ពណ៌នាអំពីអនុលោមបច្ចនីយន័យ

*ចំពោះបច្ច័យ ១០ មាន* ***នហេតុប្បច្ច័យ*** *ជាដើម ដែលពោលទុកអំពីខាងដើម ជាបច្ចនីយៈ ក្នុងអនុលោមបច្ចនីយន័យ; បច្ច័យដែលនៅសល់មិនបានទេ ។ សូម្បីក្នុងបច្ច័យដែលមាន ដែលតាំងនៅដោយអនុលោម ក្នុងហេតុប្បច្ច័យទាំងនោះ* ***ឈានប្បច្ច័យ និងមគ្គប្បច្ច័យ*** *រមែងមិនបានដោយបច្ចនីយៈ ។ ពាក្យទាំងពួង គប្បីជ្រាបដោយអំណាចនៃពាក្យដែលពោលហើយអំពីខាងដើម ៕*

ចប់អនុលោមបច្ចនីយន័យ

## ៤.ពណ៌នាអំពីបច្ចនីយានុលោមន័យ

*អហេតុកមោហៈប៉ុណ្ណោះ រមែងបានឈានប្បច្ច័យ និងមគ្គប្បច្ច័យ ក្នុងនហេតុប្បច្ចយុប្បន្ន និងក្នុងបច្ចនីយានុលោម ។ ធម៌ដែលនៅសល់ រមែងមិនបាន ។* ***នកម្មប្បច្ច័យ នហេតុប្បច្ច័យ នអធិបតិប្បច្ច័យ និង នបុរេជាតប្បច្ច័យ*** *អ្នកសិក្សាគប្បីជ្រាបថា រមែងបានអហេតុកចិត្ត ៨ ក្នុងនឈានប្បច្ច័យ ។ ពាក្យថា* **"អារម្មណេ ឯកំ** *= ក្នុងអារម្មណប្បច្ច័យ មាន ១ វារៈ"* *គឺអព្យាកតៈជាមួយអព្យាកតៈ ដោយអំណាចនៃអហេតុកកិរិយាចេតនាក្នុងអរូប ។ វិសជ្ជនាណា រមែងបាន និងមិនបាន ដោយឧបាយនេះ, បណ្ឌិតគប្បីជ្រាបវិធីគណនាចំនួន ក្នុងបច្ច័យទាំងពួង ដោយអំណាចនៃវិសជ្ជនានោះចុះ ៕*

ចប់បច្ចនីយានុលោមន័យ

ចប់សំសដ្ឋវារៈ

.....................

## ៦.សម្បយុត្តវារៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***សម្បយុត្តវារៈ*** *តទៅ ៖*

*ពាក្យថា* **"កុសលំ ធម្មំ សម្បយុត្តោ** *= ប្រកបជាមួយកុសលធម៌"*

សេចក្ដីថា ញ៉ាំងកុសលធម៌ឲ្យជាសម្បយុត្តប្បច្ច័យ ។ ពាក្យដែលនៅសល់ក្នុងវណ្ណនានេះ គប្បីជ្រាបតាមន័យដែលពោលទុកក្នុងសំសដ្ឋវារៈ ។ ចំណែកក្នុងទីបំផុតនៃសម្បយុត្តវារៈនេះ ពាក្យថា **“ក៏អត្ថថា សំសដ្ឋៈ** = ប្រឡូកប្រឡំ មានន័យសេចក្ដីស្មើគ្នានឹង **សម្បយុត្ត** = ប្រកប, ក៏អត្ថថា **សម្បយុត្ត** (ប្រកប) មានសេចក្ដីស្មើគ្នានឹង **សំសដ្ឋៈ** = ប្រឡូកប្រឡំ” ដូច្នេះ; ព្រះមានព្រះភាគត្រាស់ទុកដើម្បីសម្ដែងសេចក្ដីមិនផ្សេងគ្នា ដោយសេចក្ដីនៃវារៈទាំងពីរនេះ ។ ពិតមែនហើយ កាលបើពោលដោយសេចក្ដីនៃវារៈទាំងពីរនេះ មិនមានវារៈណាប្លែកផ្សេងគ្នាឡើយ ដូចជាបដិច្ចស័ព្ទជាមួយនឹងសហជាត និងបច្ចយៈ ជាមួយនិស្សយស័ព្ទដូច្នោះ; សូម្បីយ៉ាងនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដើម្បីកំណត់សេចក្ដីរបស់គ្នានឹងគ្នា ។ ពិតមែនហើយ ក្នុងពាក្យថា “សេះទាំងឡាយ ដែលគេយកមកទឹមបញ្ចូលគ្នាជាគូ” ជាដើម សូម្បីវត្ថុដែលមិនបានប្រកបគ្នា ក៏លោកហៅថា “សំសដ្ឋៈ” បានដែរ ។ ក្នុងពាក្យថា “វីមំសាណា សហគតៈហើយដោយកោសជ្ជៈ សម្បយុត្តហើយ ដោយកោសជ្ជៈ” ដូច្នេះជាដើម សូម្បីវត្ថុរបស់ដែលប្រឡូកប្រឡំគ្នា ក៏មកជាសម្បយុត្តបាន ។ វារៈទាំង ២ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដើម្បីសង្កត់ឲ្យធ្ងន់ដល់ភាវៈដែលសម្បយុត្តប្បច្ច័យ មានលក្ខណៈកើតក្នុងគ្រាជាមួយគ្នាជាដើម ជាសំសដ្ឋវារៈ និងដើម្បីសង្កត់ឲ្យធ្ងន់

*ដល់សំសដ្ឋធម៌ ដែលមានការកើតក្នុងគ្រាជាមួយគ្នាជាដើម ជាលក្ខណៈ ជាសម្បយុត្តប្បច្ច័យ ដោយសម្បយុត្តវារៈ ។ មួ៉ាងទៀត វារៈទាំង ២ នេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយជាលំអនៃទេសនាតាមអំណាចអធ្យាស្រ័យរបស់ពពួកសត្វដែលនឹងត្រូវត្រាស់ដឹង ដោយប្រការនោះ និងដោយអំណាចនៃព្រះប្រាជ្ញាដែលបែកខ្ញែកខ្ញាយ ក្នុងនិរុត្តិបដិសម្ភិទា ៕*

**ចប់សម្បយុត្តវារៈ**

## ៧.បញ្ហាវារវិភង្គ

*ក្នុងវារៈ ៦ នេះ បណ្ឌិតគប្បីជ្រាបបកិណ្ណកៈដូច្នេះថា “បច្ច័យប្រភេទខ្លះ មិនតាំងនៅដោយអនុលោមឡើយ, តាំងនៅដោយបច្ចនិកៈប៉ុណ្ណោះ ក៏មាន, ប្រភេទខ្លះ មិនតាំងនៅដោយបច្ចនីកៈឡើយ, តាំងនៅដោយអនុលោមប៉ុណ្ណោះ ក៏មាន, បច្ច័យប្រភេទខ្លះ តាំងនៅទាំងដោយអនុលោម ទាំងដោយបច្ចនីកៈ មិនប្រាកដទាំងពីរចំណែកទេ” ។ ក្នុងបកិណ្ណកៈទាំងនោះ **បញ្ហាទី ១** គប្បីជ្រាបដោយអំណាចនៃបច្ចាជាតប្បច្ច័យ, **បញ្ហា ទី ២** គប្បីជ្រាបដោយអំណាចនៃចតុក្កបដ្ឋាន, **បញ្ហាទី ៣** គប្បីជ្រាបដោយអំណាចនៃបច្ច័យដែលនៅសល់ដ៏សមគួរ ៕*

# ពណ៌នាអំពីហេតុប្បច្ច័យ

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង **បញ្ហាវារៈ** ដូចតទៅ ៖

ពាក្យថា **“កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយអំណាចនៃហេតុប្បច្ច័យ”** ជាដើម ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដើម្បីសម្ដែងវិសជ្ជនាបុច្ឆា ដែលគប្បីលើកឡើងក្នុងកុសលត្តិកៈ ដោយអំណាចនៃបច្ច័យដែលបានមានជាអាទិ៍ថា **“កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ដោយអំណាចនៃហេតុប្បច្ច័យ គប្បីមានឬ ?”** ដូច្នេះ ដែលធម្មតាកុសលធម៌នេះ កាលខ្លួនឯងកើតឡើង រមែងកើតឡើង ព្រោះបច្ច័យ ២២ ដ៏សេស វៀរបច្ឆាជាតប្បច្ច័យ និងវិបាកប្បច្ច័យចេញ ។ កុសលធម៌កាលនឹងជាបច្ច័យដល់កុសលធម៌ ក៏រមែងជាបច្ច័យដោយបច្ច័យ ២០ ដែលនៅសល់ វៀរបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ វិបាកប្បច្ច័យ និងវិប្បយុត្តប្បច្ច័យចេញ; ព្រោះហេតុដូច្នោះ កុសលធម៌ រមែងជាបច្ច័យដល់កុសលធម៌ ដោយបច្ច័យពួកណា, ដើម្បីនឹងសម្ដែងបច្ច័យពួកនោះ តាមលំដាប់ ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **“ហេតុប្បច្ចយេន”** ជាដើម ។

គប្បីជ្រាបសេចក្ដីអធិប្បាយក្នុងពាក្យនេះ ដូចតទៅ ៖

ទេសនានេះ យ៉ាងណា ដែលព្រះមានព្រះភាគមិនត្រាស់ថា **“ហេតុជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្ត”** ដូចនៅក្នុង **បច្ចយវិភង្គវារៈ**

ទេ, (ប៉ុន្តែ) ត្រាស់ថា "ជាបច្ច័យដល់ខន្ធទាំងឡាយ ដែលសម្បយុត្ត" ដូច្នេះ, ក្នុងកាលដែលព្រះពុទ្ធអង្គត្រាស់ទេសនាយ៉ាងនោះ មានប្រយោជន៍ ក្នុងកាលដែលទ្រង់ឆ្លើយយ៉ាងនោះ, ពិតមែនហើយ ព្រះមានព្រះភាគត្រាស់ថា **"ធម្មានំ"** ដូច្នេះ ដើម្បីសម្តែងអត្ថថា សូន្យទទេ ក្នុងបច្ចយវិភង្គវារៈនោះ ធម៌ទាំងឡាយកាលនឹងកើតអំពីបច្ច័យ រមែងកើតជាគំនរធម៌, មិនកើតឡើងដោយសភាពឯកោតែឯងទេ, ព្រោះហេតុដូច្នោះ ដើម្បីសម្តែងអត្ថថា ជាគំនរក្នុងបញ្ហា-វិភង្គវារៈនេះ ទើបព្រះអង្គត្រាស់ថា **"ខន្ធានំ"** ។ ប្រការមួយទៀត ការសម្តែងបច្ចយុប្បន្ន ព្រះអង្គទ្រង់លើកឡើងហើយ ដោយអំណាចនៃខន្ធក្នុងបដិច្ចវារៈជាដើម, ព្រោះហេតុដូច្នោះ ទើបទ្រង់លើកឡើងសម្តែងសូម្បីតែក្នុងបញ្ហាវារវិភង្គនេះទៀត ដោយលំដាប់នោះតែម្តង ។ ***សួរថា*** ព្រោះហេតុអ្វី ក្នុងវារៈទាំងនេះ ទើបទ្រង់លើកឡើងដើម្បីសម្តែងយ៉ាងនោះ ? ដោះស្រាយថា ដើម្បីសម្តែងការចែកដោយមិនឲ្យប្របូកប្របល់គ្នា ។ ពិតណាស់ កាលព្រះអង្គទ្រង់ត្រាស់ដោយន័យជាដើមថា "ធម៌ដ៏សេសកើតឡើង ព្រោះអាស្រ័យធម៌តែម្យ៉ាង" ដូច្នេះ អ្នកសិក្សា ក៏មិនអាចនឹងជ្រាបបច្ច័យ និងបច្ចយុប្បន្ន ដោយការមិនប្របូកប្របល់គ្នាថា ធម៌នោះកើតឡើង ព្រោះអាស្រ័យធម៌ឈ្មោះនោះទេ, កាលបើយ៉ាងនេះ ខទ្ទេស និងនិទ្ទេស ក៏នឹងមិនមានបញ្ហាប្លែកគ្នាឡើយ, ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ព្រះពុទ្ធអង្គទ្រង់ចែកទេសនាឡើងយ៉ាងនេះ ក៏ដើម្បីសម្តែង

វិភាគដោយការមិនច្រឡូកច្រឡំគ្នា ។

ពាក្យថា **“ចិត្តសមុដ្ឋានំ”** នេះ ទ្រង់ត្រាស់ដើម្បីសម្ដែងកុសលថា ជាបច្ច័យដល់អព្យាកតៈ ដោយហេតុប្បច្ច័យ ។ ប៉ុន្តែ ក្នុងបច្ចយវិភង្គ ព្រះមានព្រះភាគទ្រង់មិនធ្វើវិភាគដោយអំណាចនៃកុសលជាដើមទេ ទ្រង់មិនត្រាស់ថា “មានចិត្តជាសមុដ្ឋាន” ឡើយ, ប៉ុន្តែត្រាស់ថា “មានហេតុនោះជាសមុដ្ឋាន” ដើម្បីសម្ដែងរូបដែលកើតឡើង ដោយអំណាចនៃហេតុទាំងអស់ដោយសាមញ្ញធម្មតា; ព្រោះហេតុដូច្នោះ រូបដែលមានអព្យាកតហេតុជាសមុដ្ឋាន ក្នុងបច្ចយវិភង្គនោះ ទើបរួមទៅដល់កម្មជរូប ក្នុងបដិសន្ធិ (ឱកន្តិក្ខណៈ) ផង ។ អ្នកសិក្សាគប្បីជ្រាបសេចក្ដីក្នុងវិសជ្ជនាដែលនៅសល់ដែលមានទម្រង់របៀបដូចគ្នានេះចុះ ៕

ចប់ហេតុប្បច្ច័យ

........................

## ពណ៌នាអំពីអារម្មណប្បច្ច័យ

ពីរបទថា **“ទានំ ទត្វា”** គឺលះនូវរបស់ដែលគួរឲ្យ; ម្យ៉ាងទៀតបានដល់ចេតនាជាហេតុឲ្យ ។ បទថា **“ទត្វា”** គឺជម្រះចេតនាឲ្យដូរផង់គឺឲ្យហ្មត់ចត់ ។

ពីរបទថា **“សីលំ សមាទយិត្វា”** គឺសមាទាននិច្ចសីល ដោយអំណាច

*នៃសីលមានអង្គ ៥ ឬអង្គ ១០ ជាដើម; សមាទានវិរតិហ្នឹងឯង ទ្រង់សម្តែងហើយដោយពាក្យនេះ, ចំណែកសម្បត្តវិរតិ និងសមុច្ឆេទវិរតិ មិនបានត្រាស់សម្តែងទុកទេ; ព្រោះមិនបានប្រាកដថា ជាសីលក្នុងលោក សូម្បីមិនបានត្រាស់ ក៏ពិតមែន, ប៉ុន្តែ ក៏ជាអារម្មណប្បច្ច័យបានដូចគ្នា; បណ្តាវិរតិទាំងពីរនោះ សមុច្ឆេទវិរតិ ជាអារម្មណ៍ដល់កុសល របស់ព្រះសេក្ខៈមួយជំពូកប៉ុណ្ណោះ មិនជាអារម្មណ៍ដល់បុគ្គលដទៃទេ ។*

*ពីរបទថា* **“ឧបោសថកម្មំ កត្វា”** *គឺកិរិយាធ្វើឧបោសថ មានអង្គ ៨ ក្នុងថ្ងៃឧបោសថ ដែលលោកពោលទុកយ៉ាងនេះថា “មិនគប្បីសម្លាប់សត្វ និងមិនគប្បីកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ” ជាដើម*[២] *។*

*ពីរបទថា* **“តំ បច្ចវេក្ខតិ”** *សេចក្តីថា ព្រះសេក្ខៈ ឬបុថុជ្ជន ក៏ដោយ រមែងពិចារណាកុសលនោះ,ម្យ៉ាងទៀត សូម្បីព្រះអរហន្ត ក៏ពិចារណាដែរ ។ ពិតមែនហើយ សម្រាប់ព្រះអរហន្ត កុសលដែលធ្វើទុកអំពីមុន ក៏ឈ្មោះថា កុសល, ក៏លោកពិចារណាដោយចិត្តណា, ចិត្តនោះ ឈ្មោះថា កិរិយាចិត្ត; ព្រោះហេតុដូច្នោះ កិរិយាចិត្តនោះ ទើបមិនបានក្នុងអធិការថា* **“កុសលោ ធម្មោ កុសលស្ស ធម្មស្ស”** *ដូច្នេះនេះទេ, ពិតណាស់ កម្មដែលធ្វើជិតៗគ្នា ត្រាស់សម្តែងទុកថា “ឲ្យហើយ, សមាទានហើយ, ធ្វើហើយ” ក្នុងពាក្យថា*

---

[២] អំ. តិក. ។

**"បុព្វេ សុចិណ្ណានិ"** ដូច្នេះ ។ កម្មទាំងនោះ គប្បីជ្រាបថា មិនបានធ្វើជិតៗគ្នាទេ ។ ម្យ៉ាងវិញទៀត ពាក្យនេះ ត្រាស់សម្ដែងទុកដើម្បីសម្ដែងកាមាវចរកុសលដ៏សេស ដែលផ្សេងដោយបុញ្ញកិរិយាវត្ថុ មានទានជាដើម ។

ពាក្យថា **"ឈានំ ទុដ្ឋហិត្វា** = ចេញចាកឈានហើយ", ម្យ៉ាងទៀត ពាក្យនេះឯង ជាព្រះបាលី ។ ពាក្យថា **"សេក្ខា គោត្រភុំ"** ត្រាស់សំដៅដល់សោតាបន្ន, ពិតមែនហើយ សោតាបន្ននោះ រមែងពិចារណាគោត្រភូ, ចំណែកពាក្យថា **"វោទានំ"** នេះ ទ្រង់ត្រាស់សំដៅដល់សកទាគាមី និងអនាគាមី, ព្រោះថា ចិត្តរបស់លោកទាំងនោះ ឈ្មោះថា ជាធម្មជាតផូរផង់ ។ បទថា **"សេក្ខា"** គឺសោតាបន្ន សកទាគាមី និងអនាគាមី ។

ពីរបទថា **"មគ្គា ទុដ្ឋហិត្វា"** គឺចេញចាកមគ្គដែលខ្លួនបានហើយ ដោយអំណាចនៃការឈានកន្លងភវង្គនៃមគ្គ និងផល, ចំណែកការចេញចាកមគ្គសុទ្ធៗនោះ ហើយពិចារណា រមែងមិនមាន ។ ការចូលទៅដល់វិបស្សនា ជាកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ អ្នកសិក្សា គប្បីជ្រាបក្នុងពាក្យថា **"កុសលំ អនិច្ចតោ"** នេះ ។ ក៏កុសលផ្នាក់វិបស្សនា ជាកាមាវចរតែម្យ៉ាង ព្រះមានព្រះភាគទ្រង់សម្ដែងរូបាវចរកុសល ដោយពាក្យថា **"ចេតោបរិយញ្ញាណេន"** នេះ ។ សម្ដែងចំពោះអរូបាវចរកុសល ដែលកំពុងកើតឡើង ដោយអំណាចជាអារម្មណ៍នៃអរូបាវចរកុសល ដោយមាន

*ពាក្យជាអាទិ៍ថា* **“ អាកាសានញ្ចាយតនំ ”** *។ ទ្រង់សម្តែងដោយអំណាចនៃធម៌ប៉ុណ្ណោះ មិនទាក់ទិនដល់បុគ្គល ដោយពាក្យថា* **“ កុសលា ខន្ធា ឥទ្ធិ-វិធញ្ញាណស្ស ”** *ជាដើម ។ ព្រោះហេតុនោះឯង បេតោបរិយញ្ញាណ សូម្បីលោកនឹងកាន់យកអំពីខាងដើមហើយ ក៏នៅតែត្រាស់សម្តែងដដែលៗ ទុកក្នុងអធិការនេះទៀត ។*

*បទថា* **“ អស្សាទេតិ ”** *គឺសោយ និងត្រេកអរ ដោយចិត្តដែលសម្បយុត្តដោយលោភៈ ដែលសហគតៈដោយសោមនស្ស ។ បទថា* **“ អភិនន្ទតិ ”** *បានដល់ ត្រេកអរ គឺជាអ្នកមានសេចក្តីត្រេកអររីករាយ ដោយអំណាចនៃតណ្ហាដែលមានបីតិ, ឬថា រមែងត្រេកអរដ៏ក្រៃលែង ដោយអំណាចនៃការសប្បាយចិត្តក្នុងធម៌ដែលខ្លួនឃើញហើយ ។*

*ពីរបទថា* **“ រាគោ ឧប្បជ្ជតិ ”** *សេចក្តីថា រាគៈរមែងកើតឡើងដល់បុគ្គលអ្នកត្រេកអរ ។ ពាក្យនេះ ត្រាស់សំដៅដល់ចិត្តដែលសហគតៈដោយលោភៈទាំង ៨ ដួង ។*

*ពីរបទថា* **“ ទិដ្ឋិ ឧប្បជ្ជតិ ”** *សេចក្តីថា ទិដ្ឋិដែលសម្បយុត្តដោយចិត្ត ៨ ដួង ដោយអំណាចនៃការឃើញខុសជាដើមថា “ខ្លួនជារបស់មាននៅក្នុងខ្លួន” រមែងកើតដល់បុគ្គលអ្នកត្រេកអរដ៏ក្រៃលែង ។ ក្នុងករណីនេះ វិចិកិច្ឆា រមែងកើតដល់បុគ្គលអ្នកមិនមានការសម្រេចចិត្ត (សង្ស័យ) ។*

ឧទ្ធច្ចៈ រមែងកើតដល់អ្នកមានចិត្តរវើរវាយ, ទោសៈ រមែងកើតដល់អ្នកក្តៅក្រហាយថា “កម្មល្អ យើងមិនទាន់បានធ្វើនៅឡើយ” ជាដើម ។

ពីរបទថា **“តំ អារព្ភ”** សេចក្តីថា ធ្វើកម្មទាំងនោះ ដែលខ្លួនសន្សំទុកហើយក្នុងកាលមុន ឲ្យជាអារម្មណ៍ ។ ពិតណាស់ សព្ទនេះ ***អាទេស*** (ផ្លាស់) ***ពហុវចនៈ*** ឲ្យជាឯកវចនៈ, ម្យ៉ាងទៀត ពាក្យនេះ ជាឯកវចនៈដោយអំណាចនៃជាតិ ។

ពាក្យថា **“ អរហា មគ្គា វុដ្ឋហិត្វា”** សេចក្តីថា ចេញហើយដោយអំណាចនៃការឈានកន្លងភវង្គ តាមលំដាប់នៃផលក្នុងមគ្គវីថិ, ក៏បច្ចវេក្ខណចិត្តរបស់ព្រះអរហន្តនោះ ជាកិរិយាព្យាកតៈ ។ ព្រះមានព្រះ-ភាគ កាលទ្រង់សម្តែងអារម្មណប្បច្ច័យនៃកិរិយាព្យាកតៈយ៉ាងនេះហើយ កាលនឹងសម្តែងអារម្មណប្បច្ច័យនៃវិបាកាព្យាកតៈទៀត ទើបទ្រង់មានព្រះតម្រាស់ថា **“ សេក្ខា វា”** ជាអាទិ៍ ។ ពីរបទថា **“ កុសលេ និរុទ្ធេ”** គឺកាលវិបស្សនាជវនវីថិរលត់ទៅ ។ បទថា **“ វិបាកោ”** បានដល់ កាមា-វចរវិបាក ។ បទថា **“តទារម្មណតា”** គឺដោយតទារម្មណ៍, អធិប្បាយថា ចិត្តនោះ (តទារម្មណចិត្ត) ធ្វើកុសលដែលឃើញច្បាស់ហើយ ដែលជាអារម្មណ៍នៃកុសលជវន ឲ្យជាអារម្មណ៍កើតឡើង ។ តែមិនមែនកើតដោយអំណាចនៃតទារម្មណ៍តែម្យ៉ាងប៉ុណ្ណោះទេ, រមែងកើតដោយអំណាច

នៃបដិសន្ធិ ភវង្គ និងចុតិដែរ ។ ពិតមែនហើយ វិបាករមែងមានកុសលជាអារម្មណ៍បានដូចគ្នា សម្រាប់បុគ្គលអ្នកធ្វើកម្មឲ្យជាអារម្មណ៍ហើយចាប់បដិសន្ធិ, ប៉ុន្តែវិបាកនោះ មិនបានសម្ដែងទុកក្នុងទីនេះទេ ព្រោះយល់បានដោយលំបាក ។ ពាក្យថា **“កុសលំ អស្សាទេតិ”** ជាដើម ទ្រង់ត្រាស់ទុកដើម្បីសម្ដែងវិបាកដែលមានកុសលជាអារម្មណ៍ក្នុងទីបំផុតនៃអកុសលជវន ។

ពាក្យថា **“វិញ្ញាណញ្ចាយតនវិបាកស្ស”** នេះ បានដល់ ភាពជាធម៌ដែលលំបាកយល់, ក៏ព្រះអង្គទ្រង់ត្រាស់ទុកដោយអំណាចនៃវិបាក ដែលអាចប្រព្រឹត្តទៅបាន ព្រោះមហគ្គតវិបាក មិនកើតដោយភាពជាគទារម្មណ៍ទេ ។ បទថា **“កិរិយាស្ស”** គឺអាកាសានញ្ចាយតនកុសល ជាបច្ច័យដោយអារម្មណប្បច្ច័យ ដល់កិរិយាចិត្តរបស់បុគ្គលអ្នកសម្រេចព្រះអរហត្តហើយចូលសមាបត្តិដោយបដិលោម ឬដោយមានឈានមួយខណ្ឌ ក្នុងអារម្មណ៍ដែលជាអាកាសានញ្ចាយតនៈ ដែលនៅមិនធ្លាប់ចូល ។

បទថា **“ចេតោបរិយញាណស្ស”** ជាដើម គប្បីប្រកបភ្ជាប់ជាមួយអាវជ្ជនៈខាងមុខ, ក្នុងសេចក្ដីនេះ មានអធិប្បាយថា ខន្ធទាំងឡាយ ដែលជាកុសល ជាបច្ច័យដល់អាវជ្ជនចិត្ត (អភិញ្ញាចិត្ត) ទាំងនោះ ដោយអារម្មណប្បច្ច័យ ។ បទថា **“រាគំ”** គឺរាគៈរបស់ខ្លួន ឬរបស់បុគ្គលដទៃ; ប៉ុន្តែក្នុងអធិការនេះ វណ្ណនាប្រាកដហើយ ដោយអំណាចនៃរាគៈរបស់ខ្លួន ។

ពាក្យថា **"អស្សាទេតិ"** ជាដើម មានអត្ថដូចពោលទុកហើយ; ប៉ុន្តែ ក្នុងធម៌មានវិចិកិច្ឆាជាដើម មិនបានត្រាស់ថា **"អស្សាទេតិ** = រមែងត្រេកអរ" ទេ ព្រោះមិនមានភាវៈដែលនឹងគួរត្រេកអរ ។ ក៏ទិដ្ឋិរមែងកើតឡើងក្នុងឋាននេះ ។ ទិដ្ឋិនោះ ព្រះមានព្រះភាគមិនត្រាស់ទុកជាមុនតាមលំដាប់ដែលមកដល់ទេ ព្រោះបទថា **"អស្សាទេតិ"** ធ្លាក់ (បាត់) ទៅ, ទិដ្ឋិនោះ ព្រះមានព្រះភាគត្រាស់សម្តែងធម៌នោះៗ ក្នុងធម៌មានវិចិកិច្ឆាជាដើម ដែលជាសភាគគ្នាជាមុន ហើយត្រាស់ទុកក្នុងលំដាប់នៃធម៌នោះៗ ។ ក៏បណ្តាធម៌មានរាគៈជាដើមនេះ គប្បីជ្រាបការកើតឡើងនៃទោមនស្ស ដោយអំណាចនៃការរម្ងាប់ចិត្តមិនបានថា "បាបធម៌ទាំងនេះ តើកើតឡើងដូចម្តេច ?" ឬដោយអំណាចនៃវិប្បដិសារីថា "យើងធ្វើសេចក្តីអាក្រក់ទុក យើងធ្វើកម្មដ៏ថោកទាបទុក" ជាដើម ។

ពីរបទថា **"ចក្ខុំ អនិច្ចតោ"** សេចក្តីថា រូប ១១ គឺឱឡារិកាយតនៈ ១០ និងវត្ថុរូប ១ លោកកាន់យកហើយ ព្រោះប្រាកដតាមលំដាប់វិបស្សនា ។ រូបាយតនៈជាដើម លោកក៏កាន់យកទៀត ព្រោះជាអារម្មណ៍នៃចក្ខុវិញ្ញាណជាដើម ។ ក៏ព្រោះទេសនានេះ ត្រាស់សម្តែងដោយអំណាចនៃវិញ្ញាណ, មិនបានត្រាស់សម្តែងដោយអំណាចនៃធាតុទេ ព្រោះហេតុដូច្នោះ ទើបមិនកាន់យកមនោធាតុផង ។ គប្បីជ្រាបអារម្មណ៍ដែលកាន់

*យកហើយ និងនៅមិនបានកាន់យកក្នុងទីទាំងពួងយ៉ាងនេះ ។ ពាក្យថា “រមែងពិចារណាផល រមែងពិចារណានូវនិព្វាន” ទ្រង់ត្រាស់ទុកដើម្បីសម្តែងអារម្មណ៍នៃកុសលដែលជាតួពិចារណា ៕*

ចប់អារម្មណបច្ច័យ

## ពណ៌នាអំពីអធិបតិបច្ច័យ

*ក្នុង* ***អារម្មណាធិបតិនិទ្ទេស*** *ព្រះអង្គទ្រង់សម្តែងកុសលដែលរាប់បញ្ចូលក្នុងភូមិ ៤ ដោយអំណាចនៃសេក្ខៈ និងបុថុជ្ជន ។ ក្នុង* ***សហជាតាធិបតិនិទ្ទេស*** *ក៏ដូចគ្នាដែរ ។ ព្រះអរហន្ត មិនមានការធ្វើឲ្យធ្ងន់ ក្នុងលោកិយកុសលទាំងឡាយឡើយ ព្រោះលោកបានសម្រេចធម៌ជាន់ខ្ពស់បំផុតហើយ, ព្រោះហេតុដូច្នោះ ទើបទ្រង់សម្តែងទុកចំពោះអរហត្តមគ្គប៉ុណ្ណោះ ៕*

ចប់អធិបតិបច្ច័យ

.......................

## ពណ៌នាអំពីអនន្តរបច្ច័យ

*ក្នុង* ***អនន្តរបច្ច័យ*** *ពីរបទថា* “**បុរិមា បុរិមា**” *ព្រះមានព្រះភាគត្រាស់សម្តែងរួមកុសលដែលកើតក្នុងភូមិជាមួយគ្នា និងភូមិផ្សេងគ្នា ។*

ពាក្យថា ***“អនុលោម ជាបច្ច័យដល់គោត្រភូ, អនុលោម ជាបច្ច័យដល់វោទាន”*** ត្រាស់សម្ដែងដោយអំណាចនៃអារម្មណ៍ដែលប្លែកផ្សេងគ្នា ។ ពាក្យថា ***“គោត្រភូ ជាបច្ច័យដល់មគ្គ, វោទាន ជាបច្ច័យដល់មគ្គ”*** ត្រាស់សម្ដែងដោយអំណាចនៃភូមិដែលផ្សេងគ្នា ។ ពាក្យថា ***“កុសល”*** ក្នុងពាក្យថា **“កុសលំ ឧដ្ឋានស្ស”** នេះ បានដល់ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **“ឧដ្ឋានំ”** គឺវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ព្រះយោគាវចរទាំងឡាយ រមែងចេញចាកកុសលជវនវីថិ ដោយវិបាកទាំងនោះ, ព្រោះហេតុដូច្នោះ វិបាកនោះ ទើបលោកហៅថា ***វុដ្ឋាន;*** វុដ្ឋាននោះ មាន ២ យ៉ាង គឺតទារម្មណ៍ ១ និងភវង្គ ១ ។ បណ្ដាវុដ្ឋានសូម្បីទាំងពីរយ៉ាងនោះ ជាវុដ្ឋានរបស់កាមាវចរកុសល, ភវង្គតែម្យ៉ាង ជាវុដ្ឋាននៃមហគ្គតកុសល ។ ពាក្យថា **“មគ្គោ ផលស្ស”** នេះ ព្រះអង្គទ្រង់ត្រាស់បំបែកទុក ព្រោះលោកុត្តរវិបាក ជាវុដ្ឋានមិនបានហេតុដែលរាប់បញ្ចូលក្នុងជវនវីថិទេ ។

ពីរបទថា **“សេក្ខានំ អនុលោមំ”** សេចក្ដីថា កុសល រមែងមិនជាអនន្តរប្បច្ច័យដល់អសេក្ខធម៌, ព្រោះហេតុដូច្នោះ ទើបទ្រង់ធ្វើការបែងចែកទុក ។ បទថា **“ផលសមាបត្តិយា”** គឺផលសមាបត្តិរបស់សោតាបត្តិផល

*សកទាគាមិផល និងអនាគាមិផល ។ បទថា* **“ ផលសមាបត្តិយា ”** *គឺ អនាគាមិផលសមាបត្តិ ។ ក្នុងអកុសលចិត្ត រមែងបានវុដ្ឋានវិបាកទាំងពីរ ។*

*ក្នុងពាក្យថា* **“ វិបាកាព្យាកតា កិរិយាព្យាកតា ”** *នេះ អ្នកសិក្សាគប្បីជ្រាបវិបាកាព្យាកតៈ ដល់វិបាកាព្យាកតៈជាមួយគ្នាប៉ុណ្ណោះ, និងកិរិយាព្យាកតៈដល់កិរិយាព្យាកតៈដូចគ្នាប៉ុណ្ណោះដែរ ។ ពាក្យថា* **“ ភវង្គំ អាវជ្ជនាយ ”** *ជាដើម ត្រាស់សម្ដែងដោយអំណាចនៃធម៌ដែលប្រឡូកប្រឡំគ្នា ។ ក្នុងពាក្យថា* **“កិរិយា ”** *នោះ កាមាវចរកិរិយា* ***ជាអនន្តរប្បច្ច័យ*** *ដល់វុដ្ឋានវិបាកទាំងពីរ, មហគ្គតកិរិយា* ***ជាអនន្តរប្បច្ច័យ*** *ដល់ភវង្គប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* ***“កុសលធម៌ទាំងឡាយ ដែលកើតមុនៗ ជាបច្ច័យដល់កុសលធម៌ដែលកើតឡើងក្រោយៗ ដោយអំណាចនៃអនន្តរៈប្បច្ច័យ”*** *ហើយសម្ដែងវារៈ ៧ ទុកក្នុងបច្ចយវិភង្គអំពីខាងដើមថា “កុសលជាបច្ច័យដល់កុសល, កុសល ជាបច្ច័យដល់អព្យាកតៈ, អកុសល ជាបច្ច័យអកុសល, អកុសល ជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈ ជាបច្ច័យដល់កុសល, អព្យាកតៈ ជាបច្ច័យដល់អកុសល (ព្រោះអំណាចនៃអនន្តរប្បច្ច័យ)”* *។ ក្នុងអធិការនេះ លោកចែកអនន្តរប្បច្ច័យទុកដោយសង្ខេប ដោយអំណាចនៃវារៈទាំងនោះ; ប៉ុន្តែ*

ពោលដោយពិស្ដារ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបកំណត់និទ្ទេស ១០-១៧-៦០ គត់ និងច្រើនជាងនោះឲ្យល្អ ដូចតទៅ ៖

ពិតមែនហើយ អនន្តរប្បច្ច័យនេះ មិនបាននិទ្ទេស ៧ តែម្យ៉ាង ប៉ុណ្ណោះទេ, ***តែរមែងបាននិទ្ទេស ១០ យ៉ាងទៀត*** គឺ

- ***កុសល*** ជាបច្ច័យដល់កុសល ១, ដល់វិបាក ១ ។
- ***អកុសល*** ជាបច្ច័យដល់អកុសល ១, ដល់វិបាក ១ ។
- ***វិបាក*** ជាបច្ច័យដល់វិបាក ១, ដល់កិរិយា ១ ។
- ***កិរិយា*** ជាបច្ច័យដល់កុសល ១, ដល់អកុសល ១, ដល់វិបាក ១ និងដល់កិរិយា ១ ។

អនន្តរប្បច្ច័យនេះ នឹងបាននិទ្ទេសចំពោះតែ ១០ យ៉ាងប៉ុណ្ណោះ ក៏មិនមែន, ***ប៉ុន្តែ នៅបាននិទ្ទេស ១៧*** យ៉ាងនេះទៀត គឺ

- ***កុសល*** ជាបច្ច័យដល់កុសល ១, កុសលវិបាក ១ និងអកុសល-វិបាក ១ ។
- ***អកុសល*** ជាបច្ច័យដល់អកុសល ១, អកុសលវិបាក ១ និង កុសលវិបាក ១ ។
- ***កុសលវិបាក*** ជាបច្ច័យដល់កុសលវិបាក ១, អកុសលវិបាក

*១ និងកិរិយា ១ ។*

***–អកុសលវិបាក*** *ជាបច្ច័យដល់អកុសលវិបាក ១, ដល់កុសល-វិបាក ១ និងដល់កិរិយា ១ ។*

***–កិរិយា*** *ជាបច្ច័យដល់កិរិយា ១, កុសល ១, អកុសល ១, កុសលវិបាក ១ និងអកុសលវិបាក ១ ។*

*អនន្តរបច្ច័យនេះ នឹងបាននិទ្ទេសចំពោះតែ ១៧ យ៉ាងប៉ុណ្ណោះក៏មិនមែន,* ***នៅបាននិទ្ទេសទាំង ៦០ ទៀត;*** *គឺអ្វីខ្លះ ? គឺ*

***–កុសល ជាអនន្តរបច្ច័យដល់កុសល ៦ យ៉ាង*** *បានដល់ កាមាវចរ-កុសល ជាអនន្តរបច្ច័យដល់កុសលទាំង ៤ យ៉ាង តាមការផ្សេងគ្នានៃភូមិ, រូបាវចរកុសល និងអរូបាវចរកុសល ជាអនន្តរបច្ច័យ ដល់កុសលដែលកើតក្នុងភូមិរបស់ខ្លួន ។*

***–ចំណែកកុសលជាអនន្តរបច្ច័យដល់វិបាក ១២ យ៉ាង*** *គឺកាមាវចរកុសល ជាបច្ច័យដល់កាមាវចរកុសលវិបាក, អកុសលវិបាក, រូបាវចរវិបាក, អរូបាវចរវិបាក និងលោកុត្តរវិបាក;* ***រូបាវចរកុសល*** *ជាបច្ច័យ ដល់រូបាវចរវិបាក, កាមាវចរវិបាក;* ***អរូបាវចរកុសល*** *ជាបច្ច័យដល់ កាមាវចរកុសលវិបាក, រូបាវចរវិបាក, អរូបាវចរវិបាក និងលោកុត្តរវិបាក;* ***លោកុត្តរកុសល*** *ជាបច្ច័យដល់លោកុត្តរវិបាក ។*

**–អកុសល ជាអនន្តរប្បច្ច័យ ៥ យ៉ាង** គឺដល់អកុសល, អកុសលវិបាក និងវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

**–កាមាវចរកុសលវិបាក ជាអនន្តរប្បច្ច័យដល់វិបាក ៤ យ៉ាង** គឺដល់កាមាវចរកុសលវិបាក, អកុសលវិបាក, រូបាវចរវិបាក និងអរូបាវចរវិបាក ។

**–រូបាវចរវិបាក ជាអនន្តរប្បច្ច័យ ៣ យ៉ាង** គឺដល់កុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ។

**–អរូបាវចរវិបាក ជាអនន្តរប្បច្ច័យ ២ យ៉ាង** គឺដល់អរូបាវចរវិបាក និងកាមាវចរកុសលវិបាក ។

**–លោកុត្តរវិបាក ជាអនន្តរប្បច្ច័យ ៤ យ៉ាង** គឺដល់កុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ កុសលវិបាក ជាអនន្តរប្បច្ច័យ ១៣ យ៉ាងដល់វិបាក ដោយប្រការដូច្នេះ ។

**–អកុសលវិបាក ជាអនន្តរប្បច្ច័យ ២ យ៉ាង** គឺដល់អកុសលវិបាក និងកាមាវចរកុសលវិបាក ។ **សូម្បីវិបាកក្នុងទីទាំងពួង ជាអនន្តរប្បច្ច័យ ១៥ យ៉ាង ដល់វិបាក** ដោយប្រការដូច្នេះ ។

**–វិបាកជាអនន្តរប្បច្ច័យ ៤ យ៉ាង** ដល់កិរិយា គឺកាមាវចរកុសលវិបាក ជាបច្ច័យដល់កាមាវចរកិរិយា, អកុសលវិបាក, រូបាវចរវិបាក និង

អរូបាវចរវិបាក ក៏ជាបច្ច័យដល់កាមាវចរកិរិយាបានដូចគ្នា ។

**–កិរិយា ជាអនន្តរប្បច្ច័យដល់កិរិយា ៥ យ៉ាង** គឺកាមាវចរកិរិយា ជាបច្ច័យដល់កិរិយាដែលប្រព្រឹត្តទៅក្នុងភូមិ ៣, រូបាវចរកិរិយា និង អរូបាវចរកិរិយា ជាបច្ច័យដល់កិរិយាក្នុងភូមិរបស់ខ្លួនៗ ។

**–កិរិយា ជាអនន្តរប្បច្ច័យដល់វិបាក ១១ យ៉ាង** គឺកាមាវចរកិរិយា ជាបច្ច័យដល់អកុសលវិបាក និងកុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៤, រូបាវចរកិរិយា ជាបច្ច័យដល់កាមាវចរកុសលវិបាក និងរូបាវចរវិបាក, អរូបាវចរកិរិយា ជាបច្ច័យដល់កុសលវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

**–ចំណែកកាមាវចរកិរិយា ជាអនន្តរប្បច្ច័យ ២ យ៉ាង** ដល់កុសល និងអកុសល គឺដល់កាមាវចរកុសល និងអកុសល ។

អនន្តរប្បច្ច័យ រមែងបាននិទ្ទេស ៦០ ទៀត មានប្រការដូច្នេះ ។

អនន្តរប្បច្ច័យនេះ នឹងបាននិទ្ទេស ៦០ គត់ប៉ុណ្ណោះ ក៏មិនមែន, នៅបាននិទ្ទេសច្រើនយ៉ាងទៀត; គឺអ្វីខ្លះ ? គឺ

**–កាមាវចរមហាកុសលចិត្តដួងទី ១** ជាអនន្តរប្បច្ច័យដល់ចិត្ត ៥៣ ដួង គឺដល់ខ្លួនឯង, ដល់រូបាវចរកុសល ៤ ដួង, លោកុត្តរកុសល-សោមនស្ស ១៦ ដួង ព្រោះប្រកបឲ្យជាបាទ រួមសេចក្ដីថា ជាបច្ច័យ ដល់កុសលចិត្ត ២១ ដួង, ជាបច្ច័យដល់វិបាក ៣២ ដួងទៀត គឺដល់

កាមាវចរវិបាក ១១ ដួង ដែលកើតដោយអំណាចនៃតទារម្មណ៍ និងភវង្គក្នុងទីបំផុតនៃជវន, ដល់រូបាវចរវិបាក និងអរូបាវចរវិបាក ដែលប្រព្រឹត្តទៅដោយអំណាចនៃភវង្គតែម្យ៉ាង, ដល់លោកុត្តរវិបាក ១២ ដែលប្រព្រឹត្តទៅដោយអំណាចនៃផលសមាបត្តិ ។

**–កុសលចិត្តដួងទី ២** ក៏ដូចគ្នាដែរ ។ **ចំណែកដួងទី ៣ និងដួងទី ៤** រមែងជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួងដែលនៅសល់ វៀរកុសលដែលកើតក្នុងភូមិខ្ពស់ៗ ឡើងទៅ និងលោកុត្តរវិបាក ។

**–មហាកុសលចិត្តដួងទី ៥ និងដួងទី ៦** ជាអនន្តរប្បច្ច័យដល់ចិត្ត ៣៣ ដួង គឺដល់ខ្លួនឯង ដល់កុសលចិត្តដែលសហគតៈដោយឧបេក្ខា ដែលកើតក្នុងភូមិខ្ពស់ៗ ឡើងទៅ ៩ ដួង និងដល់វិបាកចិត្ត ២៣ ដួង ។

**–មហាកុសលចិត្តដួងទី ៧ និងដួងទី ៨** ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួងប៉ុណ្ណោះ ។

–រូបាវចរកុសលចិត្ត ៥ ជាអនន្តរប្បច្ច័យដល់ចិត្ត ១០ ដួង គឺដល់រូបាវចរកុសលដែលកើតខាងក្រោយខ្លួន ១, ដល់មហាវិបាកញាណ-សម្បយុត្ត ៤ ដួង និងដល់រូបាវចរវិបាក ៥ ដួង ។

ដោយន័យនេះឯង បណ្តា **អរូបាវចរកុសល** ទាំងឡាយ អរូបាវចរ-កុសលដួងទី ១ ជាអនន្តរប្បច្ច័យដល់ចិត្ត ១១ ដួង ព្រមជាមួយនឹងវិបាក

របស់ខ្លួន ៗ

**–អរូបាវចរកុសលដួងទី ២** ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង ។

**–អរូបាវចរកុសលដួងទី ៣** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៣ ដួង ។

**–អរូបាវចរកុសលដួងទី ៤** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៥ ដួង គឺចិត្ត ១៤ ដួង និងផលសមាបត្តិ ១ ។

លោកុត្តរកុសល ជាអនន្តរប្បច្ច័យដល់វិបាករបស់ខ្លួនៗ ប៉ុណ្ណោះ ។

**–បណ្តាចិត្តដែលសហគតៈដោយលោភៈ ៨ ដួង** អកុសលចិត្តដួងមួយៗ ជាបច្ច័យដល់ចិត្ត ២១ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ១១ ដួង, មហគ្គតវិបាក ៩ ដួង និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

**–ចិត្តដែលសហគតៈដោយទោសៈ ២ ដួង** ជាអនន្តរប្បច្ច័យដល់ចិត្ត ៧ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ៦ ដួង ដែលសហគតៈដោយឧបេក្ខា និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

**–ចិត្តដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ** ជាអនន្តរប្បច្ច័យដល់ចិត្ត ២១ ដួង គឺកាមាវចរវិបាកមនោវិញ្ញាណធាតុ ១១ ដួង ព្រមជាមួយនឹងអហេតុកវិបាក ដែលសហគតៈដោយសោមនស្ស មហគ្គតវិបាក ៩ ដួង និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

**– បញ្ចវិញ្ញាណចំណែកខាងកុសលវិបាក** ជាអនន្តរប្បច្ច័យដល់មនោ-ធាតុចំណែកខាងកុសលវិបាក ។

**– មនោធាតុ** ជាអនន្តរប្បច្ច័យដល់មនោវិញ្ញាណធាតុ ផ្នែកខាងវិបាក ២ ដួង ។ បណ្ដាមនោវិញ្ញាណធាតុ ផ្នែកខាងវិបាក ២ ដួងនោះ ដួងដែលសហគតៈដោយសោមនស្ស ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង គឺមនោវិញ្ញាណធាតុផ្នែកខាងវិបាក ១០ ដួង ដែលមាននាទីជាភវង្គដល់ខ្លួនឯង កើតខាងក្រោយខ្លួន ក្នុងវេលាជាតទារម្មណ៍ និងដល់វោដ្ឋព្វនកិរិយា ។

ចំណែក **អហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខា** ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួងដូចគ្នា គឺដល់អាវជ្ជនមនោធាតុ អាវជ្ជន-មនោវិញ្ញាណធាតុ ដែលមានឋាន ២ និងវិបាកមនោវិញ្ញាណធាតុ ១០ ។

**– មហាវិបាកដែលជាតិហេតុកៈ** ជាបច្ច័យដល់ចិត្ត ២១ ដួង គឺមនោ-វិញ្ញាណធាតុផ្នែកខាងវិបាក ដែលជាកាមាវចរ ១០ វៀរសោមនស្ស-សន្តីរណៈ រូបាវចរវិបាក អរូបាវចរវិបាក និងអាវជ្ជនចិត្តទាំងពីរចេញ ។

**– ទុហេតុកវិបាក** ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួងដែលនៅសល់ វៀរមហគ្គតវិបាកចេញ ។

**– រូបាវចរវិបាក ៥** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៩ ដួង គឺដល់សហេតុកកុសលវិបាកបដិសន្ធិចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិទាំងបី ១៧ ដួង

និងអាវជ្ជនចិត្ត ២ ដួង ។

***បណ្ដាអរូបាវចរវិបាកទាំងឡាយ អរូបាវចរវិបាកចិត្តដួងទី ១*** ជាអនន្តរប្បច្ច័យដល់ចិត្ត ៩ ដួង គឺតិហេតុកបដិសន្ធិ ផ្នែកខាងកុសលវិបាកថ្នាក់កាមាវចរ ៨, អរូបាវចរវិបាក ៨ និងមនោទ្វារាវជ្ជនចិត្ត ១ ។

**–*អរូបាវចរវិបាកចិត្តដួងទី ២*** ជាអនន្តរប្បច្ច័យដល់ចិត្ត ៨ ដួង វៀរវិបាកថ្នាក់ទាបជាង ១ ដួងចេញ ។

**–*អរូបាវចរវិបាកចិត្តដួងទី ៣*** ជាអនន្តរប្បច្ច័យដល់ចិត្ត ៧ ដួង វៀរវិបាកដែលទាបជាង ២ ដួងចេញ ។

**–*អរូបាវចរវិបាកចិត្តដួងទី ៤*** ជាបច្ច័យដល់ចិត្ត ៦ ដួង វៀរវិបាកថ្នាក់ទាប ៣ ដួងចេញ ។

**–*លោកុត្តរវិបាក ៤ ដួង*** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៤ ដួង គឺតិហេតុកវិបាក ១៣ ដួង និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ។ បញ្ចវិញ្ញាណផ្នែកខាងអកុសលវិបាក ជាអនន្តរប្បច្ច័យដល់អកុសលវិបាក-មនោធាតុ ។ មនោធាតុ ជាអនន្តរប្បច្ច័យដល់អហេតុកមនោវិញ្ញាណធាតុផ្នែកខាងអកុសលវិបាក ។ ឯអហេតុកមនោវិញ្ញាណធាតុ ផ្នែកខាងអកុសលវិបាកនោះ ជាអនន្តរប្បច្ច័យដល់ចិត្ត ១២ ដួង គឺដល់ខ្លួនឯងដែលកើតខាងក្រោយ ក្នុងវេលាជាតទារម្មណកាមាវចរវិបាក ៩ ដែល

ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ និងភវង្គក្នុងចុតិកាល និងកាមាវចរ-កិរិយា ២ ដួង ដែលសហគតៈដោយឧបេក្ខា ។

**–កិរិយាមនោធាតុ** ជាបច្ច័យដល់ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង ។

**–ហសិតុប្បាទកិរិយា** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៣ ដួង ដោយមិនរាប់ដដែលៗ ទេ គឺដល់តិហេតុកវិបាក ៩ ដែលប្រព្រឹត្តទៅដោយអំណាចនៃភវង្គក្នុងបញ្ចវោការភព និងដល់វិបាកដែលសហគតៈដោយសោមនស្ស ៥ ដែលប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណ៍ និងដល់ខ្លួនឯងដែលកើតខាងក្រោយ ។

**–វោដ្ឋព្វនកិរិយា** ជាបច្ច័យដល់ចិត្ត ៤៥ ដួង គឺកាមាវចរកិរិយា ១០ វៀរកិរិយាមនោធាតុ, កាមាវចរកុសល ៨, អកុសល ១២ និងវិបាកចិត្ត ១៥ ដែលប្រព្រឹត្តទៅដោយអំណាចនៃភវង្គក្នុងបញ្ចវោការភព ។

**–កាមាវចរតិហេតុកកិរិយា** ដែលសហគតៈដោយសោមនស្ស ២ ដួង ជាអនន្តរប្បច្ច័យដល់ចិត្ត ២៥ ដួង ដែលរាប់រួចហើយ មិនរាប់ដដែលៗ ទៀតទេ គឺដល់តិហេតុកវិបាក ១៣ ដែលប្រព្រឹត្តទៅដោយអំណាចនៃភវង្គ, សោមនស្សសហគតវិបាក ៥ ដោយអំណាចនៃតទារម្មណ៍, រូបាវចរកិរិយា ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃបរិកម្ម អរហត្តផលសមាបត្តិ ដែលសហគតៈដោយសោមនស្ស ៤ ដោយអំណាចនៃអរហត្តផលសមាបត្តិ

និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ។

**-ទុហេតុកសោមនស្សសហគតកិរិយា ២ ដួង** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៧ ដួង ដោយមិនរាប់ដដែលៗ បន្ថែមទៀតទេ គឺដល់ភវង្គ-ចិត្ត ១៣ តាមដែលពោលហើយ តទារម្មណ៍ ៥ និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ។

**-កាមាវចរតិហេតុកឧបេក្ខាសហគតកិរិយា ២ ដួង** ជាអនន្តរ-ប្បច្ច័យដល់ចិត្ត ២៨ ដួង ដោយមិនរាប់ដដែលៗ បន្ថែមលើគ្នាទៀតទេ គឺដល់ភវង្គចិត្ត ១៣ ដួងនុ៎ះឯង, ឧបេក្ខាសហគតវិបាក ៦ ដែលប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណ៍, រូបាវចរកិរិយា ១ ដែលប្រព្រឹត្តទៅដោយអំណាចនៃបរិកម្ម, អរូបាវចរកិរិយា ៤, អរហត្តផលសមាបត្តិ ១ និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ដួង ។

**-ទុហេតុកឧបេក្ខាសហគតកិរិយា ២** ជាអនន្តរប្បច្ច័យដល់ចិត្ត ១៨ ដួង ដោយមិនរាប់ដដែលៗទេ គឺដល់ភវង្គចិត្ត ១៣ នុ៎ះផង, ដល់តទារម្មណចិត្ត ៦ និងដល់ខ្លួនឯង ដែលកើតខាងក្រោយ ១ ផង ។

**បណ្តារូបាវចរកិរិយាទាំងឡាយ ដួងទីមួយៗ** ជាអនន្តរប្បច្ច័យដល់ចិត្ត ១០ ដួង គឺតិហេតុកភវង្គ ក្នុងបញ្ចវោការភព ៩ ដួង និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

*បណ្ដាអរូបាវចរកិរិយាចិត្តទាំងឡាយ ៖*

**–*អរូបាវចរកិរិយាចិត្តដួងទី ១*** ជាអនន្តរប្បច្ច័យដល់ចិត្ត ១១ ដួង គឺភវង្គចិត្ត ៩ ក្នុងបញ្ចវោការភព, ១ ដួងទៀត ក្នុងចតុវោការភព និងដល់ខ្លួនឯងដែលកើតខាងក្រោយ ១ ដួង ។

**–*អរូបាវចរកិរិយាចិត្តដួងទី ២*** រមែងបានភវង្គចិត្ត ៧ ដួង ក្នុងចតុ-វោការភព ។

**–*អរូបាវចរកិរិយាចិត្តដួងទី ៣*** បាន ៣ ដួង ។

**–*អរូបាវចរកិរិយាចិត្តដួងទី ៤*** រមែងបានភវង្គចិត្ត ៨ ដួង និងផលសមាបត្តិ ១ ទៀត ។ បណ្ដាអរូបាវចរកិរិយាទាំងនោះ ដួងមួយៗ ជាអនន្តរប្បច្ច័យដល់ចិត្ត ១១-១២-១៣ និង ១៥ ដួង តាមលំដាប់ដូច្នេះឯង ។ អនន្តរប្បច្ច័យ រមែងបាននិទ្ទេសសូម្បីច្រើនយ៉ាងដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា “បណ្ឌិតគួរកំណត់និទ្ទេស ១០-១៧-៦០ និងសូម្បីច្រើនជាងនោះ (នៃអនន្តរប្បច្ច័យ) ឡើ” ។

**–*សមនន្តរប្បច្ច័យ*** ជាដើម មានសេចក្ដីភ្លឺច្បាស់ហើយ ៕

## ចប់អនន្តរប្បច្ច័យ

..........................

## ពណ៌នាអំពីឧបនិស្សយប្បច្ច័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង **ឧបនិស្សយប្បច្ច័យ** ដូចតទៅ ៖*

*ពីរបទថា* **"សទ្ធំ ឧបនិស្សាយ"** *គឺធ្វើសទ្ធា បានដល់ការជឿក្នុងកម្ម និងផលរបស់កម្ម លោកនេះ និងលោកខាងមុខជាដើម ឲ្យជាទីអាស្រ័យយ៉ាងមាំទាំ; ដូចជាបុគ្គលជឿថា ខាងក្រោមផែនដីមានទឹក ហើយជីកនូវផែនដី យ៉ាងណាមិញ, កុលបុត្រមានសទ្ធា ក៏ដូច្នោះដែរ ជឿផល និងអានិសង្ស របស់ទានជាដើមហើយ រមែងបរិច្ចាគទានជាដើម ។ ព្រោះហេតុដូច្នោះ ទើបលោកពោលថា* **"សទ្ធំ ឧបនិស្សាយ"** *។*

*ក្នុងពាក្យថា* **"សីលំ ឧបនិស្សាយ"** *ជាដើម អធិប្បាយថា ធ្វើធម៌មានសីលជាដើមនេះ ឲ្យជាឧបនិស្ស័យ; ពិតមែនហើយ បុគ្គលអ្នកមានសីល ជាអ្នកឈ្លាសក្នុងសីលានុភាព និងក្នុងអានិសង្សនៃសីល ព្រោះអាស្រ័យសីល ទើបឲ្យទានដល់បុគ្គលអ្នកមានសីល, សមាទានសីលថ្នាក់ខ្ពស់ឡើងទៅ រក្សាឧបោសថក្នុងបក្ខ មានថ្ងៃ ១៤ រោចជាដើម ឲ្យបរិសុទ្ធមិនឲ្យដាច់, ព្រោះអាស្រ័យសីលសម្បត្តិ រមែងញ៉ាំងគុណធម៌ មានឈានជាដើម ឲ្យកើតឡើង ។ សូម្បីបុគ្គលអ្នកបានឮ បានស្តាប់ច្រើន ដឹងនូវជម្រៅនៃសម្បត្តិគ្រប់យ៉ាង ដែលរាប់បញ្ចូលដោយបុញ្ញកិរិយាវត្ថុ មានទានជាដើម និងសេចក្តីផ្សេងគ្នានៃការសៅហ្មង និងផូរផង់នៃកុសល មានទានជាដើម ដោយសុតមយបញ្ញាហើយ អាស្រ័យសុតៈបំពេញកុសលមានទាន*

ជាដើម ។ សូម្បីបុគ្គលអ្នកលះបង់ មានចិត្តបង្អោនទៅក្នុងការបរិច្ចាគ អាស្រ័យការដល់ព្រមដោយចាគធម៌របស់ខ្លួន ទើបឲ្យទាន, សមាទានសីល ព្រោះយល់ថា ទានដែលបុគ្គលមានសីលឲ្យហើយ រមែងមានផលច្រើន, រក្សាឧបោសថ ព្រោះការបដិបត្តិយ៉ាងនោះ ទើបជាអ្នកមានចិត្តបរិសុទ្ធ រមែងញ៉ាំងគុណធម៌មានឈានជាដើម ឲ្យកើតឡើងបាន ។ ចំណែកបុគ្គលអ្នកមានបញ្ញាកំណត់ដឹងប្រយោជន៍ ក្នុងលោកនេះ និងលោកខាងមុខ ព្រមទាំងឧបាយដែលនឹងឆ្លងផុតចាកលោក អាស្រ័យការដឹងទូទៅគ្រប់យ៉ាង ដោយគិតថា "ឧបដិបត្តិនេះ បុគ្គលអាចធ្វើខ្លួនឲ្យសម្រេចនូវប្រយោជន៍ក្នុងលោកនេះខ្លះ ប្រយោជន៍ក្នុងលោកខាងមុខខ្លះ ព្រមទាំងឧបាយដែលឆ្លងផុតចាកលោកផង" ដូច្នេះ រមែងបំពេញកុសល មានទានជាដើម នឹងជាឧបនិស្ស័យនៃទានជាដើមតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន, រមែងជាឧបនិស្ស័យសូម្បីនៃសទ្ធាជាដើម របស់ខ្លួនដែលនឹងកើតតទៅក្នុងពេលខាងមុខ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ***សទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា ជាឧបនិស្សយប្បច្ច័យដល់សទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា*** ។

បទថា **"បរិកម្មំ"** ***អ្នកសិក្សា គប្បីកាន់យកបរិកម្មក្នុងចំណែកខាងដើម មិនមែនជាអនន្តរប្បច្ច័យទេ;*** បរិកម្មនៃទិព្វចក្ខុញ្ញាណនុ៎ះឯង រមែងមានដល់ញាណទាំងពីរនេះ ***គឺយថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ,*** មិនមានបរិកម្មផ្សេងដែលបែកចេញទៅទេ; ញាណទាំង ២ នេះជាបរិវារ

(បរិកណ្ឌញ្ញាណ) នៃទិព្វចក្ខុនោះឯង, កាលទិព្វចក្ខុនោះ សម្រេចហើយ ញាណទាំងពីរនេះ ក៏សម្រេចដែរ ។ កាលបើដូច្នេះ អ្នកសិក្សាគប្បីជ្រាបថា បរិកម្មនៃទិព្វចក្ខុញ្ញាណដែលប៉ះចំពោះការបង្អោនចិត្ត ដើម្បីការដឹងយ៉ាងនោះ ជាបរិកម្មនៃញាណទាំង ២ នេះឯង ។ ព្រោះថា ញាណទាំង ២ នេះ នឹងមានគតិដូចទិព្វចក្ខុគ្រប់យ៉ាង ក៏មិនបាន; ព្រោះហេតុដូច្នោះ ទើបមាន បរិកម្មពិសេស ក្នុងញាណទាំង ២ នោះទៀត ។ ពាក្យថា **“ទិព្វចក្ខុ ទិព្វាយ សោតធាតុយា”** សេចក្ដីថា ទិព្វចក្ខុរបស់បុគ្គលអ្នកឃើញរូបក្នុងទី ឆ្ងាយ ហើយត្រូវការនឹងស្ដាប់សំឡេងនៃរូបទាំងនោះ ជាឧបនិស្សយប្បច្ច័យ ដល់សេចក្ដីដូរផង់នៃសោតធាតុ ។ ក៏ទិព្វសោតធាតុ រមែងជាឧបនិស្សយ-ប្បច្ច័យដល់ឥទ្ធិវិធញ្ញាណ ដោយអំណាចនៃភាពជាអ្នកបានឮសំឡេងនៃរូប ទាំងនោះ ហើយប្រាថ្នានឹងទៅក្នុងទីនោះ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីជា ឧបនិស្សយប្បច្ច័យ ដោយអំណាចនៃសេចក្ដីជាឧបការដល់ធម៌នោះៗ ក្នុងទី ទាំងពួង ដោយប្រការដូច្នេះ ។ ពាក្យថា **“មគ្គំ ឧបនិស្សាយ អនុប្បន្នំ សមាបត្តឹ”** សេចក្ដីថា ព្រះអរិយបុគ្គលណាញុំាងសមាបត្តិនោះៗ ឲ្យកើត ឡើង ព្រោះអន្តរាយក្នុងផ្លូវ ជាសភាពស្រាលស្ដើងហើយ និងលះបានហើយ ដោយមគ្គនោះៗ, ព្រោះហេតុដូច្នោះ មគ្គរបស់ព្រះអរិយបុគ្គលទាំងនោះ ទើបឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សមាបត្តិ ។ បទថា **“វិបស្សន្តិ”**

*គឺរមែងឃើញច្បាស់ ដើម្បីត្រូវការមគ្គខាងលើឡើងទៅ ។ ពាក្យថា* **“អត្ថបដិសម្ភិទា”** *ជាដើម ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយបដិសម្ភិទាទាំងឡាយ ដែលសម្រេចបាន ព្រោះការបានដល់មគ្គនោះឯង ។ ឯមគ្គនោះឯង ឈ្មោះថា ជាឧបនិស្ស័យ ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ ខាងក្រោយបដិសម្ភិទាទាំងនេះ សម្រេចហើយ ដោយប្រការដូច្នេះ ។*

*ពាក្យថា* **“សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ”** *សេចក្ដីថា រមែងញុំាងមានះឲ្យប្រព្រឹត្តទៅថា “យើងជាអ្នកមានសទ្ធាជ្រះថ្លា” ។ ពីរបទថា* **“ទិដ្ឋឹ គណ្ហាតិ”** *សេចក្ដីថា បុគ្គលទៅដោយអំណាចនៃការជឿក្នុងពាក្យនោះៗ មិនពិចារណាសេចក្ដីដោយបញ្ញា គឺកាន់យកទិដ្ឋិ ដោយអំណាចនៃការយល់ឃើញខុសថា “បុគ្គលមាន” ជាដើម ។ ពាក្យថា* **“សីលំ សុតំ ចាគំ បញ្ញំ”** *សេចក្ដីថា កើតមានះឡើងថា យើងជាអ្នកមានសីល ជាអ្នកស្ដាប់ហើយ មានការលះ មានការដឹងគ្រប់យ៉ាង ។ ក៏កាលបុគ្គលញុំាងការសម្គាល់ខុស ដោយអំណាចនៃទិដ្ឋិឲ្យកើតឡើងក្នុងសីលៈ សុតៈ ចាគៈ និងបញ្ញា ដូចការសម្គាល់ខុសដោយអំណាចនៃមានះ រមែងកាន់យកនូវទិដ្ឋិ ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុងពាក្យថា* **“រាគស្ស”** *ជាដើម បណ្ដាទិដ្ឋិ និងមានះទាំងនោះ ធម៌នីមួយៗ ជាឧបនិស្សយប្បច្ច័យដល់រាគៈ ក្នុងវេលាអាស្រ័យសម្បត្តិ មានសទ្ធាជាដើម ហើយលើកតម្កើងខ្លួនឯង, ជាឧប-*

និស្សយប្បច្ច័យដល់ទោសៈ ក្នុងវេលាអាស្រ័យសម្បត្តិ មានសទ្ធាជាដើម ហើយ និយាយចំអកឡុកឡាយដល់អ្នកដទៃ, ជាឧបនិស្សយប្បច្ច័យ ដល់មោហៈ ដែលសម្បយុត្តដោយរាគៈ និងទោសៈទាំង ២, ព្រោះអាស្រ័យមានះ និងទិដ្ឋិមានប្រការដូចបានពោលហើយ អាស្រ័យសម្បត្តិ មានសទ្ធាជាដើម ហើយប្រាថ្នាភវសម្បត្តិ និងភោគសម្បត្តិ ។ ***លោកិយកុសល*** ប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

***ចំណែកលោកុត្តរកុសល ជាធម៌ស្ងប់ ប្រណីត ខ្ពង់ខ្ពស់ កម្ចាត់អកុសលបានដាច់អស់; ព្រោះហេតុដូច្នោះ ទើបមិនជាឧបនិស្សយប្បច្ច័យដល់អកុសល ដូចព្រះចន្ទមិនជាឧបនិស្ស័យដល់ភាពងងឹតដូច្នោះដែរ*** ។ ព្រោះហេតុនោះ លោកុត្តរកុសលនុ៎ះ ទើបព្រះមានព្រះភាគទ្រង់មិនកាន់យកក្នុងអធិការនេះ ។

ពាក្យថា **"អាគារេបតិ"** ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្ដែងអព្យាកតធម៌ ដោយអំណាចនៃកាយិកទុក្ខ; ពិតមែនហើយ អ្នកមានសទ្ធា អាស្រ័យសទ្ធា មិនរួញរា (មិនខ្ជិល) ចំពោះត្រជាក់ពេក, ក្ដៅពេក យកចិត្តទុកដាក់ក្នុងការកសាងជាដើម មានប្រការផ្សេងៗ ឈ្មោះថា ***រមែងធ្វើខ្លួនឱ្យក្ដៅក្រហាយ*** ។ បុគ្គលគិតថា "យើងបានភោគសម្បត្តិហើយ នឹង

ធ្វើបុណ្យ” ឈ្មោះថា ***រមែងសោយទុក្ខ ដោយមានការស្វែងរកជាមូល*** ។ សូម្បីបុគ្គលអ្នកមានសីល ឈ្មោះថា ***រមែងធ្វើខ្លួនឱ្យក្តៅក្រហាយ*** ដោយអំណាចនៃការកាន់ធុតង្គ មានការនៅកណ្តាលវាលជាវត្ត (អព្ភោកាសិកធុតង្គ) ជាដើម, ដើម្បីរក្សាសីល ឈ្មោះថា រមែងសោយទុក្ខដោយមានការស្វែងរកជាមូល ដោយអំណាចនៃការត្រាច់ស្វែងរកអាហារជាដើម ។ សូម្បីបុគ្គលអ្នកស្តាប់ហើយគិតថា “យើងនឹងបដិបត្តិឲ្យសមគួរដល់ភាពជាពហុស្សូត្រ” បដិបត្តិតាមន័យដែលពោលហើយនុ៎ះឯង ឈ្មោះថា ***រមែងធ្វើខ្លួនឱ្យក្តៅក្រហាយ*** ។ ឈ្មោះថា ***រមែងសោយទុក្ខ ព្រោះមានការស្វែងរកជាមូល*** ។ សូម្បីបុគ្គលអ្នកលះបង់ ព្រោះចិត្តបង្អោនទៅក្នុងការបរិច្ចាគ លះបង់រហូតមិនសល់បច្ច័យ (ទ្រព្យសម្បត្តិ) ដែលសម្រាប់ទុកចិញ្ចឹមជីវិតខ្លួន ឬធ្វើការលះបង់នូវអវយវៈជាដើម ឈ្មោះថា ***ធ្វើខ្លួនឱ្យក្តៅក្រហាយ***, ឈ្មោះថា ***រមែងសោយទុក្ខដែលមានការស្វែងរកជាមូល*** ដើម្បីបានមកនូវវត្ថុដែលនាំឲ្យបរិច្ចាគ ។ សូម្បីបុគ្គលអ្នកមានបញ្ញា អាស្រ័យបញ្ញាមិនគិតដល់ត្រជាក់ និងក្តៅជាដើម ព្យាយាមយកចិត្តទុកដាក់ (មនសិការ) ក្នុងការទន្ទេញឲ្យចាំ ដោយគិតថា “យើងនឹងមានបញ្ញាឲ្យខ្ពស់ឡើងៗ” ឈ្មោះថា ***រមែងធ្វើខ្លួនឱ្យក្តៅក្រហាយ*** ។ ឃើញទោសក្នុងមិច្ឆាអាជីវៈ និងអានិសង្សក្នុងសម្មាអាជីវៈ លះមិច្ឆាអាជីវៈ និងរកគ្រឿងចិញ្ចឹមជីវិត

ដោយអាជីវៈដ៏ហ្មត់ចត់ ឈ្មោះថា ***រមែងសោយទុក្ខដែលមានការស្វែងរកជាមូល*** ដែរ ។

ពីរបទថា **"កាយិកស្ស សុខស្ស"** គឺដល់សេចក្ដីសុខផ្លូវកាយ ក្នុងវេលាសេចក្ដីសុខកើតឡើងដល់កាយ ដែលមានរូបដ៏ប្រណីត មានសទ្ធាជាដើម ជាសមុដ្ឋានពាល់ត្រូវហើយ ក្នុងវេលាប្រើប្រាស់ឧបករណ៍នៃសេចក្ដីសុខដែលកើតឡើង ព្រោះអាស្រ័យសម្បត្តិ មានសទ្ធាជាដើម, និងដល់សេចក្ដីសុខផ្លូវកាយដែលមានរូប, មានបាមោជ្ជៈ និងបីតិដែលមានការក្ដៅក្រហាយ ដោយអំណាចនៃឧបករណ៍សេចក្ដីសុខទាំងនោះ ជាមូល ជាសមុដ្ឋានពាល់ត្រូវហើយ, និងដល់សេចក្ដីសុខផ្លូវកាយក្នុងវេលាវិបាកសុខកើតឡើង ព្រោះឧបករណ៍នៃសេចក្ដីសុខទាំងនោះ ធ្វើហើយក្នុងកាលកើតឡើងនៃសេចក្ដីសុខ, និងដល់ទុក្ខផ្លូវកាយ ក្នុងវេលាទុក្ខកើតឡើងតាមន័យដែលពោលហើយនុ៎ះឯង, និងក្នុងវេលាមានការសម្លាប់ ព្រមទាំងចាប់ចងដែលបុគ្គលអ្នកអត់ទ្រាំមិនបាន ដោយគុណសម្បត្តិ មានសទ្ធាជាដើមប្រកបហើយ ។ ក្នុងវេលាផលសមាបត្តិ អាស្រ័យសទ្ធាជាដើមប្រព្រឹត្តទៅធម៌នីមួយៗ មានសទ្ធាជាដើមនេះ គប្បីជ្រាបថា ជាឧបនិស្សយប្បច្ច័យដល់ផលសមាបត្តិ ។ ពីរបទថា **"កុសលំ កម្មំ"** គឺកុសលចេតនា ជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន ។ ប៉ុន្តែចេតនានោះ បានចំពោះតែ

មានកម្លាំងខ្លាំងក្លាប៉ុណ្ណោះ, តែបើមានកម្លាំងខ្សោយ រមែងមិនបានឡើយ ។ ក្នុងសេចក្ដីនោះ មានរឿង (ជាឧទាហរណ៍) ដូចតទៅនេះ ៖

***និយាយតៗ គ្នាមកថា ស្ត្រីម្នាក់មានបំណងនឹងចងកសម្លាប់ខ្លួន ទើបព្យួរខ្សែទុកត្រង់ដើមឈើ ចាត់ចែងរបស់ដែលគួរចាត់ចែង; ពេលនោះ មានចោរម្នាក់គិតថា “ពេលយប់យើងនឹងចូលទៅក្នុងផ្ទះ យកខ្សែមកចងរបស់របរខ្លះ ហើយក៏លួចទៅ” ទើបយកកាំបិតចូលទៅកាត់; លំដាប់នោះ ខ្សែនោះ ក៏បានក្លាយជាពស់មានពិស បញ្ចេញសំឡេងគំរាមថា “សុសុ” ; ចោរខ្លាចមិនហ៊ានចូលទៅ; ស្ត្រីនោះ ចេញអំពីផ្ទះ ស៊កកចូលទៅក្នុងរង្វង់ខ្សែចងកស្លាប់ទៅ; ចេតនាដ៏មានកម្លាំង ហាមនូវអន្តរាយហើយ ជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន ដោយប្រការដូច្នេះ ។***

ប៉ុន្តែ ពាក្យនេះ មិនគួរប្រកាន់ទាល់តែសោះ, ព្រោះថា កម្មដែលបានឱកាសហាមអន្តរាយនៃវិបាកយ៉ាងនេះហើយ រមែងឲ្យផល; ចំណែកកម្មដែលញុំាងវិបាកឲ្យកើត ពោលមិនបានទេថា “មិនជាឧបនិស្សយប្បច្ច័យដល់វិបាក” ។ ក្នុងពាក្យថា “**កម្មំ**” នេះ បណ្ឌិតគប្បីជ្រាបថា បានដល់ កម្មដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ។ ក៏ពាក្យដែលលោកពោលទុកថា ***“មគ្គជាឧបនិស្សយប្បច្ច័យដល់ផលសមាបត្តិ”*** ខាងមុខនោះ, ពោល

*ដោយអំណាចនៃធម៌ដែលមិនមានចេតនា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងទុកថា* ***"ធម៌ដែលញុំាងវិបាកឱ្យកើតឡើងនោះឯងជាឧបនិស្សយប្បច្ច័យដល់វិបាករបស់ខ្លួន"*** *។*

*ពាក្យថា* **"រាគំ ឧបនិស្សាយ បាណំ ហនតិ"** *សេចក្ដីថា ប្រយោជន៍ណា រមែងមានដោយជាសារៈក្នុងវត្ថុណា, ខុសហើយក្នុងវត្ថុនោះ ឬសម្លាប់សត្វដើម្បីប្រយោជន៍នោះ ។ សូម្បីក្នុងអទិន្នាទានជាដើម អ្នកសិក្សាគប្បីជ្រាបសេចក្ដីដោយឧបាយនេះចុះ ។*

*ពាក្យថា* **"សន្ធឹ ឆិន្ទតិ"** *ជាដើម ត្រាស់ទុកដោយអំណាចនៃអទិន្នាទាន ។*

*ពាក្យថា* **"សន្ធឹ"** *ក្នុងអធិការនោះ សំដៅយកជញ្ជាំងផ្ទះ ។*

*ពីរបទថា* **"និល្លោបំ ហរតិ"** *គឺអែបចូលទៅលួច ។*

*ពីរបទថា* **"ឯកាគារិកំ ករោតិ"** *គឺរួមច្រើនៗ នាក់ ឡោមព័ទ្ធប្លន់យកផ្ទះមួយខ្នងប៉ុណ្ណោះ ។*

*ពីរបទថា* **"បរិបន្ថេ តិដ្ឋតិ"** *គឺស្ទាក់រាំងដល់អ្នកដែលធ្វើដំណើរតាមផ្លូវ ។*

*ក្នុងពាក្យថា* **"ទោសំ ឧបនិស្សាយ"** *ជាដើម សេចក្ដីថា ញុំាង*

*ទោសៈឲ្យកើតឡើង ដោយអំណាចនៃការឈឺចិត្ត ខូចចិត្តថា “គេបានសាង* ***ភាពវិនាសអន្តរាយ*** *ឲ្យដល់យើង” ជាដើម ឲ្យជាឧបនិស្ស័យ ។ ពាក្យថា* **“ មោហំ ឧបនិស្សាយ ”** *គឺញុំាងមោហៈដែលបិទបាំងទោសក្នុងបាណាតិបាត ជាដើម ឲ្យជាឧបនិស្ស័យ ។ ពីរបទថា* **“ មានំ ឧបនិស្សាយ ”** *គឺញុំាង មានះថា ធ្វើម្ដេច ទើបសម្លាប់មិនបាន, ធ្វើដូចម្ដេច ទើបយើងលួចមិនបាន ឲ្យជាឧបនិស្ស័យ, ឬអធិប្បាយថា មាននរណាមួយ គេប្រមាថមើលងាយ ហើយ លើកយកការប្រមាថមើលងាយនោះ ឲ្យជាឧបនិស្ស័យខ្លះ ។*

*ពីរបទថា* **“ ទិដ្ឋឹ ឧបនិស្សាយ ”** *គឺធ្វើទិដ្ឋិក្នុងយញ្ញទាំងឡាយ ឲ្យជា ឧបនិស្ស័យ ដូចព្រាហ្មណ៍ទាំងឡាយ និងពួកបារាសិកៈ និងមិលក្ខៈជាដើម ។*

*ពីរបទថា* **“បត្ថនំ ឧបនិស្សាយ ”** *គឺធ្វើការប្រាថ្នាមានជាអាទិ៍យ៉ាង នេះថា “បើការងារដូច្នេះ របស់ខ្ញុំសម្រេច, ខ្ញុំនឹងធ្វើពលិកម្មយ៉ាងនេះដល់ លោក, ឬលោកចូរនាំគ្រឿងបួងសួងទេវតាប្រភេទនោះ មកឲ្យខ្ញុំ, ឬក៏ចូរ នាំយកទៅឲ្យបុគ្គលឯណោះ, ឬថា ចូរលោកមករួមជាសម្លាញ់របស់យើង ដែលកំពុងធ្វើការងារទាំងនេះ” ឲ្យជាឧបនិស្ស័យ ។ ក្នុងពាក្យថា* **“រាគោ ទោសោ មោហោ មានោ ទិដ្ឋិ បត្ថនា រាគស្ស”** *នេះ រាគៈជាឧបនិស្ស័យ ដល់រាគៈផង និងដល់ធម៌មានទោសៈជាដើមផង ។ សូម្បីក្នុងទោសៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ពីរបទថា* **“បាណាតិបាតោ បាណាតិបាតស្ស”** *សេចក្ដីថា បុគ្គលអ្នកសម្លាប់សត្វ រមែងសម្លាប់សត្វដទៃទៀត ព្រោះតាំងនៅក្នុងសេចក្ដីមិនសង្រួម ឬថារមែងសម្លាប់ញាតិមិត្តរបស់អ្នកដែលត្រូវគេសម្លាប់ហើយប្រទូសរ៉ាយជាបន្តទៅទៀត ។ បាណាតិបាត ជាឧបនិស្សយប្បច្ច័យដល់បាណាតិបាត ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត* ***បាណាតិបាត ជាឧបនិស្សយប្បច្ច័យដល់អទិន្នាទានជាដើម*** *ក្នុងវេលាសម្លាប់ម្ចាស់របស់ ឬអ្នកចាំយាំល្បួចរបស់គេ, ក្នុងការសម្លាប់ស្វាមីគេ ហើយលួងលោមយកភរិយាគេ, ក្នុងវេលានិយាយកុហកថា “មិនបានសម្លាប់” ជាដើម, ក្នុងវេលានិយាយញុះញង់ ដើម្បីបិទបាំងកម្មដែលខ្លួនឯងធ្វើហើយ ឬដើម្បីត្រូវការធ្វើកម្មដែលមិនបានធ្វើក្នុងវេលានិយាយពាក្យទ្រគោះបោះបោក ពាក្យរោយរាយឥតប្រយោជន៍ ដោយន័យនោះ ក្នុងវេលាសម្លឹងរំពៃ ប្រាថ្នាចង់បាននូវសម្បត្តិរបស់អ្នកដទៃ, ក្នុងវេលាគិតថា “កាលគេត្រូវ (យើង) សម្លាប់ឲ្យស្លាប់ហើយ, ញាតិមិត្តសម្លាញ់អាមាត្យ (បរិវារ) គេ ក៏សូន្យទៅអស់” ជាដើម និងក្នុងវេលាប្រកាន់សេចក្ដីយល់ឃើញខុស ដោយអំណាចនៃអ្នកធ្វើកម្មដែលធ្វើបានដោយលំបាកថា “បាណាតិបាត របស់យើងនឹងធ្ងន់ណាស់ ដោយអាការយ៉ាងនេះ” ជាដើម ។ បណ្ឌិតគប្បីជ្រាបការប្រព្រឹត្តទៅនៃធម៌ មានអទិន្នាទានជាដើមជាមូល ដោយឧបាយនេះចុះ ។*

ពីរបទថា **"មាតុឃាតកម្មំ មាតុឃាតកម្មស្ស"** សេចក្ដីថា មាតុ-ឃាតកម្ម ជាឧបនិស្សយប្បច្ច័យដល់មាតុឃាតកម្ម ចំពោះបុគ្គលដែលឃើញអ្នកដទៃសម្លាប់មាតា ហើយសម្លាប់នូវមាតារបស់ខ្លួនខ្លះ, យល់ថា "ការធ្វើយ៉ាងនោះ សមគួរ" ឬដោយអំណាចនៃការសម្លាប់ក្នុងភពមួយ ហើយសម្លាប់ក្នុងភពដទៃទៀត ឬក៏ក្នុងភពជាមួយគ្នា ដោយអំណាចនៃការប្រាប់រឿយៗ ថា "ចូរលោកទៅសម្លាប់មាតារបស់យើង" ឬថាដោយអំណាចនៃការប្រហារជាលើកទី ២ ដើម្បីឲ្យស្លាប់ជាប្រាកដ ដោយការប្រហារ ២ លើក ។ សូម្បីបទដែលនៅសល់ អ្នកសិក្សាគប្បីជ្រាបសេចក្ដីដ៏សមគួរតាមដែលពោលហើយដោយន័យនេះចុះ ។

អាចារ្យពួកខ្លះពោលថា "អកុសលដ៏មានកម្លាំង មិនជាឧបនិស្សយ-ប្បច្ច័យដល់អកុសលដែលមានកម្លាំងខ្សោយទេ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទេសនាទុក ដោយអំណាចនៃអនន្តរិយកម្ម ដែលជាប់ដោយកម្មបថប៉ុណ្ណោះ" ដូច្នេះ មិនគួរប្រកាន់យកដោយពិតប្រាកដទេ ។ ព្រោះថា បុគ្គលធ្វើកម្ម មានបាណាតិបាតជាដើមហើយ ត្រូវគេដាស់តឿនក្រើនរំលឹកថា "ហេតុអ្វី ទើបបានជាធ្វើកម្មយ៉ាងនោះ" រមែងសំដែងអាការក្រោធខ្លះ, ក្ដៅក្រហាយខ្លះ; កាលបើកិលេសមានប្រមាណតូចកើតឡើងហើយ គេបណ្ដោយឲ្យកិលេសនោះពង្រីកខ្លួន មិនព្រមធ្វើការសង្កត់សង្កិនទេ;

ព្រោះហេតុដូច្នោះ អកុសលដ៏មានកម្លាំង រមែងជាឧបនិស្សយប្បច្ច័យដល់អកុសលដែលមានកម្លាំងខ្សោយ និងអកុសលដែលមានកម្លាំងខ្សោយក៏រមែងជាឧបនិស្សយប្បច្ច័យ សូម្បីដល់អកុសលដែលមានកម្លាំងខ្លាំងដូចគ្នាដែរ; ក៏ពាក្យណា ដែលលោកពោលទុកក្នុងវណ្ណនានិទ្ទេសនៃបច្ចយវិភង្គថា "ធម៌ ដែលឈ្មោះថា ជាឧបនិស្សយប្បច្ច័យ ព្រោះអត្ថថា ជាហេតុមានកម្លាំង" , ពាក្យនោះ លោកពោលទុក ព្រោះភាវៈជាហេតុប៉ុណ្ណោះ មានកម្លាំង, មិនមែនព្រោះតួបច្ចយធម៌ដែលជាទីចូលទៅអាស្រ័យទេ ។ ***ពិតមែនហើយ កម្ម និងកិលេសទាំងឡាយ ដែលមានកម្លាំងខ្លាំងក្តី ដែលមានកម្លាំងខ្សោយក្តី ចាត់ថា ជាហេតុដែលមានកម្លាំងខ្លាំងទាំងអស់*** ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុងពាក្យថា **"រាគំ ឧបនិស្សាយ ឆានំ ឧេតិ"** ជាដើម ដូចតទៅ ៖

បុគ្គលចូលទៅអាស្រ័យនូវសេចក្តីត្រេកអរក្នុងឧបបត្តិភព ឬក្នុងភោគទាំងឡាយថា "ធ្វើដូចម្តេចហ្ន៎ ទើបយើងចូលដល់ភាពជាសម្លាញ់ របស់ពួកទេវតាជាន់ចាតុម្មហារាជិកាជាដើម" ដូច្នេះ ហើយទើបឲ្យទាន; សូម្បីក្នុងការសមាទានសីល និងរក្សាឧបោសថជាដើម ក៏មានន័យដូចគ្នានេះដែរ; ក៏បុគ្គលកាលធ្វើឈានឲ្យកើត ដើម្បីត្រូវការសង្កត់នូវរាគៈ, ធ្វើវិបស្សនាឲ្យកើតដើម្បីត្រូវការលះរាគៈ, ធ្វើមគ្គឲ្យកើត ដើម្បីត្រូវការកាត់ផ្តាច់នូវភព

កាត់ផ្តាច់នូវជាតិ ឈ្មោះថា ***ចូលទៅអាស្រ័យភាគៈ*** ធ្វើឲ្យកើតឡើង ។ ម្យ៉ាងទៀត កាលបើញ៉ាំងអភិញ្ញា និងសមាបត្តិឲ្យកើត ***ដើម្បីត្រូវការឱ្យប្រាសចាកភាគៈ*** ក៏ឈ្មោះថា ***ចូលទៅអាស្រ័យភាគៈ*** ឲ្យកើតឡើងដូចគ្នា ។ ពិតមែនហើយ ដោយសេចក្តីត្រូវការប៉ុណ្ណេះ អ្នកនោះ រមែងជាអ្នកប្រាសចាកភាគៈបាន ។

បទថា **“សទ្ធាយ”** គឺការជឿដែលប្រព្រឹត្តទៅដោយអំណាចនៃទានជាដើម; សូម្បីក្នុងសីលជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ដូចកាលញ៉ាំងសទ្ធាជាដើម ឲ្យកើតដោយអំណាចនៃទានជាដើម ឈ្មោះថា ចូលទៅអាស្រ័យភាគៈឲ្យកើត យ៉ាងណា, អ្នកសិក្សាគប្បីជ្រាបថា សូម្បីភាគៈជាដើម ក៏ឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សទ្ធាជាដើមដូច្នោះដែរ ។

ពីរបទថា **“ តស្ស បដិឃាតត្ថាយ”** គឺដើម្បីហាមនូវវិបាកនោះ, អធិប្បាយថា ដើម្បីមិនឲ្យឱកាសនៃវិបាកកើតឡើង; ក្នុងសប្បដិឃាតធម៌ទាំងឡាយ មានអធិប្បាយត្រឹមតែប៉ុណ្ណេះ ។ ***សួរថា*** អនន្តរិយកម្មពួកណាមិនមានបដិឃាត, ហេតុអ្វីទើបបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា **“តស្ស បដិឃាតត្ថាយ”** ទុកក្នុងអនន្តរិយកម្មទាំងនោះ ? ឆ្លើយថា ត្រាស់ទុកដោយអំណាចនៃអជ្ឈាស្រ័យរបស់បុគ្គលនោះ ។ ពិតមែនហើយ បុគ្គលនោះរមែងមានអជ្ឈាស្រ័យថា “ នឹងប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់ការកម្ចាត់

បង់នូវ (វិបាក) នោះចេញ” ។ ព្រះមានព្រះភាគទ្រង់កាន់យកអធ្យាស្រ័យនោះ ទើបត្រាស់ទុកយ៉ាងនេះ ។ ពាក្យថា **“ វាគំ ឧបនិស្សាយ អត្តានំ អាតាបេតិ ”** អ្នកសិក្សា គប្បីជ្រាបសេចក្តីទាំងអស់ ដោយន័យមុននោះ ដូចគ្នាថា បុគ្គលឃើញនូវចំណែកបុណ្យ ក៏ជាការធ្វើបានដោយលំបាករបស់អ្នកត្រេកអរហើយ ក្នុងសម្បត្តិណា រមែងធ្វើយ៉ាងនោះខ្លះ ។

ពីរបទថា **“កាយិកស្ស សុខស្ស”** គឺសេចក្តីសុខដែលបាន ព្រោះការធ្វើកុសល ដោយអំណាចនៃការឈានកន្លងអកុសល មានរាគៈជាដើម ឬថា ដោយអំណាចនៃការបរិភោគកាម របស់បុគ្គលដែលនៅមិនឃើញទោស ដោយអំណាចនៃរាគៈជាដើម ។ បទថា **“ ទុក្ខស្ស ”** គឺសេចក្តីទុក្ខដែលកើតឡើង ដោយអំណាចនៃការដុតកម្តៅកិលេសជាដើម (ការធ្វើខ្លួនឯងឲ្យក្តៅក្រហាយ) ឬសេចក្តីទុក្ខដែលកើតឡើង ដោយអំណាចនៃការសម្លាប់និងការចាប់ចង ដែលប្រព្រឹត្តទៅព្រោះហេតុនៃរាគៈជាដើម ។ បទថា **“ផលសមាបត្តិយា ”** សំដៅដល់គុណធម៌ដែលយោគាវចរឲ្យកើតឡើង ព្រោះកាត់ផ្តាច់កិលេស មានរាគៈជាដើមបាន ឬសំដៅដល់គុណជាតិដែលលោកដល់ព្រមហើយដោយការនឿយណាយ ចំពោះរាគៈជាដើមនោះហើយ ។ ពីរបទថា **“កាយិកំ សុខំ ”** ជាដើម សេចក្តីថា កាលបើសេចក្តីសុខកើតឡើង បុគ្គលត្រេកអរចំពោះសេចក្តីសុខនោះ ធ្វើសេចក្តីសុខនោះ ឲ្យកើតរឿយៗ

ដោយបច្ច័យតែម្យ៉ាងដូចគ្នានោះឯង សេចក្ដីសុខកាលមុន ឈ្មោះថា ជាឧបនិស្សយប្បច្ច័យដល់សេចក្ដីសុខគ្រាក្រោយ ។

ក៏ក្នុងភាពត្រជាក់ជាដើម កាលបើបុគ្គលសេពច្រើនពេកទៅ នូវភាពក្ដៅមានការក្ដៅព្រោះភ្លើងជាដើម សេចក្ដីសុខខាងដើម រមែងជាឧបនិស្សយ-ប្បច្ច័យដល់សេចក្ដីទុក្ខខាងក្រោយ ។ ម្យ៉ាងទៀត ក្នុងអធិការនេះ កាយិក-សុខរបស់បុគ្គលអ្នកស្រវឹងក្នុងកាមទាំងឡាយថា "សម្ផស្សនៃដៃដែលមានរោមដ៏ទន់របស់បរិព្វាជិកានេះ ជាសុខពិតហ្ន៎" ដូច្នេះ រមែងជាឧបនិស្សយ-ប្បច្ច័យនៃកាយិកទុក្ខក្នុងនរក ។ ចំណែកព្រះយោគីអ្នកមានសេចក្ដីសុខព្រោះមិនមានរោគ ចូលផលសមាបត្តិ, កាយិកសុខរមែងជាឧបនិស្សយ-ប្បច្ច័យដល់ផលសមាបត្តិ ។

ក៏កាលបុគ្គលសេពនូវសេចក្ដីសុខ ដើម្បីកម្ចាត់ទុក្ខ ដូចព្រះមាន-ព្រះភាគចូលផលសមាបត្តិរម្ងាប់អាពាធ ដើម្បីកម្ចាត់ទុក្ខ កាយិកទុក្ខរមែងជាឧបនិស្សយប្បច្ច័យដល់កាយិកសុខ និងផលសមាបត្តិ ។ រដូវដែលជាទីសប្បាយ រមែងជាឧបនិស្សយប្បច្ច័យដល់សុខ និងផលសមាបត្តិ, ឯរដូវដែលមិនជាទីសប្បាយ រមែងជាឧបនិស្សយប្បច្ច័យដល់ទុក្ខ ។ ម្យ៉ាងទៀត កាលបើបុគ្គលប្រាថ្នាសោយសេចក្ដីសុខដែលកើតហើយ ដោយអំណាចនៃរូបដែលតាំងនៅក្នុងសមាបត្តិ ដោយគ្របសង្កត់ការមិនសប្បាយទុក ព្រោះរដូវ សូម្បីរដូវមិនជាទីសប្បាយ (របស់លោក) ក៏ជាបច្ច័យដល់ផលសមាបត្តិ

បានដូចគ្នា ។ សូម្បីក្នុងភោជន និងសេនាសនៈ ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា **“កាយិកំ សុខំ”** ជាដើម ព្រះមានព្រះភាគទ្រង់សម្ដែងទុករួមគ្នាដោយចំពោះទៀត ។ ប៉ុន្តែ អ្នកសិក្សាគប្បីជ្រាបសេចក្ដីនៃធម៌ទាំងនោះជាបច្ច័យ តាមន័យដែលពោលហើយអំពីខាងដើមដូចគ្នា ។ ពាក្យថា **“ផលសមាបត្តិ កាយិកស្ស សុខស្ស”** គឺសេចក្ដីសុខដែលកើតឡើង ដោយអំណាចនៃរូបដែលមានសមាបត្តិជាសមុដ្ឋាន; ពិតមែនហើយ យោគីចេញពីសមាបត្តិហើយ រមែងបានសោយនូវសេចក្ដីសុខនោះ ។

ក្នុងពាក្យថា **“កាយិកំ ឧបនិស្សាយ សុខំ ឆានំ”** ជាដើម អ្នកសិក្សាគប្បីជ្រាបសេចក្ដីសុខ និងសេចក្ដីទុក្ខ ជាឧបនិស្សយប្បច្ច័យដោយអំណាចនៃសុខដែលបានទទួលហើយ នៅមិនទាន់សាបសូន្យទៅថា “ហៃតុអ៊ីហ្ន៎ ! សេចក្ដីសុខរបស់យើងនេះ មិនគប្បីសាបសូន្យទៅ” ឬដោយអំណាចនៃការបានដល់សុខដែលខ្លួននៅមិនទាន់បានថា “ធ្វើដូចម្ដេចហ្ន៎ ! យើងគប្បីចូលដល់សេចក្ដីសុខយ៉ាងនេះ ក្នុងកាលតទៅ” ; សូម្បីក្នុងទុក្ខ ក៏គប្បីជ្រាបដោយអំណាចនៃការសាបសូន្យទៅថា “ធ្វើដូចម្ដេចហ្ន៎ ! ទុក្ខគប្បីសាបសូន្យទៅ” ឬដោយអំណាចនៃការប្រាថ្នាមិនឲ្យទុក្ខកើតថា “ទុក្ខយ៉ាងនេះ មិនគប្បីកើតតទៅទៀតទេ” ។ រដូវ ភោជន និងសេនាសនៈ មានន័យដូចពោលហើយនុ៎ះឯង ។ សូម្បីក្នុងពាក្យថា **“កាយិកំ សុខំ”** ជាដើមទៀត

មានសេចក្តីថា ព្រោះសទ្ធារមែងកើតឡើងដល់បុគ្គលដែលបានដល់នូវសុខ ដូចក្នុងពាក្យថា "ម្នាលមោគ្គល្លានអ្នកនិរទុក្ខ ការចូលដល់នូវព្រះពុទ្ធជាសរណៈនោះ ជាការល្អ"[៣] ដូច្នេះ, រមែងកើតដល់បុគ្គលដែលដល់ហើយនូវទុក្ខក៏បាន ដូចក្នុងពាក្យថា "ព្រះមានព្រះភាគអ្នកត្រាស់ដឹងប្រពៃ ចំពោះព្រះអង្គឯងនោះ ទ្រង់សម្តែងធម៌ដើម្បីកំណត់ដឹងនូវទុក្ខយ៉ាងនេះ"[៤] ។ ម្យ៉ាងទៀត បុគ្គលរមែងធ្វើធម៌ឲ្យបរិបូណ៌ក្នុងសីលជាដើម ដើម្បីប្រកបខ្លួនទុកក្នុងសុខ និងប្រាសចាកអំពីសេចក្តីទុក្ខ, ព្រោះហេតុដូច្នោះ សុខ និងទុក្ខ ទើបព្រះមានព្រះភាគទ្រង់សម្តែងថា ជាឧបនិស្ស័យនៃសទ្ធាជាដើម; សូម្បីវដ្តូវជាដើម អ្នកសិក្សា គប្បីប្រកបអធិប្បាយតាមសមគួរចុះ ។ សូម្បីក្នុងពាក្យថា **"កាយិកំ សុខំ ឧបនិស្សាយ បាណំ ហនតិ"** ជាដើម គប្បីជ្រាបនូវសេចក្តីសុខជាដើម ដោយភាវៈជាឧបនិស្សយប្បច្ច័យ តាមគន្លងន័យដែលខ្ញុំពោលហើយនុ៎ះឯង ។ ក្នុងបទភាជនិយនៃឧបនិស្សយ-ប្បច្ច័យនេះ អ្នកសិក្សា គប្បីជ្រាបថា ឧបនិស្សយប្បច្ច័យទាំង ៣ ទ្រង់ចែកទុក ២៣ វារៈ គឺកុសល ៨, អកុសល ៦, អព្យាកតៈ ៩ នេះ គឺកុសលជាបច្ច័យដល់កុសល ក៏ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ៣ វារៈដែរ, គឺអកុសល ២ វារៈ និងដល់អព្យាកតៈ ៣ វារៈ; សូម្បីអកុសលជាបច្ច័យ

---

[៣] សំ. សឡា. ។

[៤] ខ. ឧ. ។

*ដល់អកុសល ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ៣ វារៈ, ដល់កុសល ១ វារៈ និងដល់អព្យាកតៈ ២ វារៈ, សូម្បីអព្យាកតៈ ក៏ជាបច្ច័យដល់អព្យាកតៈដោយអំណាចនៃឧបនិស្សយប្បច្ច័យ ៣ វារៈ, ដល់កុសល ៣ វារៈ និងដល់អកុសល ៣ វារៈ ៕*

ចប់ឧបនិស្សយប្បច្ច័យ

---

## ពណ៌នាអំពីបុរេជាតប្បច្ច័យ

*ក្នុង **បុរេជាតប្បច្ច័យ** សូម្បីចក្ខាយតនៈជាដើម ព្រះមានព្រះភាគត្រាស់សម្ដែងទុកដោយអំណាចនៃរូបគ្រោតគ្រាត, ចំណែកអាបោធាតុជាដើម ជាអារម្មណបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ ចំណែកវត្ថុបុរេជាតពាក្យថា* **“ ចក្ខាយតនំ ”** *ជាដើម ព្រះមានព្រះភាគត្រាស់សម្ដែងទុកដើម្បីសម្ដែងចក្ខាយតនៈជាដើមនោះថា ជាវត្ថុរូបដែលកើតមុន ។ ពាក្យថា* **“ វត្ថុវិបាកាព្យាកតានំ ”** *គឺវត្ថុជាបច្ច័យដល់វិបាកាព្យាកតៈ ត្រាស់សំដៅដល់បុរេជាតប្បច្ច័យក្នុងបវត្តិកាល ៕*

ចប់បុរេជាតប្បច្ច័យ

…………………………

## ពណ៌នាអំពីបច្ឆាជាតប្បច្ច័យ

*ក្នុង* ***បច្ឆាជាតប្បច្ច័យ*** *ពាក្យថា* **“ឥមស្ស កាយស្ស”** *បានដល់កាយដែលប្រកបដោយមហាភូតរូប ៤ ។ ពាក្យថា* **“បច្ឆាជាតប្បច្ចយេន បច្ចយោ”** *សេចក្ដីថា ជាធម៌ដែលកើតខាងក្រោយ និងជាបច្ច័យដោយអំណាចនៃការឧបត្ថម្ភ ។ បច្ឆាជាតប្បច្ច័យនេះ មានមកហើយដោយអនុលោម ក្នុងបញ្ហាវារៈនេះថា ភាវៈជាបច្ច័យ ព្រោះអត្ថថា ឧបត្ថម្ភនេះឯងឈ្មោះថា* ***បច្ឆាជាតប្បច្ច័យ*** *៕*

ចប់បច្ឆាជាតប្បច្ច័យ

## ពណ៌នាអំពីអាសេវនប្បច្ច័យ

*ក្នុងការកាន់យកពាក្យជាដើមថា* **“អនុលោមំ គោត្រភុស្ស** *= អនុលោមជាបច្ច័យដល់គោត្រភូ” ក្នុង* ***អាសេវនប្បច្ច័យ*** *ចែកចេញទៅជាចំណែកមួយៗ គប្បីជ្រាបហេតុនៃការចែកចេញទៅនោះ ដោយន័យដែលពោលទុកអំពីខាងដើមចុះ ៕*

ចប់អាសេវនប្បច្ច័យ

..............................

## ពណ៌នាអំពីកម្មប្បច្ច័យ

*ក្នុងពាក្យថា* **“កុសលា ចេតនា សម្បយុត្តកានំ”** *នេះ ក្នុងកម្មប្បច្ច័យ* ***ចេតនា*** *ព្រះមានព្រះភាគមិនត្រាស់ថា សហជាត** *ព្រោះមិនមានការបែកជាសហជាតកម្មប្បច្ច័យ និងនានក្ខណិកកម្មប្បច្ច័យទេ; ប៉ុន្តែ ក្នុងការវិសជ្ជនាអព្យាកតធម៌ មានការបែក (វិភាគ) នោះ, ព្រោះហេតុដូច្នោះ ចេតនាដែលជាសហជាត និងនានក្ខណិកៈ ទើបព្រះមានព្រះភាគត្រាស់ទុក ក្នុងវារៈនោះ ។* ***បដិសន្ធិ*** *សព្វ ទ្រង់ត្រាស់សម្តែងទុកដោយអំណាចនៃកដត្តារូប ។*

*ពីរបទថា* **“ចេតនា វត្ថុស្ស”** *គឺចេតនាជាបច្ច័យដល់វត្ថុ ទ្រង់ត្រាស់សម្តែងទុកដើម្បីបង្ហាញឲ្យឃើញថា អរូបធម៌អាស្រ័យវត្ថុ ក្នុងបដិសន្ធិខណៈរមែងប្រព្រឹត្តទៅ ព្រោះវត្ថុជាបច្ច័យ ក៏ពិតមែន, ប៉ុន្តែ ចេតនា ក៏ជាបច្ច័យដល់វត្ថុបានដែរ ។ សូម្បីក្នុងវិបាកប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបសេចក្តីក្នុងបដិសន្ធិវារៈ ដោយន័យនេះចុះ ៕*

### ចប់កម្មប្បច្ច័យ

.......................

* បាលីហៅថា នានាក្ខណិកៈ ។

## ពណ៌នាអំពីអាហារប្បច្ច័យ

*ពីរបទថា* **“ឥមស្ស កាយស្ស”** *ក្នុង* ***អាហារប្បច្ច័យ*** *សេចក្ដីថា ជាបច្ច័យដោយអំណាចនៃអាហារប្បច្ច័យ ព្រោះការញ៉ាំងរូបដែលមានអាហារជាសមុដ្ឋានឲ្យកើតឡើង (ជនកសត្តិ), ដោយអំណាចនៃឧបការៈ ឧបត្ថម្ភដល់រូបដ៏សេស; ក្នុងកាយដែលសម្រេចដោយមហាភូតរូប ៤ នេះ, ក្នុងបវត្តិកាលដោយអំណាចនៃសន្តតិ ៤ ។*

*សូម្បីក្នុង* ***ឥន្ទ្រិយប្បច្ច័យ*** *ជាដើម អ្នកសិក្សាគប្បីជ្រាបបដិសន្ធិវារៈតាមដែលខ្ញុំពោលទុកហើយនោះឯង ។ ពាក្យដែលនៅសល់ ក្នុងទីទាំងពួងមានសេចក្ដីភ្លឺច្បាស់ហើយមែនពិត ៕*

ចប់អាហារប្បច្ច័យ

...............

# អធិប្បាយការរាប់វារៈក្នុងអនុលោម

## ត្រូវយជនានៃបញ្ហាវារៈ

### ហេតុមូលកន័យ

*ឥឡូវនេះ ដើម្បីនឹងសម្ដែងវិសជ្ជនាតាមដែលបានពោលហើយ ក្នុងបញ្ហាវារៈនេះ ដោយអំណាចនៃការរាប់ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា* **“ហេតុយា សត្ត** *= ក្នុងហេតុប្បច្ច័យមាន ៧ វារៈ” ជាដើម; បណ្ដាបទទាំងនោះ បទថា* **“សត្ត”** *បានដល់មានវិសជ្ជនា ៧ វារៈ យ៉ាងនេះ គឺវិសជ្ជនា ៣ វារៈ បានដល់កុសលជាមួយកុសល, អព្យាកតៈជាមួយកុសល និងកុសលាព្យាកតៈជាមួយកុសល ។ អកុសលមាន ៣ វារៈ ដូចគ្នានឹងអកុសលដែរ; អព្យាកតៈជាមួយអព្យាកតៈ មាន ១ វារៈប៉ុណ្ណោះ ។*

*ពីរបទថា* **“អារម្មណេ នវ”** *គឺក្នុងអារម្មណប្បច្ច័យមានវិសជ្ជនា ៩ វារៈ ដែលគ្រប់ៗ វារៈ មានបទដើម ១ បទ, បទអវសាន (ចុង) ១ បទ ។ ពីរបទថា* **“អធិបតិយា ទស”** *បានដល់ក្នុងអធិបតីមានវិសជ្ជនា ១០ វារៈយ៉ាងនេះ គឺវិសជ្ជនា ៤ វារៈ ដែលមានកុសលជាមូល គឺកុសលជាបច្ច័យដល់កុសល ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ, ជាបច្ច័យដល់អកុសល ដោយអារម្មណប្បច្ច័យប៉ុណ្ណោះ, ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ និងដោយអារម្មណប្បច្ច័យ, ជាបច្ច័យដល់កុសលា-*

ព្យាកតៈ ដោយសហជាតប្បច្ច័យប៉ុណ្ណោះ ។ វិសជ្ជនា ៣ វារៈ ដែលមាន អកុសលជាមូល គឺអកុសលជាបច្ច័យដល់អកុសល ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ, ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ ប៉ុណ្ណោះ, ជាបច្ច័យដល់អកុសលាព្យាកតៈ ដោយសហជាតប្បច្ច័យប៉ុណ្ណោះ; ឯវិសជ្ជនា ៣ វារៈដែលមានអព្យាកតៈជាមូល គឺអព្យាកតៈជាបច្ច័យ ដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ, ជាបច្ច័យ ដល់កុសល ដោយអារម្មណប្បច្ច័យប៉ុណ្ណោះ, ជាបច្ច័យដល់អកុសល ដោយ អារម្មណប្បច្ច័យដូចគ្នា; ក្នុងអធិបតិប្បច្ច័យនេះ រមែងបានអារម្មណាធិបតី ៧ វារៈ និងសហជាតាធិបតី ៧ វារៈ ដូចគ្នា ។

ពីរបទថា **“អនន្តរេ សត្ត”** បានដល់ ក្នុងអនន្តរប្បច្ច័យ មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺវិសជ្ជនា ២ វារៈ មានកុសលជាមូល, វិសជ្ជនា ២ វារៈ មានអកុសលជាមូល, វិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ។ សូម្បី ក្នុងសមនន្តរប្បច្ច័យ ក៏មានវិសជ្ជនាទាំង ៧ វារៈនេះ ដូចគ្នាដែរ ។

ពីរបទថា **“សហជាតេ នវ”** សេចក្ដីថា ក្នុងសហជាតប្បច្ច័យមាន វិសជ្ជនា ៩ វារៈយ៉ាងនេះ គឺវិសជ្ជនាមានកុសលជាមូល ៣ វារៈ, មាន អកុសលជាមូល ៣ វារៈ, មានអព្យាកតៈជាមូល ១ វារៈ, មានកុសលា- ព្យាកតៈជាមូល ១ វារៈ និងមានអកុសលាព្យាកតៈជាមូល ១ វារៈទៀត ។

ពីរបទថា **"អញ្ញមញ្ញេ តីណិ"** បានដល់ ក្នុង ***អញ្ញមញ្ញប្បច្ច័យ មានវិសជ្ជនា ៣ វារៈ*** យ៉ាងនេះ គឺកុសលជាមួយកុសល ១ វារៈ, អកុសលជាមួយអកុសល ១ វារៈ និងអព្យាកតៈជាមួយអព្យាកតៈ ១ វារៈ ។

ពីរបទថា **"និស្សយេ តេរស"** សេចក្ដីថា ក្នុងនិស្សយប្បច្ច័យ មានវិសជ្ជនា ១៣ វារៈយ៉ាងនេះ គឺវិសជ្ជនាដែលមានកុសលជាមូល ៣ វារៈ, មានអកុសលជាមូល ៣ វារៈ និងមានអព្យាកតៈជាមូល ៣ វារៈ ដោយសហជាតប្បច្ច័យនោះឯង ។ ក្នុងវិសជ្ជនាមានអព្យាកតៈជាមូលនេះ រមែងបានបុរេជាតប្បច្ច័យផង ។ ពិតមែនហើយ អព្យាកតៈជាមួយអព្យាកតៈ ជាសហជាតនឹងគ្នាក៏បាន, ជាបុរេជាតនឹងគ្នាក៏បាន ។ អព្យាកតៈ ជាបច្ច័យដល់កុសលដោយបុរេជាតប៉ុណ្ណោះ, ***ជាបច្ច័យ*** ដល់អកុសល ក៏ដូចគ្នា ។ កុសលាព្យាកតៈ ជាបច្ច័យដល់កុសល ដោយសហជាត និងបុរេជាត, ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប៉ុណ្ណោះ, អកុសលាព្យាកតៈ ជាបច្ច័យដល់អកុសលដោយសហជាត និងបុរេជាត, ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតតែម្យ៉ាង ។

ពីរបទថា **"ឧបនិស្សយេ នវ"** សេចក្ដីថា ក្នុង ***ឧបនិស្សយប្បច្ច័យ មានវិសជ្ជនា ៩ វារៈ*** គ្រប់ៗ វារៈ មានបទដើម ១ បទ និងបទអវសាន ១ បទ ។ ក្នុងវិភង្គនៃបច្ច័យទាំងនោះ ព្រះមានព្រះភាគទ្រង់សម្ដែងប្រភេទទុក ២៣ វារៈ; បណ្ដាវារៈទាំងនោះ អារម្មណូបនិស្សយប្បច្ច័យ មាន ៧

វារៈ, អនន្តរូបនិស្សយប្បច្ច័យមាន ៧ វារៈ, បកតូបនិស្សយប្បច្ច័យមាន ៩ វារៈ ។

ពីរបទថា **“បុរេជាតេ តីណិ”** សេចក្ដីថា ក្នុងបុរេជាតប្បច្ច័យមានវិសជ្ជនា ៣ វារៈយ៉ាងនេះ គឺអព្យាកតៈជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈជាបច្ច័យដល់កុសល, អព្យាកតៈជាបច្ច័យដល់អកុសល ។

ពីរបទថា **“បច្ឆាជាតេ តីណិ”** សេចក្ដីថា ក្នុងបច្ឆាជាតប្បច្ច័យមានវិសជ្ជនា ៣ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យដល់អព្យាកតៈ, អកុសលជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈជាបច្ច័យដល់អព្យាកតៈ ។

ពីរបទថា **“អាសេវនេ តីណិ”** គឺក្នុង ***អាសេវនប្បច្ច័យ មានវិសជ្ជនា ៣ វារៈ*** ដូចគ្នានឹងអញ្ញមញ្ញប្បច្ច័យដែរ ។

ពីរបទថា **“កម្មេ សត្ត”** គឺក្នុង កម្មប្បច្ច័យមានវិសជ្ជនា ៧ វារៈ ដូចហេតុប្បច្ច័យដែរ; បណ្ដាវិសជ្ជនាទាំង ៧ វារៈនោះ នានក្ខណិកកម្មប្បច្ច័យមានមកក្នុងវិសជ្ជនា ២ វារៈ ។ ក្នុង ៥ វារៈ ដែលនៅសល់ បានចំពោះតែសហជាតប្បច្ច័យប៉ុណ្ណោះ ។

ពីរបទថា **“វិបាកេ ឯកំ”** បានដល់ វិបាកប្បច្ច័យមាន ១ វារៈ គឺអព្យាកតៈជាមួយអព្យាកតៈ ។

ក្នុង ***អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ***

បច្ច័យនីមួយៗ មាន ៧ វារៈ ដូចគ្នានឹងហេតុប្បច្ច័យដែរ; ក៏ក្នុងអធិការនេះ ឥន្ទ្រិយប្បច្ច័យមានមកដោយអំណាចនៃសហជាត និងបុរេជាត ។

ពីរបទថា **“សម្បយុត្តេ តីណិ** = ក្នុងសម្បយុត្តប្បច្ច័យ មាន ៣ វារៈ” បានដល់ ***ក្នុងសម្បយុត្តប្បច្ច័យ មានវិសជ្ជនា ៣ វារៈ*** ដូចគ្នានឹងអញ្ញមញ្ញប្បច្ច័យដែរ ។

ពីរបទថា **“វិប្បយុត្តេ បញ្ច”** សេចក្តីថា ***ក្នុងវិប្បយុត្តប្បច្ច័យ មានវិសជ្ជនា ៥ វារៈ*** យ៉ាងនេះ គឺវិសជ្ជនាដែលមានកុសលជាមូល ១ វារៈ, មានអកុសលជាមូល ១ វារៈ, មានអព្យាកតជាមូល ៣ វារៈ គឺអព្យាកតៈជាមួយកុសល និងអព្យាកតៈជាមួយអកុសល ជាបច្ច័យដោយសហជាត និងបច្ឆាជាត, អព្យាកតៈជាមួយអព្យាកតៈ ជាបច្ច័យដោយសហជាត បុរេជាត និងបច្ឆាជាត, ***កុសលជាមួយអព្យាកតៈ និងអកុសលជាមួយអព្យាកតៈ*** ជាបច្ច័យដោយវត្ថុបុរេជាត ។

ពីរបទថា **“អត្ថិយា តេរស”** ក្នុងអត្ថិប្បច្ច័យ មានវិសជ្ជនា ១៣ វារៈយ៉ាងនេះ ***គឺមានកុសលជាមូល ៣ វារៈ*** បានដល់កុសលជាមួយកុសល ជាបច្ច័យដោយសហជាត, អព្យាកតៈជាមួយកុសលជាបច្ច័យ ដោយសហជាត និងបច្ឆាជាត, កុសលាព្យាកតៈជាមួយកុសលជាបច្ច័យ ដោយសហជាតតែម្យ៉ាង, ***ដែលមានអកុសលជាមូល*** ក៏មាន ៣ វារៈ ដូចគ្នាដែរ,

ប៉ុន្តែ ***អព្យាកតៈជាមួយអព្យាកតៈ*** ជាបច្ច័យដោយសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយប្បច្ច័យ, ***កុសលជាមួយអព្យាកតៈ*** និង ***អកុសលជាមួយអព្យាកតៈ*** ជាបច្ច័យដោយវត្ថារម្មណបុរេជាតប្បច្ច័យ, ***កុសល អព្យាកតៈ*** ជាបច្ច័យដល់កុសល ដោយសហជាត និងបុរេជាត ***អកុសល*** និង ***អព្យាកតៈ*** នោះឯង ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យដូចគ្នា, ***អកុសល អព្យាកតៈ*** ជាបច្ច័យដល់អកុសល ដោយសហជាតប្បច្ច័យ និងបុរេជាត-ប្បច្ច័យ, ***អកុសល*** និង ***អព្យាកតៈ*** នោះឯង ជាបច្ច័យដល់អព្យាកតៈ ដោយសហជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយ-ប្បច្ច័យដូចគ្នា ។

ក្នុង ***នត្ថិប្បច្ច័យ*** និង ***វិគតប្បច្ច័យ មានវិសជ្ជនា ៧ វារៈ*** ដូចអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យដែរ ។ ក្នុងពាក្យថា **“អវិគតេ តេរស** = ក្នុងអវិគតប្បច្ច័យមាន ១៣ វារៈ” នេះ ដូចគ្នានឹងអត្ថិប្បច្ច័យដែរ ។

ក្នុងបញ្ហាវារអនុលោមនេះ មានការកំណត់វិធីរាប់ ៧ យ៉ាងនេះ គឺវិសជ្ជនា ១ វារៈ, ៣ វារៈ, ៥ វារៈ, ៧ វារៈ, ៩ វារៈ, ១០ វារៈ និង ១៣ វារៈ ។ ក្នុងចំនួនវិសជ្ជនាទាំង ៧ យ៉ាងនេះ វិសជ្ជនា ១ វារៈ មាន ១ បច្ច័យប៉ុណ្ណោះ ដោយអំណាចនៃវិបាកប្បច្ច័យ ។

*វិសជ្ជនា ៣ វារៈ មាន ៥ បច្ច័យ ដោយអំណាចនៃអញ្ញមញ្ញ-ប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ។*

*វិសជ្ជនា ៥ វារៈ មាន ១ បច្ច័យប៉ុណ្ណោះ ដោយអំណាចនៃវិប្បយុត្តប្បច្ច័យ ។*

*វិសជ្ជនា ៧ វារៈ មាន ១០ បច្ច័យ ដោយអំណាចនៃហេតុ-ប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។*

*វិសជ្ជនា ៩ វារៈ មាន ៣ បច្ច័យ ដោយអំណាចនៃអារម្មណ-ប្បច្ច័យ សហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ វិសជ្ជនា ១០ វារៈ មាន ១ បច្ច័យ ដោយអំណាចនៃអធិបតិប្បច្ច័យ ។*

*វិសជ្ជនា ១៣ វារៈ មាន ៣ បច្ច័យ ដោយអំណាចនៃនិស្សយ-ប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។*

*ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីកំណត់វារៈទាំងឡាយដែលសម្ដែងទុកក្នុងបច្ច័យនោះៗ ដូចបានចង្អុលបញ្ជាក់មកនេះ ដោយអំណាចនៃការរាប់ចំនួនឲ្យល្អ ហើយគប្បីជ្រាបចំនួនក្នុងការប្រៀបធៀបបច្ច័យ ក្នុងទុកមូល និងតិកមូលជាដើម ដោយអំណាចនៃបច្ច័យទាំងនោះចុះ ។*

*បណ្ឌិតមិនគួរប្រកបបច្ច័យដែលជាវិសភាគគ្នា ឬសភាគគ្នាទុកជាមួយគ្នា*

ទេ ។ តើដូចម្ដេច ? គឺអធិបតីដ៏សេស វៀរវីមំសាធិបតី និងក្នុងអារម្មណប្បច្ច័យ, អនន្តរប្បច្ច័យ, សមនន្តរប្បច្ច័យ, ឧបនិស្សយប្បច្ច័យ, បុរេជាតប្បច្ច័យ, អាសេវនប្បច្ច័យ, អាហារប្បច្ច័យ, ឈានប្បច្ច័យ, នត្ថិប្បច្ច័យ, វិគតប្បច្ច័យ ជាវិសភាគនៃហេតុប្បច្ច័យមុន ។ សហជាតប្បច្ច័យជាដើម ជាសភាគនៃហេតុប្បច្ច័យនោះ ។ ព្រោះហេតុអ្វី ? ព្រោះមានសភាពដូចគ្នា ។ ពិតមែនហើយ ហេតុប្បច្ច័យ ជាបច្ច័យដោយហេតុដល់ធម៌ពួកណា, ក៏ជាសហជាតប្បច្ច័យជាដើម ដល់ធម៌ពួកនោះដែរ, ប៉ុន្តែ មិនជាអារម្មណប្បច្ច័យជាដើម ដល់ធម៌ពួកនោះទេ, ព្រោះហេតុនោះ អារម្មណប្បច្ច័យជាដើម ទើបឈ្មោះថា ជាវិសភាគដល់ហេតុប្បច្ច័យនោះ; ព្រោះហេតុដូច្នោះ ហេតុប្បច្ច័យនោះ ទើបមិនគួរប្រកបទុកជាមួយអារម្មណប្បច្ច័យជាដើមនោះទេ; ឬថាមិនគួរប្រកបអារម្មណប្បច្ច័យជាដើមនោះទុកជាមួយនឹងហេតុប្បច្ច័យនោះឡើយ ។

សូម្បីបុរេជាតប្បច្ច័យ, បច្ឆាជាតប្បច្ច័យ, សម្បយុត្តប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ, នត្ថិប្បច្ច័យ, វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ក៏ខុសគ្នាដែរ ទើបមិនគួរប្រកបទុកជាមួយគ្នាទេ ។ បណ្ដាធម៌ទាំងនោះ អ្នកសិក្សានឹងបានវារៈពួកណា ក្នុងការប្រកបជាមួយធម៌ដែលបញ្ចូលគ្នាបាន វៀរនូវធម៌ដែលបញ្ចូលគ្នាមិនបានចេញ, ដើម្បីនឹងសម្ដែង

វារៈទាំងនោះ ដោយសង្ខេប ទើបព្រះមានព្រះភាគត្រាស់ថា **“ហេតុ-ប្បច្ចយា អធិបតិយា ចត្តារិ** = ព្រោះក្នុងហេតុប្បច្ច័យ, អធិបតិប្បច្ច័យ មាន ៤ វារៈ” ជាដើម ។

បណ្ដាវារៈទាំងនោះ ព្រោះការប្រៀបធៀបហេតុប្បច្ច័យជាមួយនឹងអធិបតិប្បច្ច័យ (ព្រោះយកហេតុប្បច្ច័យរួមជាមួយអធិបតិប្បច្ច័យ) បាន ៧ វារៈ ដោយអំណាចនៃបច្ច័យដែលតិចជាង ក៏ពិតមែន, ប៉ុន្តែ ព្រោះក្នុងបណ្ដាអធិបតីទាំងឡាយ វីមំសាធិបតីប៉ុណ្ណោះ ជាហេតុប្បច្ច័យ, ក្រៅអំពីនេះ មិនជាអធិបតីទេ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់វៀរនូវធម៌ដែលជាវិសភាគ (បញ្ចូលគ្នាមិនបាន) ចេញ ហើយត្រាស់ថា **“ចត្តារិ”** ដូច្នេះ ដោយអំណាចនៃធម៌ដែលជាសភាគគ្នាវិញ ។ វិសជ្ជនាទាំង ៤ វារៈនោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះ គឺកុសលធម៌ ជាបច្ច័យដល់កុសលធម៌ដោយអំណាចនៃហេតុប្បច្ច័យ និងអធិបតិប្បច្ច័យ គឺវីមំសាដែលជាកុសល ជាបច្ច័យដល់ខន្ធដែលសម្បយុត្តគ្នា, កុសលធម៌ ជាបច្ច័យដល់អព្យាកតធម៌ដោយអំណាចនៃហេតុប្បច្ច័យ និងអធិបតិប្បច្ច័យ គឺវីមំសា-ធិបតីដែលជាកុសល ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន, កុសលធម៌ ជាបច្ច័យដល់កុសលធម៌ និងអព្យាកតធម៌ ដោយអំណាចនៃហេតុប្បច្ច័យ

និងអធិបតិប្បច្ច័យ គឺវីមំសាធិបតីដែលជាកុសល ជាបច្ច័យដល់ខន្ធដែលសម្បយុត្តនឹងរូបដែលមានចិត្តជាសមុដ្ឋាន, អព្យាកតធម៌ ជាបច្ច័យដល់អព្យាកតធម៌ដោយអំណាចនៃហេតុប្បច្ច័យ និងអធិបតិប្បច្ច័យ គឺវីមំសាធិបតីដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តនឹងរូបដែលមានចិត្តជាសមុដ្ឋាន ។ ក្នុងទីនេះ គប្បីកាន់យកវិបាកាព្យាកតៈអំពីលោកុត្តរធម៌ប៉ុណ្ណោះ, ចំណែកអារម្មណប្បច្ច័យ និងអនន្តរប្បច្ច័យជាដើមលោកមិនបានប្រកបទុកទេ ព្រោះជាវិសភាគគ្នា; អ្នកសិក្សា កាលជ្រាបវារៈដែលបាន និងមិនបាន ក្នុងបច្ច័យទាំងអស់ ដោយឧបាយនេះហើយ គប្បីអធិប្បាយវារៈដោយអំណាចដែលគួរបាន ។

ពីរបទថា **“សហជាតេ សត្ត”** សេចក្តីថា ក្នុងសហជាតប្បច្ច័យមាន ៧ វារៈ ដែលបានហើយក្នុងហេតុប្បច្ច័យ ។

ពីរបទថា **“អញ្ញមញ្ញេ តីណិ”** បានដល់ ក្នុងអញ្ញមញ្ញប្បច្ច័យ មាន ៣ វារៈ គឺវិសជ្ជនាដែលបាន ក្នុងសុទ្ធិកអញ្ញមញ្ញប្បច្ច័យ (អញ្ញមញ្ញប្បច្ច័យសុទ្ធ) នោះឯង ។

ពីរបទថា **“និស្សយេ សត្ត”** បានដល់ ក្នុងនិស្សយប្បច្ច័យ មាន ៧ វារៈ គឺវិសជ្ជនាដែលបានក្នុងហេតុប្បច្ច័យ ។

*ពីរបទថា* **"វិបាកេ ឯកំ"** *គឺ ១ វារៈ ដែលបានក្នុងវិបាកប្បច្ច័យសុទ្ធៗ ។ ពាក្យថា* **"ឥន្ទ្រិយមគ្គេសុ ចត្តារិ** *= ក្នុងឥន្ទ្រិយប្បច្ច័យ និងមគ្គប្បច្ច័យ មាន ៤ វារៈ" មានន័យដូចដែលបានពោលហើយ អំពីខាងដើមនោះឯង ។*

*ពីរបទថា* **"សម្បយុត្តេ តីណិ"** *បានដល់ ក្នុងសម្បយុត្តប្បច្ច័យមាន ៣ វារៈ គឺវិសជ្ជនាដែលបានក្នុងសុទ្ធិកសម្បយុត្តប្បច្ច័យនោះឯង ។*

*ពីរបទថា* **"វិប្បយុត្តេ តីណិ"** *បានដល់ ក្នុងវិប្បយុត្តប្បច្ច័យ មាន ៣ វារៈ អ្នកសិក្សា គប្បីជ្រាបវិសជ្ជនាដែលលើកយករូប មានកុសលចិត្តជាដើម ជាសមុដ្ឋានឡើងជាបច្ចយុប្បន្ន ។ ពីរបទថា* **"អត្ថិអវិគតេសុ សត្ត** *= ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មាន ៧ វារៈ" គឺវិសជ្ជនាដែលបានក្នុងហេតុប្បច្ច័យនោះឯង ដោយប្រការដូចពណ៌នាមកហើយនេះ ។*

***ហេតុប្បច្ច័យ*** *បានដល់ ការប្រកបសេចក្ដីអធិប្បាយរួមជាមួយបច្ច័យ ១១ មានអធិបតិប្បច្ច័យជាដើមពួកណា, ព្រះមានព្រះភាគ លុះទ្រង់សម្ដែងវិធីរាប់ក្នុងទុមូលកន័យ ដោយអំណាចនៃបច្ច័យពួកនោះហើយឥឡូវនេះ ដើម្បីទ្រង់សម្ដែងវិធីរាប់ក្នុងតិមូលកន័យជាដើម ទើបទ្រង់តាំងការកំណត់ ហើយត្រាស់ថា* **"ហេតុសហជាតនិស្សយអត្ថិអវិគតន្តិ សត្ត** *= ព្រោះក្នុងបច្ច័យ ៥ គឺហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយ-*

បច្ច័យ អត្ថិបច្ច័យ និងអវិគតបច្ច័យ មាន ៧ វារៈ” ជាដើម ដោយប្រការដូច្នេះ ។ ប៉ុន្តែ ក្នុងគម្ពីរទាំងឡាយ អាចារ្យចារឹកនូវឈ្មោះបច្ច័យមានអក្សរភ្លាត់យ៉ាងនេះ គឺនិស្សយ ឧបនិស្សយ អធិបាតិ, ពាក្យនេះ លោកសរសេរដោយអំណាចនៃការភ្លេចផ្គងចិត្ត, ព្រោះហេតុនោះ ក្នុងឋានដូច្នេះទើបគួរបំពេញបាលីឲ្យគ្រប់, ក៏សេចក្ដីដែលលោកតាំងទុកនោះ រមែងសម្ដែងនូវអត្ថនេះថា ហេតុបច្ច័យនេះ រមែងបានវិសជ្ជនា ៧ វារៈ ដែលបានក្នុងវិភង្គរបស់ខ្លួនប៉ុណ្ណោះ ព្រោះរាប់បញ្ចូលជាមួយបច្ច័យ ៤ មានសហជាតបច្ច័យជាដើម ។ ក៏ប្រសិនបើ រាប់អញ្ញមញ្ញបច្ច័យចុះក្នុងអធិការនេះរមែងបានវិសជ្ជនា ៣ វារៈ, ក្នុងអញ្ញមញ្ញបច្ច័យ បើរាប់សម្បយុត្តបច្ច័យមកបញ្ចូលផង ក៏គង់បានវិសជ្ជនាទាំង ៣ វារៈនោះឯង ។ ក្នុងហេតុវិប្បយុត្តទុកៈ បើរាប់វិប្បយុត្តបច្ច័យបញ្ចូលទៅជាមួយគ្នា ក៏បានវិសជ្ជនា ៣ វារៈ ។ បើរាប់វិបាកបច្ច័យផង រមែងបានវិសជ្ជនា ១ វារៈប៉ុណ្ណោះ ព្រោះប្រៀបធៀបបច្ច័យទាំងអស់ ដែលជាសភាគជាមួយវិបាក ។ ប្រសិនបើ រាប់ឥន្ទ្រិយបច្ច័យ និងមគ្គបច្ច័យ បញ្ចូលទៅក្នុងទីនេះផង រមែងបានវិសជ្ជនា ៤ វារៈ ដែលបានក្នុងទុមូលកន័យជាមួយឥន្ទ្រិយ និងមគ្គបច្ច័យទាំងនោះ ។

បើរាប់អញ្ញមញ្ញបច្ច័យជាមួយបច្ច័យទាំង ២ នោះ ឲ្យនាំវិសជ្ជនា ២ វារៈចេញ គឺកុសលធម៌ ជាបច្ច័យដល់អព្យាកតៈ, កុសលធម៌ ជាបច្ច័យ

ដល់កុសលធម៌ និងអព្យាកតៈ ក្នុងវិសជ្ជនា ៤ វារៈ ដែលសម្ដែងទុកក្នុងហេតាធិបតិទុកៈ រមែងបានវិសជ្ជនា ២ វារៈដែលនៅសល់; សូម្បីនឹងបន្ថែមសម្បយុត្តប្បច្ច័យបញ្ចូលទៅក្នុងទីនោះទៀត ក៏គង់បានវិសជ្ជនាទាំង ២ វារៈនោះឯង ។ បើបន្ថែមវិប្បយុត្តប្បច្ច័យចូលទៅ នឹងបានវិសជ្ជនា ២ វារៈក្រៅអំពីនោះផង; បើបន្ថែមវិបាកប្បច្ច័យបញ្ចូលទៅក្នុងបច្ច័យទាំងនោះ រមែងបានវិសជ្ជនា ១ វារៈ ក្នុងទីគ្រប់កន្លែង ។ កាលបើមិនបន្ថែមបច្ច័យដែលមានវិធីរាប់ចំនួនបានតិចជាងហេតាធិបតិទុកៈ ជាមួយអធិបតិ-ប្បច្ច័យទេ រមែងបានវិសជ្ជនា ៤ វារៈប៉ុណ្ណោះ ។ កាលបន្ថែមចូលទៅផង រមែងបានវិសជ្ជនា ២ វារៈ និង ១ វារៈ ដោយអំណាចនៃបច្ច័យទាំងនោះឯង ។ អ្នកសិក្សា កាលបើជ្រាបចំនួនដែលបានក្នុងការប្រកបរួមគ្នានៃបច្ច័យនោះៗ ដូចពណ៌នាមកនេះ ហើយគប្បីពង្រីកចំនួន (វិធីរាប់) ក្នុងតិមូលក-ន័យជាដើម តទៅ ៖

ក៏បណ្ដាយជនាទាំងនេះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃហេតុប្បច្ច័យដែលមាន ៩ យជនា ដោយសាមញ្ញធម្មតា យជនា ៤ មុនយជនាទាំងពួង ជាអវិបាកយជនាប៉ុណ្ណោះ (គឺមិនមានវិបាកប្បច្ច័យនៅរួមទេ); ប៉ុន្តែ ក្នុងពេលវិសជ្ជនាអព្យាកតៈជាមួយអព្យាកតៈ រមែងបានវិបាកហេតុក្នុងកន្លែងនេះដែរ ។ យជនា ៥ តអំពីនោះ ទ្រង់ត្រាស់សម្ដែងទុក ដោយ

អំណាចនៃហេតុដែលជាវិបាក ។ វិបាកដែលជាសហជាត និងរូបដែលជាសហជាតជាមួយវិបាកទាំងអស់ ក៏ត្រាស់សម្តែងទុកក្នុងទីនោះដែរ; បណ្តាឃដនាទាំងនោះ វិបាក និងរូបដែលមានវិបាកនោះ ជាសមុដ្ឋាន រមែងបានក្នុង **ឃដនាទី ១** ។

វិបាក និងវត្ថុរូប ក្នុងបដិសន្ធិកាល បានក្នុង **ឃដនាទី ២** ។

ក្នុង **ឃដនាទី ៣** បានចំពោះអរូបធម៌តែម្យ៉ាង ។

**ឃដនាទី ៤** បានចំពោះរូបដែលមានវិបាកចិត្តជាសមុដ្ឋានតែម្យ៉ាង ។

**ឃដនាទី ៥** បានចំពោះវត្ថុរូបតែប៉ុណ្ណោះ ។

**ឃដនា ១៥** តអំពីនោះ ទាក់ទងជាមួយឥន្ទ្រិយ ទ្រង់ត្រាស់សម្តែងទុក ដោយអំណាចនៃអមោហហេតុ ។ ក្នុងបណ្តាឃដនាទាំង ១៥ នោះ ពួកឃដនាដំបូង មាន ៩ មិនមានអធិបតីទេ ។ ពួកឃដនាចុងក្រោយ មាន ៦ មានអធិបតី ។ សូម្បីក្នុងឃដនាដែលមិនមានអធិបតី ៤ ឃដនាដំបូង គ្រប់ៗ កន្លែង ត្រាស់សម្តែងដោយអមោហហេតុដូចគ្នាទាំងអស់ ដោយសាមញ្ញធម្មតា ។ ឃដនា ៥ ខាងក្រោយ ត្រាស់សម្តែងដោយអំណាចនៃអមោហហេតុដែលជាវិបាក ។

បណ្តាឃដនាដែលមិនមានអធិបតីទាំងនោះ **ឃដនាដំបូង** ទ្រង់សម្តែងទុកក្នុងហេតាធិបតិទុកៈអំពីខាងដើមថា មាន ៤ វារៈ ។

ក្នុង ***ឃដនាទី ២*** មិនមានរូបដែលមានចិត្តជាសមុដ្ឋានទេ ។

ក្នុង ***ឃដនាទី ៣*** មិនមានវត្ថុរូបឡើយ ។

ក្នុង ***ឃដនាទី ៤*** បានកុសលធម៌ ជាបច្ច័យដល់ចិត្តជរូបអព្យាកតៈ, រមែងបានរូបដែលមានអព្យាកតៈ (ចិត្តជរូប និងបដិសន្ធិកម្មជរូប) ជាសមុដ្ឋានប៉ុណ្ណោះ ។

***ឃដនាទី ៥*** ដែលប្រកបជាមួយវិបាក ក្រៅអំពីនោះ មានន័យដូចពោលហើយ អំពីខាងដើម ។ បណ្ដាឃដនាដែលមានអធិបតី ៣ ឃដនាខាងដើម ត្រាស់សម្ដែងទុកដោយអំណាចនៃហេតុដែលជាវិបាក និងមិនមែនជាវិបាក ដោយសាមញ្ញធម្មតា ។

បណ្ដាឃដនាទាំងនោះ ក្នុង ***ឃដនាទី ១*** មាន ៤ វារៈ ដូចន័យដែលពោលមកហើយនោះឯង ។

ក្នុង ***ឃដនាទី ២*** មិនមានរូបទេ ។

ក្នុង ***ឃដនាទី ៣*** ក៏មិនមានអរូបដែរ ។

ឃដនា ៣ ក្រៅអំពីនោះត្រាស់ទុកដោយអំណាចនៃហេតុខាងវិបាក ។

បណ្ដាឃដនាទាំងនោះ ***ឃដនាទី ១*** បានទាំងរូប ទាំងនាម ។

***ឃដនាទី ២*** បានតែនាមប៉ុណ្ណោះ ។

***ឃដនាទី ៣*** *បានចំពោះរូបប៉ុណ្ណោះ ។*

*អ្នកសិក្សា កាលបើជ្រាបវិធីរាប់ចំនួនដែលបានក្នុងការប្រកបរួមនៃបច្ច័យនោះៗ ដូចពណ៌នាមកហើយ គប្បីអធិប្បាយពង្រីកវិធីរាប់ចំនួន ក្នុងតិមូលកន័យជាដើមតទៅ ។*

## ចប់ហេតុមូលកន័យ

..............................

## អារម្មណាមូលកន័យ

*គប្បីជ្រាបនូវវិនិច្ឆ័យ ក្នុង* ***ឃដនាដែលមានអារម្មណ៍ជាមូល*** *ដូចតទៅ ៖*

*បច្ច័យ ៧ មានអធិបតិប្បច្ច័យជាដើម ជាសភាគជាមួយអារម្មណប្បច្ច័យ, បច្ច័យដែលនៅសល់ ១៦ ទៀត ជាវិសភាគ ព្រោះហេតុដូច្នោះ កុំប្រកបបច្ច័យទាំង ១៦ នោះ (ជាមួយអារម្មណប្បច្ច័យ) ឡើយ ប្រកបបានចំពោះតែ ៧ បច្ច័យប៉ុណ្ណោះ ។*

*បណ្តាបទទាំងនោះ ពីរបទថា* **“អធិបតិយា សត្ត”** *សេចក្តីថា ក្នុង* ***អធិបតិប្បច្ច័យ មានវិសជ្ជនា ៧ វារៈ*** *គឺវិសជ្ជនា ៣ វារៈ ដែលមានកុសលជាមូលយ៉ាងនេះ គឺកុសលធម៌ ជាបច្ច័យដល់កុសលធម៌ ១, ដល់អកុសលធម៌ ១ និងដល់អព្យាកតធម៌ ១ ។ វិសជ្ជនា ១ វារៈ មានអកុសល*

*ជាមូល ។ វិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ។*

*ពីរបទថា* **"និស្សយេ តីណិ"** *គឺវិសជ្ជនា ៣ វារៈ មានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុនោះឯង ។*

*ពីរបទថា* **"ឧបនិស្សយេ សត្ត"** *ដូចដែលបានពោលទុកអំពីខាងដើមហើយ ។*

*ពីរបទថា* **"បុរេជាតេ តីណិ"** *គឺវិសជ្ជនា ៣ វារៈ ដែលមានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុ និងអារម្មណ៍ ។*

*ពីរបទថា* **"ទិប្បយុត្តេ តីណិ"** *គឺវិសជ្ជនា ៣ វារៈ ដែលមានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុតែម្យ៉ាង ។*

*ពីរបទថា* **"អត្ថិអវិគតេសុ តីណិ"** *គឺវិសជ្ជនា ៣ វារៈ ដែលមានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុដែលជាអារម្មណ៍ ។ ម្យ៉ាងទៀត ដូចនៅក្នុងហេតុមូលកន័យ លោកតាំងឃដនាទុកដើម្បីសម្តែងសេចក្តីកំណត់យ៉ាងណា, សូម្បីក្នុងអារម្មណមូលកន័យជាដើម ក៏ដូច្នោះដែរ ។*

*បណ្តាឃដនាទាំងនោះ ឃដនា ៥ ដែលលោកតាំងទុកនៅក្នុងអារម្មណមូលកន័យនេះជាមុនសិន បណ្តាឃដនាទាំងនោះ ៖*

***-ឃដនាទី ១*** *មានអធិបតីដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។ បណ្តាបទទាំងនោះ បទថា* **"សត្ត"** *គឺវិសជ្ជនាដែលបានក្នុងអារម្មណាធិបតិទុកៈ*

នោះឯង ។

**-យដនទី ២** មិនមានអធិបតីទេ ។ បណ្ដាបទទាំងនោះ បទថា **"គីណិ"** គឺវិសជ្ជនាដែលមានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុ និង អារម្មណ៍ ឬអារម្មណ៍តែម្យ៉ាង ។

**-យដនទី ៣** ប្រកបក្នុងនិស្សយប្បច្ច័យ ។ បណ្ដាបទទាំងនោះ បទថា **"គីណិ"** គឺមានអព្យាកតៈជាមូលដោយអំណាចនៃវត្ថុ ។

**-យដនទី ៤** និង **យដនទី ៥** មានអធិបតី; ក្នុងពីរខនោះ បទថា **"ឯកំ"** ក្នុងយដនទី ៤ បានដល់ អកុសលដែលមានអព្យាកតៈជាមូល ដោយអំណាចនៃវត្ថុ និងអារម្មណ៍ ឬដោយអំណាចនៃអារម្មណ៍តែម្យ៉ាង ។ បទថា **"ឯកំ"** ក្នុងយដនទី ៥ បានដល់ អកុសលដែលមានអព្យាកតៈ ជាមូល ដោយនិស្សយប្បច្ច័យ ។

អ្នកសិក្សា គប្បីជ្រាបវិធីរាប់ក្នុងតិមូលកន័យជាដើម ដោយអំណាច នៃបច្ច័យដែលបាននៅក្នុងអធិការនេះ ដូចពណ៌នាមកហើយ ។ សូម្បីក្នុង ន័យដែលមានអធិបតិប្បច្ច័យជាមូល ក៏ដូចគ្នាដែរ ។ ប៉ុន្តែ ខ្ញុំសូមមិនពោល អធិប្បាយយ៉ាងពិស្ដារ ដោយអំណាចអារម្មណ៍ ឥន្ទ្រិយ និងវិបាកប្បច្ច័យ ទេ, នឹងពោលចំពោះតែកន្លែងណា ដែលសមគួរនឹងពោលក្នុងកន្លែងនោះៗ ប៉ុណ្ណោះ ៕

## អធិបតិមូលកន័យ

គប្បីជ្រាបនូវវិនិច្ឆ័យ ក្នុង ***អធិបតិមូលកន័យ*** ដូចតទៅ ៖

ពីរបទថា **" សហជាតេ សត្ត** = ក្នុងសហជាតប្បច្ច័យ មាន ៧ វារៈ" បានដល់ វិសជ្ជនា ៧ វារៈ គឺវិសជ្ជនា ៣ វារៈ មានកុសលជាមូល ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ, វិសជ្ជនា ៣ វារៈ មានអកុសលជាមូល, វិសជ្ជនា ១ វារៈទៀត មានអព្យាកតៈជាមូល ។ អារម្មណាធិបតិប្បច្ច័យ រមែងមិនបានសហជាតប្បច្ច័យទេ, ឯសហជាតប្បច្ច័យ ក៏រមែងមិនបានអារម្មណាធិបតិប្បច្ច័យដែរ ។

ពីរបទថា **"អញ្ញមញ្ញេ តីណិ** = ក្នុងអញ្ញមញ្ញប្បច្ច័យ មាន ៣ វារៈ" គឺមានវិសជ្ជនា ៣ វារៈ ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យប៉ុណ្ណោះ ។

ពីរបទថា **"និស្សយេ អដ្ឋ** = ក្នុងនិស្សយប្បច្ច័យ មាន ៨ វារៈ" គឺមានកុសលជាមូល ៣ វារៈ, មាន អកុសលជាមូល ៣ វារៈ និងមាន អព្យាកតៈជាមូល ២ វារៈ ។ ពិតមែនហើយ អធិបតីដែលជាអព្យាកតៈ រមែងជាទីអាស្រ័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ, ជាទីអាស្រ័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យតែម្យ៉ាង; ប៉ុន្តែ មិនជាទីអាស្រ័យនៃកុសលធម៌ ដោយប្រការទាំងពីរទេ ព្រោះហេតុដូច្នោះ វិសជ្ជនាដែលមានអព្យាកតៈជាមូល មាន ២ វារៈប៉ុណ្ណោះ រួម

ត្រូវជាវិសជ្ជនា ៨ វារៈ ដោយការអធិប្បាយមកនេះ ។

វិសជ្ជនា ៧ វារៈ ក្នុងឧបនិស្សយប្បច្ច័យ ដូចគ្នានឹងអារម្មណប្បច្ច័យនោះឯង ។

ពីរបទថា **“បុរេជាតេ ឯកំ** = ក្នុងបុរេជាតប្បច្ច័យ មាន ១ វារៈ**”** បានដល់អព្យាកតាធិបតី ជាបច្ច័យដល់អកុសល ដោយអំណាចនៃអារម្មណ៍ ។

ពីរបទថា **“វិបាកេ ឯកំ** = ក្នុងវិបាកប្បច្ច័យ មាន ១ វារៈ**”** គឺលោកុត្តរអព្យាកតៈ ជាមួយនឹងអព្យាកតៈ ។ វិសជ្ជនា ៧ វារៈ ក្នុងអាហារប្បច្ច័យជាដើម បានហើយក្នុងឯកមូលកន័យអំពីខាងដើមនោះឯង ។

ពីរបទថា **“វិប្បយុត្តេ ចត្តារិ** = ក្នុងវិប្បយុត្តប្បច្ច័យ មាន ៤ វារៈ**”** គឺអព្យាកតៈជាមួយកុសល, អព្យាកតៈជាមួយអកុសល, អព្យាកតៈជាមួយអព្យាកតៈ និងកុសលជាមួយអព្យាកតៈ ។

វិសជ្ជនា ៨ វារៈ ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដូចគ្នានឹងនិស្សយប្បច្ច័យនោះដែរ ។

ក៏ក្នុងអធិការនេះ យជនាទាំងឡាយ លោកមិនប្រកបជាមួយនឹងអារម្មណប្បច្ច័យជាដើម តាមលំដាប់ទេ ប្រកបតែជាមួយអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យប៉ុណ្ណោះ ។ ***សួរថា ព្រោះហេតុអ្វី ?*** ឆ្លើយថា ព្រោះរួមអធិបតីទាំងពីរបច្ច័យ ទុកជាមួយគ្នា ។

*បណ្ដាយជនាទាំងនោះ ក្នុង **យជនាខាងដើម** បានវត្ថុដែលជាអារម្មណ៍ (វត្ថារម្មណ៍) ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។*

*ក្នុង **យជនាទី ២** បានវត្ថុតែម្យ៉ាង សម្រាប់បុគ្គលដែលត្រេកអរយ៉ាងខ្លាំងក្លា ដោយអំណាចជាទីអាស្រ័យ (សម្រាប់បុគ្គលដែលធ្វើឲ្យធ្ងន់ដោយអំណាចជាទីអាស្រ័យហើយត្រេកអរ) ។*

*ក្នុង **យជនាទី ៣** បានដល់ ធម៌មានកុសលជាដើម ជាបច្ច័យដល់រូបទាំងឡាយ ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ ។ បានវត្ថុជាបច្ច័យដល់អកុសល ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។*

*យជនា ៣ វារៈ ក្រៅអំពីនោះ ត្រាស់សម្ដែងទុកដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។ បណ្ដាយជនាទាំងនោះ វិសជ្ជនា ៧ វារៈ ក្នុង **យជនាទី ១** ខ្ញុំពោលទុករៀបរយហើយអំពីខាងដើម ។*

*បទថា **“ឯកំ”** ក្នុង **យជនាទី ២** គឺវត្ថុជាអារម្មណ៍ដែលកើតមុនជាបច្ច័យដល់អកុសល ។ ក្នុង **យជនាទី ៣** វត្ថុប៉ុណ្ណោះ ជាបច្ច័យដល់អកុសល ។*

***យជនា ៣ វារៈ** តអំពីនោះ ទូទៅដល់ធម៌ដែលជាវិបាក និងមិនមែនជាវិបាក ទ្រង់ត្រាស់ទុកដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ ។ បណ្ដាយជនាទាំងនោះ ក្នុង **យជនាទី ១** បានទាំងរូប ទាំងអរូប ។*

***យជនាទី ២*** បានចំពោះតែអរូបម្យ៉ាង ។

***យជនាទី ៣*** បានចំពោះតែរូបប៉ុណ្ណោះ ។

***យជនា ៣*** ក្រៅអំពីនោះ ទ្រង់ត្រាស់ទុកដោយអំណាចនៃវិបាកាធិបតិប្បច្ច័យ ។

*សូម្បីបណ្ដាយជនា ៣ នោះ* ***យជនាទី ១*** *បានទាំងរូប ទាំងអរូប ។*

***យជនាទី ២*** *បានចំពោះតែអរូបប៉ុណ្ណោះ ។*

***យជនាទី ៣*** *បានចំពោះរូបតែប៉ុណ្ណោះ ។*

*យជនា ៦ ក្រៅអំពីនោះ ប្រកបដោយអាហារ និងឥន្ទ្រិយប្បច្ច័យ ទ្រង់ត្រាស់ទុកដោយអំណាចនៃចិត្តាធិបតិប្បច្ច័យ ។ បណ្ដាយជនាទាំង ៦ នោះ មិនមានវិបាក ៣ យជនា, មានវិបាក ៣ យជនា ។ វិធីរាប់ចំនួនក្នុងយជនាទាំងនោះ ច្បាស់លាស់ហើយ ។ យជនា ៦ ក្រៅអំពីនោះ ទ្រង់ត្រាស់ទុកដោយអំណាចនៃវីរិយាធិបតី ។*

***សួរថា*** *ក៏កាលបើពោលតាមលំដាប់នៃអធិបតីហើយ ព្រះមានព្រះភាគ គួរតែត្រាស់យជនាដោយអំណាចនៃវីរិយាធិបតី ទុកជាលំដាប់ដំបូង មិនមែនឬ ? (ប៉ុន្តែ) ហេតុដូចម្ដេច ទើបព្រះពុទ្ធអង្គមិនទ្រង់ត្រាស់យ៉ាងនោះទៅវិញ ? ដោះស្រាយថា ព្រោះយជនាទាំងនោះ ដូចគ្នានឹងយជនាដែលត្រាស់ទុកដោយអំណាចនៃហេតុខាងមុខ ។ ពិតមែនហើយ*

យជនាដែលត្រាស់ទុក ដោយអំណាចនៃហេតុខាងមុខ ជាប់ទាក់ទងដោយមគ្គ ព្រោះអមោហហេតុ ជាវីមំសាធិបតី និងព្រោះវីមំសាធិបតី ជាតួសម្មាទិដ្ឋិ ។ ម្យ៉ាងទៀត សូម្បីវីរិយៈ ក៏ចាត់ជាមគ្គ ព្រោះជាសម្មាវាយាម និងមិច្ឆា-វាយាម ព្រោះហេតុដូច្នោះ យជនាទាំងឡាយ ទើបព្រះមានព្រះភាគត្រាស់សម្តែងបង្កិលផ្លាស់ប្តូរទៅ ជាមួយនឹងវីរិយៈនោះថា ដូចគ្នានឹងយជនាដែលទ្រង់ត្រាស់ទុក ដោយអំណាចនៃហេតុខាងមុខ ។ សូម្បីវិធីរាប់ចំនួនក្នុងយជនាទាំងនោះ ជាក់ច្បាស់ហើយ ៕

---

## អនន្តរ-សមនន្តរមូលកន័យ

បទថា **"សត្ត"** ក្នុងយជនាដែលមាន ***អនន្តរប្បច្ច័យ*** និង ***សមនន្តរ-ប្បច្ច័យជាមូល*** សេចក្តីថា មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យដល់កុសល និងអព្យាកតៈ, អកុសល ជាបច្ច័យដល់អកុសល និងអព្យាកតៈ, អព្យាកតៈ ជាបច្ច័យដល់កុសល អកុសល និងអព្យាកតៈ សូម្បីទាំង ៣ ។ ពីរបទថា **"កម្មេ ឯកំ** = ក្នុងកម្មប្បច្ច័យ មាន ១ វារៈ" គឺកុសលមគ្គចេតនា ជាបច្ច័យដល់វិបាកាព្យាកតៈរបស់ខ្លួន; ក្នុងបច្ច័យទាំងនោះ មានយជនា ៣ ប៉ុណ្ណោះ; យជនាទាំងនោះ ប្រកបតាមលំដាប់វិសជ្ជនាដែលមានវារៈច្រើន ។

*គប្បីជ្រាបវិនិច្ឆ័យក្នុង **យថនាដែលមានសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និងនិស្សយប្បច្ច័យជាមូល** តទៅ ៖*

*បច្ច័យណាៗ ដែលត្រាស់សម្តែងទុកក្នុងទុមូលកន័យ, បច្ច័យនោះៗ ជាសភាគជាមួយបច្ច័យដែលនៅខាងដើម; ព្រោះហេតុដូច្នោះ អ្នកសិក្សា កាលបើជ្រាបវិធីរាប់ចំនួនក្នុងទុមូលកន័យហើយ គប្បីជ្រាបវិធីរាប់ចំនួន ក្នុងយថនាទាំងឡាយ គ្រប់ៗ កន្លែង ដោយអំណាចនៃបច្ច័យដែលរាប់ចំនួន បានតិចជាង ក្នុងបច្ច័យដែលនាំមករាប់ភ្ជាប់ខាងចុង ។*

## សហជាតមូលកន័យ

*បណ្តាយថនាទាំងនោះ យថនាដែលមាន **សហជាតប្បច្ច័យជាមូល** មាន ១០ យថនា; ក្នុងយថនាទាំង ១០ នោះ ដែលជា **អវិបាកយថនា** មាន ៥, ជា **សវិបាកយថនា** មាន ៥ ។*

*ក្នុងពីរយ៉ាងនោះ និងសម្តែងយថនាដែលជា **អវិបាកយថនា** ជាមុន ក្នុង **យថនាទី ១** មានវិសជ្ជនា ៩ វារៈយ៉ាងនេះ គឺកុសលជាបច្ច័យ ដល់កុសល, អព្យាកតៈ និងកុសលាព្យាកតៈ; កុសលាព្យាកតៈ ជាបច្ច័យដល់ អព្យាកតៈ រួមជា ៤ វារៈ ។ អកុសល ជាបច្ច័យដល់អកុសល, អព្យាកតៈ*

និងអកុសលាព្យាកតៈ; អកុសលាព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ; អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈប៉ុណ្ណោះ (រួមជា ៩ វារៈ) ។ បណ្ដាវិសជ្ជនាទាំងនោះ ក្នុងវិសជ្ជនា ៨ វារៈ មានកុសល និងអកុសលជាដើម បានទាំងអរូប (នាម) ទាំងរូប ដែលមានចិត្តជាសមុដ្ឋាន, ក្នុងអព្យាកតៈ បានចំពោះតែវត្ថុរូប ។ បណ្ដារូបទាំងឡាយ វត្ថុរូបប៉ុណ្ណោះ បានវិសជ្ជនាខាងអព្យាកតៈ ក្នុង ***យដនាទី ២*** ។

បណ្ដាយដនាទាំង ៣ អរូបប៉ុណ្ណោះ បានក្នុង ***យដនាទី ៣*** ។

ក្នុង ***យដនាទី ៤*** បានចំពោះរូបដែលមានចិត្តជាសមុដ្ឋានប៉ុណ្ណោះ ។

ក្នុង ***យដនាទី ៥*** បានចំពោះអរូបធម៌ និងវត្ថុរូប ក្នុងបដិសន្ធិកាល ។

ក្នុង ***សវិបាកយដនា*** ត្រង់ ***យដនាទី ១*** បានវិបាកចិត្ត និងរូបដែលមានវិបាកចិត្តជាសមុដ្ឋាន ។

***យដនាទី ២*** បានវិបាក និងវត្ថុរូប ។

***យដនាទី ៣*** បានចំពោះវិបាកតែម្យ៉ាង ។

***យដនាទី ៤*** បានចំពោះរូបដែលមានវិបាកចិត្តជាសមុដ្ឋានតែម្យ៉ាង ។

***យដនាទី ៥*** បានចំពោះតែវត្ថុរូប ៕

---

## អញ្ញមញ្ញមូលកន័យ

ក្នុង ***អញ្ញមញ្ញមូលកន័យ*** មានឃដនា ៦; បណ្ដាឃដនាទាំង ៦ នោះ ឃដនា ៣ ដំបូង ជាអវិបាកឃដនា, ឃដនា ៣ ចុងក្រោយ ជាសវិបាកឃដនា; វិធីរាប់ចំនួនក្នុងឃដនាទាំងនោះ ជាក់ច្បាស់ហើយ ៕

---

## និស្សយមូលកន័យ

គប្បីជ្រាបវិនិច្ឆ័យក្នុងន័យដែលមាន ***និស្សយប្បច្ច័យជាមូល*** តទៅ ៖

ពាក្យថា **"និស្សយប្បច្ចយា អារម្មណេ តីណិ** = ព្រោះនិស្សយ-ប្បច្ច័យក្នុងអារម្មណប្បច្ច័យ មាន ៣ វារៈ" អ្នកសិក្សាគប្បីជ្រាបវិសជ្ជនា ៣ វារៈ ដោយអំណាចនៃកុសលវារៈជាដើម ដែលលើកវត្ថុឡើងជាអារម្មណ៍ប្រព្រឹត្តទៅ (ដោយយកវត្ថុជាអារម្មណ៍) ។ ពីរបទថា **"ឧបនិស្សយេ ឯកំ** = ក្នុងឧបនិស្សយប្បច្ច័យ មាន ១ វារៈ" គឺអកុសលដែលគោងវត្ថុជាអារម្មណូបនិស្ស័យកើតឡើង; ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលខ្ញុំពោលទុកហើយ ក្នុងទុកមូលកន័យអំពីខាងដើម ។

ក្នុងនិស្សយប្បច្ច័យនេះ មានឃដនា ២០ ។ បណ្ដាឃដនាទាំងនោះ ឃដនា ៦ ខាងដើម ទ្រង់ត្រាស់ទុកដោយអំណាចនៃសហជាត និងបុរេជាត ។ ឃដនា ៤ ក្រៅអំពីនោះ ទ្រង់ត្រាស់ទុកដោយអំណាចនៃបុរេជាតតែម្យ៉ាង ។

*បន្ទុំទៅយជនា ១០ ទៀត ទ្រង់ត្រាស់សម្ដែងដោយអំណាចនៃសហជាត តែម្យ៉ាង ។*

*បណ្ដាយជនាទាំងនោះ ពាក្យថា* ***“តេរស = ១៣”*** *ក្នុង* ***យជនាទី ១*** *បានដល់ វិសជ្ជនា ១៣ វារៈ ដែលព្រះមានព្រះភាគត្រាស់សម្ដែងទុកនោះ ដូចគ្នានឹងនិស្សយប្បច្ចយវិភង្គដែរ ។ ពាក្យថា* ***“អដ្ឋ = ៨”*** *ក្នុង* ***យជនា ទី ២*** *បានដល់ វិសជ្ជនា ៨ វារៈ គឺវិសជ្ជនា ៧ វារៈ ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ និង ១ វារៈទៀត ដែលអកុសលធ្វើវត្ថុឲ្យធ្ងន់ ។*

*ពាក្យថា* ***“សត្ត = ៧ វារៈ”*** *ក្នុង* ***យជនាទី ៣*** *គឺវិសជ្ជនា ៧ វារៈ ដែលបានហើយក្នុងឥន្ទ្រិយប្បច្ច័យនោះឯង ។*

*ពាក្យថា* ***“បញ្ច = ៥ វារៈ”*** *ក្នុង* ***យជនាទី ៤*** *គឺវិសជ្ជនា ៥ វារៈ ដែលបានហើយក្នុងវិប្បយុត្តប្បច្ច័យនោះឯង ។*

*ពាក្យថា* ***“ចត្តារិ = ៤ វារៈ”*** *ក្នុង* ***យជនាទី ៥*** *បានដល់ វិសជ្ជនាដែលមានកុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន និងវត្ថុជាបច្ច័យដល់អកុសល ។*

*ពាក្យថា* **“តីណិ = *៣ វារៈ*”** *ក្នុង* ***ឃដនាទី ៦*** *គឺកុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។*

*ក្នុងឃដនា ៤ ដោយអំណាចនៃ* ***បុរេជាតប្បច្ច័យ*** *។ ពាក្យថា* **“តីណិ = *៣ វារៈ*”** *ក្នុង* ***ឃដនាទី ១*** *វត្ថុជាបច្ច័យដល់កុសលជាដើម និងវត្ថុ មានចក្ខុជាដើម ជាបច្ច័យដល់អព្យាកតៈ ។*

*ក្នុង* ***ឃដនាទី ២*** *វត្ថុប៉ុណ្ណោះ ជាបច្ច័យដល់កុសលជាដើម ។*

*ក្នុង* ***ឃដនាទី ៣*** *ពាក្យថា* **“ឯកំ”** *គឺវត្ថុ ជាបច្ច័យដល់អកុសល ។*

*ក្នុង* ***ឃដនាទី ៤*** *វត្ថុ មានចក្ខុជាដើម ជាបច្ច័យដល់ពួក ៥ នៃវិញ្ញាណចិត្ត (គឺទ្វិបញ្ចវិញ្ញាណ) ។ អ្នកសិក្សា គប្បីជ្រាបតាមន័យដែលខ្ញុំចែកឃដនា ១០ ចេញជា ២ ចំណែក គឺ* ***សវិបាកឃដនា និងអវិបាកឃដនា*** *ដោយអំណាចនៃសហជាតប្បច្ច័យ ហើយពោលទុកក្នុងសហជាតមូលកន័យ ៕*

## ឧបនិស្សយមូលកន័យ

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងយដនាដែលមាន* ***ឧបនិស្សយប្បច្ច័យជាមូល*** *ដូចតទៅ ៖*

*ពីរបទថា* **"អារម្មណេ សត្ត** *= ក្នុងអារម្មណប្បច្ច័យ មាន ៧ វារៈ" គឺវិសជ្ជនាដែលបានក្នុងអារម្មណូបនិស្សយប្បច្ច័យ ។ ពាក្យថា* **"អធិបតិយា សត្ត** *= ក្នុងអធិបតិប្បច្ច័យ មាន ៧ វារៈ" បានដល់ វារៈទាំងនោះឯង ។ បណ្តាអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ វិសជ្ជនាទាំងនោះ បានក្នុងអនន្តរូបនិស្សយប្បច្ច័យ ។*

*ពីរបទថា* **"និស្សយេ ឯកំ** *= ក្នុងនិស្សយប្បច្ច័យ មាន ១ វារៈ" គឺវត្ថុ ជាបច្ច័យដល់អកុសល ។*

*ពីរបទថា* **"បុរេជាតេ ឯកំ** *= ក្នុងបុរេជាតប្បច្ច័យ មាន ១ វារៈ" បានដល់ វត្ថុ ឬអារម្មណ៍ ជាបច្ច័យដល់អកុសលនោះឯង ។*

*ពីរបទថា* **"អាសេវនេ តីណិ** *= ក្នុងអាសេវនប្បច្ច័យ មាន ៣ វារៈ" ត្រាស់សម្តែងទុកដោយអំណាចនៃអនន្តរូបនិស្សយប្បច្ច័យ ។*

*ពីរបទថា* **"កម្មេ ទ្វេ** *= ក្នុងកម្មប្បច្ច័យ មាន ២ វារៈ" ទ្រង់ត្រាស់*

*សម្ដែងទុក ដោយអំណាចនៃបកតូបនិស្សយប្បច្ច័យ ។ ប៉ុន្តែ* ***លោកុត្តរៈ-កុសលចេតនា រមែងជាអនន្តរូបនិស្សយប្បច្ច័យ*** *។*

*ពីរបទថា* **“ ទិប្បយុត្តេ ឯកំ** *= ក្នុងវិប្បយុត្តប្បច្ច័យ មាន ១ វារៈ” ត្រាស់ទុកដោយអំណាចនៃអារម្មណូបនិស្ស័យ ។ ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក៏ដូចគ្នាដែរ ។*

*វិសជ្ជនា ៧ វារៈ ក្នុង* ***នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ*** *ដូចគ្នានឹងអនន្តរប្បច្ច័យដែរ ។*

*ក៏យជនាដែលមាន* ***ឧបនិស្សយប្បច្ច័យជាមូល*** *មាន ៧ ។ បណ្ដាយជនាទាំងនោះ យជនា ៣ ខាងដើម ទ្រង់ត្រាស់សម្ដែងដោយអំណាចនៃអារម្មណូបនិស្សយប្បច្ច័យ ។ ក្នុងយជនា ៣ នោះ ត្រង់* ***យជនាទី ១*** *បទថា* **“សត្ត** *= ៧ វារៈ” សេចក្ដីថា មានវិសជ្ជនា ៧ វារៈយ៉ាងនេះ គឺកុសល ជាបច្ច័យដល់កុសលជាដើម, អព្យាកតៈ ក៏ដូចគ្នាដែរ (រួមជា ៦), អកុសល ជាបច្ច័យដល់អកុសលតែម្យ៉ាង ។*

*បទថា* **“ឯកំ** *= ១ វារៈ” ក្នុង* ***យជនាទី ២*** *សេចក្ដីថា អព្យាកតៈ មានចក្ខុជាដើម ជាបច្ច័យដល់អកុសល ។*

*ក្នុង* ***យជនាទី ៣*** *បានដល់ វត្ថុជាបច្ច័យដល់អកុសល ។ យជនា ២ តអំពីនោះ ត្រាស់សម្ដែងទុកដោយអំណាចនៃអនន្តរូបនិស្សយប្បច្ច័យ ។*

ការរាប់ចំនួនក្នុងយជនាទាំងនោះ ជាក់ច្បាស់ហើយ ។

តអំពីនោះ យជនា ២ ទៀត ត្រាស់ទុកដោយអំណាចនៃអនន្តរូ-បនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ ក្នុងយជនា ២ នោះ លោកិយកុសល និងអកុសលចេតនា លោកកាន់យកដោយសេចក្ដីជាបច្ច័យ ក្នុងយជនាទី ១, ចំណែកក្នុងយជនាទី ២ លោកកាន់យកតែលោកុត្តរ-កុសលតែម្យ៉ាង ៕

---

## បុរេជាតមូលកន័យ

គប្បីជ្រាបនូវវិនិច្ឆ័យក្នុងយជនាដែលមាន ***បុរេជាតប្បច្ច័យជាមូល*** ដូចតទៅ ៖

ពីរបទថា “**អារម្មណេ តីណិ** = ក្នុងអារម្មណប្បច្ច័យ មាន ៣ វារៈ” គឺអព្យាកតៈ ជាបច្ច័យដល់កុសលជាដើម ។

ពីរបទថា “**អធិបតិយា ឯកំ** = ក្នុងអធិបតិប្បច្ច័យ មាន ១ វារៈ” គឺអព្យាកតៈ ជាបច្ច័យដល់អកុសល ។ ក្នុងយជនាដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងន័យនេះ មានយជនា ៧ ក្នុងយជនាទាំងនោះ ៖

***-យជនា ទី ១*** ត្រាស់សម្ដែងទុកដោយអំណាចនៃវត្ថុ និងអារម្មណ៍ ។

*__-យជនាទី ២__ ត្រាស់សម្ដែងទុកដោយអំណាចនៃវត្ថុ ។*

*__-យជនាទី ៣__ ត្រាស់សម្ដែងទុកដោយអំណាចនៃអារម្មណ៍ ។*

*__-យជនាទី ៤__ ត្រាស់សម្ដែងទុកដោយអំណាចនៃវេលាដែលមានវត្ថុជាអារម្មណ៍ ។*

*__-យជនាទី ៥__ ត្រាស់ទុកដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។*

*__-យជនាទី ៦__ ត្រាស់សម្ដែងទុកដោយអំណាចនៃវេលាដែលមានវត្ថុជាអារម្មណាធិបតី ។*

*__-យជនាទី ៧__ ត្រាស់សម្ដែងទុកដោយអំណាចនៃចក្ខុវត្ថុជាដើម ៕*

---

## បច្ឆាជាតមូលកន័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុងយជនាដែលមាន __បច្ឆាជាតប្បច្ច័យជាមូល__ ដូចតទៅ ៖*

*បច្ច័យ ២០ រមែងប្រកបមិនបាន, ប្រកបបានចំពោះតែបច្ច័យ ៣ ប៉ុណ្ណោះ; ក្នុងន័យនេះ មានយជនាតែ ១ ប៉ុណ្ណោះឯង, យជនានោះ គប្បីជ្រាបដោយអំណាចនៃកុសលជាដើម ជាបច្ច័យដល់កាយ ។ សូម្បីក្នុងន័យដែលមានអាសេវនប្បច្ច័យជាមូល ក៏មានយជនា ១ ដូចគ្នាដែរ ៕*

# កម្មមូលកន័យ

*គប្បីជ្រាបវិនិច្ឆ័យក្នុងយជនាដែលមាន **កម្មប្បច្ច័យជាមូល** តទៅ ៖*

*ពីរបទថា **“អនន្តរេ ឯកំ** = ក្នុងអនន្តរប្បច្ច័យ មាន ១ វារៈ” លោកពោលទុកដោយអំណាចនៃចេតនាក្នុងមគ្គ ។ ក្នុងពាក្យថា **“អញ្ញមញ្ញេ តីណិ** = ក្នុងអញ្ញមញ្ញប្បច្ច័យ មាន ៣ វារៈ” ដូច្នេះ គប្បីកាន់យកវត្ថុក្នុងបដិសន្ធិកាលផង ។ ពីរបទថា **“ឧបនិស្សយេ ទ្វេ** = ក្នុងឧបនិស្សយប្បច្ច័យ មាន ២ វារៈ” គឺវារៈ ២ ដែលពោលទុកអំពីខាងដើម ដោយអំណាចនៃអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។ សូម្បីយជនាដ៏សេស ក៏គប្បីជ្រាបតាមន័យដែលបានពោលហើយ អំពីខាងដើមនោះដែរ ។ ក៏ក្នុងន័យនេះ មានយជនា ១១ ពួក; បណ្តាយជនាទាំងនោះ **យជនា ២ ដំបូង ត្រាស់សម្តែងទុកដោយអំណាចនៃនានក្ខណិកកម្មប្បច្ច័យ ដោយ បែងចែកជាបកតូបនិស្ស័យ និងអនន្តរូបនិស្ស័យ**, ក្រៅអំពីនោះ យជនា ៨ ទៀត ត្រាស់សម្តែងទុកដោយអំណាចនៃឯកក្ខណិកកម្មប្បច្ច័យ អំពីធម៌ដែលជាសវិបាក និងអវិបាក ។ ក្នុងយជនាទាំង ៨ នោះ ៖*

*- **យជនាទី ១** បានដល់ ចិត្តជរូប ព្រមទាំងអរូប ។*

*- **យជនាទី ២** បានដល់ វត្ថុ ព្រមទាំងអរូប ។*

**-យមកទី ៣** បានចំពោះតែអរូបម្យ៉ាង ។

**-យមកទី ៤** បានចំពោះតែចិត្តជរូប, ចំណែកកម្មជរូប បានក្នុងបដិសន្ធិកាល ។

**-យមក ៥** ដទៃក្រៅពីនោះ **ជាសវិបាក** មានន័យដូចដែលខ្ញុំបានពោលទុកអំពីខាងដើមនុ៎ះឯង ៕

---

## វិបាកមូលកន័យ

យមក ៥ ក្នុងន័យដែលមាន **វិបាកប្បច្ច័យជាមូល** មានសេចក្ដីជាក់ច្បាស់ហើយ ៕

---

## អាហារមូលកន័យ

ពាក្យថា **"សត្ត = ៧ វារៈ"** ជាដើម ក្នុងន័យដែលមាន **អាហារ-ប្បច្ច័យជាមូល** មានន័យដូចដែលខ្ញុំពោលហើយដែរ ។ ក៏ក្នុងន័យនេះមានយមក ៣៤ ។ បណ្ដាយមកទាំងនោះ **យមក ៥ ដំបូង** លោកពោលទុកជា **សវិបាកយមក និងអវិបាកយមក** ។

ក្នុងឈានទាំងនោះ អាហារទាំង ៤ រមែងបានក្នុង ***ឈានទី ១*** ។ ចំពោះនាមាហារ ៣ ប៉ុណ្ណោះ បានក្នុង ***ឈានទី ២*** ។

***ឈានទី ៣*** មានវត្ថុជាបច្ចុប្បន្នដែរ ។

***ឈានទី ៤*** មិនមានវត្ថុឡើយ ។

***ឈានទី ៥*** មានរូបប៉ុណ្ណោះ ជាបច្ចុប្បន្ន ។ ឈាន ៥ ដទៃក្រៅអំពីនោះ មានន័យដូចដែលខ្ញុំបានពោលហើយអំពីខាងដើម ។

***ឈាន ៩ តអំពីនោះ*** ព្រះមានព្រះភាគត្រាស់សម្ដែងទុក ដោយអំណាចនៃអាហារ គឺចេតនា (មនោសញ្ចេតនាហារ) ***ឈាន ៩ ក្រៅអំពីនោះ*** ត្រាស់សម្ដែងទុកដោយអំណាចនៃវិញ្ញាណាហារដែលមិនមានអធិបតី, ***ឈាន ៦ ក្រៅអំពីនោះ*** ត្រាស់សម្ដែងដោយអំណាចនៃវិញ្ញាណាហារដែលមានអធិបតី; ក្នុងឈានទាំង ៦ នោះ ***ឈាន ៣*** ត្រាស់សម្ដែងដោយអំណាចនៃធម៌ដែលជាសវិបាកឈាន និងអវិបាកឈានដូចគ្នា (ឬរួមគ្នា), ឈាន ៣ ទៀត ត្រាស់សម្ដែងដោយអំណាចនៃសវិបាកឈានតែម្យ៉ាង; ក្នុងឈាន ៣ នោះ មិនមានវត្ថុរូប ព្រោះមិនមានលោកិយវិបាកទេ ៕

# ឥន្ទ្រិយមូលកន័យ

*ពាក្យថា* **“ចុរេជាតេ ៦កំ** *= ក្នុងបុរេជាតប្បច្ច័យមាន ១ វារៈ”* *ក្នុងន័យដែលមាន* ***ឥន្ទ្រិយប្បច្ច័យជាមូល*** *មានយជនា ១ គឺអព្យាកតៈជាមួយអព្យាកតៈដោយអំណាចនៃចក្ខុន្ទ្រិយជាដើម ។ យជនាដែលមានមូល ២ ដ៏សេស គប្បីជ្រាបតាមន័យដែលខ្ញុំបានពោលហើយអំពីខាងដើម ។ ក្នុងន័យនេះ មានយជនា ៧៦ ។*

*បណ្ដាយជនាទាំង ៧៦ នោះ ៖*

***-យជនាទី ១*** *បានដល់ ឥន្ទ្រិយទាំងអស់ ដោយអត្ថថា ជាបច្ច័យ ។*

***-យជនាទី ២*** *មិនមានរូបជីវិតិន្ទ្រិយទេ ព្រោះរូបជីវិតិន្ទ្រិយនោះរមែងមិនជាទីអាស្រ័យឡើយ ។*

***-យជនាទី ៣*** *បានដល់ អរូបជីវិតិន្ទ្រិយជាបច្ច័យដល់រូប ។*

***-យជនាទី ៤*** *បានដល់ ចក្ខុន្ទ្រិយជាដើម ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ។*

***-យជនា ៩*** *តអំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃអរូបឥន្ទ្រិយដែលកើតព្រមគ្នា ។*

***-យជនា ៩*** *បន្ទាប់អំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃឥន្ទ្រិយដែលជាតួមគ្គ ។*

-**យជនា ៩** គអំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃឥន្ទ្រិយ ដែលជាអន្តឈាន ។

-**យជនា ៩** បន្តពីនោះ ត្រាស់សម្ដែងដោយអំណាចនៃឥន្ទ្រិយ ដែលជាឈាន និងមគ្គ ។

-**យជនា ៩** គអំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃមនិន្ទ្រិយ តែម្យ៉ាង ។

-**យជនា ៦** បន្ទាប់អំពីនោះ មានអធិបតី ។

-**យជនា ៦** គអំពីនោះ ប្រកបដោយមគ្គ ដោយអំណាចនៃវីរិយា-ធិបតី និងវីមំសាធិបតី ។

-**យជនា ៩** គអំពីនោះ មិនមានអធិបតី ដោយអំណាចនៃអមោហ-ហេតុទេ ។

-**យជនា ៦** មានអធិបតី ។ បណ្ដាយជនាទាំងអស់នោះ យជនាដែលមិនប្រកប និងប្រកបដោយវិបាកប្បច្ច័យ គប្បីជ្រាបតាមន័យដែលខ្ញុំបានពោលហើយអំពីខាងដើមនោះឯង ៕

## ឈានមូលកន័យ

*សូម្បីក្នុងយជនាដែលមាន* ***ឈានប្បច្ច័យជាមូល*** *យជនាដែលមានមូល ២ គប្បីជ្រាបតាមន័យដែលខ្ញុំបានពោលហើយ អំពីខាងដើមដូចគ្នា ។ ក៏ក្នុងន័យនេះ មានយជនា ៣៦; បណ្ដាយជនាទាំងនោះ* ***យជនា ៩ ដំបូង*** *ត្រាស់សម្ដែងទុកដោយអំណាចនៃអង្គឈានទូទៅ មិនសំដៅដល់សេចក្ដីជាឥន្ទ្រិយ ឬមគ្គឡើយ ។*

***យជនា ៩*** *បន្ទាប់អំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃអង្គឈានដែលជាតួមគ្គ ។*

***យជនា ៩*** *តអំពីនោះ ត្រាស់សម្ដែងដោយអំណាចនៃអង្គឈានដែលជាឥន្ទ្រិយ និងមគ្គ ។*

*ម្យ៉ាងទៀត បណ្ដាពួក ៩ ទាំងបួនពួកនេះ* ***យជនា ៤ ខាងដើម*** *ទូទៅដល់វិបាក និងអវិបាក ។*

***យជនា ៥*** *ក្នុងទីបំផុត បានដល់ វិបាកប៉ុណ្ណោះ ។ យជនាទាំងនោះខ្ញុំបានពោលទុកហើយ អំពីខាងដើមដូចគ្នា ៕*

# មគ្គមូលកន័យ

*យជនាដែលមានមូល ២ ក្នុងន័យដែលមាន **មគ្គប្បច្ច័យជាមូល** គប្បីជ្រាបតាមន័យដែលខ្ញុំបានពោលទុកហើយដូចគ្នានោះចុះ ។ ក៏ក្នុងន័យនេះមានយជនា ៥៧; បណ្ដាយជនាទាំងនោះ ៖*

- ***យជនា ៩ ដំបូង** ត្រាស់សម្ដែងដោយអន្តមគ្គសុទ្ធ, មិនរួមដល់សេចក្ដីដែលជាឥន្ទ្រិយ និងឈានទេ ។*
- ***យជនា ៩ បន្ទាប់អំពីនោះ** ត្រាស់សម្ដែងដោយអំណាចនៃមគ្គដែលជាឥន្ទ្រិយ ។*
- ***យជនា ៩ តអំពីនោះ** ត្រាស់ដោយអំណាចមគ្គដែលជាឈាន ។*
- ***យជនា ៩** ត្រាស់ដោយអំណាចមគ្គដែលជាឥន្ទ្រិយ និងឈាន ។*
- ***យជនា ៦ តអំពីនោះ** ត្រាស់សម្ដែងដោយអំណាចនៃមគ្គ ដែលជាអធិបតី ។*
- ***យជនា ៩ តអំពីនោះ** ត្រាស់សម្ដែងដោយអំណាចនៃមគ្គ និងហេតុដែលជាអធិបតី ។*
- ***យជនា ៦ តអំពីនោះ** ត្រាស់សម្ដែងដោយអំណាចនៃមគ្គ និងហេតុដែលជាអធិបតី ។*

*ក្នុងពួកដែលមាន **យជនា ៩** មាន ៥ ពួក **ជាសវិបាកយជនា***

គឺមួយពួកៗ មាន ៥ យជនា, ក្នុងពួកដែលមាន ***យជនា ៦ ជាសវិបាក-យជនា*** មួយពួកៗ មាន ៣ យជនា ។ ពួកដ៏សេស ជាសាធារណៈ ។ យជនាទាំងអស់ មានន័យដូចដែលខ្ញុំបានពោលហើយអំពីខាងដើម ៕

## សម្បយុត្តមូលកន័យ

យជនាដែលមានមូល ២ ក្នុងន័យដែលមាន ***សម្បយុត្តប្បច្ច័យជាមូល*** ប្រាកដច្បាស់ហើយ ។ ក៏ក្នុងន័យនេះ មានយជនា ២ ប៉ុណ្ណោះ ។ ក្នុងយជនាទាំង ២ នោះ យជនា ១ ត្រាស់សម្ដែងដោយអំណាចនៃធម៌ទូទៅ, យជនា ១ ទៀត ត្រាស់ដោយអំណាចនៃវិបាក ៕

## វិប្បយុត្តមូលកន័យ

សូម្បីក្នុងន័យដែលមាន ***វិប្បយុត្តប្បច្ច័យជាមូល*** យជនាដែលមានមូល ២ ជាក់ច្បាស់ហើយ ។ ក៏ក្នុងន័យនេះ មានយជនា ១៣ ។ បណ្ដាយជនាទាំងនោះ ពាក្យថា **“បញ្ច = ៥ វារៈ”** ក្នុងយជនាទី ១ គឺកុសលជាបច្ច័យដល់អព្យាកតៈ, អកុសល ជាបច្ច័យដល់អព្យាកតៈ, ចំណែកអព្យាកតៈ ជាបច្ច័យដល់កុសល អកុសល និងអព្យាកតៈ ។ ក៏ក្នុងន័យនេះ មានវិប្បយុត្តប្បច្ច័យជាដើមនេះ កើតព្រមគ្នាក៏មាន, កើតខាងក្រោយគ្នា

និងកើតមុនគ្នាក៏មាន ។

ក្នុង ***យមនាទី ២*** ចំពោះតែជាបុរេជាត និងសហជាតប៉ុណ្ណោះ ។ បច្ច័យទាំងនោះឯង ត្រាស់សម្ដែងទុកក្នុង ***យមនាទី ៣*** ដោយអំណាចនៃអធិបតី ។ បណ្ដាបច្ច័យទាំងនោះ បានវារៈ ៤ យ៉ាងនេះ គឺកុសលជាបច្ច័យដល់អព្យាកតៈ, អកុសលជាបច្ច័យដល់អព្យាកតៈ, ប៉ុន្តែ អព្យាកតៈជាបច្ច័យដល់អព្យាកតៈ និងអកុសល ដោយអំណាចនៃអារម្មណាធិបតិ-ប្បច្ច័យ ។

បទថា **"តីណិ = ៣ វារៈ"** ក្នុង ***យមនាទី ៤*** គឺកុសលជាដើមជាបច្ច័យដល់អព្យាកតៈ ។ ក៏ក្នុងន័យនេះ បានទាំងរូបឥន្ទ្រិយ ទាំងនាម-ឥន្ទ្រិយ ។

ក្នុង ***យមនាទី ៥*** នាមប៉ុណ្ណោះ ជាបច្ច័យ ។

ក្នុង ***យមនាទី ៦*** រូប គឺវត្ថុរូបជាបច្ច័យ ។

ក្នុង ***យមនាទី ៧*** រូបជាបច្ច័យដល់កុសល និងអព្យាកតៈ ដោយអំណាចនៃវិបស្សនា ។ ហទយវត្ថុប៉ុណ្ណោះ ជាបច្ច័យដល់អកុសល ដោយអំណាចជាទីត្រេកអរ ។

ក្នុង ***យមនាទី ៨*** ហទយវត្ថុនោះឯង ជាបច្ច័យដល់អកុសល ។

ក្នុង ***យមនាទី ៩*** ចក្ខុជាដើម ជាបច្ច័យដល់អព្យាកតៈ ។

ក្នុង ***ឃដនាទី ១០*** កុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។

ក្នុង ***ឃដនាទី ១១*** វត្ថុជាបច្ច័យដល់ខន្ធទាំងឡាយ ក្នុងបដិសន្ធិកាល ។

ក្នុង ***ឃដនាទី ១២*** ខន្ធទាំងឡាយ ជាបច្ច័យដល់កដត្តារូប ក្នុងបដិសន្ធិកាល ។

ក្នុង ***ឃដនាទី ១៣*** ខន្ធទាំងឡាយ ជាបច្ច័យដល់វត្ថុរូប ក្នុងបដិសន្ធិកាល ៕

---

## អត្ថិមូលកន័យ

ក្នុងន័យដែលមាន ***អត្ថិប្បច្ច័យជាមូល*** ពីរបទថា “ **ឧបនិស្សយេ ឯកំ** = ក្នុងឧបនិស្សយប្បច្ច័យ មាន ១ វារៈ” គឺអព្យាកតៈ ជាបច្ច័យដល់អកុសលដោយអំណាចនៃអារម្មណូបនិស្ស័យ ។ ឃដនាដ៏សេស ក្នុងទុមូលកន័យ មានន័យងាយស្រួលទាំងអស់ ។ ក៏ក្នុងន័យនេះ មានឃដនា ២៩ ។ បណ្តាឃដនាទាំងនោះ ***ឃដនាទី ១*** បាន សហជាតប្បច្ច័យ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ដោយអំណាចនៃអរូប, វត្ថុអារម្មណ៍, មហាភូតរូប, ឥន្ទ្រិយ និងអាហារ ។

ក្នុង ***ឃដនាទី ២*** បានកវឡិង្ការាហារ និងរូបជីវិតិន្ទ្រិយដែលកើត

ខាងក្រោយ ។

***យជនាទី ១ និងទី ២*** ប៉ុណ្ណោះ ព្រមជាមួយនឹងអធិបតិប្បច្ច័យ លោកចាត់ជា ***យជនាទី ៣ និងយជនាទី ៤*** ក្នុងយជនាតទៅ ៖

ចំពោះយជនាទី ១ ជាមួយនឹងអាហារ ៤ ចាត់ទុកជា ***យជនាទី ៥*** ។

យជនាទី ១ ជាមួយនឹងរូបជីវិតិន្ទ្រិយ ចាត់ជា ***យជនាទី ៦*** ជាមួយរូប និងអរូបឥន្ទ្រិយ ចាត់ទុកជា ***យជនាទី ៧ ទៀត*** ។

ឬថា ចំពោះយជនាទី ២ ប៉ុណ្ណោះ ជាមួយនឹងឥន្ទ្រិយទាំងឡាយ ចាត់ជា ***យជនាទី ៧*** ។

ចំពោះយជនាទី ១ និងទី ២ ជាមួយវិប្បយុត្តប្បច្ច័យ ចាត់ជា ***យជនាទី ៨ និងយជនាទី ៩*** ។

បណ្ដាយជនាទាំងនោះ ***យជនាទី ៩*** ជាមួយអធិបតិប្បច្ច័យ ចាត់ជា ***យជនាទី ១០*** ។

បន្ទាប់អំពីនោះ យកវត្ថុរូបចេញ ដោយអំណាចជាបច្ច័យ ក្នុង ***យជនាទី ១១*** ។

អរូបធម៌ទាំងឡាយប៉ុណ្ណោះ ជាបច្ច័យក្នុង ***យជនាទី ១២*** ។

ក្នុង ***យជនាទី ១៣*** មានវត្ថុដែលជាអារម្មណ៍ជាបច្ច័យ ។

ក្នុង ***បដនាទី ១៤*** មានវត្ថុប៉ុណ្ណោះ ជាបច្ច័យ ។

ក្នុង ***បដនាទី ១៥*** មានអារម្មណ៍ប៉ុណ្ណោះ ជាបច្ច័យ ។

ក្នុង ***បដនាទី ១៦*** មានវត្ថុប៉ុណ្ណោះ ជាអារម្មណ៍ ។

ក្នុង ***បដនាទី ១៧*** វត្ថុនោះឯង ជាអារម្មណ៍ដោយអំណាចជាអារម្មណាធិបតី ។

ក្នុង ***បដនាទី ១៨*** វត្ថុនោះឯង ជាអារម្មណ៍ដោយអំណាចនៃអារម្មណូបនិស្សយប្បច្ច័យ ។

ចក្ខុជាដើមប៉ុណ្ណោះ ជាបច្ច័យ ក្នុង ***បដនាទី ១៩*** ។

***បដនាទី ១៩ ទាំងនេះ*** ឈ្មោះថា ***បកិណ្ណកបដនា*** ដែលព្រះអដ្ឋកថាចារ្យសម្ដែងទុកដោយមិនកាន់យកនូវសហជាត ។ ***បដនា ១០*** តអំពីនោះ ត្រាស់សម្ដែងទុកដោយអំណាចនៃសហជាតបដនា ៕

---

## នត្ថិ-វិគតមូលកន័យ

ក្នុងន័យដែលមាន ***នត្ថិ និងវិគតប្បច្ច័យជាមូល*** មានបដនា ៣ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ និងកម្មប្បច្ច័យ ដូចក្នុងន័យដែលមានអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យជាមូលដែរ ៕

---

## អវិគតមូលកន័យ

*យជនាដែលមាន **អវិគតប្បច្ច័យជាមូល** ក៏ដូចគ្នានឹងយជនាដែលមាន អត្ថិប្បច្ច័យជាមូលនោះដែរ ។*

***ក៏យជនាដែលពោលទុកក្នុងបញ្ហាវារៈទាំងអស់នេះ មាន ២ យ៉ាង ប៉ុណ្ណោះ គឺបកិណ្ណកយជនា និងសហជាតយជនា ។***

*បណ្ដាបកិណ្ណកយជនា និងសហជាតយជនាទាំងនោះ ជាយជនាដែលលោកពោលទុកតាំងអំពីដើម, ប៉ុន្តែ យជនាដែលមាន **អារម្មណ-ប្បច្ច័យជាមូល** ជាដើមទាំងអស់ មិនរួមជាមួយសហជាតឈ្មោះ **បកិណ្ណក-យជនា** ទេ ។*

*បកិណ្ណកយជនាទាំងនោះ សូម្បីក្នុងយជនាដែលមាន **អារម្មណប្បច្ច័យជាមូល** មាន ៥ យជនា ។*

*ក្នុងយជនាដែលមាន **អធិបតិប្បច្ច័យជាមូល** មាន ៦ យជនា ។*

*ក្នុងយជនាដែលមាន **អនន្តរប្បច្ច័យជាមូល** មាន ៣ យជនា ។*

*ក្នុងយជនាដែលមាន **សមនន្តរប្បច្ច័យជាមូល** មាន ៣ យជនា ។*

*ក្នុងយជនាដែលមាន **និស្សយប្បច្ច័យជាមូល** មាន ១០ យជនា ។*

*ក្នុងយជនាដែលមាន **ឧបនិស្សយប្បច្ច័យជាមូល** មាន ៧ យជនា ។*

*ក្នុងយជនាដែលមាន **បុរេជាតប្បច្ច័យជាមូល** មាន ៧ យជនា ។*

ក្នុងឃដនាដែលមាន **បច្ឆាជាតប្បច្ច័យជាមូល និងអាសេវនប្បច្ច័យជាមូល** តែម្យ៉ាងៗ មាន ១ ឃដនាប៉ុណ្ណោះ ។

ក្នុងឃដនាដែលមាន **កម្មប្បច្ច័យជាមូល** មាន ២ ឃដនា ។

ក្នុងឃដនាដែលមាន **អាហារជាមូល** មាន ១ ឃដនា ។

ក្នុងឃដនាដែលមាន **ឥន្ទ្រិយជាមូល** មាន ៤ ឃដនា ។

ក្នុងឃដនាដែលមាន **វិប្បយុត្តប្បច្ច័យជាមូល** មាន ៩ ឃដនា ។

ក្នុងឃដនាដែលមាន **អត្ថិប្បច្ច័យជាមូល** មាន ១៩ ឃដនា ។

ក្នុងឃដនាដែលមាន **នត្ថិប្បច្ច័យ និងវិគតប្បច្ច័យជាមូល** មាន ៣ ឃដនា ។

ក្នុងឃដនាដែលមាន **អវិគតប្បច្ច័យជាមូល** មាន ១៩ ឃដនា ។

ព្រោះហេតុដូច្នោះ បកិណ្ណកឃដនាទាំងអស់ ទើបមាន ១០៣ ឃដនា ។ ក៏ឃដនាទាំងអស់នេះ ហៅថា **បកិណ្ណកឃដនា** ព្រោះមិនមានការកំណត់ដោយសហជាតប្បច្ច័យទេ ។

ក៏ឃដនាដែលបានសហជាត លោកហៅថា **សហជាតឃដនា** ។ ឃដនាទាំងនោះ រមែងមិនបានក្នុងឃដនាដែលមានអារម្មណប្បច្ច័យជាមូលទេ, ក្នុងឃដនាដែលមានអនន្តរប្បច្ច័យ, សមនន្តរប្បច្ច័យ, ឧបនិស្សយ-

ប្បច្ច័យ, បុរេជាតប្បច្ច័យ, បច្ឆាជាតប្បច្ច័យ, អាសេវនប្បច្ច័យ, នត្ថិ-ប្បច្ច័យ និងវិគតប្បច្ច័យ (មានអារម្មណប្បច្ច័យ) ជាមូល; ព្រោះថា បច្ច័យទាំងនោះ រមែងមិនជាបច្ច័យដល់ធម៌ដែលកើតព្រមគ្នាឡើយ ។ ម្យ៉ាងទៀត ធម៌ទាំងនោះ មិនជាបច្ច័យដល់ធម៌ដែលកើតព្រមគ្នា យ៉ាងណា, ក៏រមែងមិនជាហេតុប្បច្ច័យ, សហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, វិបាក-ប្បច្ច័យ, ឈានប្បច្ច័យ, មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ដល់ធម៌ដែលមិនបានកើតព្រមគ្នាដូច្នោះដែរ ។

ព្រោះហេតុដូច្នោះ យជនាទាំងអស់ ២៤ ក្នុងយជនាដែលមានហេតុប្បច្ច័យជាមូល ទើបឈ្មោះថា ***សហជាតយជនា*** ប៉ុណ្ណោះ ។

ក្នុងយជនាដែលមាន ***អធិបតិប្បច្ច័យជាមូល*** មាន ២៤ យជនា ។

ក្នុងយជនាដែលមាន ***សហជាតប្បច្ច័យជាមូល*** មាន ១០ យជនា ។

ក្នុងយជនាដែលមាន ***អញ្ញមញ្ញប្បច្ច័យជាមូល*** មាន ៦ យជនា ។

ក្នុងយជនាដែលមាន ***និស្សយប្បច្ច័យជាមូល*** មាន ១០ យជនា ។

ក្នុងយជនាដែលមាន ***កម្មប្បច្ច័យជាមូល*** មាន ៩ យជនា ។

ក្នុងយជនាដែលមាន ***វិបាកប្បច្ច័យជាមូល*** មាន ៥ យជនា ។

ក្នុងយជនាដែលមាន ***អាហារប្បច្ច័យជាមូល*** មាន ៣៣ យជនា ។

ក្នុងយជនាដែលមាន **ឥន្ទ្រិយប្បច្ច័យជាមូល** មាន ៧២ យជនា ។

ក្នុងយជនាដែលមាន **ឈានប្បច្ច័យជាមូល** មាន ៣៦ យជនា ។

ក្នុងយជនាដែលមាន **មគ្គប្បច្ច័យជាមូល** មាន ៥៧ យជនា ។

ក្នុងយជនាដែលមាន **សម្បយុត្តប្បច្ច័យជាមូល** មាន ២ យជនា ។

ក្នុងយជនាដែលមាន **វិប្បយុត្តប្បច្ច័យជាមូល** មាន ៤ យជនា ។

ក្នុងយជនាដែលមាន **អត្ថិប្បច្ច័យជាមូល** មាន ១០ យជនា ។

ក្នុងយជនាដែលមាន **អវិគតប្បច្ច័យជាមូល** មាន ១០ យជនា ។

សហជាតយជនាទាំងអស់ ទើបមាន ៣១២ យជនា ។

យជនាទាំងអស់ ៤១៥ **គឺបកិណ្ណកយជនាខាងដើម ១០៣ យជនា និងសហជាតយជនាទាំងនេះ ៣១២ យជនាទៀត ដែលមានមកហើយក្នុងបញ្ហាវារៈ ដោយប្រការដូច្នេះ** ។

បណ្ដាបច្ច័យទាំងនោះ បច្ចយធម៌ពួកណា មិនប្រាកដដោយអំណាចនៃឈ្មោះទេ, ប៉ុន្តែ គេដឹងបានសូម្បីពួកបច្ចយធម៌នោះ គប្បីសម្ដែងក្នុងយជនាទាំងឡាយ ដែលលោកពោលទុកដោយទូទៅដល់ធម៌ដែលជាវិបាក និងមិនមែនជាវិបាក តាំងអំពីន័យដែលមានហេតុជាមូលជាដើមទៅ; ពិតមែនហើយ ធម៌ទាំងនេះ គឺហេតុ ១២ អារម្មណ៍ ៦ អធិបតី ៤ អាហារ ៤ ឥន្ទ្រិយ ២០ អង្គឈាន ៧ និងអង្គមគ្គ ១២ ឈ្មោះថា **បច្ចយធម៌;**

បណ្ដាធម៌ទាំងនោះ ធម៌ពួកណាៗ ជាកុសលដោយចំណែកមួយ, ជាអកុសលដោយចំណែកមួយ, វិបាករបស់កុសលដោយចំណែកមួយ, វិបាករបស់អកុសលដោយចំណែកមួយ, វិបាកដោយចំណែកមួយ, មិនមែនវិបាកដោយចំណែកមួយ បណ្ឌិតកំណត់ធម៌ពួកនោះៗ ឲ្យល្អ ហើយគប្បីប្រកបធម៌ដែលជាវិបាក បញ្ចូលទៅក្នុងយជនាដែលជាវិបាក គប្បីប្រកបធម៌ដែលមិនមែនវិបាកបញ្ចូលទៅក្នុងយជនា ដែលមិនមែនវិបាក តាមសមគួរដែលនឹងប្រកបបានចុះ ។

ចប់អនុលោមគណនា ក្នុងយជនានៃបញ្ហាវារៈ

# បច្ចនីយន័យ

## ពណ៌នាអំពីសេចក្តីនៃបច្ចនីយុទ្ធារៈ

ឥឡូវនេះ ***ជាបច្ចនីយន័យ*** ។ គប្បីជ្រាបវិនិច្ឆ័យក្នុង ***បច្ចនីយន័យ*** នោះ ដូចតទៅនេះ ៖

បញ្ហាទាំងឡាយ ដែលបានដោយន័យជាដើមថា ***“អកុសលធម៌អាស្រ័យអកុសលធម៌កើតឡើង ព្រោះនហេតុប្បច្ច័យ”*** ក្នុងបដិច្ចវារៈជាដើម អធិប្បាយពង្រីកចេញទៅដោយសង្ខេប ដោយអំណាចនៃបច្ច័យទាំងឡាយដែលបានហើយ យ៉ាងណាមិញ, ដើម្បីសម្ដែងបច្ចនីយៈដោយសង្ខេប មានលក្ខណៈដូចគ្នា ដែលមិនពិស្ដារ, ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយ អធិប្បាយ ពង្រីកបច្ច័យនៃកុសលជាដើម ដោយអនុលោមមានន័យជាដើមថា ***“កុសលធម៌ជាបច្ច័យដល់កុសលធម៌ ដោយអំណាចនៃអារម្មណប្បច្ច័យ”*** ដូច្នេះ ។ ក៏បច្ច័យទាំងនោះឯង ព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយអំណាចនៃបច្ច័យជាពួកៗ (ដុំៗ), មិនបានសម្ដែងដោយអំណាចនៃបច្ច័យតែម្យ៉ាងៗ នោះទេ, បណ្ឌិតគប្បីបំបែកបច្ច័យដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកជាពួក ហើយគប្បីជ្រាបក្នុងកន្លែងនោះចុះ ។

***ពិតមែនហើយ បច្ច័យទាំងអស់ ២៤ នេះ រមែងរួមចូលក្នុងបច្ច័យ***

***ទាំង ៨ ។ ក្នុងបច្ច័យទាំង ៨ អ្វីខ្លះ ? គឺក្នុងអារម្មណប្បច្ច័យ សហជាត-ប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ។***

*តើដូចម្ដេច ?*

*ពិតមែនហើយ បណ្ដាបច្ច័យទាំង ១៦ ដ៏សេស វៀរបច្ច័យទាំង ៨ នេះចេញ* ***បច្ច័យទាំង ៦ នេះ គឺហេតុប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ កើតព្រមគ្នា ដោយចំណែកមួយ រមែងរួមចុះក្នុងសហជាតប្បច្ច័យ*** *ព្រោះជាបច្ច័យដល់ធម៌ដែលកើតព្រមគ្នានោះឯង ។*

*ចំណែកបច្ច័យទាំង ៥ នេះ* ***គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ កើតឡើងហើយរលត់ទៅ រមែងរួមចុះក្នុងឧបនិស្សយប្បច្ច័យ ដោយលក្ខណៈនៃអនន្តរូបនិស្សយប្បច្ច័យ ព្រោះជាបច្ច័យដល់ធម៌ដែលកើតឡើងក្នុងលំដាប់នៃខ្លួន ។***

***និស្សយប្បច្ច័យ មាន ២ យ៉ាង*** *ដោយចែកជាសហជាតនិស្សយ-ប្បច្ច័យ និងបុរេជាតនិស្សយប្បច្ច័យ; ក្នុងពីរយ៉ាងនោះ សហជាតនិស្សយ-ប្បច្ច័យ រមែងរួមចូលក្នុងសហជាតប្បច្ច័យ ព្រោះជាទីអាស្រ័យនៃធម៌ទាំងឡាយ ដែលកើតរួមគ្នា, បុរេជាតនិស្សយប្បច្ច័យ រមែងរួមចូលក្នុង*

បុរេជាតប្បច្ច័យ ។

***សហជាតាធិបតិប្បច្ច័យ មាន ២ យ៉ាង*** គឺសហជាតាធិបតិប្បច្ច័យ និង អារម្មណាធិបតិប្បច្ច័យ ។ ក្នុង ២ យ៉ាងនោះ សហជាតាធិបតិប្បច្ច័យ រមែងរួមចូលក្នុងសហជាតប្បច្ច័យ ព្រោះជាអធិបតិប្បច្ច័យដល់ធម៌ទាំងឡាយ ដែលកើតរួមគ្នានោះឯង ។ អារម្មណាធិបតិប្បច្ច័យ ជាអារម្មណូបនិស្ស័យ នោះឯង, ព្រោះហេតុដូច្នោះ ទើបរួមចូលក្នុងឧបនិស្សយប្បច្ច័យដោយ លក្ខណៈនៃអារម្មណូបនិស្ស័យ ។

***វិប្បយុត្តប្បច្ច័យ មាន ៣ យ៉ាង*** ដោយចែកជាសហជាត បុរេជាត និងបច្ឆាជាត; ក្នុង ៣ យ៉ាងនោះ សហជាតវិប្បយុត្តប្បច្ច័យរមែងរួមចូល ក្នុងសហជាតប្បច្ច័យ ព្រោះជាវិប្បយុត្តប្បច្ច័យ ដល់ធម៌ទាំងឡាយ ដែល កើតព្រមគ្នានោះឯង ។ បុរេជាតវិប្បយុត្តប្បច្ច័យ រមែងរួមចូលក្នុង បុរេជាតប្បច្ច័យ ព្រោះធម៌ដែលកើតឡើងមុន ជាបច្ច័យដល់ធម៌ដែល កើតឡើងខាងក្រោយ ។ បច្ឆាជាតវិប្បយុត្តប្បច្ច័យ រមែងរួមចុះក្នុងបច្ឆា-ជាតប្បច្ច័យ ព្រោះធម៌ដែលកើតឡើងខាងក្រោយ ជាបច្ច័យដោយអំណាចនៃ ការឧបត្ថម្ភដល់ធម៌ដែលកើតពីមុន ។

***អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ម្យ៉ាងៗ មាន ៦*** ដោយអំណាចនៃ សហជាត បុរេជាត បច្ឆាជាត អាហារ ឥន្ទ្រិយ និងដោយអំណាចនៃអត្ថិ

និងអវិគត ម្យ៉ាងៗ ១ បច្ច័យទៀត ។ បណ្ដាបច្ច័យទាំងនោះ សហជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ រមែងរួមចូលក្នុងសហជាតប្បច្ច័យ ព្រោះធម៌ទាំងឡាយ ដែលកើតព្រមគ្នាប៉ុណ្ណោះ ជាបច្ច័យដោយអំណាចនៃអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ បុរេជាតប្បច្ច័យរមែងរួមចូល ក្នុងបុរេជាតប្បច្ច័យ ព្រោះធម៌ដែលកើតមុន ជាបច្ច័យដល់ធម៌ដែលកើតក្រោយ ។ បច្ឆាជាតប្បច្ច័យទាំងឡាយ រមែងរួមចូលក្នុងបច្ឆាជាតប្បច្ច័យ ព្រោះធម៌ដែលកើតក្រោយ ជាបច្ច័យដោយអំណាចនៃការឧបការទល់ទ្រដល់ធម៌ដែលកើតមុន ។ ធម៌ទាំងឡាយដែលជាអាហាររមែងរួមចូលក្នុងកវឡិង្ការាហារប្បច្ច័យ ។ ធម៌ទាំងឡាយដែលជាឥន្ទ្រិយ រមែងរួមចូលក្នុងរូបជីវិតិន្ទ្រិយប្បច្ច័យដូច្នេះឯង ។ បច្ច័យទាំង ១៦ នេះ គប្បីជ្រាបថាតែងរួមចូលក្នុងបច្ច័យទាំង ៨ នេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បច្ច័យទាំង ៨ នេះ សង្គ្រោះចូលក្នុងអញ្ញមញ្ញប្បច្ច័យ ។ ពិតមែនហើយ អារម្មណប្បច្ច័យដែលសម្ដែងទុកអំពីខាងដើមមាន ២ យ៉ាង ដោយចែកជាអធិបតី និងមិនមែនជាអធិបតី ។ ក្នុង ២ យ៉ាងនោះ បច្ច័យដែលជាអធិបតី រមែងរួមចូលក្នុងឧបនិស្សយប្បច្ច័យ ដោយលក្ខណៈនៃអារម្មណូបនិស្ស័យ, ដែលមិនបានជាអធិបតី រមែងជា

អារម្មណប្បច្ច័យសុទ្ធ ។

***សូម្បីកម្មប្បច្ច័យ ក៏មាន ២ យ៉ាង*** ដោយអំណាចនៃសហជាតកម្ម-ប្បច្ច័យ និងនានក្ខណិកកម្មប្បច្ច័យ ។ ក្នុង ២ យ៉ាងនោះ សហជាត-ប្បច្ច័យរមែងរួមចូលក្នុងសហជាតប្បច្ច័យ ព្រោះជាកម្មប្បច្ច័យដល់ធម៌ទាំងឡាយ ដែលកើតរួមគ្នាជាមួយនឹងខ្លួន ។ ***នានក្ខណិកកម្មប្បច្ច័យ មាន ២ យ៉ាង*** គឺដែលមានកម្លាំងខ្លាំង និងទុព្វល (កម្លាំងខ្សោយ) ។ ក្នុង ២ យ៉ាងនេះ កម្មប្បច្ច័យដែលមានកម្លាំង ជាបច្ច័យជាទីអាស្រ័យដ៏មានកម្លាំងខ្លាំង ដល់វិបាកធម៌ទាំងឡាយ ព្រោះហេតុដូច្នោះ ទើបរួមចូលក្នុងឧប-និស្សយប្បច្ច័យ ។ម្យ៉ាងទៀត កម្មប្បច្ច័យដ៏មានកម្លាំង រមែងជាបច្ច័យដល់រូបទាំងឡាយដែរ, ចំណែកកម្មប្បច្ច័យដែលមានកម្លាំងខ្សោយ រមែងជាបច្ច័យដល់អរូបទាំងឡាយ ដោយនានក្ខណិកកម្មប្បច្ច័យប៉ុណ្ណោះ ។

សូម្បីអាហារប្បច្ច័យ ក៏មាន ២ យ៉ាង គឺជារូប និងអរូប ។ ក្នុង ២ យ៉ាងនោះ អរូបាហារ ជាបច្ច័យដល់ធម៌ដែលកើតព្រមគ្នាជាមួយនឹងខ្លួនប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបរួមចូលក្នុងសហជាតប្បច្ច័យ ។ រូបាហារមិនមែនជាបច្ច័យដល់ធម៌ទាំងឡាយ ដែលកើតព្រមគ្នា ឬកើតមុន ឬក៏កើតខាងក្រោយឡើយ ។ រូបាហារដែលកន្លងហួសឧប្បាទក្ខណៈ ហើយដល់នូវឋិតិខណៈរបស់ខ្លួន រមែងញ៉ាំងភារៈជាអាហារប្បច្ច័យឲ្យសម្រេច

ព្រោះហេតុដូច្នោះ ទើបចាត់ជាអាហារប្បច្ច័យប៉ុណ្ណោះ ។

សូម្បីឥន្ទ្រិយប្បច្ច័យ ក៏មាន ២ យ៉ាង គឺជារូប និងអរូប ។ ក្នុង ២ យ៉ាងនោះ ឥន្ទ្រិយប្បច្ច័យដែលជាអរូប រមែងឲ្យសម្រេចភាវៈជាឥន្ទ្រិយប្បច្ច័យដល់ធម៌ទាំងឡាយដែលកើតព្រមគ្នាជាមួយនឹងខ្លួន ព្រោះហេតុដូច្នេះ ទើបរួមចូលក្នុងសហជាតប្បច្ច័យ; ចំណែករូបឥន្ទ្រិយប្បច្ច័យមាន ២ យ៉ាង ដោយចែកជាខាងក្នុង និងខាងក្រៅ; ក្នុង ២ យ៉ាងនោះ ឥន្ទ្រិយប្បច្ច័យខាងក្នុងកើតឡើងមុន ជាឥន្ទ្រិយប្បច្ច័យដល់ចក្ខុវិញ្ញាណជាដើម ព្រមទាំងសម្បយុត្តធម៌ដែលកើតឡើងខាងក្រោយ ព្រោះហេតុដូច្នោះ ទើបរួមចូលក្នុងបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ ឥន្ទ្រិយប្បច្ច័យខាងក្រៅបានដល់ រូបជីវិតិន្ទ្រិយ ។ រូបឥន្ទ្រិយនោះ សូម្បីនឹងជាបច្ច័យដល់ធម៌ទាំងឡាយ ដែលកើតរួមគ្នា ក៏រមែងជាបច្ច័យដោយអំណាចត្រឹមតែជាការតាមចិញ្ចឹមអនុបាលប៉ុណ្ណោះ, មិនមែនដោយអំណាចនៃការឲ្យកើតឡើង ព្រោះហេតុដូច្នោះ ទើបចាត់ជាឥន្ទ្រិយប្បច្ច័យប៉ុណ្ណោះ ។ បច្ច័យទាំង ៨ នេះ គប្បីជ្រាបថា រមែងរួមបញ្ចូលគ្នាដោយប្រការដូច្នេះ; នេះជាសង្គហន័យ ដោយអំណាចជាអញ្ញមញ្ញៈនៃបច្ច័យដ៏សេស ១៦ និងបច្ច័យទាំង ៨ នោះឯង ក្នុងបច្ច័យ ៨ ត្រឹមតែប៉ុណ្ណោះ ។

ឥឡូវនេះ អ្នកសិក្សា គប្បីជ្រាបបច្ច័យទាំង ២៤ ដែលរួមចូលក្នុងបច្ច័យនីមួយៗ នៃបច្ច័យទាំង ៨ នេះ ។ បណ្ដាបច្ច័យទាំង ២៣ នោះ គឺ ៖

**-អារម្មណប្បច្ច័យ** ប៉ុណ្ណោះ រមែងរួមចូលក្នុងអារម្មណប្បច្ច័យដែលជាទី ១ នៃបច្ច័យទាំង ៨ នោះមុន, បច្ច័យដ៏សេស ២៣ រមែងរួមបញ្ចូលមិនបានទេ ។

**-បច្ច័យទាំង ១៥** នេះ គឺហេតុប្បច្ច័យ សហជាតាធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ សហជាតនិស្សយប្បច្ច័យ សហជាតកម្មប្បច្ច័យ វិបាកប្បច្ច័យ សហជាតាហារប្បច្ច័យ សហជាតិន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ សហជាតវិប្បយុត្តប្បច្ច័យ សហជាតត្ថិប្បច្ច័យ និងសហជាតអវិគតប្បច្ច័យ រមែងរួមចូលក្នុងសហជាតប្បច្ច័យទី ២ ។

**-បច្ច័យទាំង ៩** នេះ គឺអារម្មណប្បច្ច័យដែលជាអធិបតី អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ ពលវកម្មប្បច្ច័យដែលជានានក្ខណិកៈ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ រមែងរួមចូលក្នុងឧបនិស្សយប្បច្ច័យទី ៣ ។

**-បច្ច័យទាំង ៦** នេះ គឺបុរេជាតប្បច្ច័យ បុរេជាតនិស្សយប្បច្ច័យ

*បុរេជាតិន្ទ្រិយប្បច្ច័យ បុរេជាតវិប្បយុត្តប្បច្ច័យ បុរេជាតត្ថិប្បច្ច័យ និង បុរេជាតអវិគតប្បច្ច័យ រមែងរួមចូលក្នុងបុរេជាតប្បច្ច័យទី ៤ ។*

***-បច្ច័យទាំង ៤*** *នេះ គឺបច្ឆាជាតប្បច្ច័យ បច្ឆាជាតវិប្បយុត្តប្បច្ច័យ បច្ឆាជាតត្ថិប្បច្ច័យ និងបច្ឆាជាតអវិគតប្បច្ច័យ រមែងរួមចូលក្នុងបច្ឆាជាត-ប្បច្ច័យទី ៥ ។*

***-នានក្ខណិកកម្មប្បច្ច័យ*** *លោកសង្គ្រោះចូលក្នុងកម្មប្បច្ច័យទី ៦ ។*

***-បច្ច័យទាំង ៣*** *នេះ គឺអាហារប្បច្ច័យ និងអាហារត្ថិប្បច្ច័យ និង អាហារអវិគតប្បច្ច័យ លោកសង្គ្រោះហើយ ដោយអំណាចនៃកវឡិង្កា-រាហារ ក្នុងអាហារប្បច្ច័យទី ៧ ។*

***-បច្ច័យទាំង ៣*** *នេះ គឺរូបជីវិតិន្ទ្រិយ ឥន្ទ្រិយត្ថិប្បច្ច័យ ឥន្ទ្រិយ-អវិគតប្បច្ច័យ រមែងរួមចូលក្នុងឥន្ទ្រិយប្បច្ច័យទី ៨ ។ អ្នកសិក្សា កាល ជ្រាបថា បច្ច័យពួកនេះៗ រួមចូលហើយក្នុងបច្ច័យនីមួយៗ បណ្ដាបច្ច័យ ទាំង ៨ នេះ យ៉ាងនេះហើយ គប្បីជ្រាបថា បច្ច័យណាដល់នូវការរួមចូល ក្នុងបច្ច័យណា, បច្ច័យនោះ លោកកាន់យកហើយ ដោយចំនួននៃបច្ច័យ ដែលរួមចូលនោះឯង ។*

*បញ្ហាទាំង ១៥ យ៉ាងនេះថា* ***“កុសលធម៌ជាបច្ច័យដល់កុសលធម៌***

***ដោយអារម្មណប្បច្ច័យ"*** *ជាដើម ក្នុងបច្ចនីយន័យនេះ បញ្ហា ៤៩ វារៈ ដែលលោកលើកឡើងវិសជ្ជនាហើយ មានអំណាចនៃបច្ច័យទាំង ៨ នេះ ដែលជាទីរួមនៃបច្ច័យទាំងអស់ មានប្រការដូច្នេះ ។ បណ្ដាបញ្ហាទាំងនោះ បញ្ហា ៤ យ៉ាង មានកុសលជាដើមថា "កុសលជាបច្ច័យដល់កុសល, កុសលជាបច្ច័យដល់អកុសល, កុសលជាបច្ច័យដល់អព្យាកតៈ និងកុសលជាបច្ច័យដល់កុសលាព្យាកតៈ" ។ បញ្ហា ៤ យ៉ាង មានអកុសលជាដើមក៏ដូចគ្នាដែរ ។ ចំណែកបញ្ហា ៣ យ៉ាង មានអព្យាកតៈជាដើម គឺអព្យាកតៈជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈជាបច្ច័យដល់កុសល និងអព្យាកតៈជាបច្ច័យដល់អកុសល ។ បញ្ហា ៤ យ៉ាង មានបច្ចុប្បន្ន ១, មានមូល ២ គឺកុសល និងអព្យាកតៈ ជាបច្ច័យដល់កុសល, កុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ, អកុសល និងអព្យាកតៈ ជាបច្ច័យដល់អកុសល, អកុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ។ បណ្ដាបញ្ហាទាំងនោះ បច្ច័យណា គប្បី (សង្គ្រោះ) បានក្នុងបញ្ហាទី ១ លោករួបរួមបច្ច័យទាំងអស់នោះ ហើយពោលថា "បច្ច័យ ៣" ។ ក្នុងបញ្ហាទី ២ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ៣ មានបច្ច័យ ៥ ។ ក្នុងបញ្ហាទី ៤ មានបច្ច័យ ១ ប៉ុណ្ណោះ ។ ក្នុងបញ្ហាទី ៥ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ៦*

*មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ៧ មានបច្ច័យ ៥ ។ ក្នុងបញ្ហាទី ៨ មានបច្ច័យ ១ ប៉ុណ្ណោះ ។ ក្នុងបញ្ហាទី ៩ មានបច្ច័យ ៧ ។ ក្នុងបញ្ហាទី ១០ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ១១ មានបច្ច័យ ៣ ។ ក្នុងបញ្ហាទី ១២ មានបច្ច័យ ២ ។ ក្នុងបញ្ហាទី ១៣ មានបច្ច័យ ៤ ។ ក្នុងបញ្ហាទី ១៤ មានបច្ច័យ ២ ។ សូម្បីក្នុងបញ្ហាទី ១៥ ក៏មានបច្ច័យ ៤ ដូចគ្នាដែរ; បច្ច័យទាំងនោះ ព្រះមានព្រះភាគមិនត្រាស់ថា* **“សហជាតបច្ចយេន”** *ទេ, ប៉ុន្តែ ព្រះអង្គទ្រង់ត្រាស់សម្តែងថា* **“សហជាតំ បច្ឆាជាតំ”** *ខ្ញុំនឹងពណ៌នាហេតុ ក្នុងការត្រាស់យ៉ាងនេះ ទៅខាងមុខឯណោះ ។*

*ក៏កាលបើពោលដោយសង្ខេប ក្នុងអធិការនេះ មានការកំណត់បច្ច័យ ៦ ពួកប៉ុណ្ណោះ គឺបច្ច័យ ១-២-៣-៤-៥ និង ៧ ។ ពិតមែនហើយ បណ្តាបច្ចយបច្ចនីយទាំង ២៤ មានជាអាទិ៍ថា ការកំណត់បញ្ហាដោយអំណាចនៃការកំណត់យ៉ាងខ្ពស់ ក្នុងបច្ចនីយនៃបញ្ហាវារៈ និងការកំណត់បច្ច័យដែលលោកប្រមូលបច្ច័យនោះៗ សម្តែងទុកមកនេះ មាននហេតុប្បច្ច័យជាដើម, បច្ច័យនៃបញ្ហាវារៈតអំពីនេះទៅ រមែងមិនបានសូម្បីតែក្នុងបច្ចនីយៈមួយឡើយ, ប៉ុន្តែ រមែងបានក្នុងកាលខាងដើម; ព្រោះហេតុដូច្នោះ បច្ច័យ ១ ប៉ុណ្ណោះ មានមកហើយយ៉ាងនេះថា “កុសលធម៌ ជាបច្ច័យដល់កុសល និងអព្យាកតៈ ដោយអំណាចនៃ*

*សហជាតប្បច្ច័យ”  ។  ក្នុងបញ្ហាពួកណា  កាលបច្ច័យនោះ  ត្រូវបដិសេធទៅហើយ, បញ្ហាពួកនោះ រមែងបន្ថយចុះទៅ ។ ក៏បច្ច័យទាំង ២ មានមកហើយក្នុងបញ្ហាណា  យ៉ាងនេះថា  “កុសលធម៌  ជាបច្ច័យដល់អកុសលធម៌ដោយអំណាចនៃអារម្មណប្បច្ច័យ  និងដោយអំណាចនៃឧបនិស្សយប្បច្ច័យ”, បណ្ដាបច្ច័យទាំងនោះ  កាលបច្ច័យម្យ៉ាង  សូម្បីត្រូវបដិសេធហើយ យ៉ាងនេះថា* **“នារម្មណប្បច្ចយា”** *បញ្ហានោះ  រមែងបានដោយអំណាចនៃបច្ច័យក្រៅពីនេះ;  ប៉ុន្ដែ  កាលបច្ច័យទាំង  ២  នោះ  ត្រូវបដិសេធហើយ វារៈនោះ  ទើបដាច់ទៅ;  បច្ច័យទាំងឡាយ  ក្នុងពួក  ៣-៤-៥  និង  ៧ រមែងបានក្នុងបញ្ហាពួកណា,  បញ្ហាពួកនោះ  រមែងបាន  ដោយអំណាចនៃបច្ច័យទាំងឡាយដែលនៅសល់  វៀរបច្ច័យដែលលោកបដិសេធចេញ; ក៏កាលបច្ច័យទាំងអស់  ត្រូវបដិសេធទៅ  វារៈទាំងអស់  រមែងដាច់ទៅដូច្នេះឯង,  នេះជាលក្ខណៈក្នុងសេចក្ដីនេះ;  បណ្ឌិតគប្បីជ្រាបប្រភេទនៃបច្ច័យទាំងឡាយ  ដែលលោកពោលដោយសង្ខេបទុកក្នុងបញ្ហានោះៗ  តាំងតែអំពីដើម  និងការបន្ថយចុះ  ឬមិនបន្ថយ  ចុះនៃបញ្ហានោះៗ  ក្នុងបច្ច័យនោះៗ ដោយលក្ខណៈនេះ  ។*

*តទៅ  ជាសេចក្ដីពិស្ដារក្នុងរឿងនេះ  ៖*

*ក្នុងបញ្ហាទី  ១  ជាមុន,  បច្ច័យ  ១៩  លោកសម្ដែងទុកហើយ  ដោយ*

បច្ច័យ ៣ ។ តើដូចម្តេច ? ពិតមែនហើយ កុសលរមែងមិនជាបច្ច័យដល់កុសល ដោយបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ វិបាកប្បច្ច័យ និងវិប្បយុត្តប្បច្ច័យមែនពិត, ប៉ុន្តែ រមែងជាបច្ច័យដោយបច្ច័យ ២០ ដែលនៅសល់ ។ បណ្តាបច្ច័យ ទាំងនោះ អារម្មណប្បច្ច័យ មាន ១ ប៉ុណ្ណោះ ។ ចំណែកបច្ច័យ ១៥ ដោយអំណាចជាទីរួមនូវបច្ច័យទាំងអស់ លោកពោលថារមែងដល់នូវការសង្គ្រោះចូលក្នុងសហជាតប្បច្ច័យ ។ កាលបើហេតុប្បច្ច័យត្រូវបដិសេធទៅ បច្ច័យទាំងនោះ រមែងមាន ១៤ ។ ក៏ពាក្យថា "កុសលជាបច្ច័យដល់កុសលដោយសហជាតប្បច្ច័យ" ព្រះអង្គត្រាស់សំដៅដល់បច្ច័យ ១២ ដែលនៅសល់ ដោយនាំបច្ច័យ ២ ចេញទៅ ព្រោះកុសលជាបច្ច័យដល់កុសល ដោយវិបាកប្បច្ច័យ (និង) វិប្បយុត្តប្បច្ច័យមិនបាន ។ លោកពោលថា បច្ច័យ ៩ រមែងរួមចូល សូម្បីតែក្នុងឧបនិស្សយប្បច្ច័យ ដោយអំណាចនៃការរួបរួមក្នុងបច្ច័យទាំងពួង ។

បណ្តាបច្ច័យទាំងនោះ ***អារម្មណប្បច្ច័យដែលជាអធិបតី និងមានអធិបតិប្បច្ច័យជាអារម្មណ៍ បន្ថែមចូលជាមួយឧបនិស្សយប្បច្ច័យ ដោយអំណាចជាអារម្មណូបនិស្ស័យ*** ។ ចំណែកកុសល រមែងមិនជានានក្ខណិក-កម្មប្បច្ច័យដល់កុសលទេ, ព្រោះហេតុដូច្នោះ ទើបលោកនាំចេញ ហើយពោលថា **"ឧបនិស្សយប្បច្ចយេន បច្ចយោ"** ព្រោះសំដៅយកបច្ច័យ ៦

ដែលនៅសល់ ។

***បច្ច័យ ១៩ គប្បីជ្រាបថា លោកសម្តែងហើយដោយបច្ច័យ ៣ ក្នុងបញ្ហាទី ១ (កុសលជាបច្ច័យដល់កុសល) មានប្រការដូច្នេះ ។***

*បណ្តាបច្ច័យទាំងនោះ ក្នុងនហេតុប្បច្ចនីយៈនេះ កុសលធម៌ជាបច្ច័យដល់កុសលធម៌ ដោយនហេតុប្បច្ច័យ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីលើកបាលីឡើងសម្តែងដោយន័យដែលលោកពោលទុក ក្នុងអារម្មណប្បច្ច័យជាដើម មានជាអាទិ៍យ៉ាងនេះថា* ***“បុគ្គលឱ្យទាន សមាទានសីល រក្សាឧបោសថហើយ រមែងពិចារណាកុសលនោះ, រមែងពិចារណាដល់កុសលទាំងឡាយ ដែលប្រព្រឹត្តក្នុងកាលមុន”*** *ក៏កាលអារម្មណប្បច្ច័យ ត្រូវបដិសេធហើយ; បណ្ឌិតគប្បីនាំសេចក្តីពិស្តារនៃអារម្មណប្បច្ច័យនោះចេញ រួចបំពេញសេចក្តីពិស្តារនៃហេតុប្បច្ច័យ ហើយគប្បីសម្តែងបាលីនោះឯង; សូម្បីក្នុងការបដិសេធបច្ច័យដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ; ក៏កាលបច្ច័យណាៗ ត្រូវបដិសេធចេញ, វារៈពួកណា បន្ថយចុះទៅ; ខ្ញុំបានពណ៌នានូវវារៈទាំងនោះ ក្នុងខាងមុខ ។*

*ក្នុងបញ្ហាទី ២ (កុសលជាបច្ច័យដល់អកុសល) លោកសម្តែងបច្ច័យ ៣ ដោយបច្ច័យ ២ ។ តើដូចម្តេច ? គឺកុសលមិនជាបច្ច័យដល់អកុសល ដោយអំណាចនៃអនន្តរប្បច្ច័យជាដើមទេ ។ ព្រោះហេតុ*

ដូច្នោះ ទើបលោកនាំយកអនន្តរប្បច្ច័យជាដើមទាំងនោះចេញ ហើយទ្រង់ត្រាស់ថា **“ឧបនិស្សយប្បច្ចយេន បច្ចយោ”** ដោយសំដៅយក ***អារម្មណា-ធិបតិប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ*** ដែលលោកសង្គ្រោះហើយដោយអារម្មណូបនិស្សយប្បច្ច័យ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា បច្ច័យទាំងឡាយ ៣ នេះ ព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយបច្ច័យ ២ ក្នុងបញ្ហាទី ២ គឺអារម្មណប្បច្ច័យសុទ្ធៗ ជាមួយអធិបតិប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ដោយអំណាចនៃអារម្មណាធិបតី ។

ក្នុងបញ្ហាទី ៣ (កុសលជាបច្ច័យដល់អព្យាកតៈ) បច្ច័យ ១៨ លោកសម្ដែងហើយ ដោយបច្ច័យ ៥ ។ តើដូចម្ដេច ? គឺកុសល មិនជាបច្ច័យដល់អព្យាកតៈ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ វិបាកប្បច្ច័យ និងសម្បយុត្តប្បច្ច័យទេ ។ រមែងជាបច្ច័យដោយអំណាចនៃបច្ច័យ ១៩ ដ៏សេស ។ បណ្ដាបច្ច័យទាំងនោះ អារម្មណ-ប្បច្ច័យមាន ១ ។ ក៏ព្រោះកុសល មិនជាបច្ច័យដល់អព្យាកតៈ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ វិបាកប្បច្ច័យ និងសម្បយុត្តប្បច្ច័យទេ ។ ហេតុប្បច្ច័យត្រូវបដិសេធចេញ, កម្មប្បច្ច័យ លោកកាន់យកផ្នែកមួយទៀត, ព្រោះហេតុដូច្នោះ ទើបលោកនាំបច្ច័យទាំង ៥ នេះចេញ ហើយសម្ដែងបច្ច័យ ១០ ដោយសហជាតប្បច្ច័យ ។ បណ្ដាបច្ច័យ ៦ ដែលលោក

ពោលទុកអំពីខាងដើម ដោយឧបនិស្សយប្បច្ច័យ វៀរអាសេវនប្បច្ច័យចេញ បច្ច័យដែលនៅសល់ មាន ៥, បច្ឆាជាតប្បច្ច័យ មាន ១ ប៉ុណ្ណោះ ។ មួយាងទៀត កម្មប្បច្ច័យមាន ២ ដោយអំណាចនៃសហជាត-កម្មប្បច្ច័យ និងនានក្ខណិកកម្មប្បច្ច័យ អ្នកសិក្សាគប្បីជ្រាបថា បច្ច័យទាំង ១៨ នេះ លោកសម្ដែងដោយបច្ច័យ ៥ ក្នុងបញ្ហាទី ៣ យ៉ាងនេះ មានប្រការដូច្នេះ ។

បច្ច័យទាំង ១៨ នេះ ដែលព្រះពុទ្ធអង្គទ្រង់សម្ដែងហើយ ដោយបច្ច័យ ៥ ក្នុងបញ្ហាទី ៣ មានប្រការដូច្នេះ ។

បច្ច័យ ១០ លោកសម្ដែងហើយ ដោយបច្ច័យ ១ ប៉ុណ្ណោះ ក្នុងបញ្ហាទី ៤ (កុសលជាបច្ច័យដល់កុសល និងអព្យាកតៈ) ។ តើដូចម្ដេច ? ពិតមែនហើយ កុសល មិនជាបច្ច័យដល់កុសលាព្យាកតៈ ដោយអំណាចនៃអញ្ញមញ្ញប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ និងវិប្បយុត្តប្បច្ច័យទេ ក្នុងបណ្ដាបច្ច័យ ១៥ ដែលលោកពោលទុកក្នុងសហជាតប្បច្ច័យ, ហេតុ-ប្បច្ច័យ ត្រូវបដិសេធចេញ, អ្នកសិក្សាគប្បីដកបច្ច័យទាំង ៥ នេះចេញហើយគប្បីជ្រាបបច្ច័យ ១០ ដែលនៅសល់ លោកសម្ដែងហើយ ដោយបច្ច័យ ១ ក្នុងបញ្ហាទី ៤ នេះ បច្ច័យទាំងនោះ លោកសម្ដែងហើយដោយបច្ច័យពួកនោះៗ ។ ក្នុងបញ្ហា ៤ យ៉ាង មានកុសលជាដើមនេះ យ៉ាងណា, អ្នកសិក្សា គប្បីជ្រាបថា បច្ច័យពួកនោះៗ ព្រះមានព្រះភាគ

ទ្រង់សម្តែងហើយ ដោយបច្ច័យនោះៗ ក្នុងបញ្ហា ៤ យ៉ាង មានអកុសលជាដើមដូច្នោះឯង (បញ្ហា ៤ គឺអកុសលជាបច្ច័យដល់អកុសល, អកុសលជាបច្ច័យដល់កុសល, អកុសល ជាបច្ច័យដល់អព្យាកតៈ, អកុសលជាបច្ច័យដល់អកុសលាព្យាកតៈ) ។

បច្ច័យ ២៣ លោកសម្តែងហើយ ដោយបច្ច័យ ៧ ***ក្នុងបញ្ហាទី ១ នៃបញ្ហា ៣ យ៉ាង មានអព្យាកតៈជាដើម*** ដទៃអំពីនោះ (គឺអព្យាកតៈជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈជាបច្ច័យដល់កុសល, អព្យាកតៈជាបច្ច័យដល់អកុសល) តើដូចម្តេច ? គឺអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ សូម្បីតែដោយបច្ច័យ ២៤ ។ ក៏កាលហេតុប្បច្ច័យត្រូវបដិសេធចេញ រមែងមានបច្ច័យ ២៣ ។ បណ្តាបច្ច័យទាំងនោះ អារម្មណប្បច្ច័យមាន ១ ប៉ុណ្ណោះ; ក៏ព្រោះអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ លោកកាន់យកមួយផ្នែកៗ ដើម្បីសង្គ្រោះនូវធម៌ដែលមិនកើតរួមគ្នា ទុកក្នុងអធិការនេះផង, ព្រោះហេតុដូច្នោះ ទើបលោកនាំបច្ច័យទាំង ៣ នេះចេញ ហើយសម្តែងបច្ច័យ ១២ ដោយអំណាចនៃសហជាតប្បច្ច័យ ។ បច្ច័យដែលលោកពោលទុកអំពីខាងដើម ដោយឧបនិស្សយប្បច្ច័យមាន ៦ ។ បុរេជាតប្បច្ច័យមាន ១ ប៉ុណ្ណោះ ។ បច្ឆាជាតប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យក៏ដូចគ្នាដែរ ។ បណ្ឌិតគប្បីជ្រាបថា បច្ច័យទាំង ២៣ នេះ លោកសម្តែង

ទុកហើយ ដោយបច្ច័យ ៧ ក្នុងអធិការនេះ មានប្រការដូច្នេះ ។

បច្ច័យ ១២ លោកសម្តែងហើយដោយបច្ច័យ ៣ ***សូម្បីតែក្នុងបញ្ហាទី ២***, តើដូចម្តេច ? គឺអារម្មណប្បច្ច័យមាន ១, បច្ច័យ ៦ គឺ អារម្មណាធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ វិគត-ប្បច្ច័យ និងឧបនិស្សយប្បច្ច័យ លោកសម្តែងហើយដោយអំណាចនៃ អារម្មណូបនិស្ស័យ ដោយឧបនិស្សយប្បច្ច័យ ។ បុរេជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ លោកសម្តែងហើយដោយបុរេជាតប្បច្ច័យ ។ បណ្ឌិតគប្បីជ្រាបថា បច្ច័យទាំង ១២ នេះ លោកសម្តែងហើយដោយបច្ច័យ ៣ ក្នុងបញ្ហាទី ២ នេះ (អព្យាកតៈជាបច្ច័យដល់កុសល) ដោយប្រការដូច្នេះ ។

សូម្បីក្នុងបញ្ហាទី ៣ (អព្យាកតៈជាបច្ច័យដល់អកុសល) ក៏មានន័យ ដូចគ្នានេះដែរ ។

***ក្នុងបញ្ហាទី ១ នៃបញ្ហា ៤ យ៉ាង ដែលមានមូល ២*** (គឺកុសល ជាបច្ច័យដល់អព្យាកតៈ និងកុសល; កុសលជាបច្ច័យដល់អព្យាកតៈ និង អព្យាកតៈ; អកុសល ជាបច្ច័យដល់អព្យាកតៈ និងអកុសល; អកុសល ជាបច្ច័យដល់អព្យាកតៈ និងអព្យាកតៈ) តអំពីនោះ ព្រះអង្គមិនត្រាស់ សម្តែងថា **“សហជាតបច្ចយេន បុរេជាតបច្ចយេន”** ទេ ហើយសម្តែង

បច្ច័យ ៣ ដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដោយបច្ច័យ ២ ដែលព្រះអង្គត្រាស់សម្ដែងថា **"សហជាតំ បុរេជាតំ"** ។ ពិតមែនហើយ កុសលក្ខន្ធទាំងឡាយ កាលឲ្យសម្រេចភារៈជាបច្ច័យដល់កុសល ព្រមជាមួយនឹងវត្ថុរូបជាសហជាត ក៏ពិតមែន, ប៉ុន្តែ ក៏មិនជាសហជាតប្បច្ច័យទេ ។ ព្រោះហេតុអ្វី ? ព្រោះលាយដោយវត្ថុរូប ។ ព្រោះហេតុដូច្នោះ ទើបលោកពោលថា **"សហជាតំ"** ដោយអំណាចនៃ ***និស្សយ អត្ថិ និងអវិគត*** ដែលជាសហជាតនោះ ។ សូម្បីក្នុងវត្ថុរូប ក៏មានន័យដូចគ្នាដែរ ។ ពិតមែនហើយ សូម្បីវត្ថុរូបនោះ នឹងកើតមុន ក៏ពិតមែន, ប៉ុន្តែ មិនមែនជាបុរេជាតប្បច្ច័យទេ ព្រោះរួមជាមួយខន្ធ; ពាក្យថា **"បុរេជាតំ"** ត្រាស់សម្ដែងហើយ ដោយអំណាចនៃនិស្សយប្បច្ច័យជាដើម ដែលកើតមុនតែម្យ៉ាង ។

បច្ច័យ ៤ ដោយអំណាចនៃសហជាត និស្សយ អត្ថិ និងអវិគតៈ ព្រះអង្គទ្រង់សម្ដែងហើយ ដោយបច្ច័យ ៤ ដែលលោកពោលថា **"សហ-ជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ"** ***ក្នុងបញ្ហាទី ២*** ។ ពិតណាស់ ក្នុងវារៈនេះ រមែងបានសហជាតប្បច្ច័យ ដោយមិនបានបច្ឆាជាតប្បច្ច័យជាដើមឡើយ ពាក្យនោះ លោកពោលដោយអំណាចនៃបច្ឆាជាត អត្ថិ និងអវិគតៈ ពោលគឺអាហារ និងឥន្ទ្រិយ ។ ព្រោះថា កុសលក្ខន្ធទាំងឡាយ អព្យាកតៈ និងមហាភូតរូប ជាបច្ច័យដល់ឧបាទាយរូប ដោយចំណែក ៤ គឺសហជាត-

ប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ក៏កុសលដែលកើតខាងក្រោយ ជាបច្ច័យដល់ខបាទាយរូបទាំងនោះឯង ជាមួយភូតរូបទាំងនោះ ក៏ដូចគ្នាដែរ ដោយអំណាចនៃអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ សូម្បី ***កពឡិង្ការាហារ*** ជាមួយកុសលដែលកើតខាងក្រោយ ក៏ជាបច្ច័យដល់កាយដែលកើតមុន ដោយអំណាចនៃអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ សូម្បីរូបជីវិតិន្ទ្រិយ ជាមួយកុសលដែលកើតខាងក្រោយ ក៏ជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនោះដែរ ។ ពាក្យថា **"សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ"** នេះ ព្រះអង្គត្រាស់សំដៅដល់ភាពជាបច្ច័យ ដោយចំណែក ៤ នេះ ។ ក៏បច្ឆាជាតប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ រមែងមិនបានក្នុងអធិការនេះទេ ។

សូម្បីក្នុងបញ្ហា ២ ចំណុច ដែលរួមជាមួយអកុសលខាងមុខ ក៏មានន័យដូចគ្នាដែរ ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃបច្ច័យទាំងឡាយ ដែលលោកពោលដោយសង្ខេបទុកក្នុងបញ្ហាទាំងឡាយនោះៗ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។ ចំណែកខ្ញុំនឹងធ្វើឲ្យជាក់ច្បាស់នូវការបន្ថយចុះ និងការមិនបន្ថយចុះនៃបញ្ហាទាំងឡាយនោះៗ ក្នុងបច្ច័យនោះៗ ខាងមុខនេះឯង ៕

**ចប់សេចក្តីនៃបច្ចនីយុទ្ធារៈ**

# ១. ពណ៌នាអំពីកុសលត្តិកប្បដ្ឋាន

*វារៈទាំង ១៥ ថា* **“កុសលោ ធម្មោ កុសលស្ស ធម្មស្ស”** *ជាដើម នេះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកហើយ ដោយអំណាចនៃអនុលោម ។ ព្រោះសូម្បីក្នុង* ***បច្ចនីយៈ*** *ក៏វារៈទាំងនេះឯង មិនមានការបន្ថែមច្រើនជាង នេះទេ, មានតែតិចជាងនេះ; ដូច្នេះ ឥឡូវនេះ ដើម្បីនឹងសម្ដែងវារៈ ដែលអាចមានក្នុងបច្ចនីយៈនៃបច្ចយវារៈណាៗ តាំងតែអំពីដើម ដោយ អំណាចនៃចំនួន ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“ នហេតុយា បណ្ណរស ”** *ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **“នហេតុយា”** *គឺវារៈ ១៥ ដែលបាន ដោយអំណាចនៃបច្ច័យសូម្បីទាំងអស់ តាមដែលព្រះអង្គទ្រង់សម្ដែងទុក ហើយ ។ ក្នុងនអារម្មណៈ ហេតុប្បច្ច័យរមែងបន្ថែមបញ្ចូលក្នុងសហជាត-ប្បច្ច័យ ។ ក្នុងវារៈនោះៗ អារម្មណប្បច្ច័យសុទ្ធៗ រមែងដាច់អស់ទៅ ។ វារៈទាំងនោះ រមែងបានវិសជ្ជនា ដោយអំណាចនៃបច្ច័យដែលនៅសល់ ។ សូម្បីក្នុងបច្ច័យដ៏សេស ក៏ដូចគ្នានឹងនអារម្មណប្បច្ច័យដែរ ។ ហេតុប្បច្ច័យ រមែងបានក្នុងសហជាតប្បច្ច័យ ។ ក៏បច្ច័យទាំងឡាយដែលតាំងនៅដោយ បច្ចនីយៈយ៉ាងនេះ គឺ* **នឧបនិស្សយេ នអនន្តរេ** *(បច្ច័យនោះៗ) រមែង ដាច់អស់ទៅក្នុងវារៈនោះៗ ។ វារៈនោះៗ រមែងបានទទួលវិសជ្ជនា*

ដោយអំណាចនៃបច្ច័យដែលនៅសល់ ។ ចំណែកក្នុងនសហជាតប្បច្ច័យទាំង ៤ វារៈនេះ រមែងដាច់អស់ទៅ គឺកុសលធម៌ ជាបច្ច័យដល់កុសលធម៌ និងអព្យាកតៈ, អកុសលធម៌ ជាបច្ច័យដល់អកុសលធម៌ និងអព្យាកតៈ, កុសល និងអព្យាកតធម៌ ជាបច្ច័យដល់កុសល, អកុសល និងអព្យាកតធម៌ ជាបច្ច័យដល់អកុសល (កុ-កុ + អព្យា, អកុ-អកុ + អព្យា, កុ + អព្យា-កុ, អកុ + អព្យា-អកុ) ; ពិតមែនហើយ លោកពោលបច្ចយ-សង្គហៈពួក ១ ដោយអំណាចនៃបច្ច័យ ១១ ថា **"សហជាតប្បច្ចយេន បច្ចយោ"** ក្នុងវារៈ ២ ចំណុចខាងដើម នៃវារៈទាំង ៤ នេះ កាលបច្ចយ-សង្គហៈនោះ ត្រូវបដិសេធទៅ វារៈទាំងនោះ រមែងមិនបានទទួលវិសជ្ជនា ដោយអាការដទៃឡើយ ។ ពាក្យថា **"សហជាតំ បុរេជាតំ"** លោកពោលសំដៅយកនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក្នុងវារៈ ២ ខាងចុង; កាលសហជាតប្បច្ច័យត្រូវបដិសេធ វារៈទាំងនោះ រមែងមិនបានវិសជ្ជនា ដោយអំណាចនៃបច្ច័យដែលនៅសល់ មានហេតុប្បច្ច័យជាដើមទេ និងមិនបានបុរេជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ ព្រមទាំងអវិគត-ប្បច្ច័យឡើយ, ព្រោះហេតុដូច្នោះ វារៈទាំង ៤ នេះ ទើបដាច់អស់ទៅ ។ ពាក្យថា **"ឯកាទស = ១១ វារៈ"** លោកពោលទុកដោយអំណាចនៃវារៈដែលនៅសល់ ។

ក្នុងសេចក្តីនេះ គប្បីមានពាក្យសួរថា កាលហេតុប្បច្ច័យត្រូវបដិសេធចេញ វារៈទាំងនោះ ទើបមានដោយអំណាចនៃអធិបតិប្បច្ច័យជាដើមដែលនៅសល់ ព្រោះហេតុអ្វី កាលសហជាតប្បច្ច័យត្រូវបដិសេធចេញហើយ ទើបវារៈមិនមានដោយអំណាចនៃហេតុប្បច្ច័យជាដើមដែលសល់ខ្លះទេ ? ដោះស្រាយថា ព្រោះមិនមានធម៌ដែលនឹងយកមកសំអាង (និប្បទេស) ; ពិតមែនហើយ ហេតុប្បច្ច័យជាដើម ឈ្មោះថា នៅមានធម៌ (សល់ទុក) សំអាង (សប្បទេស) ព្រោះនៅមានសហជាតប្បច្ច័យមួយចំណែកទៀត (ឬព្រោះជាចំណែកមួយនៃសហជាតប្បច្ច័យ) ។ ព្រោះហេតុដូច្នោះ កាលហេតុប្បច្ច័យជាដើមនោះ ត្រូវបដិសេធចេញហើយ វារៈទាំងនោះ រមែងបានទទួលវិសជ្ជនាដោយអំណាចនៃបច្ច័យដទៃ, ប៉ុន្តែសហជាតប្បច្ច័យ មិនមានធម៌ (សល់ទុក) សំអាងទេ រមែងរួមយកហេតុប្បច្ច័យជាដើមទាំងអស់មកបញ្ចូលផង កាលសហជាតប្បច្ច័យនោះ ត្រូវបដិសេធទៅហើយ ហេតុប្បច្ច័យជាដើម សូម្បីទាំងអស់នោះ ក៏ត្រូវបដិសេធទៅដែរ ។ ព្រោះថា ហេតុប្បច្ច័យជាដើម ឈ្មោះថា មិនកើតព្រមគ្នា រមែងមិនមាន ។ ព្រោះសហជាតប្បច្ច័យមិនមានធម៌មកសំអាង កាលសហជាតប្បច្ច័យនោះ ត្រូវបដិសេធចេញ វារៈទាំង ២ នោះ ទើបមានមិនបាន ដោយប្រការដូច្នេះ ។ ក្នុងវារៈដែលលោកវិសជ្ជនា ហើយថា

**“សហជាតំ ចុរេជាតំ”** ដូច្នេះ សូម្បីសហជាតប្បច្ច័យប៉ុណ្ណោះ នឹងមិនមាន ក៏ពិតមែន, ប៉ុន្តែ ក្នុងអធិការនេះ អរូបក្ខន្ធដែលកើតរួមគ្នាប៉ុណ្ណោះ ជាបច្ច័យ ដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ, ក៏កាល សហជាតប្បច្ច័យត្រូវបដិសេធហើយ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យដែលកើតរួមគ្នាដោយចំណែកមួយដោយពិតប្រាកដ ក៏ត្រូវ បដិសេធទៅដែរ, ព្រោះហេតុដូច្នោះ វារៈទាំងនោះ ទើបមានមិនបាន ព្រោះ សហជាតប្បច្ច័យនោះ ត្រូវបដិសេធចេញទៅ ។ វារៈទាំង ៤ នេះ ក្នុង អធិការនេះ ទើបដាច់បាត់ទៅ ដោយប្រការទាំងពួងយ៉ាងនេះឯង ។ ពាក្យថា **“ឯកាទស”** លោកពោលដោយអំណាចនៃវារៈដែលនៅសល់ប៉ុណ្ណោះ ។

សូម្បីក្នុងនអញ្ញមញ្ញប្បច្ច័យ ននិស្សយប្បច្ច័យ និងនសម្បយុត្ត-ប្បច្ច័យ វារៈទាំង ៤ នោះឯងដាច់ទៅ; ***សួរថា*** ព្រោះហេតុអ្វី ? ដោះ ស្រាយថា ព្រោះមានគតិដូចសហជាតប្បច្ច័យដែរ ។ ម្យ៉ាងទៀត ដូចជា សហជាតប្បច្ច័យដែលជាអរូបធម៌ រមែងរួមអរូបក្ខន្ធ ៤ ទុក ដោយមិន មានសល់ យ៉ាងណាមិញ, សូម្បីអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ និង សម្បយុត្តប្បច្ច័យ ក៏ដូច្នោះដែរ ។ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា កាល បច្ច័យទាំងនេះ ត្រូវបដិសេធចេញហើយ វារៈទាំងនោះ ទើបមានមិនបាន ព្រោះបច្ច័យទាំងនោះ មានគតិដូចនឹងសហជាតប្បច្ច័យដែរ; ព្រោះហេតុ

*នោះ ទើបព្រះមានព្រះភាគត្រាស់ថា* **“នអញ្ញមញ្ញេ ឯកាទស, ននិស្សយេ ឯកាទស, នសម្បយុត្តេ ឯកាទស”** ។

*ក្នុងសេចក្ដីនេះ គប្បីមាន* ***ពាក្យសួរថា*** *បច្ច័យទាំងនេះ មានគតិដូចសហជាតប្បច្ច័យដែរ ព្រោះជាទីរួមនៃខន្ធ ៤ ដែលផ្សេងគ្នាដោយកុសលក្ខន្ធជាដើម ដោយមិនប្លែកគ្នា ក៏ពិតមែន, ប៉ុន្តែ បើវៀរសហជាតប្បច្ច័យកុសល ក៏មិនជាបច្ច័យដល់កុសលាព្យាកតៈ ដោយប្រការដទៃឡើយ, ព្រោះហេតុដូច្នោះ កាលកុសលនោះ ត្រូវបដិសេធចេញ វារៈនោះ ក៏ដាច់ទៅ (ជាធម្មតា), ប៉ុន្តែ កុសលរមែងមិនជាអញ្ញមញ្ញប្បច្ច័យដល់កុសលា-ព្យាកតៈទេ, កាលកុសលនោះ ត្រូវបដិសេធទៅ ធ្វើដូចម្ដេច វារៈនោះ ទើបត្រូវដាច់ទៅផង ? ដោះស្រាយថា ព្រោះមានការប្រព្រឹត្តទៅដោយអំណាចនៃធម៌ដែលអាស្រ័យនូវគ្នានឹងគ្នា; ដូចយ៉ាងថា កុសលាព្យាកតៈមិនជាសហជាតប្បច្ច័យដល់កុសលទេ តែវារៈនោះ ក៏ដាច់ទៅ, ក្នុងកាលដែលលើកកុសលនោះចេញ ព្រោះមានការប្រព្រឹត្តទៅដោយនិស្សយ-ប្បច្ច័យជាដើម ដោយអំណាចនៃធម៌ដែលកើតរួមគ្នា យ៉ាងណាមិញ, សូម្បីក្នុងអធិការនេះ កាលលើកកុសលនោះចេញ វារៈនោះរមែងដាច់ទៅ ព្រោះមានការប្រព្រឹត្តទៅដោយសហជាតជាដើម ដោយអំណាចនៃធម៌*

ដែលជាអញ្ញមញ្ញប្បច្ច័យដូច្នោះ ។

ក៏បទថា **"នអញ្ញមញ្ញប្បច្ចយេន បច្ចយោ"** មានសេចក្តីដូច្នេះ ៖

ធម៌ពួកណា ដល់នូវការរាប់ថា ជាអញ្ញមញ្ញប្បច្ច័យ ធម៌ពួកនោះក៏មិនជាបច្ច័យ (ដោយអញ្ញមញ្ញប្បច្ច័យដែរ) ; ប៉ុន្តែ កុសលកាលជាបច្ច័យដល់កុសលាព្យាកតៈ ដោយអំណាចនៃសហជាតប្បច្ច័យជាដើម រមែងប្រាកដដោយធម៌ គឺអញ្ញមញ្ញប្បច្ច័យប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ កាលកុសលនោះ ត្រូវបដិសេធចេញ វារៈនោះ ទើបដាច់ទៅ ។ ក៏វារៈនោះរមែងដាច់ទៅ យ៉ាងណាមិញ, វារៈ ៣ ដែលនៅសល់ ក៏រមែងដាច់ទៅព្រោះហេតុដូច្នោះ វារៈទាំង ៤ នោះ រមែងដាច់ទៅ ដោយប្រការដូច្នេះ ។

សូម្បីក្នុងពាក្យថា **"ននិស្សយេ ឯកានស"** នេះ មានវិនិច្ឆ័យដូច្នេះ ព្រោះបច្ចយធម៌ទាំងឡាយ ដែលកើតរួមគ្នាដោយចំណែកមួយ ជាទីអាស្រ័យនៃវារៈទាំងនោះ, ព្រោះហេតុដូច្នោះ កាលធម៌ជាទីអាស្រ័យត្រូវបដិសេធចេញ វារៈទាំងនោះ ទើបដាច់ទៅផង ។

ពីរបទថា **"នបុរេជាតេ តេរស** = នបុរេជាតប្បច្ច័យ មាន ១៣ វារៈ**"** សេចក្តីថា មាន ១៣ វារៈ ព្រោះនាំយក ២ វារៈ មានមូល ២ ក្នុង (បទ) វិសជ្ជនាដែលលោកពោលទុកថា **"សហជាតំ បុរេជាតំ"** ចេញ; ដូចយ៉ាងថា កាលលើកសហជាតប្បច្ច័យចេញ វារៈទាំងនោះ រមែងមិន

បានវិសជ្ជនា ដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគត-ប្បច្ច័យ ដែលជាបុរេជាតប៉ុណ្ណោះ យ៉ាងណាមិញ, កាលបើបុរេជាតប្បច្ច័យត្រូវលើកចេញហើយ (វារៈទាំងនោះ) រមែងមិនបានវិសជ្ជនា ដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដែលជាសហជាតប៉ុណ្ណោះឡើយ; ព្រោះហេតុដូច្នោះ អ្នកសិក្សា គប្បីជ្រាបថា មាន ១៣ វារៈ ព្រោះនាំចេញនូវវារៈទាំងនោះ ។

ក្នុងពាក្យថា **“នបច្ឆាជាតេ បណ្ណរស”** នេះ រមែងបានបញ្ហាទាំង-ឡាយនោះ សូម្បីដោយអំណាចនៃបច្ច័យដែលសល់ វៀរបច្ឆាជាតប្បច្ច័យក្នុងអាគតស្ថាន (ដែលមានមក) ថា **“បច្ឆាជាតប្បច្ចយេន បច្ចយោ”** ឬថា **“សហជាតំ បុរេជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ”** ដូច្នេះចេញ, ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគត្រាស់ទុក ១៥ វារៈប៉ុណ្ណោះ ។

ក្នុងពាក្យថា **“នកម្មេ”** ជាដើម មានវិនិច្ឆ័យថា ព្រោះសូម្បីកម្ម-ប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ក៏ជាចំណែកមួយនៃខន្ធ ៤ ដែលផ្សេងគ្នាដោយកុសលជាដើម, ព្រោះហេតុដូច្នោះ លើកវៀរនូវធម៌ទាំងនោះចេញ ធម៌ដែលកើតរួមគ្នាទើបចាត់ជាបច្ច័យបានដោយអំណាចនៃធម៌ដែលនៅសល់, ព្រោះហេតុនោះការវិសជ្ជនាបញ្ហា ទើបមិនបន្ថយចុះ សូម្បីត្រឹមតែមួយវារៈឡើយ ។

ពាក្យថា **“នសម្បយុត្តេ ឯកាទស”** សេចក្តីថា ព្រោះធម៌ដែលសម្បយុត្តគ្នា ជាបច្ច័យនឹងគ្នា ដោយអំណាចនៃសហជាតប្បច្ច័យជាដើម ក្នុងវារៈទាំង ៤ នោះ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា វារៈទាំងនោះ ប៉ុណ្ណោះដាច់ទៅ ព្រោះបដិសេធសម្បយុត្តប្បច្ច័យចេញ ។

ពាក្យថា **“នវិប្បយុត្តេ នវ”** សេចក្តីថា វារៈទាំង (៦) នេះ គឺវារៈ ៤ ដែលមានអវសានបទមួយបទ កើតអំពីធម៌ដែលមានមូល ២ និងវារៈ ២ ដែលមានអវសានបទ កើតអំពីធម៌ដែលមានមូល ១ និងមូល ២ ប្រកបហើយ ដោយបច្ចយធម៌ដែលវិប្បយុត្តគ្នា ដោយចំណែកមួយ ។ វារៈទាំងនោះ រមែងជាបច្ច័យដោយអំណាចនៃសហជាតជាដើម កាលវិប្បយុត្តប្បច្ច័យ ត្រូវបដិសេធចេញទៅ វារៈទាំងអស់នោះ រមែងដាច់ទៅដែរ, ព្រោះហេតុដូច្នោះ ទើបបាន ៩ វារៈប៉ុណ្ណោះ; ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា **“នវិប្បយុត្តេ នវ”** ។

សូម្បីក្នុង ***នោនត្ថិប្បច្ច័យ*** និង ***នោអវិគតប្បច្ច័យ*** អ្នកសិក្សាគប្បីជ្រាបតាមវារៈទាំង ៩ នោះឯង; ពិតមែនហើយ វារៈទាំងនោះប្រកបដោយធម៌ គឺអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យដោយចំណែកមែនពិត, ព្រោះហេតុដូច្នោះ វារៈទាំងនោះ ទើបដាច់ទៅ ព្រោះការបដិសេធអត្ថិ-ប្បច្ច័យ និងអវិគតប្បច្ច័យទាំងនោះចេញ; វារៈពួកណាដែលបានហើយ,

អ្នកសិក្សាគប្បីធ្វើការវិសជ្ជនាក្នុងវារៈពួកនោះ ដោយអំណាចនៃអារម្មណ-ប្បច្ច័យ ឬអនន្តរប្បច្ច័យជាដើម; អ្នកសិក្សា គប្បីធ្វើការវិសជ្ជនា ដោយអំណាចនៃបច្ច័យ ៥ ដែលផ្សេងគ្នា ដោយអំណាចនៃសហជាតប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ, ឬដោយអំណាចនៃធម៌ដែលវិប្បយុត្តគ្នាដែលនៅមាន និងនៅមិនទាន់ប្រាសចាកទៅដូច្នេះឯង ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងវារៈដែលបានក្នុង **បច្ចនីយន័យ** ដោយការរាប់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងសម្ដែងការរាប់បច្ច័យ ដោយអំណាចនៃបច្ច័យដែលមានមូល ២ ជាដើម ទើបទ្រង់បំពេញពាក្យថា **“នហេតុប្បច្ចយា នារម្មណេ បណ្ណរស”** ជាដើម; គប្បីជ្រាបនូវវិនិច្ឆ័យក្នុងពាក្យនោះ ដូចតទៅ ៖

ក្នុង ***នហេតុមូលកទុកៈ*** បច្ច័យដែលរាប់បានច្រើន កាលប្រកបជាមួយបច្ច័យដែលរាប់បានតិចជាង ទើបជាបច្ច័យដែលរាប់បានតិចទៅ ។ ក្នុង ***តិមូលកន័យ*** វារៈ ២ គឺកុសល ជាបច្ច័យដល់អកុសល អកុសលជាបច្ច័យដល់កុសល (កុ-អកុ, អកុ-កុ); ក្នុងពាក្យថា **“នឧបនិស្សយេ តេរស”** រមែងដាច់ទៅ ។ ព្រោះហេតុអ្វី ? ព្រោះ ***នឧបនិស្សយប្បច្ច័យ*** លោកតភ្ជាប់ទុកជាមួយ ***នអារម្មណប្បច្ច័យ*** ។ ពិតមែនហើយ វារៈទាំង

*នេះ ប្រព្រឹត្តទៅដោយអំណាចនៃអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ឯបច្ច័យទាំងពីរនោះ ដែលលោកលើកចេញ (បដិសេធ) ហើយ វារៈនោះ ជាធម៌ដែលលោកកាន់យក ដោយអំណាចនៃអារម្មណាធិបតី និងអារម្មណូប-និស្សយប្បច្ច័យប៉ុណ្ណោះ ។*

*ពីរបទថា* **“នឧបនិស្សយេ តេរស”** *សូម្បីក្នុង* ***ឆមូលកន័យ*** *ក៏គឺវារៈទាំង ១៣ នោះឯង ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***សត្តមូលកន័យ*** *ដូចតទៅ ៖*

*ពីរបទថា* **“នឧបនិស្សយេ សត្ត”** *បានដល់ វារៈ ៨ គឺវារៈ ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃអនន្តរូបនិស្សយប្បច្ច័យ និងបកតូប-និស្សយប្បច្ច័យទាំងនេះ គឺៈ*

*១.កុសល ជាបច្ច័យដល់កុសល (កុ-កុ)*

*២.កុសល ជាបច្ច័យដល់អកុសល (កុ-អកុ)*

*៣.អកុសល ជាបច្ច័យដល់អកុសល (អកុ-អកុ)*

*៤.អកុសល ជាបច្ច័យដល់កុសល (អកុ-កុ) ។*

*និងជាមួយវារៈ ៤ ដែលដាច់ទៅក្នុងអធិការនេះ ព្រោះបញ្ចូលជាមួយនសហជាតប្បច្ច័យ រមែងដាច់ទៅ, ព្រោះហេតុដូច្នោះ ទើបព្រះមាន-ព្រះភាគត្រាស់ថា* **“សត្ត** *= ៧ វារៈ”* *ដោយអំណាចនៃបច្ច័យដែល*

*នៅសល់ ។*

*ពីរបទថា* **“នបុរេជាតេ ឯកាទស** *= មាន ១១ វារៈ” ព្រោះបញ្ចូលជាមួយ* ***នសហជាតប្បច្ច័យ*** *។*

*ពីរបទថា* **“នបច្ឆាជាតេ នវ”** *សេចក្ដីថា ពិតមែនហើយ ក្នុងវារៈទាំង ១១ នេះ ព្រោះនាំយកវារៈ ២ ដែលមានមូល ២ និងមានអព្យាកតៈជាអវសានបទ មានវិសជ្ជនាដែលបានហើយថា* **“ សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ”** *ចេញ; សូម្បីកាលមានការបដិសេធសហជាតប្បច្ច័យ វារៈទាំងនោះ ក៏នៅមិនបានដាច់ទៅ ដោយអំណាចនៃបច្ឆាជាតប្បច្ច័យទេ; ប៉ុន្តែ កាលមានការបដិសេធបច្ឆាជាតប្បច្ច័យ និងសហជាតប្បច្ច័យ វារៈទាំងនោះ រមែងដាច់ទៅ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា* **“នវ** *= ៩ វារៈ” ដោយអំណាចនៃបច្ច័យដែលនៅសល់ ។*

*ពីរបទថា* **“ ននិស្សយេ ឯការស ”** *ក្នុង* ***អដ្ឋមូលកន័យ*** *ពាក្យអធិប្បាយទាំងអស់ ដូចគ្នានឹងពាក្យដែលខ្ញុំពោលហើយអំពីខាងដើម ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***នវមូលកន័យ*** *ដូចតទៅ ៖*

*ពីរបទថា* **“នឧបនិស្សយេ បញ្ច”** *សេចក្ដីថា ក្នុងនវមូលកន័យ មាន ៥ វារៈ គឺវារៈ ពួក ៣ នៃកុសលជាដើម ដែលមានអព្យាកតៈជាទីបំផុត និងវារៈ ២ ទៀត ដែលមានមូល ២ មានអព្យាកតៈជាអវសានបទ គប្បី*

ជ្រាបវិសជ្ជនាក្នុងវារៈទាំង ៥ នោះ ដោយអំណាចនៃធម៌ ***គឺនានក្ខណិក-កម្មប្បច្ច័យ កវឡិង្ការាហារ រូបជីវិតិន្ទ្រិយ និងបច្ឆាជាតប្បច្ច័យ*** ។ វារៈទាំងនោះឯង រមែងមានសូម្បីក្នុងពាក្យជាដើមថា **"នបុរេជាតេ បញ្ច"** ។ ក្នុង ***ទសមូលកន័យ*** ពីរបទថា **"នបច្ឆាជាតេ តីណិ"** គឺវារៈដែលនៅសល់ក្រៅអំពីវារៈ ២ ដែលមានមូល ២ មានអព្យាកតៈជាអវសានបទ ដែលបានដោយអំណាចនៃបច្ឆាជាតប្បច្ច័យ ។ វារៈទាំង ៣ នោះឯង រមែងមាន សូម្បីក្នុងនវិប្បយុត្តប្បច្ច័យ ។ ពីរបទថា **"នោអត្ថិយា ទ្វេ"** គឺកុសល និងអកុសល ជាបច្ច័យដល់កម្មជរូប ដោយអំណាចនៃនានក្ខណិក-កម្មប្បច្ច័យ ។ ក្នុងអធិការនេះ រមែងមិនបានវិបាកទេ ព្រោះបញ្ចូលគ្នាជាមួយនឹងនឧបនិស្សយប្បច្ច័យ ។ ការរាប់ក្នុង ***ឯកាទសមូលកន័យ*** ដូចគ្នានឹងន័យដែលខ្ញុំបានពោលហើយ អំពីខាងដើមនោះឯង ។

ពីរបទថា **"នកម្មេ ឯកំ"** ***ក្នុងទ្វាទសមូលកន័យ*** គឺអព្យាកតៈជាមួយនឹងអព្យាកតៈ ។ ក្នុងសេចក្ដីនេះ អ្នកសិក្សា គប្បីជ្រាបវិសជ្ជនាដោយអំណាចនៃអាហារ និងឥន្ទ្រិយ ។ អ្នកសិក្សា គប្បីកាន់យកវិសជ្ជនានេះឯង ក្នុងអាគតស្ថានថា **"ឯកំ = ១ វារៈ"** ដូច្នេះ សូម្បីក្នុង ***តេរស-មូលកន័យ*** ជាដើម ។ ប៉ុន្តែនៅក្នុង ***នអាហារប្បច្ច័យ*** គប្បីជ្រាបវិសជ្ជនាដោយអំណាចនៃឥន្ទ្រិយ; ក្នុង ***នឥន្ទ្រិយប្បច្ច័យ*** គប្បីជ្រាបវិសជ្ជនា

ដោយអំណាចនៃអាហារ ។

ក្នុង **ចុទ្ទសមូលកន័យ** ជាដើម រមែងមិនបាន **នោអត្ថិប្បច្ច័យ និង នោអវិគតប្បច្ច័យ** ទេ ព្រោះភ្ជាប់ដោយនកម្មប្បច្ច័យ, ព្រោះហេតុនោះ ទើបលោកមិនពោលទុកឡើយ ។ លោកពោលពាក្យថា “ **នាហារប្បច្ចយា នឈានប្បច្ចយា** ” ទុក ដោយនាំយក **នឥន្ទ្រិយប្បច្ច័យ** ចេញ, ព្រោះហេតុដូច្នោះ ក្នុងឋានដូច្នោះ អ្នកសិក្សាគប្បីជ្រាបវិសជ្ជនា ១ ដោយអំណាចនៃឥន្ទ្រិយប្បច្ច័យ ។ ពាក្យថា “ **នវិបាកប្បច្ចយា នឥន្ទ្រិយប្បច្ចយា** ” លោកពោលទុកដោយនាំយកអាហារចេញ, ព្រោះហេតុដូច្នោះ ក្នុងឋាននេះគប្បីជ្រាបវិសជ្ជនា ១ ដោយអំណាចនៃអាហារប្បច្ច័យ; ក៏ឈ្មោះថា ការរាប់ក្នុងវារៈទាំង ២ នេះ ដែលតាំងនៅដោយសេចក្ដីជាបច្ចនីយៈ រមែងមិនមាន, ព្រោះហេតុដូច្នោះ ទើបលោកមិនបានសម្ដែងទុកដូចគ្នាឡើយ ៕

ចប់នហេតុមូលកន័យ

# នអារម្មណមូលកន័យជាដើម

*សូម្បីក្នុង* ***នអារម្មណមូលកន័យ*** *ជាដើម គប្បីជ្រាបនូវវិនិច្ឆ័យដូចតទៅនេះ ៖*

*ការកំណត់ចំនួនមូលក្នុងទុកៈទាំងពួង មាន ៤ ប៉ុណ្ណោះ គឺ ១៥-១៣-១១-៩ ។ ចំណែកក្នុងតិមូលកន័យជាដើម រមែងបានវិសជ្ជនាមានចំនួនដែលលោកកំណត់ទុកហើយ គឺ ៧-៥-៣-២-១ ក្រៅពីនេះទៅទៀត ព្រោះការប្រកបរួមគ្នានៃបច្ច័យជាច្រើន វិសជ្ជនាណាៗ រមែងមានបាន, ព្រោះការប្រកបរួមគ្នានៃបច្ច័យពួកណា, ក្នុងបច្ច័យទាំងនោះ អ្នកសិក្សាគប្បីកំណត់វិសជ្ជនា និងបច្ច័យនោះៗ ឲ្យល្អ ហើយលើកឡើង តាមន័យដែលខ្ញុំពោលហើយអំពីខាងដើមចុះ; ក៏ក្នុង* ***នអារម្មណមូលកន័យ*** *ជាដើមទាំងអស់នេះ អ្នកសិក្សាគប្បីភ្ជាប់បទទាំងឡាយ មាន* ***នារម្មណបទ*** *ជាដើម ជាមួយនឹង* ***នហេតុបទ*** *ដែលកន្លងមកហើយជាលំដាប់ដំបូង ហើយធ្វើឲ្យជាចក្រ (បង្វិលផ្លាស់ប្ដូរទៅ); ក៏ព្រោះបទទាំងនោះ ដូចគ្នានឹងន័យដែលបានពោលហើយ ក្នុងនហេតុមូលកន័យនោះឯង, ព្រោះហេតុដូច្នោះ ទើបលោកមិនសម្ដែងដោយពិស្ដារទេ សម្ដែងទុកត្រឹមតែសង្ខេបៗ ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុងបទទាំងនោះ ដូចតទៅ ៖*

*ក្នុង* ***នហេតុមូលកន័យ*** *ព្រោះក្នុងនអារម្មណប្បច្ច័យ និងព្រោះក្នុង*

*នខុបនិស្សយប្បច្ច័យ រមែងបានវារៈ ១៥ ប្លែកៗ គ្នា, បានវារៈ ១៣ ព្រោះប្រកបរួមគ្នា យ៉ាងណាមិញ, ក្នុងទីទូទៅ ក៏បានវារៈ ១៣ ប៉ុណ្ណោះ ដូច្នោះដែរ ។ម្យ៉ាងទៀត ក្នុង* ***នឧបនិស្សយប្បច្ច័យ*** *វារៈ ៧ រមែងមាន ដោយនអារម្មណប្បច្ច័យ និងនសហជាតប្បច្ច័យ យ៉ាងណា, សូម្បីក្នុង នសហជាតប្បច្ច័យ ក៏មាន ៧ វារៈ ដោយនឧបនិស្ស័យ និងនអារម្មណ-ប្បច្ច័យដូច្នោះដែរ ។*

*ពាក្យថា* **“ននិស្សយប្បច្ចយា នឧបនិស្សយប្បច្ចយា នបច្ឆាជាតេ តីណិ”** *គឺវិសជ្ជនា ៣ វារៈ មានកុសលជាដើម មានអព្យាកតៈជាទីបំផុត; បច្ច័យទាំងនោះ មានកម្មជរូប និងអាហារជរូប ជាបច្ចុប្បន្ន ក្នុងពួក ៤ មាន* ***នអាហារ និងនឥន្ទ្រិយ*** *ជាមូល រមែងមិនបានវារៈដោយពិត ដូចក្នុង នហេតុមូលកន័យទេ ព្រោះមិនភ្ជាប់កម្មប្បច្ច័យ (ទៅជាមួយឡើយ) ។*

*ក្នុង* ***នឥន្ទ្រិយមូល*** *ពាក្យថា* **“នឧបនិស្សយេ ច នបុរេជាតេ ច បច្ឆាជាតេ ច នអាហារេ តីណីតិ ភាគញ្ញំ”** *អធិប្បាយថា អ្នកសិក្សា គប្បីភ្ជាប់ បច្ច័យទាំង ២ នេះ អំពីនឥន្ទ្រិយប្បច្ច័យ ហើយធ្វើការរាប់ដោយនអាហារ-ប្បច្ច័យ ជាមួយបច្ច័យទាំងពីរនេះ យ៉ាងនេះ គឺ* **នឥន្ទ្រិយប្បច្ចយា ។ល។ នឧបនិស្សយប្បច្ចយា នាហារេ តីណិ, នឥន្ទ្រិយប្បច្ចយា ។ល។ នបុរេជាត-ប្បច្ចយា នាហារេ តីណិ** *។ បណ្ដាបទទាំងនោះ បទថា* **“តីណិ”** *គឺកុសល*

ជាដើមនោះឯង ជាបច្ច័យដល់អព្យាកតៈ ។

ក្នុងពាក្យនោះ មានអធិប្បាយដូចតទៅនេះ ៖

កុសល និងអកុសល ជាបច្ច័យដល់កម្មជរូប និងដល់កាយដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ, ចំណែកចិត្ត និងចេតសិកដែលជាអព្យាកតៈ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យតែម្យ៉ាង; អ្នកសិក្សា គប្បីធ្វើការវិសជ្ជនា ៣ វារៈ ដោយអំណាចនៃបច្ច័យទាំងនេះ ដូចបានអធិប្បាយមកនេះ ។

ព្រះមានព្រះភាគត្រាស់ថា **“នាហារេ ទ្វេ”** ព្រោះភ្ជាប់ជាមួយបច្ឆាជាតប្បច្ច័យខាងមុខ ក្នុងសេចក្ដីនេះ បានវិសជ្ជនាត្រឹមតែប៉ុណ្ណោះ គឺ កុសល ជាបច្ច័យដល់អព្យាកតៈដោយអំណាចនៃកម្មជរូប និងអកុសល ជាបច្ច័យដល់អព្យាកតៈ ដោយអំណាចនៃកម្មជរូបដូចគ្នា; ប៉ុន្តែ ព្រោះអាហារត្រូវបដិសេធចេញ កវឡិង្ការាហារ ទើបមិនបានភាវៈជាបច្ច័យ សូម្បីដោយអំណាចនៃអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យឡើយ ។

ក្នុង ***ចតុមូលកន័យ*** កន្លែងផ្នែកដែលពោលដោយបដ្ឋាន ដែលមាននវិប្បយុត្តប្បច្ច័យជាមូល ។ ពីរបទថា **“នឧបនិស្សយេ បញ្ច** = មានវិសជ្ជនា ៥ វារៈ**”** គឺកុសល ជាបច្ច័យដល់កុសលដែលកើតព្រមគ្នា, កុសល ជាបច្ច័យដល់អព្យាកតៈ ពោលគឺកម្មជរូប, អកុសល ជាបច្ច័យដល់អកុសលដែលកើតព្រមគ្នា, អកុសល ជាបច្ច័យដល់អព្យាកតៈ គឺកម្មជរូប, អព្យាកតៈ

*ជាបច្ច័យដល់អព្យាកតៈដែលកើតព្រមគ្នា ។ ពាក្យថា* **“នទិប្បយុត្តប្បច្ចយា ។ ល ។ នឧបនិស្សយេ តីណិ”** *គឺវារៈ ៣ មានកុសលវារៈជាដើម ជាបច្ច័យដល់អព្យាកតៈ តាមន័យដែលខ្ញុំពោលហើយអំពីខាងដើម ។*

*ពាក្យថា* **“នោអត្ថិប្បច្ចយា នហេតុយា នវ** *= វារៈ ៩ ដែលលោកពោលថា កើតព្រោះនហេតុប្បច្ច័យ ក្នុងនោអត្ថិប្បច្ច័យ” ។ ពិតមែនហើយ វារៈទាំងអស់នោះ វារៈមួយដែលមានមូលមួយជាទីបំផុត រមែងបាន ដោយអំណាចនៃអនន្តរប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ។*

*ពីរបទថា* **“នអារម្មណេ នវ”** *សេចក្តីថា អ្នកសិក្សា គប្បីតាំងវារៈទាំងនោះឯង ទុកក្នុងនអារម្មណប្បច្ច័យ ហើយបែងចែកនឧបនិស្សយប្បច្ច័យចេញជា ២ ។ ពីរបទថា* **“យាវ និស្សយម្ហិ”** *សេចក្តីថា ក្នុងន័យដែលមាននោអត្ថិប្បច្ច័យជាមូល អ្នកសិក្សា គប្បីតាំងទុកក្នុងនអារម្មណប្បច្ច័យ ដោយការបង្វិលផ្លាស់ប្តូរយ៉ាងនេះ គឺ* **“នោអត្ថិប្បច្ចយា នហេតុប្បច្ចយា នអារម្មណាប្បច្ចយា”** *ទៅរហូតដល់និស្សយប្បច្ច័យហើយ គប្បីធ្វើការវិសជ្ជនា ២ វារៈ ក្នុងនឧបនិស្សយប្បច្ច័យ និងដោយបច្ច័យ ៣ យ៉ាងនេះ ឬបច្ច័យយ៉ាងណាមួយ មាននអធិបតិប្បច្ច័យជាដើម បន្ទាប់អំពីនេះទៅ ។*

*ព្រះមានព្រះភាគទ្រង់តាំងលក្ខណៈយ៉ាងនេះហើយ ទ្រង់កាន់យកបច្ច័យ ៧ តាំងអំពីនអារម្មណប្បច្ច័យ រហូតដល់ននិស្សយប្បច្ច័យទៀត*

*ហើយត្រាស់សម្ដែងថា* **“នឧបនិស្សយេ ទ្វេ”** *។ ក្នុងសេចក្ដីនោះ អ្នកសិក្សា គប្បីតែងយោជនាអំពីនារម្មណប្បច្ច័យជាមួយបទទាំងពួង មាននិស្សយប្បច្ច័យជាទីបំផុត ទាំងខាងមុខ និងខាងក្រោយយ៉ាងនេះ គឺ* **“នោអត្ថិប្បច្ចយា នហេតុប្បច្ចយា នអារម្មណប្បច្ចយា នឧបនិស្សយេ ទ្វេ, នោអត្ថិប្បច្ចយា នហេតុនារម្មណនាធិបតិប្បច្ចយា នឧបនិស្សយេ ទ្វេ”** *។ ក៏បទថា* **“ទ្វេ”** *ក្នុងអធិការនេះ អ្នកសិក្សា គប្បីជ្រាបដោយអំណាចបច្ច័យនៃកម្មជរូប, ដោយអំណាចនៃនានក្ខណិកកម្ម គឺកុសល ជាបច្ច័យដល់អព្យាកតៈ, អកុសល ជាបច្ច័យដល់អព្យាកតៈ ។ ក្នុង* ***នបុរេជាតប្បច្ច័យ*** *ជាដើម ជាមួយនឹង* ***នឧបនិស្សយបទ*** *គប្បីជ្រាបវិសជ្ជនា ២ ក្នុងកន្លែងទាំងពួង; ក៏ក្នុងអធិការនេះ លោកមិនកាន់យកកម្មប្បច្ច័យទេ ។ ពិតមែនហើយ កាលកាន់យកកម្មប្បច្ច័យនោះ វារៈទាំងនោះ រមែងដាច់ទៅផង, រមែងមិន បានវិសជ្ជនាផង; ក្នុងការប្រៀបធៀបវិសជ្ជនាណាៗ ជាមួយនឹងវិសជ្ជនាណាៗ, វិសជ្ជនាណាមានបាន និងវិសជ្ជនាណាដាច់ទៅ, អ្នកសិក្សា គប្បីកំណត់វិសជ្ជនាទាំងអស់នោះឲ្យល្អ ហើយគប្បីពង្រីកចំនួន ក្នុងបច្ចនីយៈទាំងអស់ចុះ ៕*

## ចប់បច្ចនីយន័យ

## ពណ៌នាអំពីអនុលោមបច្ចនីយន័យ

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***អនុលោមប្បច្ចនីយន័យ*** *ដូចតទៅ ៖*

*បច្ច័យណាៗ ក្នុងបច្ច័យដែលមានការរាប់ហើយ ក្នុងអនុលោម យ៉ាងនេះ គឺ* **"ហេតុយា សត្ត, អារម្មណេ នវ** *= ក្នុងហេតុប្បច្ច័យ មាន ៧ វារៈ, ក្នុងអារម្មណប្បច្ច័យមាន ៩ វារៈ" , និងក្នុង* ***បច្ចនីយៈ*** *យ៉ាងនេះ គឺ* **" នហេតុយា បណ្ណរស, នអារម្មណេ បណ្ណរស** *= ក្នុង នហេតុប្បច្ច័យ មាន ១៥ វារៈ, ក្នុងនអារម្មណប្បច្ច័យ មាន ១៥ វារៈ" តាំងនៅហើយ ដោយអនុលោម, អ្នកសិក្សា គប្បីជ្រាបការរាប់ ដោយ អំណាចនៃវារៈដែលដូចគ្នា ក្នុងបណ្តាវារៈដែលបានហើយ ត្រង់* ***បច្ចនីយន័យ*** *នៃបច្ច័យនោះៗ ដែលតាំងនៅដោយសេចក្តីជាបច្ចនីយៈ ជាមួយនឹងវារៈ ដែលបានក្នុងអនុលោមន័យរបស់បច្ច័យនោះៗ ។*

*ពិតមែនហើយ ក្នុង* ***អនុលោមន័យ*** *វារៈ ៧ បានហើយក្នុងពាក្យថា* **"ហេតុយា សត្ត** *= ក្នុងហេតុប្បច្ច័យ មាន ៧ វារៈ" , ក្នុង* ***បច្ចនីយៈ*** *វារៈ ១៥ ក្នុងអារម្មណប្បច្ច័យ បានហើយក្នុងពាក្យថា* **" នអារម្មណេ បណ្ណរស** *= ក្នុងនអារម្មណប្បច្ច័យមាន ១៥ វារៈ" ; វារៈទាំង ១៥ ដែលលោកពោលទុកក្នុងនអារម្មណប្បច្ច័យ មាន ១៥ វារៈ បណ្តា*

*វារៈទាំង ១៥ ដែលលោកពោលទុកក្នុងនអារម្មណប្បច្ច័យ វារៈទាំង ៧ នេះ គឺ* “**កុសលោ កុសលស្ស, អព្យាកតស្ស, កុសលាព្យាកតស្ស; អកុសលោ អកុសលស្ស, អព្យាកតស្ស, អកុសលាព្យាកតស្ស, អព្យាកតោ អព្យាកតស្ស** = *កុសលជាបច្ច័យដល់កុសល, កុសលជាបច្ច័យដល់អព្យាកតៈ, កុសលជាបច្ច័យដល់កុសលាព្យាកតៈ; អកុសលជាបច្ច័យដល់អកុសល, អកុសលជាបច្ច័យដល់អព្យាកតៈ, អកុសល ជាបច្ច័យដល់អកុសលាព្យាកតៈ និងអព្យាកតៈជាបច្ច័យដល់អព្យាកតៈ*” *ដូចគ្នានឹងវារៈ ៧ ដែលលោកពោលទុកក្នុងហេតុប្បច្ច័យដែរ ។ ពាក្យថា* “**ហេតុប្បច្ចយា នអារម្មណេ សត្ត** = *ព្រោះហេតុប្បច្ច័យ ក្នុងនអារម្មណប្បច្ច័យមាន ៧ វារៈ*” *លោកពោលសំដៅយកវារៈទាំង ៧ នោះ ។ សូម្បីក្នុងពាក្យថា* “**នអធិបតិយា សត្ត** = *ក្នុងនអធិបតិប្បច្ច័យ មាន ៧ វារៈ*” *ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកក្នុងនសហជាតប្បច្ច័យ រមែងមិនបានវារៈ សូម្បីត្រឹមតែម្យ៉ាង ព្រោះហេតុប្បច្ច័យ ដែលមិនកើតព្រមគ្នា មិនមានឡើយ, ព្រោះហេតុដូច្នោះ ទើបលោកមិនតែងយោជនាដោយនសហជាតប្បច្ច័យនោះទេ ។*

*វារៈ ៣ មានកុសលវារៈជាដើម បានដល់ រូបាព្យាកតៈ ក្នុងនអញ្ញមញ្ញប្បច្ច័យ ។ ពាក្យថា* “**តីណិ**” *លោកពោលសំដៅយកវារៈទាំង ៣ នោះ; ក្នុងនសម្បយុត្តប្បច្ច័យ ក៏ដូចគ្នាដែរ; ចំណែកក្នុង*

***នវិប្បយុត្តប្បច្ច័យ*** *អ្នកសិក្សាគប្បីជ្រាបវារៈ ៣ ដោយអំណាចនៃអរូបធម៌ គឺកុសល ជាបច្ច័យដល់កុសល, អកុសល ជាបច្ច័យដល់អកុសល, អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ។*

***ននិស្សយប្បច្ច័យ នោអត្ថិប្បច្ច័យ នោអវិគតប្បច្ច័យ*** *រមែងមិនបាន ដូចនសហជាតប្បច្ច័យទេ ព្រោះហេតុនោះ ទើបលោកមិនតែងយោជនា ភ្ជាប់ជាមួយបច្ច័យទាំងនោះ ។ ក្នុងសេចក្ដីនេះ មានការកំណត់វិធីរាប់ ២ យ៉ាង គឺ* **សត្ត** *= ៧,* **តីណិ** *= ៣, ដោយប្រការដូច្នេះ ។ អ្នកសិក្សា គប្បីបន្ថយចំនួននៃបច្ច័យដែលរាប់បានច្រើន ជាមួយបច្ច័យដែលរាប់បាន តិច ដោយអំណាចនៃការកំណត់ទាំងនោះ ហើយគប្បីជ្រាបការរាប់ក្នុង* ***បច្ចយយជនា*** *ទាំងឡាយតទៅ ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***យជនា*** *នោះ ដូចតទៅ ៖*

*ពាក្យថា* **“ហេតុសហជាតនិស្សយអត្ថិអវិគតន្តិ នអារម្មណេ សត្ត”** *សេចក្ដីថា អ្នកសិក្សា គប្បីជ្រាបថា ក្នុង* ***នអារម្មណប្បច្ច័យ*** *មាន ៧ វារៈ ដោយន័យនេះថា កុសលធម៌ ជាបច្ច័យដល់កុសលធម៌ ព្រោះបច្ច័យ ៥* ***គឺហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគត-ប្បច្ច័យ*** *។ កុសលហេតុ ជាបច្ច័យដល់ខន្ធដែលសម្បយុត្តដោយ* ***ហេតុ-ប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និង***

***នអារម្មណប្បច្ច័យ*** ។ សូម្បីក្នុងពាក្យថា **“នាធិបតិយា សត្ត”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក្នុង ***យដនាទី ២*** លោកពោលថា **“តីណិ** = ៣**”** ក្នុងបច្ច័យ ដែលនៅសល់ វៀរនសម្បយុត្តប្បច្ច័យចេញ ព្រោះបន្ថែមអញ្ញមញ្ញប្បច្ច័យ បញ្ចូលទៅផង ។ ចំណែកក្នុងនសម្បយុត្តប្បច្ច័យ លោកពោលថា **“ឯកំ** = ១**”** សំដៅដល់នាម និងរូប ក្នុងបដិសន្ធិកាលដែលវិប្បយុត្តជាមួយគ្នា ។ ក្នុងអធិការនេះ រមែងមិនបានអញ្ញមញ្ញប្បច្ច័យ ជាបច្ចនីយៈឡើយ ព្រោះថែមបញ្ចូលទៅក្នុងអនុលោមយដនា, ព្រោះហេតុដូច្នោះ ទើបលោកមិនពោលថា **“នអញ្ញមញ្ញេ”** ដូច្នេះទេ ។ បច្ច័យដែលបញ្ចូលបាន សូម្បីក្នុងយដនាដែលនៅសល់ ក៏រមែងមិនបានជាបច្ចនីយៈ ដូចក្នុងអធិការនេះដែរ ។

ក្នុង ***យដនាទី ៣*** មានវិសជ្ជនា ៣ វារៈប៉ុណ្ណោះ ព្រោះសម្បយុត្តប្បច្ច័យ ត្រូវបន្ថែមចូលទៅផង ។

ក្នុង ***យដនាទី ៤*** មានវិសជ្ជនា ៣ វារៈ គឺកុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ព្រោះបន្ថែមវិប្បយុត្តប្បច្ច័យចូលទៅផងដែរ ។

ក្នុង ***យដនាទី ៥*** ព្រោះមានវិបាកចូលទៅផង គ្រប់ៗ កន្លែង

*ទើបមានវិសជ្ជនា ១ វារៈ គឺអព្យាកតៈ ជាមួយអព្យាកតៈ ។ ក្នុងវិបាកប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ក្រៅអំពីនេះ ក៏មានន័យដូចគ្នានេះដែរ ។*

*ពាក្យថា* **“ហេតុសហជាតនិស្សយឥន្ទ្រិយមគ្គអត្ថិអវិគតន្តិ នអារម្មណេ ចត្តារិ** *= ព្រោះបច្ច័យ ៧ គឺហេតុប្បច្ច័យ សហជាតប្បច្ច័យ និស្សយប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ មគ្គប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក្នុងនអារម្មណប្បច្ច័យ មាន ៤ វារៈ” សេចក្តីថា អ្នកសិក្សា គប្បីជ្រាបនូវវិសជ្ជនា ៤ វារៈ ក្នុងនអារម្មណប្បច្ច័យ ដោយអំណាចនៃបច្ច័យទាំង ៧ នេះ គឺកុសល ជាបច្ច័យដល់កុសល, កុសល ជាបច្ច័យដល់អព្យាកតៈ, កុសល ជាបច្ច័យដល់កុសលាព្យាកតៈ, អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ។ សូម្បីក្នុងយជនាដែលនៅសល់ ក៏មានន័យដូចៗ គ្នានេះដែរ ។ ពីរបទថា* **“នអញ្ញមញ្ញេ ទ្វេ** *= ក្នុងនអញ្ញមញ្ញប្បច្ច័យ មាន ២ វារៈ” គឺកុសល ជាបច្ច័យដល់អព្យាកតៈ, អព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ។ សូម្បីក្នុងវិសជ្ជនា ២ ខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។ អ្នកសិក្សា គប្បីជ្រាបវិធីរាប់ដោយអំណាចនៃបច្ច័យដែលបានក្នុងយជនាទាំងអស់ ដោយឧបាយនេះចុះ ។*

*យជនាទាំងអស់នេះ លោកពោលថា មាន ៤១៥ យជនា ដោយអំណាចនៃ* ***សហជាតយជនា*** *និងដោយអំណាចនៃ* ***បកិណ្ណកយជនា*** *ក្នុង*

អនុលោមបច្ចនីយន័យនេះ ៗ បណ្តាយដនាទាំងឡាយនោះ សូម្បីបច្ច័យតែមួយ៉ាង ក្នុងបណ្តាបច្ច័យទាំងឡាយ ដែលតាំងនៅដោយអនុលោម ក្នុងយដនានោះៗ រមែងមិនបាន ជាបច្ចនីយៈទេ ។ ក្នុងហេតុមូលកន័យ នេះ បច្ច័យ ១៩ មានមកហើយដោយជាបច្ចនីយៈ ព្រោះបច្ច័យ ៥ តាំងនៅហើយ ដោយអនុលោមក្នុងយដនាទី ១ ចំពោះបច្ច័យដ៏សេស ដែលជាអនុលោម មានមកហើយដោយជាបច្ចនីយៈ ។ សូម្បីក្នុងបច្ច័យដែលនៅសល់ កាលបើពោលដោយអនុលោមក្នុងអធិការនេះ បណ្តាបច្ច័យជាច្រើន បច្ច័យមួយ៉ាងៗ ប៉ុណ្ណោះ ដែលមកហើយ ដោយជាបច្ចនីយៈ អ្នកសិក្សា គប្បីជ្រាបវិធីរាប់ទាំងអស់នេះ តាមសមគួរ សូម្បីក្នុងន័យដែលមានអារម្មណប្បច្ច័យជាមូលជាដើម ដូចន័យដែលមានហេតុប្បច្ច័យជាមូលនុ៎ះចុះ ៕

## ចប់អនុលោមបច្ចនីយន័យ

.............................

# ពណ៌នាអំពីបច្ចនីយានុលោមន័យ

វារៈពួកណា ដូចគ្នានឹងវារៈដែលបានដោយអនុលោមនៃបច្ច័យដែលតាំងនៅដោយអនុលោម ក្នុងវារៈទាំងឡាយ ដែលបានដោយបច្ចនីយៈនៃបច្ច័យដែលតាំងនៅជាបច្ចនីយៈ ក្នុងបច្ច័យទាំងឡាយ ដែលមានការរាប់បាន

*ហើយ ក្នុងអនុលោមយ៉ាងនេះ គឺ* **“ហេតុយា សត្ត អារម្មណេ នវ”** *និងក្នុងបច្ចនីយៈយ៉ាងនេះ គឺ* **“នហេតុយា បណ្ណរស នារម្មណេ បណ្ណរស”** *អ្នកសិក្សា គប្បីជ្រាបវិធីរាប់ ដោយអំណាចនៃវារៈទាំងនោះ សូម្បីក្នុង* ***បច្ចនីយានុលោម*** *(នេះ) ។*

*ពិតមែនហើយ ក្នុង* ***នហេតុប្បច្ច័យ*** *ត្រង់* ***បច្ចនីយន័យ*** *បានវារៈ ១៥ ដូចព្រះបាលីថា* **“នហេតុយា បណ្ណរស”** *។ ក្នុងអារម្មណប្បច្ច័យ ត្រង់* ***អនុលោមន័យ*** *បានវារៈ ៩ ដូចព្រះបាលីថា* **“អារម្មណេ នវ”** *។ វារៈ ៩ ពួកណា ក្នុងបណ្តាវារៈ ១៥ ដែលលោកពោលទុកក្នុងនហេតុប្បច្ច័យ ដូចៗ គ្មានឹងវារៈ ៩ ដែលលោកពោលទុកក្នុងអារម្មណប្បច្ច័យដែរ ។ អ្នកសិក្សា គប្បីជ្រាបការរាប់ដោយអំណាចនៃវារៈទាំងនោះ ។ បណ្តាវារៈទាំងនោះ វារៈទាំង ៩ ណា ដែលលោកពោលទុកហើយ ក្នុងអារម្មណប្បច្ច័យ វារៈទាំងនោះ ដូចនឹងវារៈទាំង ៩ នេះដែរ* ***គឺកុសល*** *ជាបច្ច័យដល់កុសល, អកុសល និងអព្យាកតៈ;* ***អកុសល*** *ជាបច្ច័យដល់អកុសល, កុសល និងអព្យាកតៈ;* ***អព្យាកតៈ*** *ជាបច្ច័យដល់អព្យាកតៈ, កុសល និងអកុសល ។ ក្នុងបណ្តាវារៈ ១៥ ដែលលោកពោលទុកក្នុងនហេតុប្បច្ច័យ ៖*

ពាក្យថា **“នហេតុយា អារម្មណេ នវ** = ព្រោះនហេតុប្បច្ច័យក្នុងអារម្មណប្បច្ច័យ មាន ៩ វារៈ” លោកពោលសំដៅដល់វារៈទាំង ៩ នោះ; សូម្បីក្នុងពាក្យថា **“អធិបតិយា ទស”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពិតមែនហើយ វារៈណាៗ ដែលលោកពោលទុកក្នុងអនុលោមគណនា (ការរាប់វារៈក្នុងអនុលោម) នៃអារម្មណប្បច្ច័យជាដើម វារៈទាំងអស់នោះ គប្បីជ្រាបថា រមែងប្រើបាន សូម្បីក្នុងការប្រៀបធៀបជាមួយហេតុប្បច្ច័យ ។

កុសលធម៌ ជាបច្ច័យដល់កុសលធម៌ដោយនហេតុប្បច្ច័យ និងអារម្មណប្បច្ច័យ អ្នកសិក្សា គប្បីជ្រាបការពង្រីកបាលីនៃវារៈទាំងនោះដោយឧបាយនេះ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម រមែងពិចារណាកុសលនោះ, រមែងពិចារណាកុសល ដែលបំពេញទុកក្នុងកាលមុន ។

ក្នុងពាក្យថា **“នហេតុប្បច្ចយា អធិបតិយា ទស** = ព្រោះនហេតុប្បច្ច័យក្នុងអធិបតិប្បច្ច័យ មាន ១០ វារៈ” នេះ អ្នកសិក្សា គប្បីពង្រីកវារៈក្នុងអនុលោមវិភង្គ ដោយអំណាចនៃអធិបតីដែលនៅសល់ ***វៀរវីមំសាធិបតីចេញ*** ។ ក្នុងអធិការនេះ មានការកំណត់វិធីរាប់ដូច្នេះ គឺ ៩-១០-៧-៣-១៣-១ អ្នកសិក្សា គប្បីបន្ថយការរាប់ (ចំនួន) នៃបច្ច័យដែលមានការរាប់បានច្រើនជាងបច្ច័យ ដែលមានការរាប់បានតិច

ជាដ ដោយអំណាចនៃការកំណត់វិធីរាប់ទាំងនោះ ហើយគប្បីជ្រាបវិធីរាប់ក្នុងការប្រៀបធៀបទាំងអស់ ក្នុងន័យដែលមានមូល ៣ ជាដើម បណ្ដាន័យទាំងឡាយ មាននហេតុមូលកន័យជាដើមនេះ ជាលក្ខណៈដែលទូទៅជាមុន ៗ ប៉ុន្តែលក្ខណៈនេះ នៅមិនប្រព្រឹត្តទៅក្នុងការប្រៀបធៀបទាំងអស់ទេ, ក៏ក្នុងការប្រៀបធៀបបច្ច័យពួកណា, ជាមួយបច្ច័យពួកណា, វារៈពួកណាជំទាស់; គប្បីនាំវារៈពួកនោះចេញ ហើយគប្បីជ្រាបវិធីរាប់ក្នុងអធិការនេះ ដោយអំណាចនៃបច្ច័យដែលនៅសល់ទាំងអស់នោះចុះ ។

ក្នុងពាក្យថា **"នហេតុប្បច្ចយា នារម្មណប្បច្ចយា អធិបតិយា សត្ត** = ព្រោះនហេតុប្បច្ច័យ នអារម្មណប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មាន ៧ វារៈ" នេះ រមែងហាមវារៈទាំង ៣ នេះ ដែលបានដោយអំណាចនៃអារម្មណាធិបតី គឺ **"កុសលោ អកុសលស្ស, អព្យាកតោ កុសលស្ស, អព្យាកតោ អកុសលស្ស** = កុសលជាបច្ច័យដល់អកុសល, អព្យាកតៈជាបច្ច័យដល់កុសល, អព្យាកតៈ ជាបច្ច័យដល់អកុសល" ព្រោះហេតុអ្វី ? ព្រោះលោកពោលថា **"នារម្មណប្បច្ចយា"** គឺហាមអារម្មណប្បច្ច័យ ។ ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ អ្នកសិក្សា គប្បីនាំវារៈទាំងនោះចេញ ហើយគប្បីជ្រាបវារៈ ៧ ដោយន័យរបស់សហជាតាធិបតី គឺ **"កុសលោ កុសលស្ស, អព្យាកតស្ស, កុសលាព្យាកតស្ស; អកុសលោ អកុសលស្ស, អព្យាកតស្ស, អកុសលាព្យាកតស្ស; អព្យាកតោ អព្យាកតស្ស** = កុសល

*ជាបច្ច័យដល់កុសល, អព្យាកតៈ និងកុសលាព្យាកតៈ; អកុសល ជាបច្ច័យដល់អកុសល, អព្យាកតៈ និងអកុសលាព្យាកតៈ; អព្យាកតៈជាបច្ច័យដល់អព្យាកតៈ" ។* ***វារៈទាំងនោះ រមែងមានដោយអំណាចនៃអធិបតីដែលនៅសល់ វៀរវីមំសាធិបតីចេញ*** *ព្រោះព្រះបាលីថា* **"នហេតុប្បច្ចយា"** *គ្រប់ៗ កន្លែង អ្នកសិក្សា គប្បីជ្រាបវិធីរាប់ដោយអំណាចនៃបច្ច័យដែលមានវិធីរាប់តិចជាង និងដោយអំណាចនៃចំនួនដែលមិនជំទាស់គ្នា ។*

*ក្នុងបច្ច័យទាំងឡាយ ដែលតាំងនៅជាបច្ចនីយៈ បច្ច័យពួកណា មិនតាំងនៅដោយអនុលោម អ្នកសិក្សាគប្បីជ្រាបបច្ច័យទាំងនោះ បានយ៉ាងណា ? គឺថាកាល* ***អនន្តរប្បច្ច័យ*** *តាំងនៅជាបច្ចនីយៈ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ រមែងមិនតាំងនៅដោយអនុលោមទេ ។ កាល* ***សហជាតប្បច្ច័យ*** *តាំងនៅជាបច្ចនីយៈ ហេតុប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ វិបាកប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ រមែងមិនតាំងនៅដោយអនុលោម ។ កាល* ***និស្សយប្បច្ច័យ*** * *តាំងនៅជាបច្ចនីយៈ វត្ថុបុរេជាតប្បច្ច័យ រមែងមិនតាំងនៅដោយអនុលោមឡើយ ។ កាល* ***អាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ*** *តាំងនៅ*

---

* សេចក្តីក្នុងប្រយោគទាំងអស់នេះ ជំទាស់គ្នាចំពោះសភាវៈ និងព្រះបាលីបញ្ហា ១០៤៨ វារៈ ព្រមទាំងបញ្ហា ១០៥១ វារៈ, ប៉ុន្តែ ចាំបាច់ត្រូវប្រែទៅតាមបាលីអដ្ឋកថាដែលត្រូវគ្នា ដូចជាច្បាប់ របស់ភូមាជាដើម ។

ជាបច្ចនីយៈ ហេតុប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ រមែងមិនតាំងនៅដោយអនុលោម ។ ប៉ុន្តែ កាល អារម្មណប្បច្ច័យ តាំងនៅជាបច្ចនីយៈ អធិបតិប្បច្ច័យ និងឧបនិស្សយ-ប្បច្ច័យ រមែងមិនតាំងនៅដោយអនុលោមឡើយ, ម្យ៉ាងទៀត អារម្មណា-ធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ រមែងមានមិនបានទេ ។ ដោយឧបាយនេះ ក្នុងទីគ្រប់កន្លែង កាលបើជ្រាបវិសជ្ជនាដែលបាន និង មិនបានទុកហើយ គប្បីពង្រីកវារៈទាំងឡាយ ដោយអំណាចនៃវិសជ្ជនា ដែលមាន ។

វារៈទាំងឡាយថា **"អនន្តរេ សត្ត** = ក្នុងអនន្តរប្បច្ច័យ មាន ៧ វារៈ" ក្នុង ***តិមូលកន័យ*** ជាដើម សូម្បីទាំងអស់ បានក្នុង ***ទុមូលកន័យ*** នោះឯង; ចំណែកក្នុង ***សត្តមូលកន័យ*** ជាដើម ពាក្យថា **"នសហជាត-ប្បច្ចយា និស្សយេ តីណិ** = ព្រោះនសហជាតប្បច្ច័យ ក្នុងនិស្សយ-ប្បច្ច័យ មាន ៣ វារៈ" គឺវារៈ ៣ ក្នុងវត្ថុនិស្សយប្បច្ច័យ ដោយអំណាចនៃបុរេជាត ។ វិសជ្ជនា ២ វារៈ ក្នុងកម្មប្បច្ច័យ ដោយអំណាចនៃនានក្ខណិកកម្មប្បច្ច័យ ។ វិសជ្ជនា ១ វារៈ ក្នុងអាហារប្បច្ច័យ ដោយអំណាចនៃកវឡិង្ការាហារ ។ វិសជ្ជនា ១ វារៈ ក្នុងឥន្ទ្រិយប្បច្ច័យ ដោយអំណាចនៃរូបជីវិតិន្ទ្រិយ ។ ក្នុងវិប្បយុត្តប្បច្ច័យ ធម៌ទាំងឡាយ មានកុសល ជាដើម ដែលមានអព្យាកតៈជាទីបំផុត ដល់ហើយតាមលំដាប់ ដោយ

ពាក្យថា **“តីណិ** = ៣ វារៈ” ដូច្នេះ ដោយអំណាចនៃបច្ឆាជាតប្បច្ច័យ ។ ពាក្យថា **“អត្ថិអវិគតេសុ បញ្ច** = ក្នុងអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មាន ៥ វារៈ” សេចក្ដីថា វិសជ្ជនាទាំង ៣ វារៈនោះផង និងវិសជ្ជនាទាំង ២ នេះ គឺ **“កុសលាព្យាកតោ អព្យាកតស្ស, អកុសលាព្យាកតា អព្យាកតស្ស** = កុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ, អកុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ” រមែងមានដោយអំណាចនៃបច្ឆាជាតិន្ទ្រិយប្បច្ច័យ ។ ក៏តាំងពីបច្ឆាជាតប្បច្ច័យ ជាបច្ចនីយៈ (បច្ចនីកៈ) ទៅ ពាក្យថា **“អត្ថិអវិគតេសុ ឯកំ”** គឺអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ដោយអំណាចនៃអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ; កាលកាន់យកនូវអាហារប្បច្ច័យហើយ ក៏មិនគួរកាន់យក ***នឥន្ទ្រិយប្បច្ច័យ*** ទេ ។ ម្យ៉ាងទៀត កាលកាន់យកនឥន្ទ្រិយប្បច្ច័យ ក៏មិនគួរកាន់យក ***នអាហារប្បច្ច័យ*** ផង ដូចគ្នាដែរ ។ ព្រោះហេតុអ្វី ? ព្រោះកាលបច្ច័យទាំង ២ ដែលអាចារ្យកាន់យកដូចគ្នាហើយ វារៈដែលនឹងរាប់ ក៏មិនមាន; សូម្បីកាលឈានប្បច្ច័យ និងមគ្គប្បច្ច័យជាដើម តាំងនៅជាបច្ចនីយៈ មិនត្រូវធ្វើអនុលោមឲ្យជាបញ្ហាមួយ ដោយអាហារប្បច្ច័យ ឬឥន្ទ្រិយប្បច្ច័យទេ (ប៉ុន្តែធ្វើឲ្យប្លែកគ្នា) ដូចដែលត្រាស់សម្ដែងថា **“ឥន្ទ្រិយេ ឯកំ** = ក្នុងឥន្ទ្រិយប្បច្ច័យ

មាន ១ វារៈ, **អត្ថិយា ឯកំ, អវិគតេ ឯកំ, អាហារេ ឯកំ, អត្ថិយា ឯកំ, អវិគតេ ឯកំ"** ក្នុងទីបំផុត ។ ពាក្យដ៏សេស ក្នុងអធិការនេះ មានសេចក្ដីភ្លឺច្បាស់ហើយ ។

ចប់នហេតុមូលកន័យ

ក្នុង ***នអារម្មណមូលកន័យ*** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងអញ្ញមញ្ញមូលកន័យ ពាក្យថា **"នអញ្ញមញ្ញប្បច្ចយា ហេតុយា តីណិ** = ព្រោះនអញ្ញមញ្ញប្បច្ច័យ ក្នុងហេតុប្បច្ច័យ មាន ៣ វារៈ" គឺកុសលជាដើម ជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ។ ពីរបទថា **"អធិបតិយា អដ្ឋ** = ក្នុងអធិបតិប្បច្ច័យ មាន ៨ វារៈ" ព្រោះ ***នសហជាតប្បច្ច័យ*** ក្នុងនិស្សយប្បច្ច័យ មាន ៣ វារៈ សេចក្ដីថា បណ្ដាវារៈ ១០ ដែលលោកពោលទុកក្នុងអធិបតិប្បច្ច័យ បានវារៈ ៨ ដែលសល់ ដោយដកចេញ ២ វារៈ គឺកុសល * ជាបច្ច័យដល់កុសល និងអព្យាកតៈ, អកុសល ជាបច្ច័យដល់អកុសល និងអព្យាកតៈ ។ ពីរបទថា **"សហជាតេ បញ្ច** = ក្នុងសហជាតប្បច្ច័យ មាន ៥ វារៈ" បានដល់វារៈ

---

* អដ្ឋកថាបាលីខ្លះជា "កុសលោ កុសលស្ស, អកុសលោ អកុសលស្ស = កុសលជាបច្ច័យដល់កុសល, អកុសលជាបច្ច័យដល់អកុសល" ដែលខុសសភាវៈ ក្នុងទីនេះ ទើបប្រែតាមអដ្ឋកថាបាលីភូមាដែលថា "កុសលោ កុសលាព្យាកតស្ស, អកុសលោ អកុសលាព្យាកតស្ស"។

ទាំង ២ នេះ គឺកុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ, អកុសល និងអព្យាកតៈ ជាបច្ច័យដល់អព្យាកតៈ ជាមួយនឹងវារៈ ៣ ដែលលោកពោលទុកក្នុងហេតុប្បច្ច័យ ។

ពីរបទថា **"និស្សយេ សត្ត** = ក្នុងនិស្សយប្បច្ច័យ មាន ៧ វារៈ" វារៈទាំង ២ នេះ គឺអព្យាកតៈ ជាបច្ច័យដល់កុសល, អព្យាកតៈ ជាបច្ច័យដល់អកុសល ជាមួយនឹងវារៈទាំង ៥ នោះ រមែងមានដោយអំណាចនៃវត្ថុ ។ ពីរបទថា **"កម្មេ តីណិ** = ក្នុងកម្មប្បច្ច័យ មាន ៣ វារៈ" គឺវារៈ ៣ ដែលលោកពោលទុកក្នុងនហេតុប្បច្ច័យនោះឯង; សូម្បីក្នុងតិកៈដែលនៅសល់ ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា **"អធិបតិយា តីណិ** = ក្នុងអធិបតិប្បច្ច័យ មាន ៣ វារៈ" គឺវារៈដែលពោលទុកអំពីខាងលើ ។

ក្នុង ***នអាហារមូលកន័យ*** ពាក្យថា **"អញ្ញមញ្ញេ តីណិ** = ក្នុងអញ្ញមញ្ញប្បច្ច័យ មាន ៣ វារៈ" អ្នកសិក្សា គប្បីជ្រាបវារៈដោយអំណាចនៃចេតសិកដែលនៅសល់ ***វៀរអាហារ*** ចេញ, ក៏សូម្បីក្នុងអធិការនេះ ក្នុងនអាហារប្បច្ច័យ និងនឥន្ទ្រិយប្បច្ច័យ លោកកាន់យកម្យ៉ាងៗ ១ បច្ច័យ, មិនកាន់យក ២ បច្ច័យរួមគ្នាទេ; ដូចអំពីខាងលើ (គឺសម្ដែងញែកគ្នា, មិនសម្ដែងរួមគ្នា) ឡើយ ។ ពាក្យថា **"នសម្បយុត្តប្បច្ចយា ហេតុយា តីណិ** = ព្រោះនសម្បយុត្តប្បច្ច័យ ក្នុងហេតុប្បច្ច័យ មាន ៣ វារៈ" មានវារៈ

ដែលលោកពោលទុកក្នុងនអញ្ញមញ្ញប្បច្ច័យអំពីខាងលើ; **អធិបតិយា អដ្ឋ** = ក្នុងអធិបតិប្បច្ច័យ មាន ៨ វារៈ គឺវិសជ្ជនាដែលលោកពោលទុកអំពីខាងលើដូចគ្នា ។

គប្បីជ្រាបនូវវិនិច្ឆ័យក្នុង ***នវិប្បយុត្តប្បច្ច័យជាមូល*** ដូចតទៅ ៖

ពីរបទថា "**កម្មេ បញ្ច** = ក្នុងកម្មប្បច្ច័យ មាន ៥ វារៈ" បានដល់មាន វារៈ ៥ យ៉ាងនេះ គឺចេតនា មានកុសលជាដើម ជាបច្ច័យដល់កុសលជាដើម ដែលកើតរួមគ្នា, កុសល និងអកុសលចេតនា ដែលកើតផ្សេងខណៈគ្នា ជាបច្ច័យដល់វិបាក និងដល់រូបដែលមានកម្មជាសមុដ្ឋាន ។ ក្នុងអាហារប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ មាន ៣ វារៈ ដូចគ្នានឹងសហជាតិ-ប្បច្ច័យដែរ ។ ក្នុងឈានប្បច្ច័យ និងមគ្គប្បច្ច័យជាដើម មាន ៣ វារៈ ដូចគ្នានឹងហេតុប្បច្ច័យដែរ ។

ក្នុង ***នោអត្ថិមូលកន័យ*** មានអធិប្បាយថា ព្រោះ ***ហេតុ*** ឈ្មោះថា **នោអត្ថិ** មិនមានឡើយ, មានតែ **អត្ថិ** ប៉ុណ្ណោះ ។ ព្រោះហេតុដូច្នោះទើបលោកមិនកាន់យក ***ហេតុប្បច្ច័យ*** នោះទេ ហើយពោលថា "**នអារម្មណេ នវ** = ក្នុងនអារម្មណប្បច្ច័យ មាន ៩ វារៈ" (ហេតុប្បច្ច័យសម្តែងមិនបានទេ) ។ បច្ច័យទាំងឡាយ ដែលចូលដល់លក្ខណៈនៃអត្ថិប្បច្ច័យ សូម្បីដទៃ រមែងមិនតាំងនៅដោយអនុលោមក្នុងអធិការនេះឡើយ ។

ពាក្យថា **“កម្មេ ទ្វេ = ក្នុងកម្មប្បច្ច័យ មាន ២ វារៈ”** នេះ លោកពោលដោយអំណាចនៃនានក្ខណិកកម្មប្បច្ច័យ; បច្ច័យទាំងអស់ រមែងបានដោយបច្ចនីយៈ ។ វារៈទាំងឡាយ តអំពីនោះ ដែលលោកមិនកាន់យកបច្ច័យណា សូម្បីដែលបានដោយអនុលោម ក៏គួរកាន់យកដោយបច្ចនីយៈ, បច្ច័យនោះ រមែងបានការប្រកបជាខាងក្រោយ ។ ព្រោះហេតុនោះឯង ក្នុងអធិការនេះ ទើបលោកពោលទុកថា **“នោអត្ថិប្បច្ចយា នហេតុប្បច្ចយា ។ ល ។ នោអវិគតប្បច្ចយា កម្មេ ទ្វេ ។ ល ។”** ។ សួរថា ព្រោះហេតុអ្វី ទើបលោកមិនកាន់យកបច្ច័យនោះ ក្នុងឋានរបស់ខ្លួនឯងទៅ ? ដោះស្រាយថា ព្រោះកាលបច្ច័យដែលសល់ទាំងអស់ តាំងនៅដោយបច្ចនីយៈ បច្ច័យមួយប៉ុណ្ណោះ រមែងបានដោយអនុលោម ។

ពិតមែន នេះជាលក្ខណៈក្នុងបច្ចនីយានុលោមនេះ គឺកាលបើបច្ច័យទាំងអស់ តាំងនៅដោយបច្ចនីយៈ បច្ច័យណាមួយប៉ុណ្ណោះ រមែងបានដោយអនុលោម, បច្ច័យនោះ លោកនឹងពោលជាខាងក្រោយ ។ សូម្បីក្នុងពាក្យថា **“នោអត្ថិប្បច្ចយា នហេតុប្បច្ចយា ។ ល ។ នោ អវិគតប្បច្ចយា ឧបនិស្សយេ នវ”** ក៏ក្នុងន័យនេះដូចគ្នាដែរ; ពាក្យនេះ លោកពោលទុកដោយអំណាចនៃ ***បកតូបនិស្សយប្បច្ច័យ***; គ្រប់ៗ វារៈ ដែលមានបាន និងមិនមានបាន ដែលលោកពោលទុកអំពីមុន និងជាខាងក្រោយ

*គប្បីជ្រាបដោយន័យនេះឯង ។*

ចប់បច្ចនីយានុលោមនៃបញ្ហាវារៈ

ចប់កុសលត្តិកបដ្ឋាន

................................

## ២.ពណ៌នាអំពីវេទនាត្តិកបដ្ឋាន

*ធម៌ទាំងនេះ គឺវេទនា ៣ រូប និព្វាន រមែងមិនបានក្នុង* ***វេទនា-ត្តិកៈទេ****, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* **“ ឯកំ ខន្ធំ បដិច្ច ទ្វេ ខន្ធា”** *ជាដើម ។ ពាក្យថា* **“ បដិសន្ធិក្ខណេ សុខាយ វេទនាយ ”** *ត្រាស់សម្តែងដោយអំណាចនៃសហេតុកបដិសន្ធិ; ចំណែកទុក្ខវេទនា រមែងមិនបានក្នុងបដិសន្ធិកាលទេ ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់មិនបញ្ជាក់ដល់បដិសន្ធិក្នុងវារៈទី ២ ។ ពាក្យថា* **“បដិសន្ធិក្ខណេ”** *ក្នុងវារៈទី ៣ ត្រាស់សម្តែងដោយអំណាចនៃសហេតុក-បដិសន្ធិ, ក៏ពាក្យដ៏សេសក្នុងអធិការនេះ បច្ច័យដទៃពីនេះ រមែងប្រព្រឹត្តទៅតាមព្រះបាលីនោះឯង; ក្នុងទីទាំងពួង ត្រាស់សម្តែងវារៈទុក ៣ វារៈ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សម្តែងថា* **“ហេតុយា តីណិ ។ បេ ។ អវិគតេ តីណិ”** *។*

ក៏ក្នុងការប្រៀបធៀបបច្ច័យព្រះអង្គទ្រង់ត្រាស់ថា **“ទិបាកេ ទ្វេ** = ក្នុងវិបាកប្បច្ច័យ មាន ២ វារៈ” ទុកក្នុងហេតុមូលកន័យ ព្រោះទុក្ខវេទនាខាងវិបាក ដែលជាសហេតុកៈមិនមាន ។ ក្នុងការប្រៀបធៀបជាមួយអធិបតិប្បច្ច័យជាដើម វិបាកប្បច្ច័យ មានវិសជ្ជនា ២ វារៈប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ? ព្រោះអធិបតិប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មិនមានក្នុងវិបាកទុក្ខវេទនាទេ ។ ក៏ក្នុងការប្រៀបធៀបបច្ច័យឯណា វិបាកប្បច្ច័យ រមែងបានវារៈ ២, សូម្បីក្នុងបច្ច័យទាំងនោះ ក៏បានវារៈ ២ ដូចគ្នាដែរ ព្រោះប្រៀបធៀបជាមួយនឹងវិបាកប្បច្ច័យ ។

ក្នុង ***នបុរេជាតប្បច្ច័យ*** ដែលជាបច្ចនីយៈ វារៈ ២ មានមកហើយ ព្រោះមិនមានទុក្ខវេទនាក្នុងអរូបភព និងក្នុងបដិសន្ធិកាលទេ ។ សូម្បីក្នុង ***វិប្បយុត្តប្បច្ច័យ*** ក៏មានវារៈ ២ ដូចគ្នាដែរ ព្រោះមិនមានទុក្ខវេទនា ក្នុងអរូបភពឡើយ ។

ក៏បច្ច័យទាំងឡាយ មានសហជាតប្បច្ច័យជាដើម ដែលគ្របដណ្តប់ដល់អរូបធម៌ទាំងអស់ រមែងដាច់ទៅក្នុងបច្ចនីយវារៈនេះ ។ ព្រោះហេតុអ្វី ? ព្រោះធម៌ដែលសម្បយុត្តដោយវេទនា អាស្រ័យធម៌ដែលសម្បយុត្តដោយវេទនា (នោះ) កើតឡើងមិនបាន, បើវៀរចាកសហជាត-

*ប្បច្ច័យជាដើម និងព្រោះធម៌ដែលសម្បយុត្តដោយវេទនា កើតឡើងបាន ដោយសារវៀរបច្ឆាជាតប្បច្ច័យចេញ ។*

*ក៏ក្នុងការប្រៀបធៀបបច្ច័យ ពាក្យថា* **“នបុរេជាតេ ឯកំ** *= ក្នុងនបុរេជាតប្បច្ច័យ មាន ១ វារៈ” ត្រាស់សំដៅដល់ធម៌ក្នុងបដិសន្ធិ ក្នុងអរូបភព និងធម៌ដែលសម្បយុត្តដោយអហេតុកអទុក្ខមសុខវេទនា ។ ពីរបទថា* **“នកម្មេ ទ្វេ** *= ក្នុងនកម្មប្បច្ច័យមាន ២ វារៈ” ត្រាស់សម្តែងដោយអំណាចនៃចេតនាដែលសម្បយុត្តដោយអហេតុកកិរិយា ។ ពិតមែនអហេតុកកិរិយា ចេតនាដែលសម្បយុត្តដោយវេទនាទាំងនោះ រមែងកើតឡើង ព្រោះអាស្រ័យធម៌ទាំងឡាយ ដែលសម្បយុត្តដោយសុខវេទនា និងអទុក្ខមសុខវេទនា ។ សូម្បីក្នុងពាក្យថា* **“នហេតុប្បច្ចយា នកម្មប្បច្ចយា នវិបាកេ”** *ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា* **“នវិប្បយុត្តេ ឯកំ** *= ក្នុងនវិប្បយុត្តប្បច្ច័យមាន ១ វារៈ” ត្រាស់សម្តែងដោយអំណាចនៃអារុប្បវិបាកចិត្តក្នុងអរូបភព ។ ក្នុងការប្រៀបធៀបបច្ច័យគ្រប់យ៉ាង គប្បីជ្រាបវិធីរាប់ដោយឧបាយនេះចុះ ។*

*បច្ច័យដែលបានក្នុង* ***អនុលោមបច្ចនីយៈ*** *ប៉ុណ្ណោះ តាំងនៅជាបច្ចនីយៈ; សហជាតប្បច្ច័យជាដើម ដែលគ្របដណ្តប់ដល់អរូបធម៌ទាំងអស់*

ក្នុង ***បច្ចនីយានុលោម*** រមែងតាំងនៅដោយអនុលោមប៉ុណ្ណោះ, មិនតាំងនៅដោយភាពជាបច្ចនីយៈទេ; តែអធិបតីរបស់អហេតុកចិត្តុប្បាទមិនមាន ព្រោះហេតុដូច្នោះ ទើបអធិបតិប្បច្ច័យមិនតាំងនៅដោយអនុលោមឡើយ ។

***ក៏ក្នុងបដិច្ចវារៈជាដើម បច្ឆាជាតប្បច្ច័យរមែងមិនមាន, ព្រោះហេតុដូច្នោះ ទើបអស់ទៅ*** ។ មួយទៀត ក្នុងអធិការនេះ បច្ច័យឯណា ដែលមានដោយអនុលោម, បច្ច័យទាំងនោះ លោកប្រកបអធិប្បាយ បន្ថែមឲ្យទៅជាមួយបច្ច័យដែលបានដោយបច្ចនីយៈ ។ ក្នុងបច្ច័យទាំងនោះ មានកំណត់វារៈ ៣ ប៉ុណ្ណោះ គឺ ៣-២-១ អ្នកសិក្សា គប្បីកំណត់តាមសេចក្ដីដ៏សមគួរ និងគប្បីជ្រាបបច្ច័យទាំងនោះ ក្នុងទីគ្រប់កន្លែងទាំងអស់; ក៏ន័យរបស់វណ្ណនាឯណា ត្រាស់សម្ដែងហើយក្នុងបដិច្ចវារៈ ន័យរបស់វណ្ណនានេះឯង ទ្រង់ត្រាស់សម្ដែងទុកក្នុងសហជាតវារៈជាដើមដែរ ។

ក៏ពាក្យថា **"សម្បយុត្តកានំ ខន្ធានំ"** ក្នុងបញ្ហាវារៈ គឺខន្ធទាំងឡាយដែលសម្បយុត្តដោយធម៌នោះ ឬដោយហេតុទាំងឡាយនោះឯង ឬក៏ដោយសុខវេទនាជាដើម ។ បទថា **"វិប្បដិសារិស្ស** = មានសេចក្ដីក្ដៅក្រហាយ" ក្នុងកុសល មានទានជាដើម យ៉ាងនេះថា "ហេតុដូចម្ដេចបានជាយើងធ្វើកម្មនេះ, កម្មអាក្រក់យើងធ្វើហើយ, កម្មដែលល្អយើងមិនទាន់បានធ្វើសោះ" ; តែមានសេចក្ដីក្ដៅក្រហាយ ព្រោះឈានវិនាសទៅ

យ៉ាងនេះថា “ឈានរបស់យើងវិនាសហើយ, យើងជាអ្នកវិនាសធំហើយ ហ្ន៎ !” ។ ពីរបទថា **“មោហោ ឧប្បជ្ជតិ”** បានដល់ មោហៈដែលសម្បយុត្ត ដោយទោសៈប៉ុណ្ណោះ ។ ពាក្យថា **“ មោហំ អារព្ភ”** បានដល់ ***មោហៈ ដែលសម្បយុត្តដោយមោហៈដូចគ្នា*** ។

ពាក្យថា ***“ភវង្គដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ភវង្គ ដែលសម្បយុត្តដោយអទុក្ខមសុខវេទនា”*** សេចក្តីថា ***ភវង្គដួងក្រោយ*** ពោលគឺ តទារម្មណ៍ជាបច្ច័យដល់ភវង្គដួងដើម ។ បទថា **“វុដ្ឋានស្ស”** គឺតទារម្មណ៍ ឬភវង្គ ។ ពិតមែន ចិត្តទាំងពីរនោះ លោកហៅថា ***វុដ្ឋាន*** ព្រោះចេញចាក កុសលជវន ឬអកុសលជវន ។ សូម្បីក្នុងពាក្យថា **“ កិរិយំ វុដ្ឋានស្ស”** នេះ ក៏មានន័យដូចគ្នានេះដែរ ។

ពីរបទថា **“ ផលំ វុដ្ឋានស្ស”** បានដល់ ផលចិត្តជាបច្ច័យដល់ ភវង្គចិត្ត ។ ពិតណាស់ ឈ្មោះថា ការចេញចាកផលចិត្ត រមែងមានដោយ ភវង្គចិត្ត; សូម្បីក្នុងអាគតស្ថានថា **“វុដ្ឋានំ”** ខាងមុខ ក៏មានន័យដូចគ្នា នេះដែរ ។

ពាក្យថា **“ទុក្ខាយ វេទនាយ សម្បយុត្តា ខន្ធា”** បានដល់ អកុសល-ក្ខន្ធដែលសម្បយុត្តដោយទោមនស្សវេទនា; ពាក្យថា **“ អទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស វុដ្ឋានស្ស”** បានដល់ ***អាគន្តុកភវង្គ គឺតទារម្មណ៍ ឬមូលភវង្គ*** ដែលសម្បយុត្តដោយឧបេក្ខាវេទនា ។ ឯចិត្តដែលសហគតៈ

ដោយសោមនស្សជាមូលភវង្គ, ហេតុដែលនឹងឲ្យកើតតទារម្មណ៍ រមែង មិនមាន, អកុសលវិបាកដែលជាឧបេក្ខាវេទនា រមែងកើតឡើងក្នុងអារម្មណ៍ ដទៃអំពីអារម្មណ៍របស់ជវន ។ ពិតណាស់ សូម្បីអកុសលវិបាកនោះ លោកក៏ហៅថា ***វុដ្ឋានៈ*** ព្រោះចេញអំពីជវនដែរ ។ និទ្ទេសនៃសហជាតប្បច្ច័យជាដើម មានសេចក្ដីងាយស្រួលទាំងអស់; ព្រោះថា ក្នុងអធិការនេះ ពាក្យដែលមិនអាចនឹងដឹងតាមន័យដែលខ្ញុំពោលទុកហើយ ក្នុងខាងក្រោយ មិនមានឡើយ, ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីកំណត់ឲ្យល្អចុះ ។

***វារៈឯណាៗ បានហើយ ក្នុងបច្ច័យណាៗ***, ឥឡូវនេះ ដើម្បីនឹងសម្ដែងសង្ខេបនូវបច្ច័យ និងវារៈទាំងអស់នោះ ដោយអំណាចនៃការរាប់ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា **“ហេតុយា តីណិ”** ជាដើម ។ វិសជ្ជនាទាំង ៣ វារៈនោះ ក្នុងពាក្យថា **“ហេតុយា តីណិ”** អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃបទសុទ្ធៗ ៣ បទ ។ វិសជ្ជនា ៩ វារៈ ក្នុង ***អារម្មណប្បច្ច័យ*** មានបច្ច័យដែលមានមូល ១ មានមូលី ១ ជាទីបំផុត ។ ក្នុង ***អធិបតិប្បច្ច័យ*** មានវិសជ្ជនា ៥ វារៈ គឺវិសជ្ជនា ៣ ដែលមិនលាយគ្នា ដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ, និងវិសជ្ជនា ២ គឺធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ១, ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ដោយ

អំណាចនៃអារម្មណាធិបតិប្បច្ច័យ ១ ។ វិសជ្ជនាទាំង ២ នេះ អ្នកសិក្សា មិនគួររាប់ទេ, តែគួររាប់វិសជ្ជនាទាំង ២ នេះ គឺធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ១, ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ១ រួមត្រូវជាវិសជ្ជនា ៥ វារៈ ដោយប្រការដូច្នេះ ។

បទថា **"សត្ត"** ក្នុងអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ បានដល់វិសជ្ជនា ៧ វារៈយ៉ាងនេះ គឺសុខវេទនាជាបច្ច័យដល់ធម៌ ២ យ៉ាង, ទុក្ខវេទនាជាបច្ច័យដល់ធម៌ ២ យ៉ាង, ឧបេក្ខាវេទនា ជាបច្ច័យដល់ធម៌បានទាំង ៣ យ៉ាង ។

ពីរបទថា **"ឧបនិស្សយេ នវ"** បានដល់ វិសជ្ជនា ៩ វារៈយ៉ាងនេះ ***គឺធម៌ដែលសម្បយុត្តដោយសុខវេទនា*** ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យទាំង ៣ យ៉ាង, ជាបកតូបនិស្សយប្បច្ច័យម្យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា, ជាឧបនិស្សយប្បច្ច័យទាំង ៣ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា, ***ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា*** ជាអនន្តរូបនិស្សយប្បច្ច័យនិងបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា, ជាបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា, ជា

*អនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យទាំង ២ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា ។* ***ធម៌ដែលសម្បយុត្តដោយឧបេក្ខា-វេទនា*** *ជាអារម្មណូបនិស្សយប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា និងសុខវេទនាដែលជាអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ។ ក៏ក្នុងអធិការនេះ កាលបើពោលដោយសេចក្ដីផ្សេងគ្នានៃបច្ច័យ បកតូបនិស្សយប្បច្ច័យមាន ៩ វារៈ, អនន្តរូបនិស្សយប្បច្ច័យមាន ៧ វារៈ, អារម្មណូបនិស្សយប្បច្ច័យមាន ៤ វារៈ រួមត្រូវជាឧបនិស្សយប្បច្ច័យ ២០ ប្រភេទ ។*

***ក៏ក្នុងអធិការនេះ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យអស់ទៅ;*** *ព្រោះថា អរូបធម៌ដែលកើតមុន ឬកើតខាងក្រោយ រមែងមិនជាបច្ច័យដល់អរូបធម៌ទេ ។*

*ពីរបទថា* **"កម្មេ អដ្ឋ"** *បានដល់ វិសជ្ជនា ៨ វារៈយ៉ាងនេះ គឺធម៌ដែលសម្បយុត្តដោយសុខវេទនា* ***ជាកម្មប្បច្ច័យ*** *ទាំង ២ យ៉ាង, ដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដោយនានក្ខណិកកម្មប្បច្ច័យតែម្យ៉ាង, ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា និងឧបេក្ខាវេទនា ។*

ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ជាបច្ច័យដោយអំណាចនៃកម្មប្បច្ច័យ ២ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ដែលជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា មិនមានទេ, ជាបច្ច័យដល់ឧបេក្ខាវេទនាដោយនានក្ខណិកកម្មប្បច្ច័យតែម្យ៉ាង, ធម៌ដែលសម្បយុត្ត ដោយឧបេក្ខា-វេទនា ជាបច្ច័យដោយកម្មប្បច្ច័យទាំង ២ យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយឧបេក្ខាវេទនា, ជានានក្ខណិកកម្មប្បច្ច័យតែម្យ៉ាង ដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា និងទុក្ខវេទនា ក្រៅអំពីនេះ ។ ក៏ក្នុងអធិការនេះពោលដោយសេចក្ដីដូច្នេះ, បច្ច័យដែលប្រកបដោយនានក្ខណិកកម្មប្បច្ច័យមាន ៨, ជាសហជាតកម្មប្បច្ច័យមាន ៣ រួមត្រូវជាកម្មប្បច្ច័យ ១១ ប្រភេទ ។ ក៏ក្នុងនិទ្ទេសនៃ ***កម្មប្បច្ច័យ*** នេះ វិប្បយុត្តប្បច្ច័យ រមែងដាច់អស់ទៅ ដូចបុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យដែរ; ព្រោះថា អរូបធម៌ទាំងឡាយ រមែងមិនជាវិប្បយុត្តប្បច្ច័យដល់អរូបធម៌ជាមួយគ្នាទេ ។

វារៈ ៧ ក្នុង ***នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ*** ដូចក្នុងអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យដែរ ។ ក្នុងអធិការនេះ មានការកំណត់វិធីរាប់ ៥ យ៉ាង គឺវិសជ្ជនា ៣-៥-៧-៨-៩ ដោយប្រការដូច្នេះ ។ ក្នុងការរួមបច្ច័យដោយអំណាចនៃការកំណត់វិធីរាប់ទាំងនោះ អ្នកសិក្សា គប្បីនាំចេញនូវបច្ច័យដែលលើស និងបច្ច័យដែលមិនបាន (កាន់យក) ក្នុងការរួមជាមួយ

បច្ច័យដែលមានវិធីរាប់បានតិចជាង ហើយជ្រាបវិធីរាប់តទៅទៀត ក្នុងការរួមជាមួយហេតុប្បច្ច័យ រមែងមិនបានអារម្មណប្បច្ច័យ និងអនន្តរប្បច្ច័យជាដើមឡើយ ។

ពីរបទថា **“អធិបតិយា ទ្វេ”** វិសជ្ជនា ២ វារៈដ៏សេស វៀរបទដែលទាក់ទងដោយទុក្ខវេទនា ។ ពិតណាស់ ឈ្មោះថា ហេតុដែលសម្បយុត្តដោយទុក្ខវេទនាដែលជាអធិបតីមិនមានទេ, ព្រោះហេតុនោះ ទើបលោកនាំចេញសូម្បីក្នុង ២ វារៈដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងពាក្យថា **“ ទ្វេ ”** ត្រង់ ***ហេតុមូលកន័យ*** មានការកំណត់វិធីរាប់ ២ វារៈប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ យជនា ៦ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដោយអំណាចនៃការកំណត់វិធីរាប់ទាំងនោះឯង ។ បណ្តាយជនាទាំង ៦ នោះ ***យជនាទី ១*** ទ្រង់ត្រាស់សម្តែងទុក ដោយអំណាចនៃធម៌មិនមានអធិបតី មិនប្រកបដោយញាណដែលជាអវិបាក ។

- ***យជនាទី ២*** ត្រាស់ដោយអំណាចនៃធម៌ដែលជាវិបាកនោះឯង ។
- ***យជនាទី ៣ និងយជនាទី ៤*** ត្រាស់ដោយអំណាចនៃធម៌ទាំងនោះទៀត, តែជាញាណសម្បយុត្ត ។
- ***យជនាទី ៥*** ត្រាស់សម្តែងដោយអំណាចនៃអមោហៈជាអធិបតីដែលជាអវិបាក ។

**-យជនាទី ៦** ត្រាស់សម្តែងទុកដោយអំណាចនៃអមោហៈ ជាអធិបតី ដែលជាវិបាក ។

ម្យ៉ាងទៀត **យជនាទី ១** ត្រាស់ដោយអំណាចនៃហេតុទាំងអស់ ។

**-យជនាទី ២** ទ្រង់ត្រាស់ដោយអំណាចនៃវិបាកហេតុទាំងអស់ ។

**-យជនាទី ៣** ទ្រង់ត្រាស់ដោយអំណាចនៃអមោហហេតុទាំងអស់ ។

**-យជនាទី ៤** ត្រាស់សម្តែងដោយអំណាចនៃអមោហហេតុ ដែលជាវិបាកទាំងអស់ ។

**-យជនាទី ៥** ត្រាស់សម្តែងដោយអំណាចនៃអមោហៈ ដែលជាអធិបតីទាំងអស់ ។

**-យជនាទី ៦** ត្រាស់សម្តែងដោយអំណាចនៃអមោហៈ ដែលជាវិបាកមានអធិបតីទាំងអស់ ។

ក្នុងអារម្មណមូលកន័យ ពីរបទថា **"អធិបតិយា ចត្តារិ"** សេចក្តីថា ក្នុងអធិបតិប្បច្ច័យមានយជនា ៤ វារៈយ៉ាងនេះ គឺសុខ ជាបច្ច័យដល់សុខ ដល់ឧបេក្ខាដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ, ឧបេក្ខា ជាបច្ច័យដល់ឧបេក្ខា និងសុខ ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ ។

សូម្បីក្នុងឧបនិស្សយប្បច្ច័យ ព្រះមានព្រះភាគក៏ត្រាស់សម្តែងវារៈទុក ៤ វារៈ ដោយអំណាចនៃអារម្មណូបនិស្សយប្បច្ច័យ ។ ក៏ក្នុងឧបនិស្សយ-

*ប្បច្ច័យ មានយដនា ១ ប៉ុណ្ណោះ ។ សូម្បីក្នុងន័យដែលមាន* ***អធិបតិប្បច្ច័យ*** *ជាដើម យដនាណាដែលបាន និងមិនបាន តាមន័យដែលពោលហើយអំពីខាងដើម អ្នកសិក្សាកំណត់យដនាទាំងអស់នោះ ហើយគប្បីជ្រាបចំនួនយដនាដែលប្រៀបធៀបនឹងគ្នាចុះ ។*

*ព្រះមានព្រះភាគទ្រង់លើកបច្ច័យទាំងឡាយឡើង ដោយអនុលោមតាមន័យដែលត្រាស់ទុកក្នុងកុសលត្តិកៈត្រង់បច្ចនីយន័យ ហើយទ្រង់សម្តែងវារៈ ៩ ក្នុងបច្ច័យទាំងពួងថា* **"នហេតុយា នវ"** *ជាដើម ដោយអំណាចនៃការរាប់ដោយបច្ចនីយៈ អាស្រ័យវារៈដែលបានក្នុងបច្ច័យទាំងនោះ, វារៈទាំងនោះ អ្នកសិក្សាគប្បីលើកបាលីឡើងសម្តែងដោយន័យថា "បុគ្គលថ្វាយទាន ដោយចិត្តដែលសម្បយុត្តដោយសុខវេទនា, ធម៌ដែលសម្បយុត្តដោយសុខវេទនា ជាបច្ច័យដល់ធម៌ដែលសម្បយុត្តដោយសុខវេទនា ដោយនហេតុប្បច្ច័យ" ជាដើម ដោយអំណាចនៃវិសជ្ជនា ៩ វារៈ មានបច្ច័យដែលមានមូល ១ និងមានមូលី ១ ជាទីបំផុត ។*

*ក៏ក្នុងការរួមបច្ច័យក្នុងអធិការនេះ ពាក្យថា* **" នហេតុប្បច្ចយា ។ បេ ។ នឧបនិស្សយេ អដ្ឋ"** *អ្នកសិក្សាគប្បីជ្រាបវារៈដោយអំណាចនៃនានាក្ខណិកកម្មប្បច្ច័យ ។ ពិតណាស់ កម្មដែលមានកម្លាំងអន់ រមែងមិនជាឧបនិស្សយប្បច្ច័យទេ, តែជាបច្ច័យដោយនានាក្ខណិកកម្មប្បច្ច័យតែម្យ៉ាង*

*ប៉ុណ្ណោះ; ក៏យដនាដ៏សេស ក្នុងអនុលោមបច្ចនីយៈ និងបច្ចនីយានុលោម ក្នុងអធិការនេះ អ្នកសិក្សាអាចរាប់បានដោយន័យ ដែលខ្ញុំពោលទុកហើយ ក្នុងខាងដើម ដោយអំណាចនៃវារៈដែលបាន ក្នុងការប្រកបនៃបច្ច័យនោះៗ, ព្រោះហេតុដូច្នោះ ទើបមិនអធិប្បាយយ៉ាងពិស្តារទេ៕*

ចប់វេទនាតិកបដ្ឋាន

.................................

## ៣.ពណ៌នាអំពីវិបាកត្តិកបដ្ឋាន

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង **វិបាកត្តិកៈ** ដូចតទៅ ៖*

*វារៈ ១៣ ឯណាដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងហេតុប្បច្ច័យថា* **“វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា”** *ដើម្បីនឹងសម្ដែងវារៈទាំងនោះ ដោយការរាប់ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* **“ហេតុយា តេរស”** *សូម្បីក្នុងពាក្យថា* **“អារម្មណេ បញ្ច”** *ជាដើម ក៏មានដូចគ្នានេះដែរ ។ ក្នុងអធិការនេះ មានការកំណត់វិធីរាប់ ៦ យ៉ាង គឺ១៣-៥-៩-៧-៣-២ ដោយប្រការដូច្នេះ ក្នុងការរួមបច្ច័យ ដោយអំណាចនៃវិធីរាប់ទាំងនោះ អ្នកសិក្សា គប្បីជ្រាបវិធីរាប់ចំនួន ដោយន័យដែលខ្ញុំពោលទុកហើយក្នុងខាងក្រោយមែនពិត ។*

*ពិតណាស់ ក្នុង **បច្ចនីយន័យ** ព្រះមានព្រះភាគដើម្បីនឹងសម្ដែងសង្ខេបនូវវារៈ ១០ ដែលត្រាស់ទុកក្នុង **នហេតុប្បច្ច័យ** ថា* **“វិបាកំ ធម្មំ បដិច្ច**

**វិបាកោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា"** *ដោយការរាប់ ទើបត្រាស់សម្តែងថា* **"នហេតុយា ឩស"** *, សូម្បីក្នុងពាក្យថា* **"នអារម្មណេ បញ្ច"** *ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងអធិការនេះ មានការកំណត់វិធីរាប់ ៨ យ៉ាង គឺ ១០-៥-១៣-១២-២-១-៩-៣ ដោយប្រការដូច្នេះ ក្នុងការរួមបច្ច័យដោយអំណាចនៃការកំណត់វិធីរាប់ទាំងនោះ អ្នកសិក្សាគប្បីជ្រាបការកំណត់ដោយពិស្តារ តាមន័យដែលខ្ញុំពោលហើយក្នុងខាងក្រោយ, ចំណែកបាលីព្រះមានព្រះភាគទ្រង់បំប្រួញទុក, ក៏អ្នកសិក្សា គប្បីប្រៀបធៀប ដោយអំណាចនៃការកំណត់ដែលមានបានទាំងនេះឯង ហើយជ្រាបអនុលោមបច្ចនីយន័យ និងបច្ចនីយានុលោមន័យចុះ ។*

***សហជាតវារៈ*** *មានគតិដូចនឹង* ***បច្ចយវារៈ និស្សយវារៈ សំសដ្ឋវារៈ និងសម្បយុត្តវារៈ*** *ដែរ គឺរមែងកំណត់តាមបាលីនុ៎ះឯង ។*

*គប្បីជ្រាបនូវវិនិច្ឆ័យក្នុង* ***បញ្ហាវារៈ*** *ដូចតទៅ ៖*

*ពីរបទថា* **"កុសលាកុសលេ និរុទ្ធេ"** *សេចក្តីថា កាលបើកុសលដែលប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនា និងសេចក្តីត្រេកអរជាដើមនេះ រលត់ទៅហើយ ។ ពាក្យថា* **"វិបាកោ តទារម្មណតា ឧប្បជ្ជតិ"** *សេចក្តីថា កាមាវចរវិបាក រមែងកើតឡើងដោយតទារម្មណ៍;* ***ចំណែកអាចារ្យពួកណាពោលថា " ក្នុងទីបំផុតនៃវិបស្សនា ជវន និងវិចិកិច្ឆាសម្បយុត្តចិត្ត ឧទ្ធច្-***

*សម្បយុត្តចិត្ត មិនមានតទារម្មណ៍ទេ” , អាចារ្យពួកនោះ គប្បីបដិសេធ ដោយព្រះបាលីនេះ ។*

*ពាក្យថា* **“ អាកាសានញ្ចាយតនកុសលំ ខិញ្ញាណញ្ចាយតនកិរិយស្ស អារម្មណាបច្ចយេន បច្ចយោ ”** *នេះ លោកពោលទុកដោយអំណាចនៃបុគ្គលដែលសម្រេចនូវព្រះអរហត្ត ហើយចូលសមាបត្តិដែលមិនធ្លាប់ចូលដោយបដិលោម ។ ក្នុងវិសជ្ជនាទាំងពួង អ្នកសិក្សាពិចារណាបាលីឲ្យល្អហើយ គប្បីជ្រាបសេចក្តី ដោយឧបាយនេះចុះ ។*

*សូម្បីក្នុងពាក្យថា* **“ ហេតុយា សត្ត, អារម្មណេ នវ, អធិបតិយា ទស ”** *ជាដើម អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃសហជាតាធិបតិប្បច្ច័យ អារម្មណាធិបតិប្បច្ច័យ សហជាតនិស្សយប្បច្ច័យ បុរេជាតនិស្សយប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ អារម្មណូបនិស្សយប្បច្ច័យ បកតូបនិស្សយ-ប្បច្ច័យ សហជាតវិប្បយុត្តប្បច្ច័យ និងបុរេជាតវិប្បយុត្តប្បច្ច័យ ព្រោះហេតុដូច្នោះ ក្នុងបច្ច័យណាៗ បានវិសជ្ជនាចំនួនប៉ុនណា ដោយប្រការណា អ្នកសិក្សាគប្បីកំណត់វិសជ្ជនាទាំងអស់នោះ ក្នុងបច្ច័យនោះៗ ដោយប្រការនោះៗ ផងចុះ, ម្យ៉ាងទៀត វិធីទាំងអស់ គឺការលើកវារៈចេញ ដោយអំណាចនៃអនុលោមក្នុងបច្ចនីយន័យជាដើម, ការរាប់ គឺការរួមបច្ច័យ មានវារៈដែលបានដោយអនុលោមជាបច្ចនីយៈ, ការបាន និងការមិនបាននូវ*

បច្ច័យដែលមានវារៈ និងការរាប់ដែលមិនបានក្នុងហេតុមូលកន័យជាដើម សុទ្ធៗ ក្នុងអនុលោមបច្ចនីយន័យ ព្រមទាំងបច្ចនីយានុលោម ដែលប្រព្រឹត្តទៅដោយអំណាចនៃការរួម (បច្ច័យ) អ្នកសិក្សា គប្បីជ្រាបដោយអំណាចន័យដែលខ្ញុំពោលទុកក្នុងខាងក្រោយនោះចុះ; ក៏សូម្បីក្នុងតិកៈ និងទុកៈ ក្រៅអំពីនេះ ក៏គប្បីជ្រាបដូចក្នុងអធិការនេះដែរ ។

***មែនពិត បដ្ឋានប្បករណ៍ ពោលដោយបាលីហើយ មានបរិមាណមិនអស់ (មិនមានទីបំផុត), សូម្បីបុគ្គលមានអាយុយឺនយូរ បដិបត្តិដោយគិតថា “នឹងពណ៌នាសេចក្ដីនៃបដ្ឋាននោះ តាមលំដាប់បទ អាយុរមែងមិនល្មមគ្រប់គ្រាន់ឡើយ”*** ។ ក៏កាលបើលោកពណ៌នាចំណែកមួយនៃបដ្ឋានហើយ សម្ដែងចំណែកដ៏សេស ទៅតាមន័យ (នោះ) អ្នកសិក្សាមិនអាចជ្រាបសេចក្ដីបាន ក៏មិនមែន, ព្រោះហេតុដូច្នោះ តពីនេះទៅ ខ្ញុំមិនពោលពាក្យមានប្រមាណប៉ុណ្ណោះទៀតទេ, នឹងពោលចំពោះតែពាក្យដែលចាំបាច់ត្រូវពោលប៉ុណ្ណោះ, ព្រោះមានប្រការដែលព្រះមានព្រះភាគមិនបានត្រាស់សម្ដែងក្នុងខាងក្រោយ នៅក្នុងតិកៈ និងទុកៈដ៏សេស ក៏ពាក្យឯណាដែលខ្ញុំមិនបានពោលដល់ ហើយកន្លងផុតទៅ (ពាក្យនោះ) អ្នកសិក្សា គប្បីជ្រាបតាមន័យរបស់ព្រះបាលីចុះ ៕

ចប់វិបាកត្តិកបដ្ឋាន

# ៨.ពណ៌នាអំពីឧបាទិន្នត្តិកប្បដ្ឋាន

*ក្នុងបញ្ហាវារៈនៃ **ឧបាទិន្នុបាទានិយតិកៈ** ព្រះមានព្រះភាគទ្រង់ត្រាស់សំដៅដល់បវត្តិកាលថា “វត្ថុជាបច្ច័យដល់ខន្ធទាំងឡាយ ដែលជាឧបាទិន្នុបាទានិយៈ ដោយបុរេជាតប្បច្ច័យប៉ុណ្ណោះ; តែក្នុងបដិសន្ធិកាល វត្ថុនោះមិនជាបុរេជាតប្បច្ច័យទេ” ។ ក្នុងពាក្យថា “កពឡិង្ការាហារដែលជាឧបាទិន្នុបាទានិយៈ ជាបច្ច័យដល់កាយដែលជាឧបាទិន្នុបាទានិយៈ ដោយអាហារប្បច្ច័យ” នេះ មានសេចក្តីថា ឈ្មោះថា កពឡិង្ការាហារដែលជាឧបាទិន្នុបាទានិយៈ បានដល់ ឱជាដែលនៅខាងក្នុងរូបដែលមានកម្មជាសមុដ្ឋាន ។ ពីរបទថា **“ឧបាទិន្នុបាទានិយស្ស កាយស្ស”** សេចក្តីថា ជាបច្ច័យដល់កាយ គឺរូបដែលមានកម្មជាសមុដ្ឋាននោះឯង ដោយអាហារប្បច្ច័យ ។*

*អាហារជាបច្ច័យ ដោយអំណាចនៃការចិញ្ចឹមរក្សា និងឧបត្ថម្ភដល់កម្មជរូប ដូចរូបជីវិតិន្ទ្រិយដែរ, មិនបានជាបច្ច័យដោយអំណាចនៃការញុំាងរូបឲ្យកើតឡើងឡើយ ។*

*ចំណែកពាក្យណា ដែលអាចារ្យពួកខ្លះពោលថា “ឱជាក្នុងខ្លួនសត្វកន្ទ្កើបជាដើម ដែលនៅរស់ ជាបច្ច័យដោយអាហារប្បច្ច័យដល់សត្វពស់ជាដើម ដែលលេបសត្វកន្ទ្កើបជាដើម ចូលទៅ” , ពាក្យនោះ មិនគប្បីកាន់យកទេ; ព្រោះថា ឱជាក្នុងខ្លួនសត្វដែលនៅរស់ រមែងមិនឲ្យសម្រេច*

*សេចក្ដីជាអាហារប្បច្ច័យ ដល់រាងកាយរបស់អ្នកដទៃឡើយ ។ ក៏ក្នុងពាក្យថា* **“ អនុបាទិន្នុបាទានិយស្ស កាយស្ស ”** *នេះ រមែងបានសេចក្ដីជាបច្ច័យដោយអំណាចនៃការឲ្យកើតឡើង ។ ក្នុងពាក្យថា* **“ ឧបាទិន្នុបាទានិយស្ស ច អនុបាទិន្នុបាទានិយស្ស ច ”** *នេះ ព្រះមានព្រះភាគទ្រង់ត្រាស់អាហារ-ប្បច្ច័យ ដោយអំណាចជាធម៌ឧបត្ថម្ភដល់កាយម្យ៉ាង, ដោយអំណាចនៃការធ្វើឲ្យកើតដល់កាយម្យ៉ាង, ឬដោយអំណាចជាធម៌ឧបត្ថម្ភដល់កាយដែលជា* ***ឧបាទិន្នុបាទានិយៈ*** *និងដែលជា* ***អនុបាទិន្នុបាទានិយៈ*** *ប៉ុណ្ណោះ ។ ក៏អាហារ ២ កាលបើជាបច្ច័យរួមគ្នា រមែងជាឧបត្ថម្ភកសត្តិ គឺទំនុកបម្រុងប៉ុណ្ណោះ, មិនជាជនកសត្តិ គឺធ្វើឲ្យកើតទេ ។ ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សា គប្បីពិនិត្យមើលបាលីឲ្យល្អហើយជ្រាបចុះ ៕*

ចប់ឧបាទិន្នត្តិកប្បដ្ឋាន

## ៥-២២.ពណ៌នាអំពីសង្កិលិដ្ឋត្តិកប្បដ្ឋាន

*ពាក្យទាំងអស់ក្នុង* ***សង្កិលិដ្ឋសង្កិលេសត្តិកៈ*** *អ្នកសិក្សា គប្បីជ្រាបតាមលំនាំរបស់ន័យដែលពោលហើយក្នុងកុសលត្តិកៈចុះ ៕*

ចប់សង្កិលិដ្ឋត្តិកប្បដ្ឋាន

..................................

## ពណ៌នាអំពីវិតក្កត្តិកប្បដ្ឋាន

*ក្នុង **វិតក្កត្តិកៈ** ពាក្យថា **"យថាកម្មូបគញ្ញាណស្ស បរិកម្មំ"** បានដល់ បរិកម្មនៃទិព្វចក្ខុញ្ញាណនោះឯង, ជាបរិកម្មដើម្បីឲ្យយថាកម្មូបគញ្ញាណនោះ កើតឡើង; ក៏ពាក្យនេះ ទ្រង់ត្រាស់សំដៅយកបរិកម្មក្នុងវេលាប្រើញាណ ដែលកើតឡើងហើយ ។ ពាក្យដ៏សេស ក្នុងអធិការនេះ លោកអធិប្បាយ ទៅតាមបាលីនុ៎ះឯង ៕*

ចប់វិតក្កត្តិកប្បដ្ឋាន

.................................

## ពណ៌នាអំពីបីតិត្តិកប្បដ្ឋាន

*ក្នុង **បីតិត្តិកៈ** ពាក្យថា **"ភវង្គដែលសហគតដោយសុខ ជាបច្ច័យ ដល់ភវង្គដែលសហគតដោយឧបេក្ខា ដោយអំណាចនៃអនន្តរប្បច្ច័យ"** ព្រះ មានព្រះភាគត្រាស់ដោយអំណាចនៃគោចរម្មណភវង្គ និងមូលភវង្គ, ពាក្យ ដ៏សេសទាំងអស់ ក្នុងអធិការនេះ គប្បីជ្រាបដោយអំណាចនៃបាលីនុ៎ះឯង ៕*

ចប់បីតិត្តិកប្បដ្ឋាន

.............................

## ពណ៌នាអំពីទស្សនត្តិកបដ្ឋាន

ត្រង់ ***ទស្សនត្តិកៈ*** ក្នុងពាក្យទាំងឡាយថា ***“រាគៈដែលគប្បីលះដោយទស្សនៈ សោតា រមែងកើតឡើង”*** ជាដើម, អ្នកសិក្សាគប្បីជ្រាបថា ធម៌ដែលកើតឡើងដល់ព្រះអរិយបុគ្គលថ្នាក់ក្រោម, រមែងមិនកើតឡើងដល់ព្រះអរិយបុគ្គលថ្នាក់ខ្ពស់យ៉ាងនេះ គឺរាគៈដែលគប្បីលះ ដោយទស្សនៈ រមែងកើតដល់បុថុជ្ជន, រាគៈដែលគប្បីលះដោយភាវនា រមែងកើតសូម្បីដល់ព្រះសោតាបន្ន, ធម៌ដែលគប្បីលះដោយទស្សនៈ រមែងមិនជាបច្ច័យដល់ធម៌ដែលគប្បីលះដោយភាវនា ដោយអំណាចនៃបច្ច័យ សូម្បីតែម្យ៉ាងឡើយ ។ ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សាគប្បីសង្កេតមើលតាមព្រះបាលី ហើយជ្រាបដោយអំណាចនៃលក្ខណៈដែលពោលទុកក្នុងកុសលត្តិកៈបុះ ៕

ចប់ទស្សនត្តិកបដ្ឋាន

## ពណ៌នាអំពីទស្សនេនបហាតព្វហេតុកត្តិកបដ្ឋាន

ក្នុង ***ទស្សនេនបហាតព្វហេតុកត្តិកៈ*** អ្នកសិក្សាគប្បីជ្រាបការចែកធម៌ដែលមានហេតុគប្បីលះដោយទស្សនៈ ដោយន័យដែលលោកពោលទុកក្នុងអដ្ឋកថាកណ្ឌ (ធម្មសង្គណី) ; មោហៈដែលសហគតៈដោយវិចិកិច្ឆា និង

*ឧទ្ធច្ចៈ ចាត់ចូលក្នុងពួកទី ៣ ព្រោះមិនមានហេតុ ។ ក្នុងអធិការនេះ ធម៌ឯណា មានហេតុដែលគប្បីលះដោយទស្សនៈ និងភាវនាដូចពោលមកហើយនេះ, ធម៌ពួកនោះ ឈ្មោះថា មានហេតុគប្បីលះ ។ ធម៌ពួកណា មិនមានហេតុ, ធម៌ពួកនោះ ឈ្មោះថា មិនមានហេតុដែលគប្បីលះដោយទស្សនៈនិងភាវនាទេ, អ្នកសិក្សាគប្បីជ្រាបវិភាគនៃ* ***បហាតព្វហេតុកធម៌ និងនបហាតព្វហេតុកធម៌*** *ដូច្នេះហើយ គប្បីជ្រាបពាក្យដ៏សេស តាមលំអាននៃលក្ខណៈដែលសម្តែងទុកក្នុងទស្សនេនបហាតព្វត្តិកៈ និងកុសលត្តិកៈចុះ ៕*

ចប់ទស្សនេនបហាតព្វហេតុកត្តិកៈ

..........................................

## ពណ៌នាអំពីអាចយគាមិតិកប្បដ្ឋាន

*អនុលោមប្បដ្ឋាន ក្នុងបដិច្ចវារៈ និងសំសដ្ឋវារៈ ក្នុង* ***អាចយគាមិតិកៈ*** *ដូចក្នុងកុសលត្តិកៈដែរ; ពាក្យដ៏សេស លោកអធិប្បាយទៅតាមបាលី ទាំងដោយវិសជ្ជនា ទាំងដោយការរាប់មែនពិត ៕*

ចប់អាចយគាមិតិកប្បដ្ឋាន

## ពណ៌នាអំពីសេក្ខត្តិកប្បដ្ឋាន

*ក្នុង* ***សេក្ខត្តិកៈ*** *អសេក្ខធម៌រមែងមិនជាបច្ច័យដល់សេក្ខធម៌ ដោយ*

បច្ច័យណា ៗ, តែសេក្ខធម៌ជាអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយ-ប្បច្ច័យ ដល់អសេក្ខធម៌ ។ ពាក្យដ៏សេស ក្នុងអធិការនេះ (គប្បី) អធិប្បាយតាមបាលីចុះ ៕

ក្នុង ***បរិត្តត្តិកប្បដ្ឋាន*** ក៏ដូចគ្នាដែរ ៕

ចប់សេក្ខត្តិកប្បដ្ឋាន

....................................

## ពណ៌នាអំពីបរិត្តារម្មណត្តិកប្បដ្ឋាន

ពីរបទថា **"អប្បមាណារម្មណា ចេតនា"** ក្នុង ***បរិត្តារម្មណត្តិកៈ*** គឺចេតនាក្នុងគោត្រភូ ជាបច្ច័យដល់សេក្ខធម៌, និងពោលថា **"បច្ចវេក្ខណា-ចេតនា"** ក៏បាន ។ ពីរបទថា **"វិបាកានំ បរិត្តារម្មណានំ"** គឺវិបាកដែលមានកម្មជាអារម្មណ៍ កើតឡើងក្នុងបដិសន្ធិកាល មានរូបជាដើម ជាអារម្មណ៍កើតឡើងដោយអំណាចនៃចក្ខុវិញ្ញាណជាដើម មានបរិត្តារម្មណ៍ដែលជវនទទួលមក កើតឡើង ដោយអំណាចនៃតទារម្មណ៍ក្នុងបវត្តិកាល; ក៏អាចារ្យពួកណាពោលថា "បដិសន្ធិរមែងមិនមាន ព្រោះគោត្រភូចិត្តជាបច្ច័យ" , អាចារ្យពួកនោះ គប្បីត្រូវហាមឃាត់ដោយសូត្រនេះ ។ ពាក្យដ៏សេសក្នុងអធិការនេះ គប្បីជ្រាបតាមន័យរបស់បាលីនុ៎ះឯង ៕

***ហីនត្តិកប្បដ្ឋាន*** *ដូចគ្នានឹងសង្កិលិដ្ឋត្តិកប្បដ្ឋានដែរ ៕*

ចប់បរិត្តារម្មណត្តិកប្បដ្ឋាន

........................................

## ពណ៌នាអំពីមិច្ឆត្តត្តិកប្បដ្ឋាន

*ក្នុង* ***មិច្ឆត្តត្តិកៈ*** *មិច្ឆត្តនិយតធម៌ រមែងមិនជាបច្ច័យណាៗ ដល់សម្មត្តនិយតធម៌ ឬសម្មត្តនិយតធម៌ រមែងមិនជាបច្ច័យណាៗ ដល់មិច្ឆត្ត-និយតធម៌ទេ, មិច្ឆត្តនិយតធម៌ ឬសម្មត្តនិយតធម៌ ឈ្មោះថា វៀរសហជាតាធិបតិប្បច្ច័យចេញ រមែងមិនមាន ។ ក្នុង* ***សម្មត្តនិយតធម៌ រមែងមិនមានអារម្មណបុរេជាតប្បច្ច័យ*** * ***ដោយពិតប្រាកដ*** *(គឺសម្មត្ត-និយតធម៌ មិនជាអារម្មណបុរេជាតប្បច្ច័យពិតប្រាកដ) ទេ ។ ក្នុង* ***មិច្ឆត្ត-និយតធម៌*** *មានអារម្មណបុរេជាតប្បច្ច័យ;* ***និយតមិច្ឆាទិដ្ឋិ*** *គប្បីប្រារព្ធអនិយតចិត្តកើតឡើងបាន; និយតចិត្ត រមែងមិនប្រារព្ធនិយតចិត្តដ៏សេសកើតឡើងបានទេ ។ ធម៌ណាៗ រមែងមិនធ្វើមិច្ឆត្តនិយតធម៌ឲ្យធ្ងន់ ហើយកើតឡើងបានឡើយ; កុសលរមែងមិនជាឧបនិស្សយប្បច្ច័យ ដល់មិច្ឆត្ត-*

* ច្បាប់ខ្លះថា ជាវត្ថុបុរេជាត, តែខុសសភាវៈ ទើបប្រែតាមបាលីភូមាថា អារម្មណបុរេជាត ។

និយតធម៌ទេ; ពាក្យដ៏សេសក្នុងអធិការនេះ គប្បីជ្រាបតាមន័យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបាលីនុ៎ះឯង ៕

ចប់មិច្ឆត្តត្តិកបដ្ឋាន

................................

## ពណ៌នាអំពីមគ្គារម្មណត្តិកបដ្ឋាន

ក្នុង ***មគ្គារម្មណត្តិកៈ*** ត្រង់អនុលោមនៃបដិច្ចវារៈ មិនមានវិបាក-បច្ច័យទេ, សូម្បីក្នុងកម្មបច្ច័យ (នៃបញ្ហាវារៈ) ក្នុងតិកៈនេះ ក៏មិនបាននានក្ខណិកកម្មបច្ច័យឡើយ ៕

ចប់មគ្គារម្មណត្តិកបដ្ឋាន

.......................................

## ពណ៌នាអំពីឧប្បន្នត្តិកបដ្ឋាន និងអតីតត្តិកបដ្ឋាន

ក្នុង ***ឧប្បន្នត្តិកៈ និងអតីតត្តិកៈ*** ក៏ដូចគ្នា ។

ពីរបទថា **“ អហេតុកំ មគ្គារម្មណំ ”** ក្នុងបច្ចនីយន័យត្រាស់សំដៅដល់អហេតុកអាវជ្ជនចិត្ត (គឺមនោទ្វារាវជ្ជនចិត្ត) ដែលមានមគ្គជាអារម្មណ៍; ពាក្យដ៏សេស ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបតាមលំអាននៃបាលីនុ៎ះឯង ។

ក្នុង ***ឧប្បន្នត្តិកៈ និងអតីតត្តិកៈ មិនមានបដិច្ចវារៈជាដើមទេ, មានតែបញ្ហាវារៈប៉ុណ្ណោះ*** ។ ព្រោះហេតុអ្វី ? ព្រោះបដិច្ចវារៈជាដើម មានចំពោះតែសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ម្យ៉ាងទៀត តិកៈទាំងអស់នេះ មានធម៌ដែលជាអតីត និងអនាគតលាយគ្នា; ក៏បច្ច័យទាំងឡាយ ដែលជាពួកនៃអនន្តរប្បច្ច័យ រមែងមិនបានក្នុងឧប្បន្នត្តិកៈនេះទេ; ព្រោះហេតុអ្វី ? ព្រោះក្នុងឧប្បន្នត្តិកៈ មិនមានធម៌ដែលជាអតីតឡើយ; ក៏ក្នុងអធិការនេះ ធម៌ទាំង ២ នេះ គឺធម៌ដែលកើតឡើងហើយ និងធម៌ដែលនៅមិនទាន់កើតឡើង រមែងមិនជាបច្ច័យដោយបច្ច័យណាៗ ដល់ធម៌ទាំង ២ នេះ គឺធម៌ដែលកើតហើយ និងធម៌ដែលនៅមិនទាន់កើតឡើង ។ បំណែកធម៌ទាំង ២ នេះ គឺធម៌ដែលនៅមិនទាន់កើតឡើង និងដែលកំពុងកើតឡើង ជាបច្ច័យដល់ធម៌ដែលកើតឡើងហើយ ដោយបច្ច័យ ២ គឺ អារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ; ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សា គប្បីជ្រាបតាមន័យដែល ពោលរួចមកហើយក្នុងព្រះបាលីនោះឯង ។

ក្នុង ***អតីតត្តិកៈ*** ធម៌ដែលជាបច្ចុប្បន្នរមែងមិនជាបច្ច័យយ៉ាងណាមួយ ដល់ធម៌ដែលជាអតីត និងអនាគត ឬធម៌ដែលជាអតីត និងអនាគតរមែងមិនជាបច្ច័យយ៉ាងណាមួយ ដល់ធម៌ដែលជាអតីត និងអនាគតឡើយ,

ក៏និព្វានរមែងមិនបានជាបច្ច័យ (និង) ជាបច្ចយុប្បន្នក្នុងតិកៈទាំងពីរនេះទេ; ពាក្យដ៏សេសក្នុងអធិការនេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងបាលីចុះ ៕

ចប់ឧប្បន្នត្តិកបដ្ឋាន និងអតីតត្តិកបដ្ឋាន

.............................................

## ពណ៌នាអំពីអជ្ឈត្តត្តិកបដ្ឋាន

***អជ្ឈត្តបទ និងពហិទ្ធាបទ*** ទ្រង់មិនកាន់យកក្នុងអជ្ឈត្តត្តិកៈទេ ។ ពិតណាស់ ពួកធម៌ទាំងពីរ គឺអជ្ឈត្តធម៌ និងពហិទ្ធាធម៌ រមែងមិនជាបច្ច័យ និងបច្ចយុប្បន្នទេ, ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា សូម្បីពណ៌របស់គ្រាប់ស្តៃដែលនៅក្នុងបាតដៃ រមែងមិនជាអារម្មណ៍ដូចគ្នានឹងពណ៌របស់បាតដៃឡើយ ៕

ចប់អជ្ឈត្តត្តិកបដ្ឋាន

...............................

## ពណ៌នាអំពីអជ្ឈត្តារម្មណត្តិកបដ្ឋាន

សូម្បីក្នុង ***អជ្ឈត្តារម្មណត្តិកៈ*** រមែងមិនបានអជ្ឈត្តារម្មណបទ និងពហិទ្ធារម្មណបទ ដូចអជ្ឈត្តបទ និងពហិទ្ធាបទទេ ។ ក្នុងតិកៈនេះ ពាក្យដ៏សេស លោកអធិប្បាយតាមបាលីនុ៎ះឯង ៕

ចប់អជ្ឈត្តារម្មណត្តិកបដ្ឋាន

# ពណ៌នាអំពីសន្និទស្សនត្តិកប្បដ្ឋាន

*សូម្បីក្នុង* ***សន្និទស្សនត្តិកៈ*** *អ្នកសិក្សា ក៏គប្បីកាន់យកសេចក្ដីដោយអំណាចនៃបាលីដូចគ្នាដែរ; ចំណែកក្នុងតិកៈនេះ អ្នកសិក្សាគប្បីបំប្រួញវារៈទាំងឡាយ ដែលមានមកហើយក្នុងព្រះបាលី ប្រៀបធៀបក្នុងបច្ច័យទាំងឡាយ ដែលប្រៀបធៀបគ្នាបាន ដោយន័យដែលពោលទុកហើយ គប្បីជ្រាបវិធីរាប់ចុះ ៕*

ចប់តិកប្បដ្ឋានក្នុងធម្មានុលោម

.........................................

# ២.ពណ៌នាអំពីទុកប្បដ្ឋាន

## ហេតុទុកៈជាដើម

*សូម្បីក្នុង* ***ទុកប្បដ្ឋាន*** *អ្នកសិក្សាគប្បីជ្រាបបញ្ហាវិសជ្ជនា និងការរាប់ក្នុងទុកៈទាំងអស់ តាមន័យដែលពោលមកហើយក្នុងបាលីនោះឯង ។ ម្យ៉ាងទៀត ក្នុងទុកប្បដ្ឋាននេះ ការវិសជ្ជនា សហេតុកទុកៈ និងហេតុសម្បយុត្ត-ទុកៈ ដូចនឹងការវិសជ្ជនាហេតុទុកៈដែរ ។ ហេតុ និងសហេតុកហេតុនៃហេតុសម្បយុត្តទុកៈ ព្រមទាំងសប្បច្ចយទុកៈ សង្ខតទុកៈ ក៏ដូចគ្នាដែរ ។ ពាក្យថា* **“ឥធំ ទុកំ យថា សប្បច្ចយទុកំ, ឯវំ ភាគព្វំ”** *នេះ ព្រះមានព្រះ*

*ភាគទ្រង់ត្រាស់ទុក ព្រោះសូម្បីសង្ខតធម៌រមែងប្រកបរួមជាមួយនឹងអសង្ខត-ធម៌មិនបាន ដូចសប្បច្ចយធម៌ប្រកបជាមួយអប្បច្ចយធម៌មិនបានដូច្នោះដែរ; សារម្មណទុកៈ ចិត្តសម្បយុត្តទុកៈ និងសំសដ្ឋទុកៈ មានវិសជ្ជនាដូចគ្នានឹងអាសវគោច្ឆកៈ ឱឃគោច្ឆកៈ និងយោគគោច្ឆកៈដែរ ព្រោះថា ធម៌ទាំង ៣ នេះ មានវិសជ្ជនាដូចគ្នាមែនពិត ៕*

ចប់ហេតុទុកៈជាដើម

## ពណ៌នាអំពីលោកិយទុកៈជាដើម

*ក៏ទុកៈទាំងនេះ គឺលោកិយទុកៈ សាសវទុកៈ សញ្ញោជនីយទុកៈ គន្ថ-នីយទុកៈ នីវរណីយទុកៈ បរាមដ្ឋទុកៈ សង្កិលេសិកទុកៈ អាសវវិប្បយុត្ត-សាសវទុកៈ សញ្ញោជនវិប្បយុត្តសញ្ញោជនីយទុកៈ គន្ថវិប្បយុត្តគន្ថនីយទុកៈ នីវរណវិប្បយុត្តនីវរណីយទុកៈ បរាមាសវិប្បយុត្តបរាមដ្ឋទុកៈ កិលេស-វិប្បយុត្តសង្កិលេសិកទុកៈ បរិយាបន្នទុកៈ និងសឧត្តរទុកៈ គឺដូចគ្នា; កិលេស-ទុកៈ ដូចសញ្ញោជនទុកៈ សង្កិលិដ្ឋទុកៈ កិលេសសម្បយុត្តទុកៈ នីវរណ-សម្បយុត្តទុកៈ ទស្សនេនបហាតព្វទុកៈ និងសរណទុកៈដែរ; មួយទៀត កិលេសទុកៈ សង្កិលិដ្ឋនីវរណទុកៈ នីវរណសម្បយុត្តកិលេសទុកៈ និងកិលេស-សម្បយុត្តទុកៈ ក៏ដូចគ្នាដែរ ។ ដោយន័យនេះ អ្នកសិក្សាគប្បីជ្រាបថា វិសជ្ជនានៃទុកៈទាំងអស់ ដែលមានសេចក្ដីដូចគ្នា រមែងជាការវិសជ្ជនាដូចគ្នា*

មែនពិត ។

កំក្នុងបដ្ឋានទាំងអស់ រមែងមិនបានកេនចិវិញ្ញយ្យទុកៈទេ; ក្នុងទុកៈដែលមានសភាពយ៉ាងនេះ គឺ “**អាសវា ចេវ អាសវសម្បយុត្តា ច, សញ្ញោជនា ចេវ សញ្ញោជនសម្បយុត្តា ច, គន្ថា ចេវ គន្ថសម្បយុត្តា ច, នីវរណា ចេវ នីវរណសម្បយុត្តា ច, កិលេសា ចេវ សង្កិលិដ្ឋា ច**” រមែងមិនបានវិបាកប្បច្ច័យ និងនានក្ខណិកកម្មប្បច្ច័យទេ ។ ក្នុងនហេតុ-សហេតុកៈ នហេតុអហេតុកទុកៈ មិនមាន **ហេតុប្បច្ច័យ** ឡើយ ។ ក្នុងទុកៈទាំងនេះ គឺហេតុហេតុសម្បយុត្តទុកៈ អាសវអាសវសម្បយុត្តទុកៈ, គន្ថ-គន្ថសម្បយុត្តទុកៈ រមែងមិនបាន **នហេតុប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គ-ប្បច្ច័យ** ទេ ។ ចំណែកក្នុងទុកៈទាំងនេះ គឺសញ្ញោជនសញ្ញោជនសម្បយុត្ត-ទុកៈ នីវរណនីវរណសម្បយុត្តទុកៈ កិលេសកិលេសសម្បយុត្តទុកៈ កិលេស-សង្កិលិដ្ឋទុកៈ រមែងបាន **នហេតុប្បច្ច័យ** ដោយអំណាចនៃមោហៈ ដែលសហគតដោយវិចិកិច្ឆា និងឧទ្ធច្ចៈ រមែងមិនបាន **នឈានប្បច្ច័យ និងនមគ្គ-ប្បច្ច័យ** ទេ ។ អ្នកសិក្សាកំណត់វិសជ្ជនាដែលបាន និងមិនបាន ក្នុងទុកៈទាំងអស់ ដូចអធិប្បាយមកហើយ គប្បីជ្រាបការរាប់វារៈ ដោយអំណាចនៃបាលីចុះ ៕

ចប់ទុកបដ្ឋាន

## ៣.ពណ៌នាអំពីទុកត្តិកបដ្ឋាន

ក្នុង ***ទុកត្តិកបដ្ឋាន*** ព្រះមានព្រះភាគទ្រង់តែងទេសនាដោយសង្ខេប ដោយអំណាចនៃការលើកចំពោះបញ្ហាឡើង យ៉ាងនេះថា **"ហេតុំ កុសលំ ធម្មំ បដិច្ច ហេតុ កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា"** អ្នកសិក្សាគួរពោលសេចក្តីពិស្តារ ដោយន័យថា "អទោសហេតុ អមោហហេតុ អាស្រ័យកុសលហេតុ គឺអលោភៈ" ជាដើម, សេចក្តីពិស្តារនោះ សូម្បីនឹងមិនបានពោលទុក ក៏អាចជ្រាបបាន ដោយន័យដែលសម្តែងទុកហើយក្នុងខាងក្រោយ; ព្រោះហេតុដូច្នោះ ទើបមិនត្រាស់សម្តែងបច្ច័យតែម្យ៉ាងទុក សូម្បីក្នុងបទតែមួយឡើយ ។ ក៏ទេសនាដែលសម្តែងទុកដោយសង្ខេបនោះ គប្បីជ្រាបថា ទេសនានោះ ទ្រង់សម្តែងយ៉ាងនេះ ។

ពិតមែន ព្រះអង្គទ្រង់ភ្ជាប់កុសលបទជាមួយនឹងហេតុទុកៈ ហើយសម្តែងបច្ច័យដែលបានទាំងអស់ ដោយអំណាចនៃអនុលោម និងបច្ចនីយ-ន័យ; ក្នុងបដិច្ចវារៈ ទ្រង់មិនសម្តែងអនុលោមបច្ចនីយន័យ បច្ចនីយា-នុលោមន័យ និងសហជាតវារៈជាដើមទេ ហើយត្រាស់សម្តែងថា "ទាំងអស់គួរអធិប្បាយឲ្យពិស្តារ ដូចបដិច្ចវារៈនុ៎ះឯង" ។

*សូម្បីក្នុង **បញ្ហាវារៈ** ព្រះអដ្ឋកថាចារ្យទ្រង់មិនវិសជ្ជនាបញ្ហាទេ ទ្រង់លើក បច្ច័យតែម្យ៉ាង ហើយសម្ដែងបច្ច័យដែលបាន ដោយអំណាចនៃអនុលោម-បច្ចនីយន័យប៉ុណ្ណោះ; ព្រះមានព្រះភាគទ្រង់ត្រាស់ថា "អ្នកសិក្សា គប្បីភ្ជាប់ សូម្បីអកុសលាព្យាកតបទជាមួយនឹងហេតុទុកៈ" ហើយសម្ដែងនៃ **ហេតុ-កុសលទុកត្តិកៈ** ដូចនឹងកុសលបទចុះ ។ បន្ទាប់ពីនោះ ទ្រង់សម្ដែងទុក-ត្តិកៈ ២១ មានហេតុវេទនាទុកត្តិកៈជាដើម ដោយន័យថា* **"ហេតុំ សុខាយ វេទនាយ សម្បយុត្តំ ធម្មំ"** *ជាដើម ។ ក៏ព្រោះហេតុដែលឃើញបាន ប៉ះខ្ទប់បាន ឬឃើញមិនបាន ប៉ះខ្ទប់មិនបាន រមែងមិនមាន, ព្រោះហេតុ-ដូច្នោះ ទើបទ្រង់មិនភ្ជាប់ **សនិទស្សនសប្បដិឃៈ និងអនិទស្សនសប្បដិឃ-បទ** ជាមួយនឹងហេតុបទទេ ។ ទ្រង់ភ្ជាប់តិកៈ ២២ ដែលមានជាមួយនឹង ហេតុទុកៈ ដូចអធិប្បាយមកហើយ; ទ្រង់ភ្ជាប់តិកៈទាំងនោះ ជាមួយនឹងទុកៈ ទាំងអស់ មាន **សហេតុកទុកៈ** ជាដើម មាន **សរណទុកៈ** ជាទីបំផុតទៀត ។*

*ក្នុងទុកៈទាំងនោះ បទណាៗ មិនប្រកបរួមនឹងបទណាៗទេ, បទនោះៗ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងបាលីនោះឯងថា "មិនបានមាន" ក្នុង អធិការនេះ ។ ព្រះមានព្រះភាគប្រកបតិកៈ ២២ នឹងទុកៈ ១ ហើយប្រកប តិកៈ ២២ នឹងទុកបទដែលបានក្នុងទុកៈ ១០០ តាមលំដាប់ គឺតិកៈ ២២*

ដូចពោលមកនេះ ហើយបន្ថែមចូលក្នុងទុកៈ ១០០ សម្ដែងបដ្ឋាន ឈ្មោះថា ***ទុកត្តិកបដ្ឋាន;*** ក្នុងទុកត្តិកបដ្ឋាននោះ ក្នុងបដ្ឋានណាៗ ទ្រង់សម្ដែងន័យហើយ ធ្វើការសង្ខេបទុកក្នុងបាលី, អ្នកសិក្សា គប្បីជ្រាបសេចក្ដីពិស្ដារនៃបាលីនោះ តាមសមគួរដល់ន័យដែលទ្រង់សម្ដែងទុកក្នុងឋាននោះៗ ចុះ ៕

ចប់ទុកត្តិកបដ្ឋាន

..............

## ៤.ពណ៌នាអំពីតិកទុកបដ្ឋាន

*សូម្បីក្នុង* ***តិកទុកបដ្ឋាន*** *ព្រះមានព្រះភាគ ក៏ទ្រង់ធ្វើទេសនាដោយអំណាចនៃការលើកត្រឹមតែបញ្ហាឡើងប៉ុណ្ណោះថា* **"កុសលំ ហេតុំ ធម្មំ បដិច្ច កុសលោ ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា"** ។

*ក្នុង* ***ទុកត្តិកបដ្ឋាន*** *នោះ ទ្រង់ប្រកបកុសលបទជាមួយហេតុទុកៈក្នុងគ្រាក្រោយ ហើយតែងទេសនាដោយសង្ខេបក្នុងវារៈទាំងពួង ដោយអំណាចនៃបច្ច័យទាំងអស់ យ៉ាងណា, ក្នុងតិកទុកបដ្ឋាននេះ ក៏ដូច្នោះដែរ ទ្រង់ប្រកបហេតុបទជាមួយកុសលត្តិកៈ ហើយទេសនាដោយសង្ខេបក្នុងវារៈទាំងពួង ដោយអំណាចនៃបច្ច័យទាំងអស់ ។ម្យ៉ាងទៀត ទ្រង់ប្រកប* ***នហេតុបទ*** *ជាមួយកុសលត្តិកៈ ធ្វើកុសលត្តិកហេតុកៈឲ្យចប់ ដូចយ៉ាងទ្រង់ប្រកបហេតុបទដូច្នោះដែរ ។*

*តអំពីនោះ ទ្រង់សម្តែង **តិកទុកៈ ២១** មានវេទនាត្តិកហេតុទុកៈ ជាដើម ដោយន័យជាដើមថា* **“សុខាយ វេទនាយ សម្បយុត្តំ ហេតុំ ធម្មំ”** *ហើយទ្រង់ប្រកបហេតុទុកៈជាមួយតិកៈ ២២ យ៉ាងនេះ ទ្រង់ប្រកបទុកៈទាំងអស់ ដោយអំណាចដែលនឹងមានបាន មានសហេតុទុកៈជាដើម មានសរណទុកៈជាទីបំផុត ជាមួយតិកៈទាំងនោះឯងទៀត; សូម្បីក្នុងអធិការនេះ បទណាៗ ប្រកបគ្នាមិនបាន, បទនោះៗ ទ្រង់បដិសេធទុក ក្នុងបាលីនុ៎ះឯង ។ ព្រះមានព្រះភាគទ្រង់កាន់យកទុកៈ ១០០ រួមបញ្ចូលក្នុងតិកៈ ២២ ហើយសម្តែងបដ្ឋាន ឈ្មោះថា **តិកទុកបដ្ឋាន** ។ សូម្បីក្នុងតិកទុកបដ្ឋាននោះ ទ្រង់សង្ខេបបាលីទុកដោយន័យណាៗ, ន័យនោះៗ អ្នកសិក្សា គប្បីជ្រាបដោយពិស្តារចុះ ៕*

ចប់តិកទុកបដ្ឋាន

.............................

## ៥.ពណ៌នាអំពីតិកត្តិកបដ្ឋាន

*សូម្បីក្នុង **តិកត្តិកបដ្ឋាន** ព្រះមានព្រះភាគ ក៏ទ្រង់ធ្វើទេសនាដោយសង្ខេប ដោយអំណាចនៃការលើកបញ្ហាឡើងថា* **“កុសលំ សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច កុសលា សុខាយ វេទនាយ សម្បយុត្តា ធម្មា**

**ឧប្បជ្ជតិ ហេតុប្បច្ចយា** = *កុសលធម៌ដែលសម្បយុត្តដោយសុខវេទនា អាស្រ័យកុសលធម៌ដែលសម្បយុត្តដោយសុខវេទនាកើតឡើង ព្រោះហេតុប្បច្ច័យ” ជាដើម ។*

*ក៏ក្នុងអធិការនេះ ទ្រង់បន្ថែមតិកៈទាំងឡាយ ចូលក្នុងតិកៈប៉ុណ្ណោះយ៉ាងនេះ* ***គឺកុសលត្តិកៈជាមួយវេទនាតិកៈជាដើម, និងវេទនាតិកៈជាដើមជាមួយកុសលត្តិកៈ*** *។ ក៏បទណាៗ ដែលប្រកបនឹងបទណាៗ មិនបាន, ព្រះមានព្រះភាគទ្រង់បន្ថយបទនោះៗ ហើយសម្ដែងវារៈ និងន័យរបស់ការរាប់ក្នុងបច្ច័យទាំងពួង ដោយអំណាចដែលមានបានប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីកំណត់បាលីឲ្យល្អ ហើយជ្រាបវារៈ និងន័យរបស់ការរាប់ទាំងនោះចុះ ។ ក៏អ្នកសិក្សាប្រកបកុសលត្តិកៈ ជាមួយវេទនាតិកៈជាដើម និងវេទនាតិកៈជាដើម ជាមួយកុសលត្តិកៈនោះ ហើយគប្បីជ្រាប (សេចក្ដី) យ៉ាងណា, គប្បីប្រកបតិកៈមួយៗ ជាមួយតិកៈដ៏សេស និងតិកៈដ៏សេស ជាមួយតិកៈទាំងនោះ ហើយគប្បីជ្រាប (សេចក្ដី) ដូច្នោះចុះ ៕*

ចប់តិកត្តិកប្បដ្ឋាន

# ៦.ពណ៌នាអំពីទុកទុកបដ្ឋាន

*សូម្បីក្នុង **ទុកទុកបដ្ឋាន** ព្រះមានព្រះភាគ ក៏ទ្រង់ធ្វើទេសនាដោយសង្ខេប ដោយអំណាចនៃការលើកបញ្ហាឡើងថា **“ហេតុសហេតុកធម៌អាស្រ័យហេតុសហេតុកធម៌ កើតឡើង ព្រោះហេតុប្បច្ច័យ”** ជាដើម ។*

*ក្នុង **ទុកទុកបដ្ឋាន** នោះ ទ្រង់ប្រកបហេតុទុកៈជាមួយសហេតុទុកៈជាដើម និងសហេតុកទុកៈជាដើម ជាមួយហេតុទុកៈនោះ, ក៏អ្នកសិក្សាគប្បីប្រកបទុកៈមួយៗ ជាមួយទុកៈដ៏សេស និងទុកៈដ៏សេស ជាមួយទុកៈមួយពួកៗនោះ តាមលំដាប់ ។ ពិតណាស់ ឈ្មោះថា **ទុកទុកបដ្ឋាន** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកៈទាំងឡាយ ក្នុងទុកៈប៉ុណ្ណោះ, អ្នកសិក្សាគប្បីជ្រាបការប្រកបទុកៈទាំងអស់ ជាមួយទុកៈទាំងអស់ ក្នុងអធិការនេះដោយវិធីនោះឯង, តែបាលីព្រះមានព្រះភាគទ្រង់សង្ខេបទុក; ក៏បទណាៗប្រកបជាមួយបទណាៗ មិនបាន ព្រះមានព្រះភាគទ្រង់បន្ថយបទនោះៗហើយទើបទេសនា ។*

ចប់ទុកទុកបដ្ឋាន

## ៧.ពណ៌នាអំពីអនុលោមប្បដ្ឋាន

*ន័យ ៦ ក្នុង* ***ធម្មានុលោមប្បដ្ឋាន*** *ដែលសម្ដែងទុកក្នុងគាថាដែលព្រះអដ្ឋកថាចារ្យពោលទុកហើយ ក្នុងអដ្ឋកថាដូច្នេះថា ៖*

***"ន័យ ៦ ក្នុងអនុលោម គឺតិកប្បដ្ឋានដែលប្រសើរ ទុកប្បដ្ឋានដ៏ខ្ពស់បំផុត ទុកទុកប្បដ្ឋាន ដែលជ្រាលជ្រៅក្រៃពេក"*** *។*

*ជាការដែលលោកសម្ដែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ អ្នកសិក្សាគប្បីជ្រាបចំពោះ* ***អនុលោមប្បដ្ឋាន*** *ប៉ុណ្ណោះ ដែលប្រដាប់ដោយអំណាចនៃបច្ច័យម្យ៉ាងៗ ៤ ន័យ មានអនុលោមន័យជាដើម ៕*

ចប់អនុលោមប្បដ្ឋាន

...................................

## ៨-១២.ពណ៌នាអំពីបច្ចនីយប្បដ្ឋាន

*ឥឡូវនេះ ដើម្បីនឹងសម្ដែង* ***បច្ចនីយប្បដ្ឋាន*** *ដែលមានឈ្មោះបានហើយ ព្រោះជាធម៌បដិបក្សគ្នា ដោយអំណាចជាបដិបក្សចំពោះបទទាំងឡាយមានកុសលបទជាដើម ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **"ន កុសលំ ធម្មំ បដិច្ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា"** *ជាដើម ។*

*បណ្ដាបទទាំងនោះ ព្រះមានព្រះភាគទ្រង់ហាមភាវៈនៃកុសល ជា*

បច្ច័យ ដោយពាក្យថា **“ន កុសលំ ធម្មំ បដិច្ច”** , ទ្រង់ហាមការកើតឡើង នៃកុសល ដោយពាក្យថា **“ន កុសលោ ធម្មោ ឧប្បជ្ជតិ”** ព្រោះហេតុ ដូច្នោះ អ្នកសិក្សា គប្បីជ្រាបបញ្ហាវិសជ្ជនាក្នុងអធិការនេះ ដោយន័យ យ៉ាងនេះថា ***“ខន្ធ ៣ ដែលជាកុសលាព្យាកតៈ និងរូបដែលមានចិត្តជា សមុដ្ឋាន អាស្រ័យខន្ធមួយដែលជាអកុសលាព្យាកតៈកើតឡើង”*** ជាដើម ។

ក៏វិធីរាប់ដែលបានក្នុងបច្ច័យនោះៗ ព្រះមានព្រះភាគត្រាស់សម្តែង ទុកហើយក្នុងបាលី សូម្បីវារៈទាំងឡាយ ដែលមានវិសជ្ជនាដូចគ្នា ក៏ទ្រង់ សម្តែងទុកក្នុងបាលីនុ៎ះឯង, ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ អ្នកសិក្សា គប្បីកំណត់បាលីហើយជ្រាបបដ្ឋានន័យទាំងអស់ តាមលំដាប់របស់ន័យ ដែលខ្ញុំពោលហើយក្នុងពេលក្រោយ ។ ក៏ក្នុងអធិការនេះ យ៉ាងណា, ***ទុកបដ្ឋាន ទុកត្តិកបដ្ឋាន តិកទុកបដ្ឋាន តិកត្តិកបដ្ឋាន និងទុកទុកបដ្ឋាន*** ក៏យ៉ាងនោះដែរ ។

ន័យ ៦ ក្នុងធម្មបច្ចនីយបដ្ឋាន ដែលលោកសម្តែងទុកដោយគាថា ដែលពោលទុកក្នុងអដ្ឋកថាដូច្នេះថា ៖

***“ន័យ ៦ ក្នុងបច្ចនីយបដ្ឋាន គឺតិកបដ្ឋានដែលប្រសើរ, ទុកបដ្ឋាន ដែលខ្ពស់បំផុត, ទុកត្តិកបដ្ឋាន តិកទុកបដ្ឋាន តិកត្តិកបដ្ឋាន និងទុកទុក-បដ្ឋានដែលជ្រាលជ្រៅ”*** ។

(ន័យ ៦) ដែលខ្ញុំសម្ដែងហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ក៏ក្នុងអធិការនេះ អ្នកសិក្សា គប្បីជ្រាបចំពោះបច្ចនីយប្បដ្ឋានប៉ុណ្ណោះ ប្រដាប់ដោយន័យ ២៤ ដោយបរិយាយមួយ គឺក្នុងបដ្ឋានមួយៗ ពោល ដោយអំណាចម្យ៉ាងៗ ៤ ន័យ មានអនុលោមន័យជាដើម ៕

ចប់បច្ចនីយប្បដ្ឋាន

..............................

## ៩-១៨.ពណ៌នាអំពីអនុលោមបច្ចនីយប្បដ្ឋាន

ឥឡូវនេះ ដើម្បីនឹងសម្ដែងបដ្ឋានដែលឈ្មោះថា អនុលោមប្បច្ចនីយៈ ព្រោះមានអនុលោម និងបច្ចនីយៈនៃធម៌ទាំងឡាយ ដោយអំណាចនៃការបដិសេធបច្ចយធម៌ ក្នុងធម៌ទាំងឡាយ មានកុសលធម៌ជាដើម, តែបដិសេធភាវៈជាកុសលជាដើម នៃបច្ចយុប្បន្នធម៌ ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពុទ្ធដីកាថា **“កុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា”** ជាដើម ។

បណ្ដាបទទាំងនេះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតភាវៈនៃកុសល ជាបច្ច័យដោយពុទ្ធដីកាថា **“កុសលំ ធម្មំ បដិច្ច”** , ទ្រង់ហាមការកើតឡើងនៃកុសលដោយពុទ្ធដីកាថា **“ន កុសលោ ធម្មោ ឧប្បជ្ជតិ”** ; ព្រោះហេតុ

*នោះ ព្រះអដ្ឋកថាទ្រង់សម្ដែងវិសជ្ជនាដោយន័យថា “រូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យកុសលក្ខន្ធហើយកើតឡើង” ជាដើម, វិសជ្ជនាទាំងអស់នោះ អ្នកសិក្សា គប្បីត្រួតត្រាមើលព្រះបាលី ហើយកំណត់មើលទុកឲ្យល្អចុះ ។ ក៏វិសជ្ជនាបានជាមួយបច្ច័យណា, មិនបានក្នុងបច្ច័យណា និងវិសជ្ជនាណា, មានការកំណត់វិធីរាប់ក្នុងបច្ច័យណា ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកហើយក្នុងព្រះបាលីឯណោះ ។ ព្រោះហេតុនោះ ក្នុងអធិការនេះ ទើបមានសេចក្ដីនៅក្នុងបាលីនុ៎ះឯង ។ ក៏ក្នុងអធិការនេះ យ៉ាងណា, សូម្បីក្នុងទុកបដ្ឋានជាដើម ក៏យ៉ាងនោះដែរ ។*

*ន័យ ៦ ក្នុងធម្មានុលោមបច្ចនីយបដ្ឋាន ដែលពោលទុកក្នុងអដ្ឋកថាដូច្នេះថា ៖*

***“ន័យ ៦ ក្នុងអនុលោមបច្ចនីយបដ្ឋាន គឺតិកបដ្ឋានដ៏ប្រសើរ ទុកបដ្ឋានដែលខ្ពស់បំផុត តិកទុកបដ្ឋាន តិកតិកបដ្ឋាន និងទុកទុកបដ្ឋានដ៏ជ្រាលជ្រៅ”** ។*

*ដែលខ្ញុំសម្ដែងហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ; ក៏ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបអនុលោមបច្ចនីយបដ្ឋាន ដែលប្រដាប់ហើយដោយបច្ច័យ ២៤ ដោយបរិយាយមួយ គឺក្នុងបដ្ឋានមួយៗ ពោលដោយអំណាចនៃបច្ច័យម្យ៉ាងៗ មាន ៤ ន័យ មានអនុលោមន័យជាដើម ៕*

**ចប់អនុលោមបច្ចនីយបដ្ឋាន**

## ១០-២៥.ពណ៌នាអំពីបច្ចនីយានុលោមបដ្ឋាន

ឥឡូវនេះ ដើម្បីនឹងសម្ដែងបដ្ឋានដែលឈ្មោះថា ***បច្ចនីយានុលោម*** ព្រោះ ***ជាបច្ចនីយៈ និងអនុលោម*** នៃធម៌ទាំងឡាយ ដោយអំណាចនៃការបដិសេធបច្ចនីយធម៌ក្នុងធម៌ទាំងឡាយ មានកុសលធម៌ជាដើម, (តែ) មិនបដិសេធសេចក្ដីជាអកុសលជាដើម នៃបច្ចយុប្បន្នធម៌ទេ; ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពុទ្ធដីកាថា **“ន កុសលំ ធម្មំ បដិច្ច អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា”** ជាដើម ។

បណ្ដាបទទាំងនោះ ព្រះមានព្រះភាគទ្រង់ហាមភាវៈនៃកុសល ជាបច្ច័យ ដោយពាក្យថា **“ន កុសលំ ធម្មំ បដិច្ច”** ទ្រង់អនុញ្ញាតការកើតឡើងនៃអកុសលដោយពាក្យថា **“អកុសលោ ធម្មោ ឧប្បជ្ជតិ”** មែនពិត, ក៏ឈ្មោះថា **“ន កុសលំ** = ធម៌ដែលមិនមែនជាកុសល” គឺបានដល់អកុសល ឬអព្យាកតៈនោះឯង ។ ឯ ***កុសល*** ឈ្មោះថា ធ្វើ ***នកុសល*** = ធម៌ដែលមិនមែនកុសលនោះ ឲ្យជាសហជាតបច្ច័យកើតឡើង រមែងមិនមាន, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់តែងពាក្យវិសជ្ជនា ដោយអំណាចនៃអកុសល និងអព្យាកតៈ ។ ក្នុងខនោះ អ្នកសិក្សា គប្បីជ្រាបវិសជ្ជនា ***អាស្រ័យ នកុសលធម៌យ៉ាងនេះ គឺខន្ធ ៣ និងរូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យអកុសលក្ខន្ធមួយកើតឡើង*** ។

ចំណែកបញ្ហាថា **“អព្យាកតធម៌រមែងកើតឡើង ព្រោះហេតុប្បច្ច័យ”** នេះ ទ្រង់វិសជ្ជនាទុកស្រេចហើយថា ខន្ធ ៣ និងរូបដែលមានចិត្តជាសមុដ្ឋាន អាស្រ័យខន្ធមួយដែលជាវិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ហើយកើត ។ ក្នុងបញ្ហាទាំងអស់ បញ្ហាដែលនៅមិនទាន់បានវិសជ្ជនា រមែងមានវិសជ្ជនាដែលសមគួរដល់សេចក្តី និងបញ្ហាដែលមានវិសជ្ជនាហើយ ក៏មានវិសជ្ជនាដែលមកហើយក្នុងបាលីនុ៎ះឯង ។ ឯវិធីរាប់ប្រភេទនៃវារៈ និងរាប់បច្ច័យក្នុងតិកៈ និងទុកៈមួយៗ ទាំងអស់ អ្នកសិក្សាគប្បីជ្រាបតាមលំអាន របស់ន័យដែលខ្ញុំពោលទុកហើយ ក្នុងខាងក្រោយ ។

ក៏ន័យ ៦ ក្នុងធម្មប្បច្ចនីយានុលោមប្បដ្ឋាន ដែលលោកសម្តែងទុកដោយគាថា ដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាដូច្នេះថា ៖

**“ន័យ ៦ ក្នុងបច្ចនីយានុលោម គឺតិកប្បដ្ឋានដ៏ប្រសើរ, ទុកប្បដ្ឋានដ៏ខ្ពង់ខ្ពស់, ទុកត្តិកប្បដ្ឋាន តិកទុកប្បដ្ឋាន តិកត្តិកប្បដ្ឋាន និងទុកទុកប្បដ្ឋានដ៏ជ្រាលជ្រៅបំផុត”** ។

ដែលខ្ញុំសម្តែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ, ក៏ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបបច្ចនីយានុលោមប្បដ្ឋាន ដែលប្រដាប់ដោយន័យ ២៤ ដោយបរិយាយមួយ គឺក្នុងបដ្ឋានមួយ ពោលដោយអំណាចនៃបច្ច័យ មានម្យ៉ាងៗ ៤ ន័យ មានអនុលោមន័យជាដើម ដោយប្រការដូច្នេះ ។%

ចប់បច្ចនីយានុលោមប្បដ្ឋាន

## បរិយោសានវណ្ណនា ពណ៌នាចុងក្រោយបករណ៍

*ក្នុងបដ្ឋាន ៤ មានធម្មានុលោមបច្ចដ្ឋានជាដើម មានន័យ ៩៦ គឺ ក្នុងបដ្ឋានមួយៗ មានម្យ៉ាងៗ ៤ ន័យ ដោយប្រការដូច្នេះ, បណ្ដាបដ្ឋានទាំងនោះ អ្នកសិក្សាគប្បីជ្រាប* ***មហាបករណ៍ដែលឈ្មោះថា*** **សមន្តប្បដ្ឋាន** *ដែលប្រកបដោយន័យ ២៤ នេះ ដោយអំណាចន័យទាំងឡាយមាន* ***តិក-ទុកប្បដ្ឋាន*** *ជាដើមនោះឯង, ក្នុងបដ្ឋានមួយៗ មាន ៦ ន័យ ដោយមិនត្រូវរួមយកន័យរបស់បច្ច័យចូលផងទេ ។*

*ចំណែកអាចារ្យខ្លះ តាំងមាតិកានៃអារម្មណ៍ដោយន័យថា* **“ កុសលារម្មណា ធម្មា, អកុសលារម្មណា ធម្មា ”** *ជាដើម ហើយសម្ដែងអារម្មណ-ប្បដ្ឋាន ដោយន័យជាដើមថា “ធម៌ដែលមានកុសលជាអារម្មណ៍ ជាបច្ច័យដល់ធម៌ដែលមានកុសលជាអារម្មណ៍ ដោយអំណាចនៃហេតុប្បច្ច័យ ” ដូច្នេះ ហើយលើកបដ្ឋាន ឈ្មោះថា* ***ផស្សប្បដ្ឋាន*** *ឡើង សម្ដែងដោយអំណាចនៃផស្សៈជាដើមទៀត, តែខនោះ មិនប្រាកដទាំងបាលី ទាំងអដ្ឋកថា ព្រោះហេតុដូច្នោះ ទើបខ្ញុំមិនបានចារឹកទុកក្នុងទីនេះទេ; ក៏ក្នុងអដ្ឋកថានេះ អ្នកសិក្សា គប្បីជ្រាបថា ខ្ញុំអធិប្បាយចំពោះបាលីដែលលើកឡើងកាន់សង្គីតិហើយតែប៉ុណ្ណោះ ។*

***ក៏ដោយកុសលចេតនារបស់ខ្ញុំ មានប្រមាណប៉ុណ្ណេះ***

ពួកសត្វទាំងឡាយនោះ អ្នកសាងកុសលជាដើម ជាប់ស៊ប់ ហើយក្នុងបច្ចយាការឯណា រមែងមិនកន្លងផុតសង្សារ ដែលអូសទាញទៅដោយសេចក្តីទុក្ខជាអនេកប្បការ, ព្រះសាស្តាទ្រង់ជាគ្រូនៃលោក ឈ្លាសក្នុងការចែកបច្ច័យ ទ្រង់អាស្រ័យបច្ចយាការនោះ ដ៏ល្អិតជ្រាលជ្រៅក្រៃលែង ជាភូមិ និងជាទីអន្ទោលទៅនៃពុទ្ធញ្ញាណ ដែលផ្សេងដោយធម៌ មានកុសល-ធម៌ជាដើម ទ្រង់តាំងព្រះទ័យមាំទាំ ប្រកាសព្រះអភិធម្ម-ប្បករណ៍ទី ៧ ឈ្មោះថា បដ្ឋាន ណា ឱ្យពិស្តារ ដោយន័យទាំងឡាយ ដែលកុលបុត្រគប្បីចូល (យល់) ដោយញាណវីថិផ្សេងៗ ខ្ញុំមិនលះហើយនូវវាទៈនៃអាចារ្យទាំងឡាយ ជនសីហឡៈ អ្នកជាវិភជ្ជវាទីបានផ្តើមទុកល្អហើយដោយសទ្ធា នូវអដ្ឋកថានៃបដ្ឋាននោះ ដោយប្រាសចាកអន្តរាយ ក្នុងកាលបើលោកកំពុង មានអន្តរាយច្រើនណាស់, អដ្ឋកថានេះប្រកាសអត្ថនៃបដ្ឋានប្បករណ៍ដ៏ប្រសើរទាំងអស់ ចប់រួចរាល់ដោយភាណវារៈ ១៤ គត់ ក្នុងថ្ងៃនេះ យ៉ាងណា; សូមតម្រិះដ៏ស្រស់ល្អត្រកាលទាំងពួង របស់ជនជាច្រើន ដល់នូវសេចក្តី

*សម្រេចឆាប់រួសរាន់ដូច្នោះចុះ ។*

*អដ្ឋកថានៃព្រះអភិធម្ម ៧ បករណ៍ សូម្បីទាំងអស់ ដែលព្រះមានព្រះភាគ ទ្រង់ជាទីពឹងនៃសត្វលោក ជាទេព ក្រៃលែងជាងទេព, ទ្រង់សម្តែងត្រង់ទេវបុរីក្នុងទេវលោក ចប់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ៕*

## បរិយោសានកថា

*ខ្ញុំតែងអដ្ឋកថានេះ ឱ្យចប់រួចរាល់ ដើម្បីឱ្យព្រះធម៌ តាំងនៅយូរអង្វែង, ឱ្យដល់ហើយនូវកុសលឯណា; ដោយ អានុភាពនៃកុសលនោះ សូមសត្វអ្នកមានប្រាណទាំងពួង ចូរ ដឹងធម៌ នៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាព្រះសទ្ធម្មរាជា ដែល នាំមកនូវសេចក្តីសុខ ហើយចូរសម្រេចនូវព្រះនិព្វាន ដែល មិនមានសេចក្តីសោក សេចក្តីចង្អៀតចង្អល់ចិត្ត ជាសេចក្តី សុខដ៏ខ្ពង់ខ្ពស់ ដោយការបដិបត្តិល្អបរិសុទ្ធិ ។*

*សូមព្រះសទ្ធម្មតាំងនៅអស់កាលយូរ, សូមសត្វទាំង ឡាយគោរពក្នុងព្រះធម៌, សូមភ្លៀងធ្លាក់ត្រូវតាមរដូវកាល; ព្រះរាជាដ៏ល្អសមរម្យពីបុរាណ បានរក្សាពួកជនដោយធម៌*

*យ៉ាងណា, សូមព្រះរាជាព្រះអង្គនេះ រក្សាពួកជននេះ ដោយធម៌, ដូចឱរសរបស់ព្រះអង្គដូច្នោះចុះ ។*

ចប់បករណ៍ឈ្មោះថា

**មហាបដ្ឋាន** ដោយបរិបូណ៌

*ព្រះថេរៈអ្នកមាននាមដែលគ្រូទាំងឡាយ កាន់យកហើយថា **"ពុទ្ធ-ឃោសៈ"** ដែលមានសេចក្ដីបរិសុទ្ធទូលំទូលាយប្រដាប់ដោយសទ្ធា, ចំណេះដឹង និងសេចក្ដីព្យាយាមដែលបរិសុទ្ធយ៉ាងក្រៃលែង, អ្នករុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ, មានសីល អាចារៈ សេចក្ដីស្មោះត្រង់ និងសេចក្ដីទន់ភ្លន់ជាដើម, អាចយាងចុះកាន់ជដៈ គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ, ប្រកបដោយសេចក្ដីឆ្លៀវឆ្លាសដោយបញ្ញា, មានចំណេះដឹងមិនទើសទាក់ក្នុងសត្ថុសាសន៍ ជម្រុងដោយបរិយត្តិ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា, ជាអ្នកមហាវេយ្យាករណ៍ ប្រកបដោយសេចក្ដីល្អនៃពាក្យពេចន៍ពីរោះ និងទូលំទូលាយ, សម្ដែងចេញបានយ៉ាងស្អាត, បង្កឲ្យកើតករណ-សម្បត្តិ, មានវាទៈប្រសើរត្រឹមត្រូវ, មនុស្សដទៃចូលចិត្តបានងាយ, ជាមហាកវី អមដោយបដិសម្ភិទាដែលធ្លុះធ្លាយ ជាអ្នកប្រដាប់ដោយវង្សនៃព្រះថេរៈ ដែលនៅក្នុងមហាវិហារទាំងឡាយ, អ្នកដែលជាប្រទីបនៃ*

*ថេរវង្ស, មានញាណដែលតាំងមាំល្អហើយក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ ផ្សេងដោយគុណ មានអភិញ្ញា ៦ ជាដើម អមដោយបដិសម្ភិទាជាដើម, បានតែងអដ្ឋកថាព្រះអភិធម្មបិដកសូម្បីទាំងអស់នេះ ចប់ហើយ ។*

***សូមអដ្ឋកថានេះ តាំងនៅក្នុងលោក សម្តែងន័យដល់កុលបុត្រទាំងឡាយ ដែលស្វែងរកធម៌ជាគ្រឿងរើដកចេញចាកលោក; ដរាបដល់ព្រះនាមថា "ពុទ្ធោ" របស់ព្រះលោកជេដ្ឋដែលស្វែងរកគុណដ៏ធំក្រៃលែង មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិភាព នៅប្រព្រឹត្តទៅក្នុងលោកចុះ ៕***

***ចប់វណ្ណនាចុងក្រោយបករណ៍***

# បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក ឈ្មោះថាបញ្ចបករណ៍
## មានធាតុកថាបករណ៍ជាដើម តតិយភាគ ១២
## ចប់ដោយបរិបូណ៌

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)